UNESCO Publishing

United Nations
Educational, Scientific and
Cultural Organization

978-92-3-100088-1
Phnom Penh, November 2016
Original: English

# ពិចារណាឡើងវិញ លើការអប់រំ

## ដើម្បីឈានទៅសម្រេចគោលដៅរួមជាសកល ?



# ពិចារណាឡើងវិញ លើការអប់រំ

ដើម្បីឈានទៅសម្រេចគោលដៅរួមជាសកល ?

បោះពុម្ពផ្សាយ ក្នុងឆ្នាំ ២០១៥ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ
អាសយដ្ឋាន 7, place de Fontenoy, 75352 Paris 07 SP, France

© UNESCO 2015

ISBN 978-92-3-100088-1

ឯកសារបោះពុម្ពផ្សាយនេះអាចរកបានដោយចំហ ក្រោមអាជ្ញាប័ណ្ណ Attribution-Share Alike 3.0 IGO (CC-BY-SA 3.0 IGO) (http://creativecommons.org/licenses/by-sa/3.0/igo/) ។ តាមរយៈការប្រើប្រាស់ខ្លឹមសារក្នុង ឯកសារបោះពុម្ពផ្សាយនេះ អ្នកប្រើប្រាស់យល់ព្រមចងកាតព្វកិច្ចទៅតាមលក្ខខណ្ឌនៃការប្រើប្រាស់របស់នហិតដ្ឋាន Open Access របស់យូណេស្កូ (http://www.unesco.org/open-access/terms-use-ccbysa-en)។

ឈ្មោះតួនាទី ដែលត្រូវបានប្រើប្រាស់ និងព័ត៌មានដែលបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនមែនជាការបញ្ចេញមតិរបស់យូណេស្កូ ពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬសមត្ថកិច្ចរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នេះ ឬពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់ដែនរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។

សមាជិករបស់ក្រុមអ្នកជំនាញជាន់ខ្ពស់ គឺជាអ្នកទទួលខុសត្រូវលើការជ្រើសរើស និងការបង្ហាញអង្គហេតុក្នុងឯកសារបោះពុម្ពផ្សាយនេះ និងលើទស្សនៈដែលត្រូវបានបញ្ចេញក្នុងឯកសារនេះ។ ទស្សនៈទាំងនេះមិនមែនជាទស្សនៈយូណេស្កូ ហើយមិនតម្រូវឲ្យយូណេស្កូជាប់កាតព្វកិច្ចអ្វីមួយឡើយ។

រចនាក្រាហ្វិច៖ UNESCO

រូបថតគ្របមុខ៖ @ Shutterstock/Arthimedes

បោះពុម្ពដោយ UNESCOបោះពុម្ពក្នុងប្រទេសបារាំង

# អារម្ភកថា

តើយើងត្រូវការការអប់រំប្រភេទណា សម្រាប់សតវត្សរ៍ទី ២១? តើអ្វីទៅជាគោលបំណង នៃការអប់រំក្នុងបរិបទដែលសង្គមកំពុងមានការប្រែប្រួលដូចបច្ចុប្បន្ននេះ? តើការរៀនសូត្រ គួររៀបចំយ៉ាងដូចម្តេច? សំណួរទាំងនេះ គឺជាដើមចម ដែលនាំឲ្យមានការបង្ហាញគំនិតក្នុង ឯកសារបោះពុម្ពផ្សាយនេះ។

ក្នុងស្មារតីនៃឯកសារបោះពុម្ពផ្សាយសំខាន់ៗចំនួនពីររបស់យូណេស្កូ រៀនដើម្បីក្លាយជា ប្រជាពលរដ្ឋល្អ៖ ពិភពនៃការអប់រំបច្ចុប្បន្ន និងអនាគត (Learning to Be: The world of education today and tomorrow) (១៩៧២) ហៅកាត់ថា “Faure Report” និងការរៀនសូត្រ៖ ទ្រព្យមហាសាលដែលជាប់នៅនឹងខ្លួនជានិច្ច (Learning: The treasure within) (១៩៩៦) ហៅ កាត់ថា “Delors Report” ខ្ញុំជឿជាក់ថា នេះជាពេលវេលាដែលយើងចាំបាច់ត្រូវគិតវែងឆ្ងាយ សារជាថ្មីអំពីការអប់រំ។

នេះជាពេលដែលពោរពេញដោយភាពមិនប្រាកដប្រជា។ មនុស្សក្នុងពិភពលោកកាន់ តែមានអាយុតិច ហើយបំណងប្រាថ្នាចង់បានសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស កាន់តែ មានការកើនឡើង។ សង្គមកាន់តែភ្ជាប់ជាមួយគ្នាជាងពេលណាៗទាំងអស់ ប៉ុន្តែការមិនយល់ អធ្យាស្រ័យ និងជម្លោះនៅតែកើតមានឡើង។ មហាអំណាចថ្មីៗកាន់តែលេចចេញរូបរាង ប៉ុន្តែវិសមភាពកាន់តែចាក់ឫសជ្រៅទៅៗ ហើយភពផែនដីកំពុងទទួលរងសម្ពាធខ្លាំងឡើង។ កាលានុវត្តភាព ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន មាន ទំហំធំធេង ប៉ុន្តែបញ្ហាប្រឈមក៏មានកម្រិតជ្រាលជ្រៅ និងស្មុគស្មាញផងដែរ។

ពិភពលោកកំពុងមានការផ្លាស់ប្តូរ ដូច្នេះការអប់រំក៏ត្រូវតែផ្លាស់ប្តូរតាមនោះផងដែរ។ សង្គម នៅគ្រប់ទិសទីទាំងអស់ កំពុងឆ្លងកាត់ការផ្លាស់ប្តូរដែលមានលក្ខណៈស៊ីជម្រៅ ដែលទាមទារ ឲ្យមានការផ្តល់ការអប់រំក្នុងទម្រង់ថ្មីៗ សំដៅលើកកម្ពស់សមត្ថភាព ដែលសង្គម និង សេដ្ឋកិច្ចត្រូវការ ទាំងពេលបច្ចុប្បន្ន ទាំងពេលអនាគត។ នេះមានន័យថា ជាការបោះជំហាន ហួសពីចំណេះដឹងអក្សរ និងលេខនព្វន្ត ទៅរកការផ្តោតការយកចិត្តទុកដាក់លើបរិយាកាស រៀនសូត្រ និងគោលវិធីរៀនសូត្រថ្មីៗ ដើម្បីបង្កើនយុត្តិធម៌ សមធម៌សង្គម និងសាមគ្គីភាពជា សកល។ ការអប់រំត្រូវតែផ្តោតលើការរៀនរស់លើភពផែនដី ដែលកំពុងស្ថិតក្រោមសម្ពាធ។ ការអប់រំត្រូវផ្តោតលើចំណេះដឹងអំពីវប្បធម៌ ជាមូលដ្ឋាននៃការគោរព និងសេចក្តីថ្លៃថ្នូរស្មើភាព គ្នារបស់មនុស្ស ដែលជួយឲ្យទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃការអភិវឌ្ឍប្រកបដោយ ចីរភាព មានភាពស៊ីសង្វាក់ជាមួយគ្នា។

នេះគឺជាចក្ខុវិស័យបែបមនុស្សនិយម ដែលចាត់ទុកការអប់រំថាជា គោលដៅរួមសំខាន់

ចាំបាច់ សម្រាប់មនុស្ស។ ខ្ញុំជឿជាក់ថា ចក្ខុវិស័យនេះ នឹងធ្វើឲ្យស្មារតីនៃធម្មនុញ្ញរបស់យូណេស្កូ ដែលបានទទួលការឯកភាពកាលពី ៧០ ឆ្នាំមុន នៅតែបន្តបិតបេរ ហើយក្នុងពេលជាមួយគ្នា ឆ្លុះបញ្ចាំងពីស្ថានភាព និងតម្រូវការថ្មី។

ការអប់រំ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះក្របខ័ណ្ឌរួមជាសកលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការអប់រំ ស្ថិតនៅចំកណ្តាលនៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីបន្សាំទៅនឹងការផ្លាស់ប្តូរផង និងធ្វើឲ្យមានការផ្លាស់ប្តូរក្នុងពិភពលោក ដែលយើងកំពុងរស់នៅផង។ ការអប់រំកម្រិតមូលដ្ឋានប្រកបដោយគុណភាព គឺជាមូលដ្ឋានចាំបាច់ សម្រាប់ការរៀនសូត្រពេញមួយជីវិត ក្នុងពិភពលោកដែលពោរពេញទៅដោយភាពស្មុគស្មាញ និងដែលកំពុងតែមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ។

ក្នុងសកលលោកទាំងមូល យើងបានសង្កេតឃើញមានការសម្រេចនូវវឌ្ឍនភាពធំធេងក្នុងការពង្រីកឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នា។ តែទោះជាយ៉ាងណាក៏ដោយ យើងត្រូវទាញយកតែមេរៀនណាដែលត្រឹមត្រូវប៉ុណ្ណោះ នៅពេលយើងរៀបចំផ្លូវដើរថ្មីទៅមុខទៀត។ ការទទួលបានសេវាអប់រំ គឺមិនទាន់គ្រប់គ្រាន់ឡើយ។ យើងត្រូវការផ្តោតការយកចិត្តទុកដាក់ថ្មីលើគុណភាពនៃការអប់រំ និងភាពឆ្លើយតបនៃការរៀនសូត្រ ពោលគឺលើអ្វីដែលកុមារ យុវជន និងមនុស្សពេញវ័យ កំពុងតែរៀនជាក់ស្តែង។ ការរៀនសូត្រក្នុងសាលារៀន និងការអប់រំក្នុងប្រព័ន្ធ គឺជាប្រភេទនៃការអប់រំ ដែលសំខាន់ និងចាំបាច់ ប៉ុន្តែយើងត្រូវតែពង្រីកវិសាលភាពនៃការអប់រំបន្ថែមទៀត ដើម្បីបណ្តុះការរៀនសូត្រពេញមួយជីវិត។ ការបញ្ជូនក្មេងស្រីឲ្យទៅរៀនតាមសាលារៀនបឋមសិក្សា គឺជារឿងសំខាន់ ប៉ុន្តែយើងក៏ត្រូវជួយពួកគេ រហូតដល់កម្រិតមធ្យមសិក្សា និងកម្រិតអប់រំខ្ពស់ជាងនេះទៀតផងដែរ។ យើងចាំបាច់ត្រូវតែផ្តោតការយកចិត្តទុកដាក់ឲ្យកាន់តែខ្លាំងជាងមុនលើគ្រូ និងអ្នកអប់រំ ដែលជាភ្នាក់ងារនាំឲ្យមានការផ្លាស់ប្តូរជាទូទៅ។

ពុំមានកម្លាំងជម្រុញណាដែលនាំឲ្យមានការផ្លាស់ប្តូរខ្លាំងជាងការអប់រំឡើយ។ ការអប់រំនាំឲ្យមានការលើកកម្ពស់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ លុបបំបាត់ភាពក្រីក្រ និងធ្វើឲ្យនិរន្តរភាពនៅបិតបេរយូរអង្វែង កសាងអនាគតកាន់តែល្អប្រសើរសម្រាប់ទាំងអស់គ្នា ដោយឈរលើមូលដ្ឋានសិទ្ធិ និងយុត្តិធម៌សង្គមស្មើភាពគ្នា ការគោរពវប្បធម៌ផ្សេងៗគ្នា សាមគ្គីភាពជាអន្តរជាតិ និងការទទួលខុសត្រូវរួម ដែលសុទ្ធតែជាមូលដ្ឋាននៃមនុស្សជាតិរួមរបស់យើង។

Irina Bokova

អគ្គនាយកយូណេស្កូ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ ដែលឯកសារនេះត្រូវបានបោះពុម្ពផ្សាយ ចំពេលដែលមានរបត់ជាប្រវត្តិសាស្ត្រ ពោលគឺជាពេលដែលសហគមន៍អន្តរជាតិ ដែលធ្វើសកម្មភាពក្នុងវិស័យអប់រំ និងអភិវឌ្ឍន៍ កំពុងបោះជំហានទៅរកក្របខ័ណ្ឌសកលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ឯកសារនេះ គឺជាលទ្ធផលនៃការពិភាក្សាដំបូងៗរបស់ខ្ញុំជាមួយនឹងលោកស្រី Irina Bokova អគ្គនាយកយូណេស្កូ ក្នុងអណត្តិទីមួយរបស់លោកស្រី។ លោកស្រីបានផ្ដល់នូវការគាំទ្រពេញទំហឹងដល់គំនិតដែលចង់ឲ្យមានការពិនិត្យឡើងវិញលើ “របាយការណ៍ Delors” ក្នុងគោលបំណងកំណត់ពីទិសដៅនាពេលអនាគតនៃការអប់រំក្នុងសកលលោក។ លោកស្រីចង់បង្ហាញថា ក្រៅតែពីការបំពេញតួនាទីនាំមុខខាងផ្នែកបច្ចេកទេសសម្រាប់ជួយដល់ចលនាអប់រំសម្រាប់ទាំងអស់គ្នា យូណេស្កូក៏មានតួនាទីដឹកនាំផ្នែកបញ្ញាស្មារតីដ៏សំខាន់ ក្នុងការអប់រំអន្តរជាតិផងដែរ។

ក្នុងទស្សនៈនេះហើយបានជាអគ្គនាយកយូណេស្កូបានបង្កើតក្រុមអ្នកជំនាញជាន់ខ្ពស់មួយក្រុម ដើម្បីគិតគូរពិចារណាឡើងវិញពីការអប់រំ ក្នុងពិភពលោកដែលកំពុងតែមានការផ្លាស់ប្ដូរ។ អ្នកជំនាញអន្តរជាតិទាំងនេះ មានភារកិច្ចរៀបចំឯកសារដ៏សំខាន់មួយ ដែលនឹងកំណត់ពីបញ្ហានានា ដែលទំនងជានឹងមានផលប៉ះពាល់លើការរៀបចំការរៀនសូត្រ និងជម្រុញឲ្យមានការជជែកវែកញែកពីចក្ខុវិស័យសម្រាប់ការអប់រំ។ ក្រុមអ្នកជំនាញនេះមានសហប្រធានចំនួនពីររូប គឺលោកស្រី Amina J. Mohammed ទីប្រឹក្សាពិសេសនៃអគ្គលេខាធិការសហប្រជាជាតិទទួលបន្ទុកការងាររៀបចំផែនការអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ និងជាអគ្គលេខាធិការរងផងដែរ និងលោកសាស្ត្រាចារ្យ W. John Morgan ប្រធានយូណេស្កូសកលវិទ្យាល័យ Nottingham ចក្រភពអង់គ្លេស។ សមាជិកផ្សេងទៀតរបស់អ្នកជំនាញជាន់ខ្ពស់ រួមមាន៖ លោក Peter Ronald DeSouza សាស្ត្រាចារ្យមកពីមជ្ឈមណ្ឌលសម្រាប់សិក្សាពីសង្គមកំពុងអភិវឌ្ឍ ទីក្រុងញូដេលី ប្រទេសឥណ្ឌា, លោក Georges Haddad សាស្ត្រាចារ្យសកលវិទ្យាល័យប៉ារីស ១ Panthéon-Sorbonne ប្រទេសបារាំង, លោកស្រី Fadia Kiwan ប្រធានកិត្តិយសវិទ្យាស្ថានវិទ្យាសាស្ត្រនយោបាយ សកលវិទ្យាល័យ Saint-Joseph ទីក្រុងបេរូត ប្រទេសលីបង់, លោក Fred van Leeuwen អគ្គលេខាធិការនៃអង្គការអប់រំអន្តរជាតិ, លោក Teiichi Sato សាស្ត្រាចារ្យសកលវិទ្យាល័យសុខាភិបាល និងសុខុមាលភាពអន្តរជាតិ ប្រទេសជប៉ុន និងលោកស្រី Sylvia Schmelkes ប្រធានវិទ្យាស្ថានវាយតម្លៃការអប់រំ ប្រទេសម៉ិចស៊ិច។

លោកស្រីអគ្គនាយកបានគាំទ្រពេញទំហឹង ពីដំបូងឲ្យផ្នែកអប់រំរបស់យូណេស្កូអនុវត្តគម្រោងនេះ។ ដោយមានការសម្របសម្រួលពីក្រុមស្រាវជ្រាវ និងព្យាករពីការអប់រំ ក្រុមការងារនេះបានជួបប្រជុំគ្នានៅទីក្រុងប៉ារីស នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងខែធ្នូ ឆ្នាំ ២០១៤ ដើម្បីអភិវឌ្ឍគំនិត និងពិភាក្សាលើសេចក្តីព្រាងបន្តបន្ទាប់នៃខ្លឹមសារឯកសារនេះ។ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដល់សមាជិកទាំងអស់របស់ក្រុមអ្នកជំនាញជាន់ខ្ពស់ ដែលបានចូលរួមចំណែកដ៏មានតម្លៃ ដល់ការងាររួមដ៏សំខាន់នេះ។ ផ្នែកអប់រំរបស់យូណេស្កូ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់កិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់សមាជិកទាំងអស់។

ឯកសារបោះពុម្ពផ្សាយនេះនឹងមិនអាចលេចចេញជារូបរាងឡើយ ប្រសិនបើពុំមានការចូលរួមចំណែករបស់បុគ្គលជាច្រើននាក់ ដូចជា អ្នកជំនាញពីស្ថាប័នផ្សេងទៀត និងសហការីរបស់យូណេស្កូ។ ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលទាំងនេះ ចំពោះការផ្តល់ការគាំទ្ររបស់ពួកគេ៖ Abdeljalil Akkari (សកលវិទ្យាល័យហ្សឺណែវ), Massimo Amadio (ការិយាល័យអប់រំអន្តរជាតិរបស់យូណេស្កូ), David Atchoarena (ផ្នែកគោលនយោបាយ និងប្រព័ន្ធរៀនសូត្រពេញមួយជីវិតរបស់យូណេស្កូ), Sylvain Aubry (គំនិតផ្តួចផ្តើមសកលដើម្បីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌), Néjib Ayed (សម្ព័ន្ធអង្គការអប់រំ វប្បធម៌ និងវិទ្យាសាស្ត្ររបស់អារ៉ាប់), Aaron Benavot (ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានសកលនៃការអប់រំសម្រាប់ទាំងអស់គ្នា), Mark Bray (សកលវិទ្យាល័យហុងកុង), Arne Carlsen (វិទ្យាស្ថានសម្រាប់ការរៀនសូត្រពេញមួយជីវិតរបស់យូណេស្កូ), Michel Carton (បណ្តាញគោលនយោបាយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិខាងការអប់រំ និងការបណ្តុះបណ្តាល), Borhene Chakroun (ផ្នែកយុវជន អក្ខរកម្ម និងអភិវឌ្ឍន៍ជំនាញ របស់យូណេស្កូ, Kai-ming Cheng (សកលវិទ្យាល័យហុងកុង), Maren Elfert (សកលវិទ្យាល័យប្រ៊ីតធីសកូឡុំបៀ), Paulin J. Hountondji (ក្រុមប្រឹក្សាអប់រំជាតិរបស់ប្រទេសបេនីន), Klaus Hüfner (សកលវិទ្យាល័យប៊ែឡាំង), Ruth Kagia (លទ្ធផលសម្រាប់ការអភិវឌ្ឍ), Taeyoung Kang (វិទ្យាស្ថានស្រាវជ្រាវ POSCO ទីក្រុងសេអ៊ូល), Maria Khan (សមាគមអាស៊ីប៉ាស៊ីហ្វិច សម្រាប់ការអប់រំកម្រិតមូលដ្ឋាន និងការអប់រំមនុស្សពេញវ័យ), Valérie Liechti (ទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍), Candy Lugas (វិទ្យាស្ថានអន្តរជាតិខាងផែនការអប់រំរបស់យូណេស្កូ), Ian Macpherson (មូលនិធិសង្គមបើកទូលាយ), Rolla Moumne Beulque (ផ្នែកគោលនយោបាយអប់រំរបស់យូណេស្កូ), Renato Opertti (ការិយាល័យអប់រំអន្តរជាតិរបស់យូណេស្កូ), Svein Osttveit (ការិយាល័យប្រតិបត្តិ ផ្នែកអប់រំរបស់យូណេស្កូ), David Post (ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានសកលនៃការអប់រំសម្រាប់ទាំងអស់គ្នា), Sheldon

Shaeffer (អ្នកឯកទេសខាងអប់រំកុមារតូច និងអភិបាលកិច្ច), Dennis Sinyolo (អង្គការអប់រំអន្តរជាតិ) និង Rosa-Maria Torres (Instituto Fronesis, Quito) ។

ចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមស្រាវជ្រាវ និងព្យាករការអប់រំ របស់យូណេស្កូ ដែលបានជួយឲ្យគម្រោងនេះសម្រេចបានលទ្ធផលជាផ្លែផ្កា។ ក្រោមការផ្តួចផ្តើមរបស់ Georges Haddad, អតីតប្រធានក្រុមនេះ ដំណើរការរៀបចំព្រាងឯកសារនេះធ្វើឡើងក្រោមការដឹកនាំ និងសម្របសម្រួល ដោយ Sobhi Tawil អ្នកឯកទេសកម្មវិធីជាន់ខ្ពស់ ដោយមានការគាំទ្រពី Rita Locatelli និង Luca Solesin ពីពីប្រធានផ្នែកសិទ្ធិមនុស្ស និងក្រមសីលធម៌សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់យូណេស្កូ នៅសកលវិទ្យាល័យ Bergamo ប្រទេសអ៊ីតាលី ក៏ដូចជា Huong Le Thu ដែលជាអ្នកឯកទេសផ្នែកកម្មវិធីរបស់យូណេស្កូ។ ជំនួយការស្រាវជ្រាវផ្សេងទៀត រួមមាន Marie Cougoureux, Jiawen Li, Giorgiana Maciuca, Guillermo Nino Valdehita, Victor Nouis, Marion Poutrel, Hélène Verrue និង Shan Yin។



Qian Tang, Ph.D.

អគ្គនាយករងទទួលបន្ទុកការងារអប់រំ

# មាតិកា


អារម្ភកថា ៣
សេចក្តីថ្លែងអំណរគុណ ៥
បញ្ជីប្រអប់ ១០
សេចក្តីសង្ខេប ១២
សេចក្តីផ្តើម ១៩

**១. ការអភិវឌ្ឍប្រកបដោយចីរភាព៖ ការព្រួយបារម្ភចម្បង** ២៧
បញ្ហាប្រឈម និងភាពតានតឹង ២៧
ឱកាសទទួលបានចំណេះដឹងថ្មីៗ ៣៦
ការស្វែងយល់ពីអភិក្រមផ្សេងទៀត ៤០

**២. ការបញ្ជាក់ឡើងវិញពីអភិក្រមមនុស្សនិយម** ៤៩
អភិក្រមអប់រំបែបមនុស្សនិយម ៥០
ការធានាយ៉ាងណាឲ្យការអប់រំកាន់តែមានបរិយាប័ន្ន ៥៩
ការប្រែប្រួលនៃទិដ្ឋភាពនៃការអប់រំ ៦៩
តួនាទីរបស់អ្នកអប់រំក្នុងសង្គមពុទ្ធិ ៨០

**៣. ការគាំទ្រគោលនយោបាយអប់រំ ក្នុងពិភពលោកដែលពោរពេញដោយភាពស្មុគស្មាញ** ៨៧
ការកើនឡើងនូវគម្លាតរវាងការអប់រំ និងការងារ ៨៧
ការទទួលស្គាល់ និងការបញ្ជាក់សុពលភាពលើការរៀនសូត្រក្នុងពិភពលោកដែលមនុស្សផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ៩៣

ការពិចារណាឡើងវិញលើការអប់រំភាពជាពលរដ្ឋ ក្នុងពិភពលោកដែលពោរពេញដោយភាពចម្រុះ និងការភ្ជាប់ទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ៩៩
អភិបាលកិច្ចលើការអប់រំជាសកល និងការតាក់តែងគោលនយោបាយជាតិ ១០២

## ៤. ការអប់រំជាទំនិញរួម? ១០៩

គោលការណ៍ដែលចាត់ទុកការអប់រំថាជាទំនិញសាធារណៈ កំពុងទទួលរងសម្ពាធ ១០៩
ការអប់រំ និងចំណេះដឹង ក្នុងនាមជាទំនិញរួមជាសកល ១១៨
ចំណុចសម្រាប់ពិចារណាជាជំហានបន្ទាប់ ១២៦

# បញ្ជីប្រអប់


| | |
|---|---|
| ១. វិសមភាពនៃចំណូលមានកម្រិតខ្ពស់នៅអាមេរិចឡាទីន បើទោះបីជាមានកំណើនសេដ្ឋកិច្ចរឹងមាំយ៉ាងណាក៏ដោយ | ៣២ |
| ២. ចំណុចប្រសព្វនៃប្រព័ន្ធចំណេះដឹងផ្សេងៗ | ៤២ |
| ៣. Sumak kawsay – ការយល់ឃើញមួយផ្សេងទៀតពីការអភិវឌ្ឍ | ៤៤ |
| ៤. ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការអប់រំ | ៤៦ |
| ៥. ជំនាញមូលដ្ឋាន ជំនាញដែលអាចផ្ទេរបាន និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ | ៥៦ |
| ៦. កុមារពិការតែងត្រូវបានគេមើលរំលង | ៦១ |
| ៧. ស្តាប់សម្លេងរបស់ក្មេងស្រីដែលពុំបានទទួលសេវាអប់រំ | ៦២ |
| ៨. ប្រទេសសេណេហ្គាល់៖ បទពិសោធន៍ “Case des Tout-Petits” | ៦៥ |
| ៩. សកលវិទ្យាល័យអន្តរវប្បធម៌ ក្នុងប្រទេសម៉ិចស៊ិច | ៦៨ |
| ១០. ការពិសោធន៍ “ប្រហោងក្នុងជញ្ជាំង” | ៧២ |
| ១១. ថ្នាក់អក្ខរកម្មចល័តសម្រាប់ក្មេងស្រី ក្នុងប្រទេសប៉ាគីស្ថាន | ៧៥ |
| ១២. ឆ្ពោះទៅការអប់រំកម្រិតឧត្តមសិក្សាហួសផុតពីទម្រង់បែបប្រពៃណី | ៧៧ |
| ១៣. គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិតខ្ពស់ និងទទួលបានការផ្តល់តម្លៃខ្ពស់ ក្នុងប្រទេសហ្វាំងឡង់ | ៨២ |
| ១៤. ការពង្រឹងឱកាសការងារ សម្រាប់យុវជន | ៩១ |

| | |
|---|---|
| ១៥. ការផ្លាស់ប្តូរនិន្នាការនៃការធ្វើចំណាកស្រុកទៅកាន់ Bangalore និង Hyderabad | ៩៤ |
| ១៦. ការបង្រៀនគួរឯកជន ធ្វើឲ្យប៉ះពាល់ដល់ឱកាសទទួលបានការអប់រំរបស់ប្រជាពលរដ្ឋក្រីក្រ ក្នុងប្រទេសអេហ្ស៊ីប | ១១៣ |
| ១៧. ការគោរព ការបំពេញ និងការការពារសិទ្ធិទទួលបានការអប់រំ | ១១៥ |
| ១៨. ការបង្កើត ការត្រួតពិនិត្យ ការទទួលបាន ការបញ្ជាក់សុពលភាព និងការប្រើប្រាស់ចំណេះដឹង | ១២១ |

# សេចក្តីសង្ខេប

លក្ខណៈពិសេសនៃការផ្លាស់ប្តូរក្នុងពិភពលោកបច្ចុប្បន្ននេះ គឺកម្រិតថ្មីៗនៃភាពស្មុគស្មាញ និងភាពផ្ទុយគ្នា។ ការផ្លាស់ប្តូរទាំងនេះនាំមកនូវភាពតានតឹង ដែលបុគ្គល និងសហគមន៍ចាំបាច់ត្រូវសម្របខ្លួនតាម និងឆ្លើយតប ដោយប្រើប្រាស់សមត្ថភាពដែលបានពីការអប់រំ។ ឯកសារបោះពុម្ពផ្សាយនេះ ជាការរួមចំណែកដល់ការពិចារណាសារជាថ្មីពីការអប់រំ និងការរៀនសូត្រនៅក្នុងបរិបទនៃការផ្លាស់ប្តូរនេះ។ ឯកសារនេះត្រូវបានរៀបចំឡើង ដោយឈរមូលដ្ឋានលើភារកិច្ចមួយ ក្នុងចំណោមភារកិច្ចសំខាន់ៗរបស់យូណេស្កូ ក្នុងនាមជាអ្នកសង្កេតការណ៍ជាសកលលើការផ្លាស់ប្តូរនានាដែលកើតមានក្នុងសង្គម ក្នុងគោលបំណងបំផុសឲ្យមានការជជែកវែកញែកគោលនយោបាយសាធារណៈ។

ឯកសារនេះអំពាវនាវឲ្យមានកិច្ចពិគ្រោះយោបល់ ក្នុងចំណោមគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ ឯកសារនេះត្រូវបានរៀបចំឡើង ដោយឈរលើចក្ខុវិស័យមនុស្សនិយមសម្រាប់ការអប់រំ និងការអភិវឌ្ឍ ដែលមានមូលដ្ឋានលើការគោរពសេចក្តីថ្លៃថ្នូរក្នុងជីវិតរបស់មនុស្ស សិទ្ធិស្មើភាពគ្នា យុត្តិធម៌សង្គម វប្បធម៌ចម្រុះ សាមគ្គីភាពអន្តរជាតិ និងការទទួលខុសត្រូវរួម ដើម្បីនិរន្តរភាពនាពេលអនាគត។ ទាំងនេះគឺជាមូលដ្ឋានសម្រាប់មនុស្សជាតិរួម។ សៀវភៅនេះធ្វើឲ្យគេឃើញយ៉ាងច្បាស់នូវចក្ខុវិស័យ ដែលត្រូវបានដាក់ចេញក្នុងឯកសារបោះពុម្ពផ្សាយសំខាន់ៗចំនួនពីររបស់យូណេស្កូ៖ រៀនដើម្បីក្លាយ ជាប្រជាពលរដ្ឋល្អ៖ ពិភពនៃការអប់រំបច្ចុប្បន្ន និងអនាគត (Learning to Be: The world of education today and tomorrow) (១៩៧២) ហៅកាត់ថា "Faure Report" និងការរៀនសូត្រ៖ ទ្រព្យមហាសាលដែលជាប់នៅនឹងខ្លួនជានិច្ច (Learning: The treasure within) (១៩៩៦) ហៅកាត់ថា "Delors Report"។

## ការអភិវឌ្ឍប្រកបដោយចីរភាព៖ ការព្រួយបារម្ភជាចម្បង

បំណងប្រាថ្នាចង់បានការអភិវឌ្ឍប្រកបដោយចីរភាព តម្រូវឲ្យយើងទាំងអស់គ្នាដោះស្រាយបញ្ហា និងភាពតានតឹងរួម និងចេះសម្គាល់កាលនុវត្តភាពថ្មី។ កំណើនសេដ្ឋកិច្ច និងការបង្កើតទ្រព្យសម្បត្តិ បានកាត់បន្ថយអត្រានៃភាពក្រីក្រនៅទូទាំងសកលលោក ប៉ុន្តែភាពងាយរងគ្រោះ វិសមភាព ការផាត់ក្រុមណាមួយចេញ និងអំពើហិង្សា មានការកើនឡើងក្នុងសង្គមមួយផង និងរវាងសង្គមមួយ និងសង្គមមួយទៀតផង ទូទាំងពិភពលោក។ ផលិតកម្មសេដ្ឋកិច្ច និង

ការប្រើប្រាស់ក្នុងនិទ្ទាការដែលពុំមាននិរន្តរភាព ជាកត្តារួមចំណែកឲ្យមានការឡើងកម្តៅផែនដី ការរិចរឹលបរិស្ថាន និងការកើនឡើងនូវគ្រោះមហន្តរាយធម្មជាតិ។ លើសពីនេះ ខណៈពេលដែល ក្នុងរយៈពេលជាច្រើនទសវត្សរ៍ចុងក្រោយនេះ មានការពង្រឹងក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ ក៏ពិតមែន ការអនុវត្ត និងការការពារបទដ្ឋានទាំងនេះ នៅតែជាបញ្ហាប្រឈម។ ឧទាហរណ៍ បើទោះបីជាស្ត្រីកាន់តែទទួលបានភាពអង់អាច តាមរយៈការទទួលបានសេវាអប់រំច្រើនជាងមុន ពួកគេនៅតែប្រឈមនឹងការរើសអើងក្នុងជីវិតសាធារណៈ និងក្នុងការងារ។ អំពើហិង្សាលើស្ត្រី និងកុមារ ជាពិសេស លើក្មេងស្រី បន្តធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។ ដូចលើកឡើងពី ខាងដើម ខណៈពេលដែលការអភិវឌ្ឍផ្នែកបច្ចេកវិទ្យារួមចំណែកបង្កើនការភ្ជាប់ទំនាក់ទំនងគ្នា ទៅវិញទៅមក និងផ្តល់ច្រកថ្មីៗសម្រាប់ធ្វើការផ្តោះប្តូរព័ត៌មាន សហការ និងបង្កើនសាមគ្គីភាព យើងក៏មើលឃើញផងដែរនូវការមិនយល់អធ្យាស្រ័យគ្នារវាងមនុស្សដែលមានវប្បធម៌ និង សាសនាផ្សេងគ្នា ការកៀងគរនយោបាយផ្អែកតាមអត្តសញ្ញាណ និងជម្លោះ។

ការអប់រំត្រូវតែរិះរកវិធីឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ ដោយធ្វើការពិចារណា លើទស្សនៈយល់ឃើញលើពិភពលោកពីប្រភពខុសៗគ្នា និងលើប្រព័ន្ធផ្តល់ចំណេះដឹងជា ជម្រើសផ្សេងៗ ក៏ដូចជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗ ដូចជា ការរីកចម្រើនខាងវិទ្យាសាស្ត្រ ខួរក្បាល និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ជាដើម។ ការពិចារណាសារជាថ្មីពីគោលបំណង នៃការអប់រំ និងការរៀបចំការរៀនសូត្រ មិនដែលបន្ទាន់ដូចពេលនេះឡើយ។

## ការបញ្ជាក់សារជាថ្មីពីការប្រើប្រាស់ អភិក្រមអប់រំបែបមនុស្សនិយម

**(Humanistic Approach to Education)**

គេមិនសង្ឃឹមថា ការអប់រំតែងឯកឯងអាចដោះស្រាយរាល់បញ្ហាប្រឈមនៃការអភិវឌ្ឍ ទាំងអស់នោះទេ ប៉ុន្តែការប្រើប្រាស់អភិក្រមអប់រំបែបមនុស្សនិយម និងគួររួមចំណែកសម្រេច នូវគំរូអភិវឌ្ឍន៍ថ្មី។ ក្នុងគំរូអភិវឌ្ឍន៍ថ្មីនេះ កំណើនត្រូវតម្រង់ទិសដោយការគ្រប់គ្រងបរិស្ថាន និង ការគិតគូរពីសន្តិភាព បរិយាប័ន្នភាព និងយុត្តិធម៌សង្គម។ អភិក្រមអភិវឌ្ឍន៍បែបមនុស្សនិយម ប្រកាន់គោលការណ៍ក្រមសីលធម៌ប្រឆាំងនឹងអំពើហិង្សា ការមិនអធ្យាស្រ័យឲ្យគ្នា ការរើសអើង និងការផាត់ក្រុមណាមួយចេញ។ សម្រាប់ការអប់រំ និងការរៀនសូត្រវិញ អភិក្រមនេះផ្តោតហួស ពីគោលការណ៍សម្ភារនិយម (utilitarianism) និងសេដ្ឋកិច្ចនិយម (economism) ដែលមាន លក្ខណៈចង្អៀត ដើម្បីបញ្ចូលទិដ្ឋភាពជាច្រើនផ្សេងទៀតនៃអត្ថិភាពរបស់មនុស្ស។ អភិក្រម នេះផ្តោតការយកចិត្តទុកដាក់លើការផ្តល់លទ្ធភាពឲ្យអ្នកដែលតែងទទួលរងការរើសអើងបាន ចូលរួមដូចក្រុមផ្សេងទៀត ដូចជា ស្ត្រីនិងកុមារ ជនជាតិដើមភាគតិច ជនពិការ ជនចំណាកស្រុក

ចាស់ជរា និងអ្នករស់នៅក្នុងប្រទេសដែលរងផលប៉ះពាល់ ដោយសារជម្លោះ។ អភិក្រមនេះទាមទារឲ្យមានការប្រើប្រាស់គោលវិធីរៀនសូត្រដែលបើកទូលាយ និងមានភាពបត់បែនដែលអាចឲ្យគេប្រើប្រាស់ពេញមួយជីវិតផង និងក្នុងគ្រប់សកម្មភាពទាំងអស់ក្នុងជីវិតផង៖ នេះជាអភិក្រមមួយ ដែលផ្ដល់ឱកាសឲ្យមនុស្សគ្រប់រូបអាចសម្រេចនូវសក្ដានុពលរបស់ពួកគេ ពោលគឺអនាគតមួយប្រកបដោយចីរភាព និងជីវិតពោរពេញទៅដោយសេចក្ដីថ្លៃថ្នូរ។ អភិក្រមមនុស្សនិយម មានភាពពាក់ព័ន្ធជាមួយនឹងការកំណត់ពីខ្លឹមសារសម្រាប់រៀនសូត្រ និងវិធីសាស្រ្តគរុកោសល្យ ក៏ដូចជាតួនាទីរបស់គ្រូ និងអ្នកអប់រំដទៃទៀត។ អភិក្រមបែបនេះរឹតតែមានភាពពាក់ព័ន្ធទៅទៀត ក្នុងបរិការណ៍នៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាថ្មីៗ ជាពិសេស បច្ចេកវិទ្យាឌីជីថល។

## ការតាក់តែងគោលនយោបាយនៅថ្នាក់មូលដ្ឋាន និងកម្រិតសកល ក្នុងពិភពលោកដ៏សែនស្មុគស្មាញ

ការកើនឡើងនូវកម្រិតនៃភាពស្មុគស្មាញខាងសង្គម និងសេដ្ឋកិច្ច បង្កើតនូវបញ្ហាប្រឈមជាច្រើន សម្រាប់ការតាក់តែងគោលនយោបាយអប់រំ ក្នុងពិភពសកលភាវូបនីយកម្មបច្ចុប្បន្ននេះ។ ប្រពលវប្បកម្មនៃសកលភាវូបនីយកម្មសេដ្ឋកិច្ច កំពុងបង្កើតនូវនិន្នាការកំណើនដែលបង្កើតការងារបានតិច ដែលធ្វើឲ្យយុវជនកាន់តែច្រើននាក់គ្មានការងារធ្វើ និងបង្កើតការងារដែលងាយរងគ្រោះ។ ខណៈពេលដែលនិន្នាការនេះរំលេចឲ្យឃើញពីការផ្ដាច់ទំនាក់ទំនងរវាងការអប់រំ និងពិភពការងារដែលកំពុងមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស និន្នាការទាំងនេះក៏ជាកាលានុវត្តភាពមួយ ដើម្បីឲ្យយើងធ្វើការពិចារណាឡើងវិញពីទំនាក់ទំនងរវាងការអប់រំ និងការអភិវឌ្ឍសង្គម។ លើសពីនេះ ការកើនឡើងនូវចល័តភាពរបស់អ្នករៀនសូត្រ និងពលករឆ្លងដែន និងនិន្នាការថ្មីៗនៃការផ្ទេរចំណេះដឹង និងជំនាញ ទាមទារឲ្យគេប្រើប្រាស់វិធីសាស្រ្តថ្មីៗ ដើម្បីទទួលស្គាល់ បញ្ជាក់សុពលភាព និងធ្វើការវាយតម្លៃលើការរៀនសូត្រ។ ពាក់ព័ន្ធនឹងភាពជាពលរដ្ឋវិញ បញ្ហាប្រឈមសម្រាប់ប្រព័ន្ធអប់រំរបស់ជាតិគឺការកំណត់ពីអត្តសញ្ញាណ និងបង្កើនការយល់ដឹង ក៏ដូចជាស្មារតីទទួលខុសត្រូវលើអ្នកដទៃទៀត ក្នុងពិភពលោកដែលកាន់តែមានទំនាក់ទំនងជាមួយគ្នា និងកាន់តែពឹងផ្អែកលើគ្នាទៅវិញទៅមកបែបនេះ។

ការពង្រីកលទ្ធភាពទទួលបានការអប់រំក្នុងពិភពលោកទាំងមូល ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងទៅនេះ កាន់តែដាក់សម្ពាធបន្ថែមទៀតលើធនធានហិរញ្ញប្បទានសាធារណៈ។ លើសពីនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាពលរដ្ឋកាន់តែចង់បញ្ចេញសម្លេងរបស់ខ្លួនក្នុងកិច្ចការសាធារណៈ និងចង់ឲ្យភាគីពាក់ព័ន្ធមិនមែនរដ្ឋចូលរួមក្នុងការងារអប់រំ

ផងដែរ ទាំងនៅថ្នាក់ជាតិ ទាំងកម្រិតសកលលោក។ ការធ្វើពិពិធកម្មភាពជាដៃគូ ធ្វើឲ្យព្រំដែនរវាងវិស័យសាធារណៈ និងឯកជនកាន់តែព្រិលទៅៗ ដែលបង្កឲ្យមានបញ្ហាដល់ការធ្វើអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យលើការអប់រំ។ ជារួម ភាពចាំបាច់ដើម្បីសម្របសម្រួលការរួមចំណែក និងតម្រូវការរបស់តួអង្គទាំង ៣ ដែលជាអ្នកកំណត់ឥរិយាបថសង្គម ពោលគឺសង្គម រដ្ឋ និងទីផ្សារ កាន់តែមានការកើនឡើង។

## កំណត់ឡើងវិញនូវបរិបទនៃការអប់រំ និងចំណេះដឹង ដែលជាទំនិញរួមរបស់សកលលោកទាំងមូល

ដោយសារតែស្ថានភាពជាក់ស្តែងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សបែបនេះ យើងចាំបាច់ត្រូវពិចារណាឡើងវិញលើគោលការណ៍ដែលតម្រង់ទិសអភិបាលកិច្ចអប់រំបច្ចុប្បន្ន៖ ជាពិសេសសិទ្ធិទទួលបានការអប់រំ និងទស្សនៈដែលចាត់ទុកការអប់រំជាទំនិញសាធារណៈ។ ជាការពិតយើងតែងចាត់ទុកការអប់រំជាសិទ្ធិមនុស្ស និងជាទំនិញសាធារណៈ ក្នុងកិច្ចពិភាក្សាជាអន្តរជាតិអំពីការអប់រំ។ ប៉ុន្តែ ខណៈពេលដែលគោលការណ៍ទាំងនេះមិនសូវជាមានការតវ៉ាជំទាស់សម្រាប់ការអប់រំកម្រិតមូលដ្ឋាន ក្នុងការពិភាក្សាជាច្រើនពុំមានការឯកភាពគ្នាជាទូទៅលើការប្រើប្រាស់គោលការណ៍នេះ សម្រាប់ការអប់រំក្រោយកម្រិតមូលដ្ឋាន និងការបណ្តុះបណ្តាលនោះទេ។ តើសិទ្ធិទទួលបានការអប់រំ និងគោលការណ៍ទំនិញសាធារណៈ ត្រូវបានគេប្រើប្រាស់សម្រាប់ការអប់រំក្រៅប្រព័ន្ធ និងក្រៅផ្លូវការ ដែលមិនសូវជាមានរចនាសម្ព័ន្ធផ្លូវការក្នុងកម្រិតណា? ដូច្នេះ ការព្រួយបារម្ភជុំវិញចំណេះដឹង ដែលសំដៅលើព័ត៌មាន ការយល់ដឹងជំនាញ គុណតម្លៃ និងឥរិយាបថ ទទួលបានតាមរយៈការរៀនសូត្រ គឺជាប្រធានបទសំខាន់សម្រាប់ការពិភាក្សានានាអំពីគោលបំណងនៃការអប់រំ។

អ្នកនិពន្ធសៀវភៅនេះស្នើឲ្យចាត់ទុកចំណេះដឹង និងការអប់រំជាទំនិញរួម។ នេះមានន័យថាការបង្កើតចំណេះដឹង ក៏ដូចជាការទទួល ការបញ្ជាក់សុពលភាព និងការប្រើប្រាស់ចំណេះដឹងគឺជាអ្វីដែលកើតមានទូទៅសម្រាប់មនុស្សគ្រប់រូប ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់សង្គម។ ប្បញ្ញត្តិទំនិញរួមបែបនេះ ផ្តល់លទ្ធភាពឲ្យយើងពិចារណាលើឥទ្ធិពលផ្សេងទៀតលើសពីឥទ្ធិពលនៃទ្រឹស្តីសង្គម-សេដ្ឋកិច្ចបែបបុគ្គលនិយម ដែលមានក្នុងប្បញ្ញត្តិ "ទំនិញសាធារណៈ" កន្លងមក។ ប្បញ្ញត្តិនេះគូសបញ្ជាក់ថា ការកំណត់ពីអ្វីដែលជាទំនិញរួមត្រូវធ្វើឡើងក្នុងដំណើរការដែលមានការចូលរួម ដោយត្រូវធ្វើការពិចារណាលើលក្ខណៈផ្សេងៗគ្នានៃបរិបទទស្សនទានសុខុមាលភាព និងប្រព័ន្ធរៀបចំចំណេះដឹង។ ចំណេះដឹង គឺជាផ្នែកបន្សល់ទុកពីជំនាន់មួយទៅជំនាន់មួយទៀតនៃបេតិកភ័ណ្ឌរួមរបស់មនុស្សជាតិ។ ដោយសារតែការអភិវឌ្ឍ

ប្រកបដោយចីរភាពបានក្លាយជាតម្រូវការចាំបាច់ក្នុងពិភព-លោក ដែលកាន់តែពឹងផ្អែកលើគ្នាទៅវិញទៅមក គេគួរចាត់ទុកការអប់រំ និងចំណេះដឹងថាជាទំនិញរួមជាសកល។ ផ្អែកតាមគុណតម្លៃនៃសាមគ្គីភាព ដែលត្រូវបានចាក់ឫសយ៉ាងជ្រៅក្នុងស្មារតីមនុស្សជាតិរួមរបស់យើង គោលការណ៍ដែលចាត់ទុកចំណេះដឹង និងការអប់រំជាទំនិញរួមសម្រាប់សកលលោកទាំងមូល មានភាពពាក់ព័ន្ធទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធចម្រុះ។ នេះក៏ជាដូចគ្នាសម្រាប់អង្គការអន្តរជាតិនានា ដូចជា យូណេស្កូ ជាដើម ដែលជាស្ថាប័នមានមុខងារសង្កេត និងកំណត់បទដ្ឋាននៅកម្រិតសកលលោក ដែលនាំឲ្យស្ថាប័ននេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីជម្រុញ និងដឹកនាំឲ្យមានការពិភាក្សាវែកញែកគោលនយោបាយសាធារណៈនៅកម្រិតសកល។

## ការពិចារណាសម្រាប់អនាគត

ខណៈពេលដែលយើងព្យាយាមសម្រេចគោលបំណងនៃការរៀនសូត្រ និងការរៀបចំការរៀនសូត្រ ឲ្យជាកិច្ចខិតខំប្រឹងប្រែងរួមរបស់សង្គមទាំងមូល សំណួរខាងក្រោមនេះអាចជាជំហានដំបូងៗ សម្រាប់ការពិភាក្សាវែកញែកបែបនេះ៖ ស្របពេលដែលសសរស្តម្ភទាំង ៤ នៃការរៀនសូត្រ - រៀនដើម្បីដឹង រៀនដើម្បីធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនរស់នៅជាមួយគ្នា នៅតែភាពពាក់ព័ន្ធ សសរស្តម្ភទាំងបួននេះកំពុងទទួលរងការគំរាមកំហែង ដោយសារចរន្តសកលភាវូបនីយកម្ម និងដោយសារការកើនឡើងនូវនយោបាយដែលប្រើប្រាស់អត្តសញ្ញាណធ្វើជាគោល។ តើគេអាចពង្រឹង និងដុសខាត់សសរស្តម្ភទាំងបួននេះឲ្យភ្លឺឡើងវិញដោយរបៀបណា? តើការអប់រំអាចឆ្លើយតបយ៉ាងដូចម្តេចខ្លះចំពោះបញ្ហាប្រឈម ដែលធ្វើឲ្យរាំងស្ទះដល់ការសម្រេចនូវនិរន្តរភាពខាងសេដ្ឋកិច្ច សង្គម និងបរិស្ថាន? តើគេអាចប្រមូលផ្តុំទស្សនៈយល់ឃើញផ្សេងៗគ្នាជាច្រើនមកបញ្ចូលគ្នាតែមួយក្នុងអភិក្រមអប់រំបែបមនុស្សនិយម ដោយរបៀបណា? តើគេអាចសម្រេចនូវអភិក្រមបែបមនុស្សនិយម តាមរយៈគោលនយោបាយ និងការអនុវត្តសកម្មភាពអប់រំដោយរបៀបណា? តើសកលភាវូបនីយកម្មមានភាពពាក់ព័ន្ធអ្វីខ្លះជាមួយនឹងគោលនយោបាយជាតិ និងការសម្រេចចិត្តក្នុងវិស័យអប់រំ? តើគួរមានការផ្តល់ហិរញ្ញប្បទានបែបណាដល់ការអប់រំ? តើមានភាពពាក់ព័ន្ធជាក់លាក់អ្វីខ្លះ ដល់ការអប់រំ ការបណ្តុះបណ្តាល ការអភិវឌ្ឍ និងការគាំទ្រគ្រូ? តើការអប់រំមានភាពពាក់ព័ន្ធអ្វីខ្លះដល់ការបែងចែករវាងទស្សនទានទំនិញឯកជន ទំនិញសាធារណៈ និងទំនិញរួម?

គួរមានការប្រមូលផ្តុំអ្នកពាក់ព័ន្ធដែលមានទស្សនៈខុសៗគ្នា ដើម្បីឲ្យពួកគេអាចចែករំលែករបកគំហើញនៃការស្រាវជ្រាវរបស់ពួកគេ និងដាក់ចេញនូវគោលការណ៍ជាបទដ្ឋាន សម្រាប់

តម្រង់ទិសដល់ការរៀបចំគោលនយោបាយនានា។ យូណេស្កូ ដែលជាស្ថាប័នបញ្ញាញាណ និងជាធនាគារគំនិត អាចបង្កើតនូវវេទិកាសម្រាប់ការពិភាក្សា និងការពិគ្រោះយោបល់បែបនេះ ដើម្បីឲ្យបង្កើនការយល់ដឹងរបស់យើងអំពីអភិក្រមថ្មីៗ សម្រាប់រៀបចំគោលនយោបាយអប់រំ និងផ្តល់សេវាអប់រំ ក្នុងគោលបំណងលើកកម្ពស់និរន្តរភាពរបស់មនុស្សជាតិ និងសុខុមាលភាពជារួមរបស់មនុស្សជាតិ។

# សេចក្ដីផ្ដើម



# សេចក្តីផ្តើម

*“ការអប់រំបណ្តុះនូវជំនឿចិត្ត។ ជំនឿចិត្តបណ្តុះក្តីសង្ឃឹម។ ក្តីសង្ឃឹមបណ្តុះសន្តិភាព”*

**ខុងជឺ ទស្សនៈវិទូចិន** ( **៥៥១-៤៧៩ មុនគ្រឹស្តសករាជ** )

## ការអំពាវនាវឲ្យមានកិច្ចពិគ្រោះយោបល់

ឯកសារនេះគឺជាការរួមភាគទានដល់ការកំណត់សារជាថ្មីនូវចក្ខុវិស័យនៃការអប់រំ ក្នុងពិភព-លោក ដែលកំពុងតែមានការផ្លាស់ប្តូរ ហើយក៏ជាផ្នែកនៃភារកិច្ចមួយ ក្នុងចំណោមភារកិច្ចសំខាន់ៗរបស់យូណេស្កូ ក្នុងនាមជាស្ថាប័នសង្កេតការណ៍ជាសកលលើការផ្លាស់ប្តូរដែលកើតមានឡើងក្នុងសង្គម។ គោលបំណងនៃឯកសារនេះ គឺបំផុសឲ្យមានការជជែកវែកញែកគោលនយោបាយសាធារណៈ ផ្តោតជាពិសេសលើការអប់រំ ក្នុងពិភពលោកដែលពោរពេញទៅដោយការផ្លាស់ប្តូរ។ ឯកសារនេះគឺជាការអំពាវនាវឲ្យមានកិច្ចពិគ្រោះយោបល់ស្របតាមចក្ខុវិស័យនៃការអប់រំ និងការអភិវឌ្ឍ បែបមនុស្សនិយម ផ្អែកតាមគោលការណ៍នៃការគោរពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សិទ្ធិស្មើភាពគ្នា និងយុត្តិធម៌សង្គម ការគោរពវប្បធម៌ចម្រុះ និងសាមគ្គីភាពជាអន្តរជាតិ និងការទទួលខុសត្រូវរួម ដែលទាំងអស់នេះសុទ្ធតែជាមូលដ្ឋាននៃមនុស្សជាតិរួម របស់យើង។ ឯកសារនេះបញ្ជាក់ពីបំណងប្រាថ្នាផង និងផ្តល់នូវការលើកទឹកចិត្តផង សម្រាប់មនុស្សគ្រប់រូបក្នុងពិភពលោក ដែលធ្វើការងារពាក់ព័ន្ធនឹងការអប់រំ។ ឯកសារនេះត្រូវបានរៀបចំឡើងសម្រាប់តាមស្មារតីនៃឯកសារបោះពុម្ពផ្សាយសំខាន់ៗចំនួនពីររបស់យូណេស្កូ៖ រៀនដើម្បីក្លាយ ជាប្រជាពលរដ្ឋល្អ៖ ពិភពនៃការអប់រំបច្ចុប្បន្ន និងអនាគត (Learning to Be: The world of education today and tomorrow) ហៅកាត់ថា “Faure Report” បោះពុម្ពក្នុងឆ្នាំ ១៩៧២ និងការរៀនសូត្រ៖ ទ្រព្យមហាសាលដែលជាប់នៅនឹងខ្លួនជានិច្ច (Learning: The treasure within) ហៅកាត់ថា “Delors Report” បោះពុម្ពក្នុងឆ្នាំ ១៩៩៦។

## មើលបកក្រោយ ដើម្បីសម្លឹងទៅមុខ[១]

ក្នុងការកំណត់សារជាថ្មីនូវចក្ខុវិស័យនៃការអប់រំ និងការរៀនសូត្រ សម្រាប់អនាគត យើងចាំបាច់ត្រូវយកការវិភាគដែលបានធ្វើកន្លងមក មកធ្វើការពិចារណា។ ឧទាហរណ៍ របាយការណ៍ Faure ឆ្នាំ ១៩៧២ បានបង្កើតនូវបញ្ញត្តិចំនួនពីរដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក នោះគឺសង្គមរៀនសូត្រ និងការអប់រំពេញមួយជីវិត ក្នុងពេលដែលប្រព័ន្ធអប់រំបែបប្រពៃណីកំពុងជួបនឹងបញ្ហាប្រឈមជាច្រើន កាលពីពេលនោះ។ នៅពេលដែលបច្ចេកវិទ្យាចេះតែមានការវិវឌ្ឍ ហើយសង្គមចេះតែមានការផ្លាស់ប្តូរ របាយការណ៍នេះបានបញ្ជាក់ថា គេមិនអាចរំពឹងថា ការអប់រំដែលមនុស្សម្នាក់ទទួលបានដំបូងៗ នៅតែអាចផ្តល់ប្រយោជន៍ដល់ពួកគេ ពេញមួយជីវិតនោះទេ។ ខណៈពេលដែលសាលារៀននៅតែជាមធ្យោបាយដែលសំខាន់ចាំបាច់ សម្រាប់ផ្ទេរចំណេះដឹងដោយមានការរៀបចំត្រឹមត្រូវ សាលារៀនត្រូវទទួលបានការបំពេញបន្ថែមពីសកម្មភាពផ្សេងទៀតនៃជីវិតក្នុងសង្គម ដូចជា ស្ថាប័នសង្គម បរិយាកាសការងារ ការកម្សាន្ត និងប្រព័ន្ធផ្សព្វផ្សាយ ជាដើម។ របាយការណ៍នេះគាំទ្រឲ្យមានការឆ្លើយតបចំពោះសិទ្ធិ និងតម្រូវការរបស់បុគ្គលម្នាក់ៗ ក្នុងការរៀនសូត្រ ដើម្បីឲ្យមានការអភិវឌ្ឍផ្ទាល់ខ្លួន ក៏ដូចជាការអភិវឌ្ឍសង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌របស់ពួកគេ។ ឯកសារនេះបានបញ្ជាក់យ៉ាងច្បាស់ថា ការអប់រំពេញមួយជីវិត គឺជាប្រធានបទគន្លឹះ សម្រាប់គោលនយោបាយអប់រំ ក្នុងប្រទេសកំពុងអភិវឌ្ឍផង និងប្រទេសអភិវឌ្ឍផង។[២]

របាយការណ៍ Delors ដែលចេញផ្សាយក្នុងឆ្នាំ ១៩៩៦ បានលើកស្នើនូវចក្ខុវិស័យរួមមួយសម្រាប់ការអប់រំ ផ្អែកទៅតាមទស្សនទានសំខាន់ៗចំនួនពីរគឺ “ការរៀនសូត្រពេញមួយជីវិត” និងសសរស្តម្ភ ៤ នៃការរៀនសូត្រ គឺរៀនដើម្បីដឹង រៀនដើម្បីធ្វើ រៀនដើម្បីរស់នៅជាមួយគ្នា និងរៀនដើម្បីក្លាយជាពលរដ្ឋល្អ។ របាយការណ៍នេះមិនមែនជាផែនការមេសម្រាប់ធ្វើការកែទម្រង់វិស័យអប់រំនោះទេ ប៉ុន្តែវាគឺជាមូលដ្ឋាន សម្រាប់ធ្វើការឆ្លុះបញ្ចាំង និងពិភាក្សាអំពីការសម្រេចចិត្តនានា ដែលគេគួរធ្វើ ក្នុងពេលតាក់តែងគោលនយោបាយនានា។ របាយការណ៍នេះលើកឡើងថា ជម្រើសពាក់ព័ន្ធនឹងការអប់រំ ត្រូវបានកំណត់ដោយការសម្រេចចិត្តថាតើយើងចង់រស់នៅក្នុងសង្គមប្រភេទណា។ ក្រៅតែពីលើកឡើងពីមុខងារបច្ចុប្បន្នរបស់វិស័យអប់រំ របាយការណ៍នេះចាត់ទុកការរៀបចំមនុស្សឲ្យមានលក្ខណៈពេញលេញ ថាជាផ្នែក

---

[១] ដកស្រង់ចេញពី Morgan, W. J. and White, I. 2013. Looking backward to see ahead: The Faure and Delors reports and the post-2015 development agenda. Zeitschrift Weiterbildung, No. 4, pp. 40-43. Medel-Añonuevo, C., Oshako, T. and Mauch, W. 2001. Revisiting lifelong learning for the 21st century.

[២] Hamburg, UNESCO Institute for Education.

មួយដ៏សំខាន់នៃគោលបំណងនៃការអប់រំ។[៣] របាយការណ៍ Delors ត្រូវបានតម្រឹមស្របតាមគោលការណ៍ក្រមសីលធម៌ និងគោលការណ៍បញ្ញាញាណ ដែលជាគោលការណ៍គ្រឹះរបស់យូណេស្កូ ដូច្នេះការវិភាគ និងអនុសាសន៍ដែលលើកឡើងក្នុងរបាយការណ៍នេះផ្ដោតច្រើនលើតម្រូវការរបស់មនុស្ស និងមិនសូវជាផ្ដោតលើតម្រូវការទីផ្សារ ដូចការសិក្សាផ្សេងទៀតអំពីកំណែទម្រង់អប់រំ ដែលបានធ្វើឡើងកាលពីពេលនោះនោះទេ។[៤]

របាយការណ៍ Faure និង Delors បានផ្ដល់ជាគំនិត សម្រាប់ការតាក់តែងគោលនយោបាយអប់រំនៅទូទាំងពិភពលោកទាំងមូល[៥] ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះ យើងត្រូវទទួលស្គាល់ថា បរិបទសកលកំពុងមានការផ្លាស់ប្ដូរ ខាងចំណេះដឹងផង និងខាងសម្ភារផង ចាប់តាំងពីទសវត្សរ៍ ១៩៧០ មក ហើយចរន្តនៃការផ្លាស់ប្ដូរបែបនេះបានកើតឡើងម្ដងទៀត ចាប់តាំងពីទសវត្សរ៍ ១៩៩០ មក។ ទសវត្សរ៍ទី ២ នៃសតវត្សរ៍ទី ២១ គឺជាចំណុចរបត់ជាប្រវត្តិសាស្ត្រថ្មីមួយ ដែលនាំមកនូវបញ្ហាប្រឈមផង និងកាលានុវត្តភាពថ្មីៗផង សម្រាប់ការរៀនសូត្រ និងការអភិវឌ្ឍរបស់មនុស្ស។ យើងកំពុងឈានចូលទៅក្នុងដំណាក់កាលជាប្រវត្តិសាស្ត្រថ្មីមួយ ដែលសង្គមនានាកាន់តែមានទំនាក់ទំនងជាមួយគ្នា និងកាន់តែពឹងផ្អែកលើគ្នាទៅវិញទៅមក និងដែលភាពស្មុគស្មាញ ភាពមិនប្រាកដប្រជា និងភាពតានតឹង បានកើនឡើងដល់កម្រិតមួយថ្មី។

## បរិបទសកលថ្មី សម្រាប់ការរៀនសូត្រ

មាននិន្នាការផ្ទុយគ្នាជាច្រើន ក្នុងស្ថានភាពជុំវិញពិភពលោក នាពេលបច្ចុប្បន្ននេះ។ ខណៈពេលដែលចរន្តសកលភាវូបនីយកម្មសេដ្ឋកិច្ច បានកាត់បន្ថយភាពក្រីក្រនៅជុំវិញពិភពលោកទាំងមូល សកលភាវូបនីយកម្មក៏នាំមកនូវប្រភេទកំណើនដែលបង្កើតការងារបានតិច បង្កើនចំនួនយុវជនដែលគ្មានការងារធ្វើ និងបង្កើតនូវប្រភេទការងារដែលងាយរងគ្រោះ។ សកលភាវូបនីយកម្មសេដ្ឋកិច្ច ក៏ពង្រីកវិសមភាពរវាងប្រទេសមួយ និងប្រទេសមួយ និងរវាងក្រុមមួយ និងក្រុមមួយទៀត ក្នុងប្រទេសតែមួយផងដែរ។ ប្រព័ន្ធអប់រំក៏រួមចំណែកធ្វើឲ្យមានវិសមភាពបែបនេះផងដែរ ដោយសារតែប្រព័ន្ធអប់រំ ពុំបានយកចិត្តទុកដាក់ចំពោះតម្រូវការអប់រំរបស់សិស្សដែលជួបការលំបាក និងរបស់មនុស្សជាច្រើន ដែលរស់នៅក្នុងប្រទេសក្រីក្រ

[៣] Power, C. N. 1997. Learning: a means or an end? A look at the Delors Report and its implications for educational renewal. Prospects, Vol. XXVII, No. 2, p.118.

[៤] Ibid.

[៥] សម្រាប់ការពិភាក្សាពីចំណុចនេះ សូមមើល Tawil, S. and Cougoureux, M. 2013. Revisiting Learning: Thetreasure within – Assessing the influence of the 1996 Delors report. Paris, UNESCO Education Research and Foresight, ERF Occasional Papers, No. 4; Elfert, M. 2015. UNESCO, the Faure report, the Delors report, and the political utopia of lifelong learning. European Journal of Education, 50.1, pp. 88-100.

ឡើយ ហើយក្នុងពេលជាមួយគ្នា ប្រព័ន្ធអប់រំប្រមូលផ្ដុំឱកាសអប់រំតែសម្រាប់ក្រុមអ្នកមាន ដែលការអនុវត្តបែបនេះធ្វើការឲ្យការបណ្ដុះបណ្ដាល និងការអប់រំដែលមានគុណភាពខ្ពស់ ក្លាយជាសេវាពិសេសផ្ដាច់មុខសម្រាប់ក្រុមអ្នកមាន។ និន្នាការកំណើនសេដ្ឋកិច្ចបច្ចុប្បន្ន គួបផ្សំនឹងកំណើនប្រជាសាស្ត្រ និងចរន្តនគរូបនីយកម្មផង កំពុងធ្វើឲ្យរិចរឹលធនធានធម្មជាតិដែលមិនអាចកកើតឡើងវិញ និងធ្វើឲ្យបំពុលបរិស្ថាន បង្កឲ្យមានការប្រែប្រួលអាកាសធាតុ និងការខូចខាតដល់ប្រព័ន្ធអេកូឡូហ្ស៊ី ដែលមិនអាចស្ដារឡើងវិញបាន។ លើសពីនេះ ដោយសារតែមានការទទួលស្គាល់កាន់តែខ្លាំងឡើងៗនូវវប្បធម៌ចម្រុះ (មិនថាជាវប្បធម៌ដែលមានតាំងពីដើមរៀងមករបស់ប្រជាជាតិ-រដ្ឋ ឬដែលកើតឡើងដោយសារកំណើននៃការធ្វើចំណាកស្រុក និងភាពងាយស្រួលក្នុងការផ្លាស់ទីពីតំបន់មួយទៅតំបន់មួយទៀត) យើងក៏បានកត់សម្គាល់ឃើញផងដែរនូវការកើនឡើងយ៉ាងគំហុកនូវជម្លោះវប្បធម៌ និងសាសនា ក៏ដូចជាចលនានយោបាយ និងជម្លោះប្រកាន់អត្តសញ្ញាណ។ អំពើភេរវកម្ម អំពើហិង្សាពាក់ព័ន្ធនឹងគ្រឿងញៀន សង្គ្រាម និងជម្លោះផ្ទៃក្នុង និងសូម្បីតែអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាក្នុងសាលារៀន ក៏កាន់តែមានការកើនឡើងផងដែរ។ និន្នាការនៃអំពើហិង្សាទាំងនេះលើកជាសំណួរឲ្យវិស័យអប់រំឆ្លើយ ដោយសារតែវិស័យនេះជាអ្នកដែលសម្រួចគុណតម្លៃ និងឥរិយាបថសម្រាប់ការរស់នៅជាមួយគ្នា។ លើសពីនេះ ដោយសារតែមានជម្លោះ និងវិបត្តិបែបនេះ កុមារជិត ៣០ លាននាក់ បាត់បង់សិទ្ធិទទួលបានការអប់រំកម្រិតមូលដ្ឋាន ដែលបង្កើតឲ្យមានមនុស្សពេញវ័យដែលមិនបានទទួលការអប់រំជាច្រើនជំនាន់នាពេលអនាគត ហើយដែលគេមិនយកចិត្តទុកដាក់ ក្នុងគោល-នយោបាយអភិវឌ្ឍន៍នានា។ បញ្ហាទាំងនេះ គឺជាបញ្ហាប្រឈមជាមូលដ្ឋាន ដែលមនុស្សត្រូវយល់ពីអ្នកដទៃ និងដើម្បីឲ្យមានការរស់នៅចុះសម្រុងគ្នា ក្នុងសកលលោកទាំងមូល។

ក្នុងពេលជាមួយគ្នា យើងក៏បានមើលឃើញពីការទាមទារចង់មានសម្លេង ក្នុងកិច្ចការសាធារណៈ ក្នុងបរិបទអភិបាលកិច្ចមូលដ្ឋាន និងសកល ដែលកំពុងមានការផ្លាស់ប្ដូរផងដែរ។ វឌ្ឍនភាពដ៏អស្ចារ្យនៃការភ្ជាប់ទំនាក់ទំនងអ៊ីនធឺណិត បច្ចេកវិទ្យាទូរស័ព្ទចល័ត និងប្រព័ន្ធផ្សព្វផ្សាយឌីជីថលផ្សេងទៀត គួបផ្សំជាមួយនឹងការបើកចំហការទទួលបានការអប់រំសាធារណៈ និងការអភិវឌ្ឍវិស័យអប់រំឯកជនក្នុងទម្រង់ផ្សេងៗផង បានធ្វើឲ្យនិន្នាការនៃការចូលរួមក្នុងសកម្មភាពសង្គម ស៊ីវិល និងនយោបាយ មានការផ្លាស់ប្ដូរ។ លើសពីនេះ ការកើនឡើងនូវចល័តភាពនៃពលករ និងអ្នករៀនសូត្ររវាងប្រទេសមួយនិងប្រទេសមួយទៀត រវាងការងារមួយនិងការងារមួយទៀត និងក្នុងបរិយាកាសនៃការរៀនសូត្រ រឹតតែបង្កើនភាពចាំបាច់ឲ្យគេធ្វើការពិចារណាឡើងវិញលើរបៀបផ្ដល់ការទទួលស្គាល់ បញ្ជាក់សុពលភាព និងវាយតម្លៃលើការរៀនសូត្រ និងសមត្ថភាព។

ការផ្លាស់ប្តូរដែលកើតឡើងទាំងនេះ មានភាពពាក់ព័ន្ធដល់ការអប់រំ និងជាសញ្ញាដែលបង្ហាញពីការលេចឡើងនូវបរិបទសកលថ្មីសម្រាប់ការអប់រំ។ មិនមែនគ្រប់ការផ្លាស់ប្តូរទាំងអស់សុទ្ធតែទាមទារឲ្យមានការឆ្លើយតបក្នុងទម្រង់ជាគោលនយោបាយអប់រំនោះទេ ប៉ុន្តែទោះជាក្នុងករណីបែបណាក៏ដោយ ការផ្លាស់ប្តូរទាំងនេះកំពុងបង្កើតនូវលក្ខខណ្ឌថ្មី។ ការផ្លាស់ប្តូរទាំងនេះតម្រូវឲ្យមានមិនត្រឹមតែការអនុវត្តថ្មីៗប៉ុណ្ណោះទេ ប៉ុន្តែក៏ទាមទារឲ្យមានការបង្កើតនូវទស្សនៈវិស័យថ្មីៗ ដើម្បីស្វែងយល់ពីលក្ខណៈនៃការរៀនសូត្រ ក៏ដូចជាពីតួនាទីរបស់ចំណេះដឹង និងការអប់រំ ក្នុងការអភិវឌ្ឍមនុស្សផងដែរ។ បរិបទថ្មីនៃការផ្លាស់ប្តូរក្នុងសង្គមទាមទារឲ្យយើងពិនិត្យសារជាថ្មីលើគោលបំណងនៃការអប់រំ និងការរៀបចំការរៀនសូត្រ។

## តើចំណេះដឹង ការរៀនសូត្រ និងការអប់រំ មានន័យយ៉ាងដូចម្តេច?

ចំណេះដឹង គឺជាប្រធានបទដ៏សំខាន់ ក្នុងការពិភាក្សាអំពីការរៀនសូត្រ ហើយចំណេះដឹងអាចត្រូវបានគេយល់ថាជារបៀបដែលបុគ្គលម្នាក់ៗ និងសង្គមយកអត្ថន័យទៅប្រើប្រាស់ក្នុងបទពិសោធន៍ផ្សេងៗ។ ដូច្នេះ ចំណេះដឹងនៅទីនេះ មានន័យទូលំទូលាយ ដោយសំដៅលើព័ត៌មាន ការយល់ដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ ដែលទទួលបាន តាមរយៈការរៀនសូត្រ។ ដូច្នេះ ចំណេះដឹងមានទំនាក់ទំនងមិនអាចកាត់ផ្តាច់បានជាមួយនឹងបរិបទវប្បធម៌ សង្គម បរិស្ថាន និងស្ថាប័ន ដែលបង្កើត និងផ្សព្វផ្សាយបន្តចំណេះដឹងទាំងនេះ។[៦]

នៅទីនេះ ការរៀនសូត្រ ត្រូវបានគេយល់ឃើញថា ជាដំណើរការ សម្រាប់ទទួលចំណេះដឹងទាំងនេះ។ ការរៀនសូត្រគឺជាដំណើរការ ផង និងជាលទ្ធផល នៃដំណើរការនេះផង, ជាមធ្យោបាយផង និងជាគោលដៅចុងក្រោយផង, ជាការអនុវត្តរបស់បុគ្គលម្នាក់ៗផង និងជាកិច្ចខិតខំប្រឹងប្រែងជាសមូហភាពផង។ ការរៀនសូត្រមានទិដ្ឋភាពច្រើនយ៉ាង ទៅតាមបរិបទ។ តើគេត្រូវទទួលបានចំណេះដឹងអ្វី ដោយសារមូលហេតុអ្វី នៅកន្លែងណា នៅពេលណា និងថាតើត្រូវយកចំណេះដឹងនេះទៅប្រើប្រាស់របៀបណា គឺជាសំណួរជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍបុគ្គលផង និងសង្គមផង។

នៅទីនេះ ការអប់រំ សំដៅលើការរៀនសូត្រ ដែលធ្វើឡើងដោយចេតនា មានគោលបំណងច្បាស់លាស់ និងមានរចនាសម្ព័ន្ធត្រឹមត្រូវ។ ឱកាសទទួលបានការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ទាមទារឲ្យមានរចនាសម្ព័ន្ធអប់រំក្នុងកម្រិតមួយ។ តែទោះជាយ៉ាងនេះក្តី ការរៀនសូត្រ

---

[៦] European Science Foundation. 2011. Responses to Environmental and Societal Challenges for our Unstable Earth (RESCUE). ESF Forward Look – ESF-COST ‘Frontier of Science’ joint initiative. Strasbourg/ Brussels, European Science Foundation/European Cooperation in Science and Technology.

ច្រើនកើតឡើងក្នុងបរិបទដែលមិនសូវមានការរៀបចំត្រឹមត្រូវ បើទោះបីជាការរៀនសូត្រធ្វើឡើងដោយមានគោលបំណង និងដោយមានចេតនាក៏ដោយ។ ការអប់រំមិនផ្លូវការ ដែលមិនសូវជាមានការរៀបចំ និងរចនាសម្ព័ន្ធត្រឹមត្រូវដូចការអប់រំក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធ អាចមានដូចជាសកម្មភាពរៀនសូត្រ ដែលកើតឡើងនៅកន្លែងធ្វើការ (ដូចជា ការហាត់ការ ជាដើម) ក្នុងសហគមន៍មូលដ្ឋាន និងក្នុងជីវិតប្រចាំថ្ងៃ ដោយមានការជម្រុញពីខ្លួនឯង ពីសង្គម ឬពីសង្គម។[៧]

> តើគេត្រូវទទួលបានចំណេះដឹងអ្វី ដោយសារមូលហេតុអ្វី នៅកន្លែងណា នៅពេលណា និងថាតើត្រូវយកចំណេះដឹង នេះទៅប្រើប្រាស់របៀបណា គឺជាសំណួរជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍបុគ្គលផង និងសង្គមផង។

ចុងក្រោយ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់គឺ ចំណេះដឹងជាច្រើន ដែលយើងរៀនចេះក្នុងជីវិត អាចកើតឡើងមិនដោយចេតនា ឬមិនដោយសារតែមានគោលបំណងត្រឹមត្រូវ។ ការរៀនសូត្រក្រៅផ្លូវការបែបនេះកើតមានឡើងក្នុងគ្រប់បទពិសោធន៍ទាំងអស់នៃសង្គម។ ប៉ុន្តែ ការពិភាក្សាជាបន្តបន្ទាប់ខាងក្រោមផ្តោតតែលើការរៀនសូត្រ ដែលមានគោលបំណង និងមានរចនាសម្ព័ន្ធត្រឹមត្រូវតែប៉ុណ្ណោះ។

## រចនាសម្ព័ន្ធនៃឯកសារនេះ

ដោយសារតែមានការព្រួយបារម្ភជាចម្បងលើការអភិវឌ្ឍមនុស្ស និងសង្គមប្រកបដោយចីរភាព ផ្នែកទីមួយនៃរបាយការណ៍នេះរៀបរាប់ពីនិន្នាការ ភាពតានតឹង និងចរន្តផ្ទុយគ្នាមួយចំនួន ដែលកើតមានក្នុងដំណើរការនៃការផ្លាស់ប្តូរក្នុងសង្គមជាសកលនាពេលបច្ចុប្បន្ននេះ ក៏ដូចជាឱកាសផ្តល់នូវចំណេះដឹងថ្មីៗ ដែលផ្តល់ដោយការផ្លាស់ប្តូរទាំងនេះ។ ក្នុងពេលជាមួយគ្នា ផ្នែកនេះក៏រំលេចឲ្យឃើញពីភាពចាំបាច់ ដើម្បីស្វែងយល់ពីវិធីសាស្ត្រផ្សេងទៀតសម្រាប់លើកកម្ពស់សុខុមាលភាពសង្គមផងដែរ ដូចជា ការទទួលស្គាល់ពីភាពចម្រុះនៃទស្សនៈយល់ឃើញក្នុងពិភពលោក និងប្រព័ន្ធអប់រំ ក៏ដូចជាភាពចាំបាច់ ដើម្បីឲ្យមាននិរន្តរភាព។

ផ្នែកទីពីរ បញ្ជាក់សារជាថ្មីពីអភិក្រមមនុស្សនិយម ដោយធ្វើការគូសបញ្ជាក់ពីភាពចាំបាច់នៃការប្រើប្រាស់អភិក្រមអប់រំរួមមួយ ដែលមានមូលដ្ឋានលើក្រមសីលធម៌បែបថ្មី។ ផ្នែកនេះអំពាវនាវឲ្យមានការបង្កើតនូវដំណើរការអប់រំមួយ ដែលមានលក្ខណៈបរិយាប័ន្ន ហើយដែលមិនបន្តបង្កើតវិសមភាព។ ក្នុងស្ថានភាពអប់រំជាសកលដែលកំពុងមានការផ្លាស់ប្តូរ គ្រូ និងអ្នក

---

[៧] Ibid.

អប់រំផ្សេងទៀត មានតួនាទីសំខាន់ ក្នុងការបណ្ដុះសមត្ថភាពពិចារណាល្អិតល្អន់ និងវិនិច្ឆ័យដោយឯករាជ្យ ជាជាងចេះតែឯកភាពតាមដោយមិនបានធ្វើការវែកញែកឆ្លុះបញ្ចាំង។

ផ្នែកបន្ទាប់ពិនិត្យលើបញ្ហានានា ដែលមានទំនាក់ទំនងជាមួយនឹងការតាក់តែងគោលនយោបាយអប់រំ ក្នុងពិភពលោកដ៏សែនស្មុគស្មាញ។ បញ្ហាទាំងនេះ មានដូចជា ការលំបាកក្នុងការផ្ដល់ការទទួលស្គាល់ និងឆ្លើយតបចំពោះគម្លាតរវាងការអប់រំក្នុងប្រព័ន្ធ និងការងារ, ការទទួលស្គាល់ និងការបញ្ជាក់សុពលភាពការរៀនសូត្រក្នុងពិភពលោកមួយដែលមនុស្សកាន់តែអាចចល័តឆ្លងដែន ផ្លាស់ប្ដូរមុខរបរវិជ្ជាជីវៈ និងកន្លែងរៀនសូត្ររបស់ខ្លួន, ការគិតពិចារណាឡើងវិញពីការអប់រំភាពជាពលរដ្ឋក្នុងពិភពលោកដែលកាន់តែមានលក្ខណៈសកលភាវូបនីយកម្ម, ការថ្លឹងថ្លែងរវាងការគោរពគុណតម្លៃផ្សេងៗគ្នា ជាមួយនឹងគុណតម្លៃជាសកល និងការយកចិត្តទុកដាក់ចំពោះតម្លៃមនុស្សជាតិជារួម។ ចុងក្រោយ យើងធ្វើការពិចារណាពីភាពស្មុគស្មាញនៃការតាក់តែងគោលនយោបាយអប់រំជាតិ ក្នុងបរិបទអភិបាលកិច្ចសកលក្នុងទម្រង់ផ្សេងៗគ្នា។

ផ្នែកទី ៤ ពិភាក្សាពីភាពចាំបាច់ ដើម្បីកំណត់ឡើងវិញនូវបរិបទនៃគោលការណ៍ជាមូលដ្ឋាន សម្រាប់អភិបាលកិច្ចនៃការអប់រំ ជាពិសេស សិទ្ធិទទួលបានការអប់រំ និងគោលការណ៍ដែលចាត់ទុកការអប់រំថាជាទំនិញសាធារណៈ។ ផ្នែកនេះស្នើឲ្យគោលនយោបាយអប់រំបង្កើនការយកចិត្តទុកដាក់លើចំណេះដឹង និងរបៀបបង្កើតចំណេះដឹង ទទួលបានចំណេះដឹង បញ្ជាក់សុពលភាពលើចំណេះដឹង និងប្រើប្រាស់ចំណេះដឹង។ ផ្នែកនេះក៏លើកឡើងពីភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវបរិបទនៃគោលការណ៍ជាមូលដ្ឋាន ដែលគ្រប់គ្រងលើការរៀបចំការអប់រំ ជាពិសេស គោលការណ៍ដែលចាត់ទុកការអប់រំថាជាទំនិញសាធារណៈ។ ផ្នែកនេះលើកស្នើថា ការចាត់ទុកការអប់រំ និងចំណេះដឹងថាជាទំនិញរួមរបស់សកលលោក អាចជាវិធីសាស្ត្រដ៏មានប្រយោជន៍ ដើម្បីឲ្យគេធ្វើការបង្រួបបង្រួមគោលបំណង និងការរៀបចំការរៀនសូត្រ ឲ្យក្លាយជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម ក្នុងពិភពលោកដែលកំពុងមានការផ្លាស់ប្ដូរ។ ផ្នែកចុងក្រោយបូកសរុបគំនិតសំខាន់ៗ និងលើកជាសំណួរ សម្រាប់ការពិភាក្សាបន្ថែមទៀត។



# ១. ការអភិវឌ្ឍប្រកបដោយចីរភាព៖ ការព្រួយបារម្ភចម្បង

# ១.	ការអភិវឌ្ឍប្រកបដោយចីរភាព៖ ការព្រួយបារម្ភចម្បង

*“យើងត្រូវគិតថា យើងគឺជាស្លឹកឈើមួយសន្លឹកនៃដើមឈើមួយដើម ហើយដើមឈើមួយដើមនេះគឺជាមនុស្សជាតិទាំងមូល។ យើងមិនអាចរស់នៅដោយគ្មានអ្នកដទៃ ដោយគ្មានដើមឈើនោះទេ”*

**Pablo Casals អ្នកកាន់ឧបករណ៍ភ្លេងសេឡូ និងជាអ្នកដឹកនាំក្រុមភ្លេងជនជាតិអេស្ប៉ាញ**

ក្នុងការពិនិត្យឡើងវិញលើគោលបំណងនៃការអប់រំនេះ ក្តីបារម្ភចម្បងលើការអភិវឌ្ឍមនុស្ស និងសង្គមប្រកបដោយចីរភាព គឺជាកត្តាតម្រង់ទិសចក្ខុវិស័យរបស់យើង។ និរន្តរភាព ឬចីរភាព សំដៅលើការអនុវត្តសកម្មភាពប្រកបដោយការទទួលខុសត្រូវរបស់បុគ្គល និងសង្គម ដើម្បីអនាគតកាន់តែប្រសើរសម្រាប់ទាំងអស់គ្នា ទាំងនៅកម្រិតមូលដ្ឋាន និងកម្រិតសកលលោកទាំងមូល ពោលគឺយុត្តិធម៌សង្គម និងការការពារបរិស្ថាន គឺជាអ្នកតម្រង់ទិសការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ការផ្លាស់ប្តូរ ដែលកំពុងកើតឡើងក្នុងពិភពលោកដែលមានទំនាក់ទំនងជាមួយគ្នា និងពឹងផ្អែកលើគ្នាទៅវិញទៅមកបែបនេះ កំពុងនាំមកនូវភាពស្មុគស្មាញ ភាពតានតឹង និងចរន្តផ្ទុយគ្នាក្នុងកម្រិតថ្មីៗជាច្រើន ក៏ដូចជាផ្តល់នូវចំណេះដឹងថ្មីៗ ដែលយើងចាំបាច់ត្រូវយកមកធ្វើការពិចារណា។ និន្នាការនៃការផ្លាស់ប្តូរទាំងនេះតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងស្វែងយល់ពីអភិក្រមជាជម្រើសផ្សេងៗ ដើម្បីសម្រេចឲ្យបាននូវវឌ្ឍនភាព ក៏ដូចជាសុខុមាលភាពរបស់មនុស្ស។

## ■ បញ្ហាប្រឈម និងភាពតានតឹង

របាយការណ៍ Delors បានលើកឡើងពីភាពតានតឹងជាច្រើន ដែលបង្កឡើងដោយសារការផ្លាស់ប្តូរបច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គម។ ភាពតានតឹងទាំងនេះ មានដូចជា ភាពតានតឹងរវាងកម្រិតសកល និងកម្រិតមូលដ្ឋាន, កម្រិតសកល និងកម្រិតជាក់លាក់, ប្រពៃណី និងទំនើប, ជំនឿសាសនា និងសម្ភារ, ការគិតរយៈពេលវែង និងរយៈពេលខ្លី, ភាពចាំបាច់នៃ

ការប្រកួតប្រជែងគ្នា និងសមភាពឱកាស, និងការពង្រីកចំណេះដឹង និងសមត្ថភាពរបស់យើងក្នុងការផ្សព្វផ្សាយចំណេះដឹងទាំងនេះ។ ភាពតានតឹងទាំង ៧ នេះ នៅតែជាទស្សនៈវិស័យដ៏មានប្រយោជន៍ ដែលគេអាចប្រើប្រាស់ ដើម្បីពិនិត្យលើចរន្តនៃការផ្លាស់ប្តូរក្នុងសង្គមនាពេលបច្ចុប្បន្ននេះ។ ភាពតានតឹងមួយចំនួន ពាក់ព័ន្ធនឹងការផ្តល់អត្ថន័យថ្មី ហើយក្នុងពេលជាមួយគ្នា មានភាពតានតឹងថ្មីៗកើតមានឡើង។ ភាពតានតឹងទាំងនេះ រួមមាន និន្នាការនៃកំណើនសេដ្ឋកិច្ចដែលក្នុងពេលជាមួយគ្នាធ្វើឲ្យមានការកើនឡើងនូវភាពងាយរងគ្រោះកំណើនវិសមភាព បង្កើនសម្ពាធមកលើប្រព័ន្ធអេកូឡូហ្ស៊ី និងបង្កើនការមិនយល់អធ្យាស្រ័យឲ្យគ្នា និងអំពើហិង្សា។ ចុងក្រោយ ខណៈពេលដែលមានការសម្រេចបាននូវវឌ្ឍនភាពមួយចំនួនខាងសិទ្ធិមនុស្ស ការអនុវត្តបទដ្ឋាននានា នៅតែជួបនឹងបញ្ហាប្រឈម។

## សម្ពាធមកលើប្រព័ន្ធអេកូឡូហ្ស៊ី និងនិន្នាការផលិតកម្ម និងការប្រើប្រាស់ក្នុងសេដ្ឋកិច្ចដែលពុំមាននិរន្តរភាព

> ការផ្លាស់ប្តូរ ដែលកំពុងកើតឡើងក្នុងពិភពលោក ដែលមានទំនាក់ទំនងជាមួយគ្នា និងពឹងផ្អែកលើគ្នាទៅវិញទៅមកបែបនេះ កំពុងនាំមកនូវភាពស្មុគស្មាញ ភាពតានតឹង និងចរន្តផ្ទុយគ្នាក្នុងកម្រិតថ្មីៗជាច្រើន ក៏ដូចជាផ្តល់នូវចំណេះដឹងថ្មីៗ ដែលយើងចាំបាច់ត្រូវយកមកធ្វើការពិចារណា។

ការធានាកំណើន ត្រូវបានគេយល់ឃើញជាយូរមកហើយថាជាគោលបំណងនៃការអភិវឌ្ឍ ផ្អែកទៅតាមគោលការណ៍ដែលថាកំណើនសេដ្ឋកិច្ច បង្កើតឲ្យមានផលជាវិជ្ជមាន ដែលទីបំផុតធានាឲ្យមានការលើកកម្ពស់សុខុមាលភាព សម្រាប់ទាំងអស់គ្នា។ ប៉ុន្តែ និន្នាការផលិតកម្ម និងការប្រើប្រាស់ដែល ពុំមាននិរន្តរភាព បង្ហាញពីនិន្នាការផ្ទុយទៅវិញ ក្នុងគំរូនៃការអភិវឌ្ឍ ដែលផ្តោតលើកំណើនសេដ្ឋកិច្ចបែបនេះ។ ជាលទ្ធផលនៃកំណើនដែលពុំមានការទប់ស្កាត់ និងការទាញប្រយោជន៍ពីធនធានធម្មជាតិហួសកម្រិត ការប្រែប្រួលអាកាសធាតុកំពុងធ្វើឲ្យមានការកើនឡើងនូវគ្រោះមហន្តរាយធម្មជាតិ ដែលធ្វើឲ្យប្រទេសក្រីក្រត្រូវប្រឈមនឹងហានិភ័យធំ។ ជាការពិត និរន្តរភាព ឬចីរភាព បានលេចចេញជាការព្រួយបារម្ភដ៏ចម្បងនៃការអភិវឌ្ឍ ក្នុងពេលដែលពិភពលោកជួបប្រទះនឹងការប្រែប្រួលអាកាសធាតុ ការរិចរឹលធនធានធម្មជាតិសំខាន់ៗ ដូចជាទឹក ជាដើម និងការបាត់បង់ជីវៈចម្រុះ។

ក្នុងពាក់កណ្ដាលចុងក្រោយនៃសតវត្សរ៍ទី ២០ (១៩៦០-២០០០) ការប្រើប្រាស់ទឹកបានកើនឡើងទ្វេដង ការបរិភោគនិងការផលិតអាហារកើនឡើង ២,៥ ដង ហើយការប្រើប្រាស់ឈើបានកើនឡើង ៣ ដង។ ការកើនឡើងនេះគឺដោយសារតែកំណើនប្រជាជន។ ចំនួនប្រជាជនក្នុងពិភពលោក បានកើនឡើងជិត ៣ ដង ក្នុងពាក់កណ្ដាលទីពីរនៃសតវត្សរ៍ទី ២០ ពោលគឺពីប្រមាណជា ២,៥ ពាន់លាននាក់ ក្នុងឆ្នាំ ១៩៥០ ដល់ជាង ៧ ពាន់លាននាក់ ក្នុងឆ្នាំ ២០១៣ ហើយគេរំពឹងថានឹងកើនឡើងដល់ជាង ៨ ពាន់លាននាក់ ក្នុងឆ្នាំ ២០២។[៨] គេប៉ាន់ប្រមាណថា ត្រឹមឆ្នាំ ២០៣០ តម្រូវការអាហារនឹងកើនឡើងយ៉ាងហោចណាស់ ៣៥ ភាគរយ តម្រូវការទឹកកើនឡើង ៤០ ភាគរយ និងតម្រូវការថាមពលកើនឡើង ៥០ ភាគរយ។[៩]

លើសពីនេះ នេះជាលើកទីមួយហើយ ដែលប្រជាជនពិភពលោកជាងពាក់កណ្ដាលរស់នៅ តំបន់ប្រជុំជន។ ត្រឹមឆ្នាំ ២០៥០ ប្រជាជនពិភពលោកពីរភាគបី ឬជាង ៦ ពាន់លាននាក់ នឹងរស់នៅតំបន់ប្រជុំជន។[១០] នៅពេលនោះ គេប៉ាន់ប្រមាណថា ៨០ ភាគរយនៃប្រជាជនរស់នៅតំបន់ប្រជុំជនក្នុងពិភពលោក នឹងប្រមូលផ្ដុំនៅតាមទីក្រុង និងទីប្រជុំជនដែលស្ថិតនៅភាគខាងត្បូងនៃសកល-លោក។[១១] កំណើនចំនួនប្រជាជនតាមទីប្រជុំជនក្នុងពិភពលោក គួបផ្សំនឹងការពង្រីកបែបផែននៃការរស់នៅរបស់មនុស្សវណ្ណៈកណ្ដាល និងនិន្នាការនៃការប្រើប្រាស់ និងផលិតកម្មផង កំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន និងលើការប្រែប្រួលអាកាសធាតុ ក៏ដូចជាបង្កើនហានិភ័យគ្រោះមហន្តរាយធម្មជាតិទូទាំងពិភពលោក។[១២] ផលប៉ះពាល់ទាំងនេះបង្កជាការគំរាមកំហែងដល់អាយុជីវិត ជីវភាពរស់នៅ និងសុខភាពសាធារណៈ ក្នុងពិភពលោកទាំងមូល។ ការពង្រីកទីក្រុងដោយពុំមានផែនការត្រឹមត្រូវ ឬមានការរៀបចំផែនការមិនបានល្អ ធ្វើឲ្យទីក្រុងកាន់តែងាយរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ និងស្ថានភាពអាកាសធាតុធ្ងន់ធ្ងរ។ អត្រាកំណើននៅទីក្រុងដែលមិនធ្លាប់មានកន្លងមក កំពុងបង្កើតនិន្នាការថ្មីខាងសង្គម នយោបាយ វប្បធម៌ និងនយោបាយ

---

[៨] UN DESA. 2013. World Population Prospects: The 2012 Revision. New York, United Nations។ ភាគច្រើននៃកំណើននេះបានកើតឡើង ហើយនឹងបន្តកើតឡើងនៅភាគខាងត្បូងនៃពិភពលោក។ ភាគរយនៃប្រជាជនសរុបក្នុងពិភពលោក ដែលរស់នៅភាគខាងត្បូងនៃពិភពលោក បានកើនឡើងពី ៦៦% ក្នុងឆ្នាំ ១៩៥០ ដល់ ៨២% ក្នុងឆ្នាំ ២០១០។ គេរំពឹងថា ចំនួននេះនឹងកើនឡើងដល់ ៨៦% នៅឆ្នាំ ២០៥០ និង ៨៨% នៅឆ្នាំ ២១០០។

[៩] National Intelligence Council. 2012. Global Trends 2030: Alternative worlds. Washington, DC, National Intelligence Council.

[១០] UN DESA. 2012. World Urbanization Prospects: The 2011 Revision. New York, United Nations.

[១១] UN-HABITAT. 2013. UN-HABITAT Global Activities Report 2013. Our presence and partnerships. Nairobi, UN-HABITAT.

[១២] SPREAD Sustainable Lifestyle 2050. 2011. Sustainable Lifestyle: Today’s facts and Tomorrow’s trends. Amsterdam, SPREAD Sustainable Lifestyle 2050.

របស់ពិភពលោក។ ដូច្នេះ ការពង្រីកទីក្រុងប្រកបដោយចីរភាព បានក្លាយជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗជាងគេ ដែលសហគមន៍សកលកំពុងជួបប្រទះក្នុងសតវត្សរ៍ទី ២១ នេះ។[១៣]

និន្នាការនៃកំណើនប្រជាសាស្ត្រ និងនគរូបនីយកម្មទាំងនេះ ក៏មានភាពពាក់ព័ន្ធសំខាន់ៗទៅនឹងការរៀបចំស្ថាប័ន និងភាពជាដៃគូ ដែលចាំបាច់ ដើម្បីធានាឲ្យមានការផ្តល់ឱកាសអប់រំពាក់ព័ន្ធ និងបត់បែន ចេញពីទស្សនវិស័យនៃការរៀនសូត្រពេញមួយជីវិតផងដែរ។ គេប៉ាន់ប្រមាណថា ចំនួនមនុស្សចាស់ នឹងកើនឡើងពីរដង នៅឆ្នាំ ២០៥០[១៤] ព្រមគ្នានឹងការកើនឡើងនូវតម្រូវការឲ្យមានការផ្តល់ការអប់រំ និងបណ្តុះបណ្តាលមនុស្សពេញវ័យឲ្យបានច្រើនបែបច្រើនយ៉ាងជាងមុន។ ដើម្បីធានាយ៉ាងណាឲ្យកំណើនចំនួនប្រជាជនក្នុងវ័យធ្វើការងារនៅអាហ្វ្រិចអាចផ្តល់មកវិញនូវភាគលាភប្រជាសាស្ត្រ[១៥] គេចាំបាច់ត្រូវផ្តល់នូវឱកាសអប់រំ និងបណ្តុះបណ្តាលពាក់ព័ន្ធ ពេញមួយជីវិត។

## ទ្រព្យសម្បត្តិមានការកើនឡើង ប៉ុន្តែភាពងាយរងគ្រោះ និងវិសមភាពក៏មានការកើនឡើងផងដែរ

អត្រាភាពក្រីក្រក្នុងសកលលោកទាំងមូលមានការថយចុះពាក់កណ្តាល ចន្លោះពីឆ្នាំ ១៩៩០ ដល់ ២០១១។ ការថយចុះភាពក្រីក្របែបនេះ កើតឡើងដោយសារតែកំណើនអត្រាសេដ្ឋកិច្ចរឹងមាំ នៅតាមប្រទេសដែលសេដ្ឋកិច្ចទើបមានការរីកចម្រើន ក៏ដូចជានៅតាមបណ្តាប្រទេសជាច្រើននៅអាហ្វ្រិច បើទោះបីជាមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ ២០០៨ ក៏ដោយ។ គេរំពឹងថា មនុស្សវណ្ណៈកណ្តាលក្នុងប្រទេសកំពុងអភិវឌ្ឍ នឹងមានការកើនឡើងខ្លាំង ក្នុងរយៈពេលពី ១៥ ដល់ ២០ ឆ្នាំទៀត ដោយកំណើនឆាប់រហ័សជាងគេនឹងកើតឡើងក្នុងប្រទេសចិន និងឥណ្ឌា។[១៦] ប៉ុន្តែ គម្លាតធំៗនៅតែមានក្នុងពិភពលោក ហើយអត្រានៃភាពក្រីក្រមានការប្រែប្រួលខ្លាំងរវាងតំបន់មួយ និងតំបន់មួយទៀតក្នុងពិភពលោក។[១៧]

---

[១៣] United Nations Human Settlement Programme, UN-Habitat, www.un-ngls.org/spip.php?page=article_fr_s&id_article=819 [Accessed February 2015].

[១៤] UN DESA. 2013. World Population Prospects: The 2012 Revision. New York, United Nations.

[១៥] Drummond, P., Thakoor, V. and Yu, S. 2014. Africa Rising: Harnessing the Demographic Dividend. IMF Working Paper 14/43. International Monetary Fund.

[១៦] National Intelligence Council. 2012. Global Trends 2030: Alternative worlds. Washington, DC, National Intelligence Council.

[១៧] ខណៈពេលដែលគេប៉ាន់ប្រមាណថា អត្រានៃភាពក្រីក្រនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិចមានកម្រិត ១២,៥% ក្នុងឆ្នាំ ២០១០ អត្រានៃភាពក្រីក្រគឺជាង ៣០% សម្រាប់អាស៊ីអាគ្នេយ៍ និងកៀក ៥០% នៅអាហ្វ្រិចសាប់សាហារ៉ា។ Global Monitoring Report 2013. Rural-Urban Dynamics and the Millennium Development Goals. Washington, DC, International Bank for Reconstruction and Development and the World Bank.

កំណើនរឹងមាំនៃផលិតផលសរុបក្នុងស្រុក (ផសស) មិនមែនសុទ្ធតែបង្កើតនូវចំនួនការងារដែលគេត្រូវការ ឬប្រភេទការងារដែលគេចង់បាននោះទេ។ ឱកាសការងារមិនបានកើនឡើងគ្រប់គ្រាន់ ដើម្បីតាមឲ្យទាន់កំណើនកម្លាំងពលកម្មឡើយ។ ក្នុងឆ្នាំ ២០១៣ មានមនុស្សជាង ២០០ លាននាក់ ដែលគ្មានការងារធ្វើ ក្នុងពិភពលោកទាំងមូល ហើយចំនួនអ្នកគ្មានការងារធ្វើក្នុងសកលលោក នឹងបន្តកើនឡើងថែមទៀត។ តំបន់ដែលមានការកើនឡើងនូវចំនួនអ្នកគ្មានការងារធ្វើច្រើនជាងគេ ដូចជា អាស៊ីបូព៌ា អាស៊ីខាងត្បូង និងអាហ្វ្រិចសាប់សាហារ៉ា ក៏ជួបនឹងការថយចុះនូវគុណភាពការងារផងដែរ។ បច្ចុប្បន្ន ការងារដែលងាយរងគ្រោះមានចំនួនជិតពាក់កណ្តាលនៃចំនួនការងារសរុប និងបានរួមចំណែកធ្វើឲ្យពលករជាច្រើននាក់រស់នៅក្រោម ឬកៀកទៅនឹងបន្ទាត់នៃភាពក្រីក្រ។ មនុស្សដែលមានការងារងាយរងគ្រោះ មានលទ្ធភាពតិចតួច ឬពុំមានលទ្ធភាពទាល់តែសោះ ក្នុងការទទួលបានសន្តិសុខសង្គម ឬចំណូលជាប់លាប់ បើធៀបជាមួយនឹងពលករដែលមានប្រាក់ឈ្នួល និងប្រាក់ខែ។[១៨]

កង្វះកិច្ចគាំពារសង្គមជាមូលដ្ឋាន នៅតាមប្រទេសភាគច្រើន ធ្វើឲ្យបញ្ហាខាងលើនេះកាន់តែធ្ងន់ធ្ងរ និងរួមចំណែកបង្កើនវិសមភាព រវាងប្រទេសនិងប្រទេស និងក្នុងប្រទេសភាគច្រើន នៅភាគខាងជើងនៃពិភពលោក ក៏ដូចជានៅភាគខាងត្បូងនៃពិភពលោក។[១៩] នៅក្នុងត្រីមាសចុងក្រោយនៃសតវត្សរ៍កន្លងទៅនេះ ទ្រព្យសម្បត្តិកាន់តែប្រមូលផ្តុំក្នុងដៃរបស់មនុស្សកាន់តែតិចនាក់។[២០] ដូច្នេះ ទ្រព្យសម្បត្តិត្រូវបានបែងចែក ដូចតទៅ៖ ជិតពាក់កណ្តាលទៅកាន់អ្នកដែលមានជាងគេ ១ ភាគរយ និងពាក់កណ្តាលទៀត ទៅកាន់អ្នកដែលនៅសល់ ៩៩ ភាគរយទៀត។[២១] ការរីកធំធេងដាច់របស់នៃវិសមភាពចំណូលបែបនេះ កំពុងរួមចំណែកបង្កើតឲ្យមានការផាត់ចេញពីសង្គម និងធ្វើឲ្យប៉ះពាល់ដល់ភាពចុះសម្រុងក្នុងសង្គម។ ក្នុងគ្រប់សង្គមទាំងអស់ វិសមភាពធ្ងន់ធ្ងរ គឺជាប្រភពនៃភាពតានតឹងក្នុងសង្គម និងជាកត្តាដែលអាចនាំឲ្យមានអស្ថិរភាពនយោបាយ និងជម្លោះហិង្សា។

១៨ International Labour Office. 2014. Global Employment Trends 2014. Geneva, International Labour Office.

១៩ UN DESA. 2013. Inequality matters. Report on the World Social Situation 2013. New York, United Nations.

២០ See World Economic Forum. 2014. Outlook on the Global Agenda 2015. Global Agenda Councils. pp. 8-10.

២១ Oxfam. 2014. Working for the Few: Political capture and economic inequality. Oxfam Briefing Paper No. 178. Oxford, UK, Oxfam.

### ប្រអប់ទី ១៖ វិសមភាពនៃចំណូលមានកម្រិតខ្ពស់នៅអាមេរិចឡាទីន បើទោះបីជាមានកំណើនសេដ្ឋកិច្ចរឹងមាំយ៉ាងណាក៏ដោយ

អាមេរិចឡាទីននិងការីបៀននៅតែជាតំបន់មួយក្នុងចំណោមតំបន់នានាដែលមានវិសមភាពចំណូលក្នុងកម្រិតខ្ពស់បំផុត បើទោះបីជាក្នុងទសវត្សរ៍ចុងក្រោយនេះ កំណើនសេដ្ឋកិច្ចមានភាពរឹងមាំ ហើយសូចនាករសង្គមមានភាពល្អប្រសើរជាងមុនក៏ដោយ។ របាយការណ៍នេះបានបង្ហាញថា៖ “ការថយចុះចំណែកប្រាក់ឈ្នួល កើតឡើងដោយសារតែផលប៉ះពាល់នៃការផ្លាស់ប្តូរបច្ចេកវិទ្យាសន្សំសំចៃកម្លាំងពលកម្ម និងដោយសារតែការចុះខ្សោយជាទូទៅនៃការធ្វើប្បញ្ញត្តិកម្ម និងស្ថាប័នទីផ្សារការងារ។ ការថយចុះបែបនេះទំនងជាមានផលប៉ះពាល់ខ្លាំងលើបុគ្គល ដែលស្ថិតនៅចំកណ្តាល និងផ្នែកខាងក្រោមនៃរបាយប្រាក់ឈ្នួល ដោយសារតែពួកគេគឺជាអ្នកដែលពឹងផ្អែកភាគច្រើនលើចំណូលពីការធ្វើការងារ” លើសពីនេះ របាយការណ៍នេះបានលើកឡើងផងដែរថា “ការបែងចែកដីធ្លីដែលពុំមានសមភាព បានបង្កើតឲ្យមានភាពតានតឹងខាងសង្គម និងនយោបាយ និងជាប្រភពដែលនាំឲ្យសេដ្ឋកិច្ចពុំមានប្រសិទ្ធភាព ដោយសារតែអ្នកដែលមានដីតូចៗច្រើនតែទៅរកឥណទាន និងប្រភពផ្សេងទៀត ដើម្បីបង្កើនផលិតភាព ខណៈពេលដែលម្ចាស់ដីធំៗអាចពុំបានទទួលការលើកទឹកចិត្តគ្រប់គ្រាន់ ដើម្បីបង្កើនផលិតភាពរបស់ខ្លួន”

ប្រភព៖ UN Department of Economic and Social Affairs, 2013. Inequality Matters. Report of the World Social Situation 2013. New York, United Nations.

## ការភ្ជាប់ទំនាក់ទំនងទៅវិញទៅមកមានការកើនឡើង ប៉ុន្តែការមិនយល់អធ្យាស្រ័យឲ្យគ្នា និងអំពើហិង្សាក៏មានការកើនឡើងផងដែរ

ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលថ្មីៗ ធ្វើឲ្យមានការកើនឡើងខ្លាំងនូវបរិមាណព័ត៌មាន និងចំណេះដឹងដែលមាន និងធ្វើឲ្យមនុស្សកាន់តែច្រើននាក់ងាយទទួលបានព័ត៌មាន និងចំណេះដឹងទាំងនេះ នៅទូទាំងពិភពលោកទាំងមូល។ ដូច្នេះ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ អាចបំពេញតួនាទីសំខាន់ ក្នុងការចែករំលែកចំណេះដឹង និងជំនាញឯកទេស ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងស្មារតីសាមគ្គីភាព។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់អ្នកសង្កេតការណ៍ជាច្រើន ពិភពលោកនេះកំពុងមានជម្លោះជាតិសាសន៍ វប្បធម៌ និងសាសនាច្រើនទៀតៗ ដោយបច្ចេកវិទ្យាសារគមនាគមន៍ដដែលនេះត្រូវបានប្រើប្រាស់ សម្រាប់ផ្សព្វផ្សាយ

មនោគមវិជ្ជា និងកៀងគរចលនានយោបាយ ដើម្បីផ្សព្វផ្សាយពីមនោគមវិជ្ជារបស់អ្នកផ្តាច់ខ្លួននិយម។ ការកៀងគរចលនានយោបាយបែបនេះ ជារឿយៗ នាំឲ្យមានអំពើហិង្សាព្រហ្មទណ្ឌ និងនយោបាយ ក៏ដូចជាជម្លោះប្រដាប់អាវុធ។

អំពើហិង្សាលើស្ត្រី និងក្មេងស្រី ច្រើនកើនឡើងនៅពេលដែលវិបត្តិ និងអស្ថិរភាពកើតមានឡើង ពោលគឺក្នុងកំឡុងពេល និងក្រោយពេលមានការបះបោរ និងការបាត់បង់ទីលំនៅ ដែលបង្កឡើងដោយជម្លោះប្រដាប់អាវុធ។ ក្នុងស្ថានភាពបែបនេះ អំពើហិង្សាលើស្ត្រីកើតមានជាទូទៅ និងអាចមានលក្ខណៈជាប្រព័ន្ធ នៅពេលដែលក្រុមប្រដាប់អាវុធប្រើប្រាស់ការរំលោភសេពសន្ថវៈ ការបង្ខំឲ្យធ្វើជាស្ត្រីពេស្យាចារ ឬការជួញដូរផ្លូវភេទ ជាយុទ្ធវិធីសម្រាប់ការធ្វើសង្គ្រាមរបស់ពួកគេ។[២២] ស្ត្រីក៏ច្រើនបាត់បង់លំនៅដ្ឋានរបស់ខ្លួនផងដែរ ដែលធ្វើឲ្យពួកគេមានសុខភាពមិនល្អ និងទទួលបានការអប់រំតិចតួច[២៣] ដែលក៏មានផលប៉ះពាល់ផ្ទាល់ដល់ស្ថានភាពគ្រួសារ និងកូនៗរបស់ពួកគេផងដែរ។

អំពើហិង្សា - រាប់បញ្ចូលទាំងអំពើហិង្សាបង្កដោយជនឧក្រិដ្ឋ ពាក់ព័ន្ធជាមួយនឹងការផលិត និងការជួញដូរគ្រឿងញៀនផងដែរនោះ (នេះជាបញ្ហាធ្ងន់ធ្ងរ នៅតំបន់មួយចំនួនក្នុងពិភពលោក ដូចជា នៅអាមេរិចភាគកណ្តាលជាដើម) អស្ថិរភាពនយោបាយ និងជម្លោះប្រដាប់អាវុធ បន្តបង្កការគំរាមកំហែងដល់អាយុជីវិត និងបន្ថយបង្អាក់ដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។[២៤] គេប៉ាន់ប្រមាណថា មានមនុស្សប្រមាណជា ៥០០ លាននាក់ កំពុងរស់នៅក្នុងប្រទេស ដែល

[២២] UN Women. 2013. A Transformative Stand-alone Goal on Achieving Gender Equality, Women's Rights and Women's Empowerment. New York, UN Women.

[២៣] World Bank. 2011. World Development Report 2011: Conflict, Security and Development. Washington, DC, The World Bank.

[២៤] ទីផ្សារគ្រឿងញៀន ភាគច្រើនស្ថិតក្នុងប្រទេសអភិវឌ្ឍ ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍ ជាប្រទេសដែលផលិតកែច្នៃ និងជួញដូរគ្រឿងញៀន។ ទីផ្សារគ្រឿងញៀនមានទំហំធំ និងកាន់តែរីកធំទៅទៀត ដូចគ្នានឹងឧស្សាហកម្មគ្រឿងញៀនផងដែរ។ អំពើហិង្សា កើតមានក្នុងឧស្សាហកម្មគ្រឿងញៀន ដោយសារតែក្រុមបដិបក្ខប្រយុទ្ធដណ្តើមដែនដីគ្នា។ ឧស្សាហកម្មគ្រឿងញៀនក៏ប្រើប្រាស់ពលករច្រើនផងដែរ ដោយពួកគេត្រូវការបុគ្គលគ្មានជំនាញ ដើម្បីធ្វើសកម្មភាពជាច្រើន។ ក្នុងប្រទេសជាច្រើន មានក្មេងប្រុសជាច្រើននាក់ដែលចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មនេះ។ មានន័យថា ពួកគេត្រូវបោះបង់ចោលការសិក្សា និងត្រូវបន្តរស់នៅប្រកបដោយគ្រោះថ្នាក់ ជាថ្នូរជាមួយនឹងប្រាក់យ៉ាងច្រើន។ ការផលិតគ្រឿងញៀនទាមទារឲ្យមានការកាន់កាប់ដែនដីក្នុងទ្រង់ទ្រាយធំ និងការមានអំណាចលើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ។ ការជួញដូរគ្រឿងញៀនក៏នាំឲ្យមានសកម្មភាពល្មើសផ្សេងទៀតផងដែរ ដូចជា ការជម្រិតទារប្រាក់ ការជួញដូរមនុស្ស និងទាសភាពផ្លូវភេទ ការចាប់ជម្រិត ជាដើម ។ល។ ដែលជាទូទៅ ធ្វើឲ្យមនុស្សត្រូវប្រឈមនឹងបញ្ហាសុវត្ថិភាព នៅតាមកន្លែងជាច្រើន។ ប្រទេស ដែលស្ថិតនៅអាមេរិចភាគកណ្តាល ដូចជា ម៉ិចស៊ិច កូឡុំប៊ី និងប្រទេសមួយចំនួន នៅអាស៊ីភាគខាងលិច គឺជាប្រទេសដែលរងគ្រោះដោយសារបញ្ហានេះ។ គេនៅមិនទាន់មានដំណោះស្រាយចំពោះបញ្ហានេះនោះទេ។

ប្រឈមនឹងបញ្ហាអស្ថិរភាព និងជម្លោះ។[២៥] ផលប៉ះពាល់សេដ្ឋកិច្ច ដែលកើតឡើងចេញពីការទប់ស្កាត់ និងការឆ្លើយតបចំពោះផលវិបាកនៃអំពើហិង្សាដែលកើតឡើងក្នុងសកលលោកទាំងមូល ត្រូវបានគេប៉ាន់ប្រមាណថាមានកម្រិតជិត ១០ លានលានដុល្លារសហរដ្ឋអាមេរិច៖ ជាង ១១ ភាគរយនៃ ផសស របស់សកលលោកទាំងមូល ឬពីរដងនៃ ផសស របស់បណ្តាប្រទេសនៅអាហ្វ្រិចទាំងអស់បញ្ចូលគ្នាក្នុងឆ្នាំ ២០១។[២៦] លើសពីនេះ ភាគរយនៃថវិកាសាធារណៈ ដែលវិនិយោគលើការងារសន្តិសុខ និងលើយោធា បានបង្វែរធនធានជាច្រើន ដែលគេអាចយកទៅប្រើប្រាស់ សម្រាប់ការអភិវឌ្ឍ។ ចំណាយយោធាក្នុងសកលលោកទាំងមូលបានបន្តកើនឡើង ចាប់តាំងពីឆ្នាំ ២០០០ មក រហូតដល់ ១៧៤២ ពាន់លានដុល្លារសហរដ្ឋអាមេរិចទូទាំងសកលលោក ក្នុងឆ្នាំ ២០១២[២៧] ហើយមានប្រទេសជាច្រើនបានបែងចែកថវិកាកាន់តែច្រើន គិតជាភាគរយនៃ ផសស លើវិស័យយោធា បើធៀបនឹងចំណាយសម្រាប់វិស័យអប់រំ។

ចំណុចទាំងនេះមានភាពពាក់ព័ន្ធសំខាន់ៗ ដល់ការរៀបចំ និងការអនុវត្តគោលនយោបាយអប់រំ សម្រាប់ប្រទេសដែលកំពុងស្ថិតក្នុងស្ថានភាពមានជម្លោះ។ គោលនយោបាយទាំងនេះចាំបាច់ត្រូវតែមានបរិយាប័ន្នភាព ទាំងក្នុងពេលរៀបចំ ទាំងក្នុងពេលអនុវត្ត ប្រសិនបើគេមិនចង់ឲ្យការអប់រំបង្កឲ្យមានបញ្ហាវិសមភាព និងភាពតានតឹងក្នុងសង្គម ដែលអាចជាកត្តាជម្រុញឲ្យមានអំពើហិង្សា និងអស្ថិរភាពនយោបាយនោះ។ ការអប់រំអំពីសិទ្ធិមនុស្ស មានតួនាទីសំខាន់ក្នុងការបង្កើនការយល់ដឹងអំពីបញ្ហា ដែលនាំឲ្យមានជម្លោះកើតមានឡើង និងជាមធ្យោបាយដើម្បីនាំមកនូវដំណោះស្រាយដែលយុត្តិធម៌។ ការអប់រំបែបនេះមានសារៈសំខាន់ ដើម្បីលើកកម្ពស់គោលការណ៍សំខាន់ៗពោលគឺការមិនរើសអើង និងការការពារអាយុជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប នៅក្នុងពេលដែលមានអំពើហិង្សា និងវិបត្តិកើតមានឡើង។ នេះទាមទារឲ្យមានការធានានូវបរិយាកាសរៀនសូត្រដែលមានសុវត្ថិភាព អហិង្សា បរិយាប័ន្ន និងមានប្រសិទ្ធភាព សម្រាប់ទាំងអស់គ្នា។

---

[២៥] Global Peace Index and Institute for Economics and Peace. 2014. Global Peace Index 2014. Institute for Economics and Peace.

[២៦] Ibid.

[២៧] Figures are in constant (2011) US$ prices and exchange rates. SIPRI Database, www.sipri.org /research/armaments/milex [Accessed February 2015].

## សិទ្ធិមនុស្សៈ វឌ្ឍនភាព និងបញ្ហាប្រឈម

សិទ្ធិមនុស្សជាសកល សំដៅលើបំណងប្រាថ្នាក្នុងបង្កើតនូវស្ថានភាពល្អប្រពៃមួយ ដែលសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានគេគោរព មិនថាពួកគេខុសប្លែកពីអ្នកដទៃ និងមានការផ្តល់ឱកាសពេញលេញដល់ពួកគេ ដើម្បីឲ្យពួកគេមានការអភិវឌ្ឍពេញលេញ។[២៨] ប៉ុន្តែ គម្លាត រវាងការអនុម័តក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ និងការអនុវត្តក្របខ័ណ្ឌទាំងនេះ នាំឲ្យមានការកើនឡើងនូវភាពតានតឹងរវាងការប្រើប្រាស់អំណាច និងគោលការណ៍សិទ្ធិ ដែលត្រូវបានចាត់ទុកថាជាច្បាប់។ បំណងប្រាថ្នាបង្កើតនីតិរដ្ឋ និងយុត្តិធម៌ ទាំងនៅកម្រិតអន្តរជាតិ និងជាតិ ត្រូវរងការបន្ទុចបង្អាក់ក្នុងករណីជាច្រើន ដោយសារតែការគ្របដណ្តប់របស់ក្រុមអ្នកមានអំណាច។ បញ្ហាប្រឈម ដែលត្រូវដោះស្រាយ គឺត្រូវធានាយ៉ាងណាឲ្យមានការគោរពសិទ្ធិមនុស្សជាសកលតាមរយៈនីតិរដ្ឋ ក៏ដូចជាតាមរយៈបទដ្ឋានសង្គម វប្បធម៌ និងក្រមសីលធម៌។

យេនឌ័រ គឺជាធាតុផ្សំដ៏សំខាន់មួយជាយូរមកហើយ នៃការរើសអើង។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ សិទ្ធិរបស់ស្ត្រី ត្រូវបានពង្រឹង ជាពិសេស តាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកវិសាលភាពនៃការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) ឆ្នាំ ១៩៧៩ និងការអនុវត្តក្របខ័ណ្ឌសកម្មភាពនៃសន្និសីទអន្តរជាតិទីក្រុងប៉េកាំង (ឆ្នាំ ១៩៩៥)។ ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលមានការសម្រេចបាននូវវឌ្ឍនភាពជាច្រើន ក្នុងការធានាឲ្យមានការលើកកម្ពស់សមភាពយេនឌ័រ ក្នុងការទទួលបានសេវាសុខភាព និងសេវាអប់រំក៏ដោយ ការបង្កើនសម្លេង និងការចូលរួមរបស់ស្ត្រី ក្នុងជីវភាពសង្គម សេដ្ឋកិច្ច និងនយោបាយមិនសូវជាមានវឌ្ឍនភាពនោះទេ។[២៩] មនុស្សភាគច្រើនដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ គឺជាស្ត្រី។[៣០] យុវជន និងមនុស្សពេញវ័យមិនចេះអក្សរភាគច្រើនក្នុងពិភពលោក ក៏ជាស្ត្រី។[៣១] លើសពីនេះ ក្នុងសកលលោកទាំងមូល ស្ត្រីកាន់កាប់អសនៈក្នុងរដ្ឋសភាតិចជាង ២០ ភាគរយតែប៉ុណ្ណោះ។[៣២] ស្ថានភាពផុយស្រួយពីដំបូងរបស់ស្ត្រីក្នុងទីផ្សារការងារ និងជាពិសេស ក្នុងវិស័យមិនរៀបរយ កាន់តែធ្ងន់ធ្ងរឡើងៗ នៅពេលដែល

---

២៨ សកលកម្មនៃសិទ្ធិមនុស្សត្រូវបានដាក់ចេញដំបូង ក្នុងសេចក្តីថ្លែងការណ៍ជាសកលឆ្នាំ ១៩៤៨ និងក្រោយមកទៀត ក្នុងធម្មនុញ្ញសិទ្ធិមនុស្ស ដែលត្រូវបានដាក់ចេញក្នុងអនុសញ្ញា ដែលត្រូវបានអនុម័តជាបន្តបន្ទាប់ដោយសហប្រជាជាតិ និងផ្តល់សច្ចាប័នដោយរដ្ឋាភិបាល។

២៩ UN. 2013. A New Global Partnership: Eradicate poverty and transform economies through sus tainable development, Report of the High-level Panel of eminent persons on the post-2015 development agenda. New York, United Nations.

៣០ Ibid.

៣១ UNESCO. 2014. Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014. Paris, UNESCO.

៣២ UN Women. 2011. Progress of the World's Women: In Pursuit of Justice. New York, UN Women.

មានការប្រកួតប្រជែងដណ្តើមការងារគ្នាធ្វើខ្លាំង ដោយសារតែឱកាសការងារមានការថយចុះ និងដោយសារតែផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបន្តកើតឡើងផ្ទួន។ បច្ចុប្បន្ននេះ ស្ត្រីក្នុងកម្លាំងពលកម្មពាក់កណ្តាល កំពុងធ្វើការងារ ដែលងាយរងគ្រោះ ដោយការងាររបស់ពួកគេពុំមានភាពជាប់លាប់ និងពុំមានការការពារទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច។[៣៣] ចំណុចនេះបន្ថែមផលវិបាកលើនិន្នាការនៃការរើសអើងដែលមានស្រាប់ ដែលស្ត្រីទទួលរងពាក់ព័ន្ធនឹងបៀវត្សរ៍ និងឱកាសឡើងឋានៈក្នុងការងារថែមទៀតផង។

## ■ ឱកាសទទួលបានចំណេះដឹងថ្មីៗ

### ពិភពអ៊ីនធឺណិត

លក្ខណៈមួយ ក្នុងចំណោមលក្ខណៈសំខាន់ៗនៃការអភិវឌ្ឍនាពេលបច្ចុប្បន្ននេះ គឺការលេចរូបរាង និងការពង្រីកខ្លួននៃពិភពអ៊ីនធឺណិត ដោយសារតែកំណើនមិនគួរឲ្យជឿនៃការភ្ជាប់ទៅនឹងបណ្តាញអ៊ីនធឺណិត និងចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃ។[៣៤] យើងកំពុងរស់នៅក្នុងពិភពលោក ដែលមនុស្សភ្ជាប់ទំនាក់ទំនងជាមួយគ្នា។ បច្ចុប្បន្ននេះ មានប្រជាជនប្រមាណជា ៤០ ភាគរយក្នុងពិភពលោក ដែលប្រើប្រាស់អ៊ីនធឺណិត ហើយចំនួននេះកំពុងកើនឡើង ក្នុងល្បឿនមួយគួរឲ្យកត់សម្គាល់។[៣៥] ខណៈពេលដែលកម្រិតនៃការភ្ជាប់បណ្តាញអ៊ីនធឺណិតមានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយ ទៅប្រទេសមួយទៀត និងពីតំបន់មួយ ទៅតំបន់មួយទៀត ចំនួនគ្រួសារដែលមានអ៊ីនធឺណិតប្រើប្រាស់ នៅភាគខាងត្បូងនៃសកលលោក គឺកើនឡើងលើសពីចំនួននៅភាគខាងជើងនៃពិភពលោកទៅទៀត។ លើសពីនេះ ជាង ៧០ ភាគរយ នៃការប្រើប្រាស់ទូរស័ព្ទក្នុងពិភពលោក បច្ចុប្បន្ននេះ គឺនៅភាគខាងត្បូងនៃពិភពលោក។[៣៦] គេរំពឹងថា មានមនុស្សចំនួន ៥ ពាន់លាននាក់ នឹងផ្លាស់ពីការមិនភ្ជាប់ទំនាក់ទំនងសោះ ទៅជាការភ្ជាប់ទំនាក់ទំនងពេញលេញ ក្នុងរយៈពេល ២០ ឆ្នាំទៀត។[៣៧] ប៉ុន្តែ គម្លាតនៅតែមានរវាងប្រទេសមួយ និងប្រទេសមួយទៀត និងរវាងតំបន់មួយ និងតំបន់មួយទៀត ដូចជា រវាងតំបន់ប្រជុំជន និងតំបន់ជនបទជាដើម។ ល្បឿនប្រដប៉ែនដែលនៅ

---

៣៣ ILO. 2012. Global Employment Trends for Women. Geneva, ILO.

៣៤ International Telecommunication Union. 2013. Trends in Telecommunication Reform: Transna tionalaspects of regulation in a networked society. Geneva, International Telecommunication Union.

៣៥ ITU. 2013. The world in 2014: Fact and Figures. Geneva, ITU.

៣៦ ITU. 2014. Trends in Telecommunication Reform, Special Edition. Fourth-generation regulation. Geneva,ITU.

៣៧ Schmidt, E. and Cohen, J. 2013. The New Digital Age: Reshaping the Future of People, Nations and Business. New York, Knopf.

យឺត និងការពុំមានការភ្ជាប់បណ្តាញ ជាកត្តាដែលធ្វើឲ្យរាំងស្ទះដល់ការទទួលបានចំណេះដឹង ការចូលរួមក្នុងសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច។

អ៊ីនធឺណិតបានផ្លាស់ប្តូររបៀបដែលមនុស្សទទួលបានព័ត៌មាន និងចំណេះដឹង របៀបដែលពួកគេធ្វើការប្រាស្រ័យទាក់ទងជាមួយគ្នា និងទិសដៅនៃការគ្រប់គ្រងវិស័យសាធារណៈ និងធុរកិច្ច។ ការភ្ជាប់ទំនាក់ទំនងឌីជីថល នឹងនាំមកនូវប្រយោជន៍ខាងសុខភាព ការអប់រំ ការប្រាស្រ័យទាក់ទង ការកម្សាន្ត និងសុខុមាលភាព។[៣៨] ការរីកចម្រើនខាងប្រាជ្ញាសិប្បនិម្មិត (Artificial Intelligence) ម៉ាស៊ីនបោះពុម្ព 3D ការបង្កើតហ្វូឡូក្រាហ្វ និងសហ្វវែរដែលចេះសម្គាល់កាយវិការ គ្រាន់តែជាឧទាហរណ៍ខ្លះ ដែលបង្ហាញពីអ្វីដែលគេកំពុងធ្វើតេស្តតែប៉ុណ្ណោះ។ បច្ចេកវិទ្យាឌីជីថល កំពុងសម្រួចសកម្មភាពរបស់មនុស្ស ចាប់ពីជីវិតប្រចាំថ្ងៃរហូតដល់ទំនាក់ទំនងអន្តរជាតិ ចាប់ពីការងាររហូតដល់ការកែកម្សាន្ត ដែលជាការកំណត់សារជាថ្មីនូវរបៀបរបបរស់នៅក្នុងជីវិតឯកជន និងសាធារណៈរបស់យើង។

បច្ចេកវិទ្យាបែបនេះ បានពង្រីកឱកាសសម្រាប់សេរីភាពនៃការបញ្ចេញយោបល់ និងកៀងគរចលនាសង្គម ស៊ីវិល និងនយោបាយ ប៉ុន្តែបច្ចេកវិទ្យាទាំងនេះក៏នាំឲ្យមានការព្រួយបារម្ភសំខាន់ៗផងដែរ។ ឧទាហរណ៍ ភាពងាយស្រួលរកបាននូវព័ត៌មានផ្ទាល់ខ្លួន ក្នុងពិភពអ៊ីនធឺណិត នាំឲ្យមានបញ្ហាធំៗ ពាក់ព័ន្ធនឹងភាពជាឯកជន និងសន្តិសុខ។ ឱកាសថ្មីៗសម្រាប់ធ្វើការប្រាស្រ័យទាក់ទង និងការចុះក្នុងសង្គម កំពុងធ្វើឲ្យមានការផ្លាស់ប្តូរនូវអ្វីដែលគេចាត់ទុកថាជាគំនិត "សង្គម" ដែលទាមទារឲ្យមានការដាក់ចេញនូវបទដ្ឋានច្បាប់ និងបទដ្ឋានសម្រាប់ការពារផ្សេងទៀត ដែលគេអនុវត្ត ដើម្បីបង្ការមិនឲ្យមានការប្រើប្រាស់ឱកាសទាំងនេះជ្រុលហួស ប្រើដោយបំពាន និងប្រើខុសគោលដៅ។[៣៩] ឧទាហរណ៍នៃការប្រើប្រាស់ខុសគោលដៅនៃអ៊ីនធឺណិត បច្ចេកវិទ្យាចល័ត និងប្រព័ន្ធផ្សព្វផ្សាយសង្គម មានចាប់ពីការអុកឡុករំខានតាមប្រព័ន្ធអ៊ីនធឺណិត រហូតដល់ការប្រព្រឹត្តសកម្មភាពឧក្រិដ្ឋ និងអាចមានទាំងអំពើភេវកម្មទៀត។ ក្នុងពិភពអ៊ីនធឺណិតថ្មីនេះ អ្នកអប់រំចាំបាច់ត្រូវរៀបចំមនុស្សជំនាន់ថ្មី "ដែលទទួលរងឥទ្ធិពលពីឌីជីថល"[៤០] ឲ្យចេះគិតគូរពីទិដ្ឋភាពពាក់ព័ន្ធនឹងក្រមសីលធម៌ និងសង្គម មិនត្រឹមតែរបស់បច្ចេកវិទ្យាឌីជីថលដែលមានស្រាប់ប៉ុណ្ណោះទេ ថែមទាំងបច្ចេកវិទ្យាដែលគេនៅមិនទាន់បង្កើតឡើងទៀតផង។

---

[៣៨] Ibid.
[៣៩] Hart, A.D. and Hart Frejd, S. 2013. The Digital Invasion: How Technology Is Shaping You and Your Relationships. Ada, MI, Baker Books.
[៤០] Prensky, M. 2001. Digital Natives, Digital Immigrants. On the horizon. MCB University Press, Vol. 9, No. 5.

## ការរីកចម្រើនខាងវិទ្យាសាស្ត្រខួរក្បាល (Neurosciences)

ការរីកចម្រើនកាលពីពេលថ្មីៗនេះខាងវិទ្យាសាស្ត្រខួរក្បាល កាន់តែទាក់ទាញចំណាប់អារម្មណ៍ពីសហគមន៍អប់រំ ដែលចង់ស្វែងយល់បន្ថែមទៀតពីទំនាក់ទំនងរវាងដំណើរការជីវសាស្ត្រ និងការរៀនសូត្ររបស់មនុស្ស។ ខណៈពេលដែលវាអាចឆាប់ពេក ដើម្បីទាញព័ត៌មានពីការរីកចម្រើននៃវិទ្យាសាស្ត្រនេះ យករៀបចំគោលនយោបាយអប់រំ សក្ដានុពលនៃវិទ្យាសាស្ត្រនេះ ក្នុងការកែលំអដំណើរការបង្រៀន និងរៀនមានទំហំធំធេង។ ឧទាហរណ៍ ការយល់ដឹងចុងក្រោយពីការវិវឌ្ឍ និងដំណើរការរបស់ខួរក្បាល នៅដំណាក់កាលផ្សេងៗនៃជីវិត កំពុងរួមចំណែកធ្វើឲ្យយើងមានការយល់ដឹងពីរបៀបដែលយើងរៀនសូត្រ និងប្រាប់យើងឲ្យដឹងថាតើពេលដែលយើងរៀនចេះអ្វីមួយ។

គំនិតសំខាន់ៗបំផុតមួយចំនួន គឺពាក់ព័ន្ធជាមួយនឹង "រយៈពេលសំខាន់បំផុត" សម្រាប់ការរៀនសូត្រ[៤១] ដែលបង្ហាញថា ការរៀនភាសាអាចធ្វើបានល្អបំផុត នៅវ័យកុមារតូច។ ចំណុចនេះគូសបញ្ជាក់ពីសារៈសំខាន់នៃការអប់រំកុមារតូច និងសក្ដានុពលនៃការរៀនសូត្រពហុភាសា នៅឆ្នាំដំបូងៗនៃជីវិត។ លទ្ធផលរកឃើញសំខាន់ៗផ្សេងទៀងបង្ហាញពី "ភាពអាចទាញយឺត (plasticity)" នៃខួរក្បាល និងសមត្ថភាពរបស់ខួរក្បាលក្នុងការផ្លាស់ប្ដូរ ជាការឆ្លើយតបចំពោះតម្រូវការក្នុងមជ្ឈដ្ឋានជុំវិញ ក្នុងជីវិត។[៤២] លទ្ធផលរកឃើញទាំងនេះផ្ដល់ជាគំនិតដល់ការរៀនសូត្រពេញមួយជីវិត និងការផ្ដល់ឱកាសរៀនសូត្រសមស្រប សម្រាប់មនុស្សគ្រប់រូប មិនថាពួកគេមានអាយុប៉ុន្មាននោះទេ។

លើសពីនេះ យើងត្រូវទទួលស្គាល់ពីផលប៉ះពាល់ ដែលកត្តាបរិស្ថាន ដូចជា អាហារូបត្ថម្ភ ការគេង ការលេងកីឡា និងការកម្សាន្ត មានមកលើការបំពេញមុខងាររបស់ខួរក្បាល។ សំខាន់ដូចគ្នាដែរ យើងត្រូវទទួលស្គាល់ពីភាពចាំបាច់ ក្នុងការប្រើប្រាស់អភិក្រមក្ដោបរួម ដែលទទួលស្គាល់ពីការពឹងអាស្រ័យលើគ្នាទៅវិញទៅមកនៃសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត ក៏ដូចជាទំនាក់ទំនងទៅវិញទៅមករវាងផ្នែក នៃខួរក្បាលដែលបំពេញមុខងារពាក់ព័ន្ធនឹងអារម្មណ៍ និងចំណេះដឹង និងរវាងផ្នែកនៃខួរក្បាលដែលបំពេញមុខងារវិភាគ និងច្នៃប្រឌិត។ ទិសដៅថ្មីៗសម្រាប់ការស្រាវជ្រាវនៃវិទ្យាសាស្ត្រខួរក្បាលនេះ នឹងធ្វើឲ្យយើងកាន់តែយល់ដឹងបន្ថែមទៀតពីទំនាក់ទំនងរវាងធម្មជាតិនិងការបណ្ដុះបណ្ដាល ដែលអាចជួយឲ្យយើងធ្វើការកែសម្រួលគំនិតផ្ដួចផ្ដើមអប់រំរបស់យើងទៅតាមនោះ។

---

[៤១] OECD 2007. Understanding the brain: The birth of a learning science. Paris, EDUCERI-OECD.
[៤២] Ibid

## ការប្រែប្រួលអាកាសធាតុ និងជម្រើសប្រភពថាមពល

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមមួយ ក្នុងចំណោមបញ្ហាប្រឈមធំៗនៃសតវត្សរ៍នេះ ពាក់ព័ន្ធនឹងការឆ្លើយតបដែលចាំបាច់ ដើម្បីដោះស្រាយបញ្ហានេះផង និងមធ្យោបាយដែលចាំបាច់ ដើម្បីទប់ទល់នឹងផលប៉ះពាល់បង្កឡើងដោយការប្រែប្រួលអាកាសធាតុផង។ កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់អំពាវនាវឲ្យមានការចូលរួមសហការគ្នា ដើម្បីទប់ស្កាត់ការបំភាយឧស្ម័ន និងបង្ការមិនឲ្យមានការបង្កផលវិបាកធ្ងន់ធ្ងរបន្ថែមទៀតលើភពផែនដី។ ការបន្សាំុតម្រូវឲ្យមានការកាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់ចំពោះផលប៉ះពាល់ដែលកើតឡើង។ ការអប់រំមានតួនាទីសំខាន់ ក្នុងការបង្កើនការយល់ដឹង និងជម្រុញឲ្យមានការផ្លាស់ប្តូរឥរិយាបថ ដើម្បីកាត់បន្ថយផលប៉ះពាល់ផង និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុផង។[៤៣]

ការអប់រំ គឺជាកត្តាដ៏សំខាន់មួយ ក្នុងការលើកកម្ពស់ និងសម្រួលដល់ការធ្វើអន្តរកាលរួមគ្នាទៅរកជម្រើសប្រភពថាមពលកកើតឡើងវិញដែលមិនបំភាយកាបូន ដែលអាចជួយកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ដើម្បីងាកចេញពីប្រភពថាមពលបំភាយកាបូន ទៅជាប្រភពថាមពលមិនបំភាយកាបូន យើងចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរជំនឿ និងការយល់ឃើញរបស់យើង និងបណ្តុះផ្នត់គំនិត ដែលអាចជួយសម្រួលដល់ការធ្វើអន្តរកាលនេះ។ ហេដ្ឋារចនាសម្ព័ន្ធថាមពលខ្លួនឯង នឹងមិននាំឲ្យមានការផ្លាស់ប្តូរសមស្របនោះឡើយ។

ក្នុងពេលជាមួយគ្នា ការអប់រំ គឺជាធាតុផ្សំដ៏សំខាន់មួយនៃសមត្ថភាពបន្សាំ ដោយសារតែគេចាំបាច់ត្រូវផ្តល់ឲ្យមនុស្សជំនាន់នេះ និងជំនាន់ក្រោយនូវចំណេះដឹង ជំនាញ និងឥរិយាបថដើម្បីបន្សាំការរស់នៅ និងសកម្មភាពចិញ្ចឹមជីវិតរបស់ពួកគេ ឲ្យស្របតាមតថភាពពិតប្រាកដនៃប្រព័ន្ធអេកូឡូហ្ស៊ី សង្គម និងសេដ្ឋកិច្ច នៃបរិស្ថាន ដែលកំពុងតែមានការផ្លាស់ប្តូរ។ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងលីម៉ា ឆ្នាំ ២០១៤ ស្តីពីការអប់រំ និងការបង្កើនការយល់ដឹងលើកទឹកចិត្ត "រដ្ឋាភិបាលឲ្យរៀបចំនូវយុទ្ធសាស្ត្រអប់រំ ដែលមានដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ក្នុងកម្មវិធីសិក្សា និងបញ្ចូលការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ និងប្រែប្រួលអាកាសធាតុ ស្របតាមអាទិភាព និងសមត្ថភាពនៅថ្នាក់ជាតិរបស់ប្រទេសទាំងនោះ។

[៤៣] Lutz, W., Muttarak, R. and Striessnig, E. 2014. Universal education is key to enhanced climate adaptation. Science. 28 November 2014. Vol. 346, No. 6213. Education is key to climate adaptation. www.iiasa.ac.at/web/home/about/news/20141127-Science-Pop.html [Accessed February 2015].

## ភាពច្នៃប្រឌិត នវានុវត្តន៍ផ្នែកវប្បធម៌ និងយុវជន

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការលេចចេញនូវការសម្តែងមតិខាងវប្បធម៌ និងសិល្បៈក្នុងទម្រង់ថ្មីៗ ដែលជាលទ្ធផលនៃការច្នៃប្រឌិតខាងវប្បធម៌ ដោយមានការជម្រុញពីកំណើននៃការភ្ជាប់ទំនាក់ទំនងជាមួយគ្នា និងការផ្លោះប្តូរវប្បធម៌ នៅទូទាំងពិភពលោក។ ដំណើរការនេះត្រូវបានជម្រុញដោយមនុស្សវ័យក្មេង។ យើងមើលឃើញនូវការបង្ហាញសោភ័ណ្ឌភាពថ្មីនៅតាមទីសាធារណៈ ដែលពោរពេញដោយភាពសម្បូរបែបខាងគំនិតច្នៃប្រឌិត ហើយយើងក៏មើលឃើញផងដែរនូវឆន្ទៈបង្កើតអ្វីដែលថ្មី ក្នុងគ្រប់វិស័យទាំងអស់ ដែលមានការចូលរួមពីយុវជន ចាប់ពីការរចនាម៉ូដ រហូតដល់ម្ហូបអាហារ តន្ត្រី និងទំនាក់ទំនងផ្ទាល់ខ្លួនជាដើម។ មានមនុស្សវ័យក្មេងអាយុចន្លោះពី ១៥ ដល់ ២៤ ឆ្នាំ ជាងមួយពាន់លាននាក់ ក្នុងពិភពលោកបច្ចុប្បន្ននេះ បានក្លាយជាជំនាន់ដែលទទួលបានព័ត៌មាន ច្រើនជាងគេ សកម្មជាងគេ ភ្ជាប់ទំនាក់ទំនងជាមួយគ្នាជាងគេ និងចល័តជាងគេ ដែលមិនធ្លាប់មានក្នុងពិភពលោក។[៤៤] មានការប៉ាន់ប្រមាណថា មានយុវជនអាយុចន្លោះពី ១៨ ដល់ ២៤ ឆ្នាំ ជាង ៩០ ភាគរយ ក្នុងពិភពលោកបច្ចុប្បន្ននេះ ដែលកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Facebook និង Twitter ជាដើម។ ពួកគេចំណាយពេលច្រើនលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីស្វែងយល់ និងចែករំលែកលទ្ធផលនៃការស្វែងយល់របស់ពួកគេ។ នេះបង្កើតនូវបរិយាកាសដែលនាំឲ្យមានការបង្កើនការយល់ដឹងពីវប្បធម៌ផ្សេងទៀត និងការចូលរួមដោះស្រាយបញ្ហាទូទាំងពិភពលោក ក៏ដូចជានាំឲ្យមានការផ្តល់តម្លៃដល់សារៈសំខាន់នៃប្រព័ន្ធចំណេះដឹងផ្សេងទៀត។ វប្បធម៌ចម្រុះកាន់តែមានភាពពាក់ព័ន្ធ ក្នុងនាមជាប្រភពនៃការច្នៃប្រឌិតថ្មី និងនវានុវត្តន៍។ បច្ចុប្បន្ននេះ នេះបានក្លាយជាធនធានដ៏មានតម្លៃ សម្រាប់ការអភិវឌ្ឍមនុស្សប្រកបដោយចីរភាព។[៤៥]

### ■ ការស្វែងយល់ពីអភិក្រមផ្សេងទៀត

## ការទទួលស្គាល់ពីទស្សនៈយល់ឃើញខុសៗគ្នាអំពីពិភពលោក

ការស្វែងយល់ពីអភិក្រមជា ជម្រើសផ្សេងទៀត ដើម្បីសម្រេចឲ្យបាននូវវឌ្ឍនភាពនិងសុខុមាលភាពរបស់មនុស្ស មានសារៈសំខាន់យ៉ាងខ្លាំងក្នុងពេលដែលយើងកំពុងប្រឈមជាមួយនឹងភាពស្មុគស្មាញនៃនិន្នាការអភិវឌ្ឍបច្ចុប្បន្ននេះ។ ប្រការសំខាន់គឺត្រូវបង្ហាញឲ្យឃើញពី

---

[៤៤] 'Youth-support' by Chernor Bah, Chair, Youth Advocacy Group for Global Education First Initiative (GEFI); Panel discussions: 'Enabling conditions for the delivery of quality global citizenship education: Where are we? Where do we want to go?' Global Citizenship Education: Enabling Conditions & Perspectives, 16 May 2014, UNESCO, Paris. www.unesco.org/new/fileadmin/MULTIMEDIA/HQ/ED/pdf/Chernor-Bah_16May2014.pdf [Accessed February 2015].

[៤៥] UNESCO. 2009. UNESCO World Report Investing in Cultural Diversity and Intercultural Dialogue. Paris, UNESCO. http://unesdoc.unesco.org/images/0018/001852/185202e.pdf [Accessed February 2015].

ភាពចម្រុះ ដែលកំពុងមានក្នុងសង្គម ទាំងនៅភាគខាងជើងនៃពិភពលោក និងភាគខាងត្បូងនៃពិភពលោក។ ភាពចម្រុះខាងវប្បធម៌ គឺជាប្រភពដ៏អស្ចារ្យជាងគេខាងភាពច្នៃប្រឌិត និងទ្រព្យធនរបស់មនុស្សជាតិ។ ប្រការនេះទាមទារឲ្យមានការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នាដើម្បីមើលមកពិភពលោក។ វាក៏ផ្តល់ឲ្យយើងនូវវិធីសាស្ត្រផ្សេងៗគ្នា សម្រាប់ដោះស្រាយបញ្ហា ដែលមានផលប៉ះពាល់ដល់យើងទាំងអស់គ្នា និងផ្តល់តម្លៃដល់ធាតុផ្សំជាមូលដ្ឋាននៃជីវិតរបស់យើង ដូចជាប្រព័ន្ធអេកូឡូហ្ស៊ីធម្មជាតិ សហគមន៍ បុគ្គល សាសនា និងជំនឿ។ យើងត្រូវទទួលស្គាល់ពីភាពផ្សេងៗគ្នានៃតថភាពក្នុងជីវិតរបស់យើង ហើយក្នុងពេលជាមួយគ្នានៅតែបញ្ជាក់សារជាថ្មីពីគុណតម្លៃសកល ដែលជាគុណតម្លៃរួមរបស់យើង។ ដោយសារតែភាពចម្រុះ ធ្វើឲ្យគេមានការពិបាកក្នុងការឯកភាពគ្នាជារួមលើនិយមន័យ និងអភិក្រមជាអន្តរជាតិ មានការស្វាគមន៍ការរួមចំណែកផ្តល់ជាគំនិត ដែលពិនិត្យលើសពីសូចនាករជាប្រពៃណី ដូចជា សុខភាព អប់រំ និងចំណូលជាដើម។ គួរឲ្យសោកស្តាយ ដោយសារតែមានការយល់ឃើញផ្សេងៗគ្នា និងដោយសារតែបរិបទផ្សេងៗគ្នា ពាក់ព័ន្ធនឹងសុខុមាលភាពមនុស្ស អភិក្រមគោលនយោបាយបច្ចុប្បន្នជាច្រើន នៅតែមានភាពលំអៀង និងមិនទាន់មានលក្ខណៈគ្រប់គ្រាន់។[៤៦]

> យើងត្រូវទទួលស្គាល់ពីភាពផ្សេងៗគ្នានៃតថភាពក្នុងជីវិតរបស់យើង ហើយក្នុងពេលជាមួយគ្នានៅតែបញ្ជាក់សារជាថ្មីពីគុណតម្លៃសកលដែលជាគុណតម្លៃរួមរបស់យើង។

[៤៦] ខណៈពេលដែលនៅកម្រិតអន្តរជាតិ នៅមិនទាន់មានការយល់ដឹងរួមគ្នានៅឡើយថា តើទស្សនទាន "សុខុមាលភាព" តម្រូវឲ្យមានអ្វីខ្លះ ឥឡូវនេះ មានការយល់ស្របគ្នាថា ការប្រើប្រាស់សូចនាករសង្គមសេដ្ឋកិច្ចបែបប្រពៃណី គឺមិនទាន់គ្រប់គ្រាន់នោះទេ។ កាលពីពេលថ្មីៗនេះ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានពិនិត្យហួសពីសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ទៅទៀត ដោយបានបញ្ចូលសូចនាករពាក់ព័ន្ធនឹងចំណូល សុខភាព និងការអប់រំផងដែរ។ ការព្រួយបារម្ភជុំវិញកំណើនវិសមភាព និងបញ្ហាយេនឌ័រ ត្រូវបានដាក់បញ្ចូលផងដែរទៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សកែសម្រួលទៅតាមវិសមភាព (IHDI) សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) និងសន្ទស្សន៍វិសមភាពយេនឌ័រ (GII)។ ការព្យាយាមផ្តោតលើសពីសូចនាករដែលធ្លាប់ផ្តោតលើទស្សនទានបែបចង្អៀតអំពីវឌ្ឍនភាពរបស់មនុស្សរួមមាន គំនិតផ្តួចផ្តើមជាច្រើនដែលកំពុងពិនិត្យលើលទ្ធភាពប្រើប្រាស់រង្វាស់ផ្សេងទៀត ដើម្បីវាស់វែងបរិយាប័ន្នភាព និងនិរន្តរភាពនៅកម្រិតសកលលោក។ សន្ទស្សន៍ទ្រព្យបរិយាប័ន្នដែលស្នើឡើងដោយសកលវិទ្យាល័យសហប្រជាជាតិ គឺជាឧទាហរណ៍មួយនៃអ្វីដែលកំពុងស្នើឡើង។ ឧទាហរណ៍ផ្សេងទៀតរួមមាន៖ គំនិតផ្តួចផ្តើមជីវិតកាន់តែប្រសើរ (OECD), EDP៖ ផលិតផលក្នុងស្រុកពិតដែលកែសម្រួលទៅតាមស្ថានភាពបរិស្ថាន (UNSEEA93), EPI៖ សន្ទស្សន៍លទ្ធផលការងារបរិស្ថាន (សកលវិទ្យាល័យ Yale), ESI៖ សន្ទស្សន៍និរន្តរភាពបរិស្ថាន (សកលវិទ្យាល័យ Yale), GPI៖ សូចនាករវឌ្ឍនភាពពិតប្រាកដ (កំណត់សារជាថ្មីនូវនិយមន័យវឌ្ឍនភាព), សូចនាករកំណើនបៃតង (OECD), ការសន្សំពិតប្រាកដ (Pearce, Atkinson & Hamilton), HCI៖ សន្ទស្សន៍មូលធនមនុស្ស (វេទិកាសេដ្ឋកិច្ចពិភពលោក), ISEW៖ សន្ទស្សន៍នៃសុខុមាលភាពសេដ្ឋកិច្ចប្រកបដោយចីរភាព (Cobb & Daly), NNW៖ សុខុមាលភាពពិតប្រាកដរបស់ជាតិ (រដ្ឋាភិបាលជប៉ុន), SDI៖ សូចនាករអភិវឌ្ឍន៍ប្រកបដោយចីរភាព (សហភាពអឺរ៉ុប រដ្ឋាភិបាលចក្រភពអង់គ្លេស)។

### ប្រអប់ទី ២៖ ចំណុចប្រសព្វនៃប្រព័ន្ធចំណេះដឹងផ្សេងៗ

វប្បធម៌អឺរ៉ុបបានផ្តល់ឲ្យយើងមិនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យយើងដឹងពីការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃវប្បធម៌នេះផងដែរ។ បើទោះបីជាយើងដឹងថាវប្បធម៌នេះគឺជាវប្បធម៌ ដែលមិនល្អឥតខ្ចោះ និងមានចំណុចប្លែកៗជាច្រើនក៏ដោយ វប្បធម៌នេះបានធ្វើឲ្យគំនិតប្រាជ្ញារបស់យើងមានការផ្លាស់ប្តូរពីទម្លាប់ធម្មតាៗទៅជាការយល់ដឹងពីនិន្នាការផ្ទុយពីអ្វីដែលយើងធ្លាប់តែគិតឃើញកន្លងមក។ អ្វីដែលខ្ញុំជំទាស់នោះគឺការរៀបចំបែបសិប្បនិម្មិត ដែលក្នុងការអប់រំបែបបរទេសនេះ ច្រើនតែគ្របដណ្តប់លើខួរក្បាលទាំងមូលរបស់យើង ដែលនាំឲ្យលុបបំបាត់ ឬបន្ថយបង្អាក់ឱកាសបង្កើតគំនិតថ្មីៗ តាមរយៈការបញ្ចូលការពិតផ្សេងៗគ្នាជាមួយគ្នា។ ចំណុចនេះហើយ ដែលជម្រុញឲ្យខ្ញុំមានគំនិតថាយើងត្រូវតែពង្រឹងវប្បធម៌របស់យើង មិនមែនដើម្បីប្រឆាំងតបតនឹងវប្បធម៌របស់បស្ចឹមប្រទេសនោះទេ ប៉ុន្តែត្រូវទទួលយក និងផ្សព្វផ្សាយវប្បធម៌នេះ និងប្រើប្រាស់វប្បធម៌នេះសម្រាប់ធ្វើជាអាហាររបស់យើង មិនមែនជាបន្ទុករបស់យើងនោះទេ, យើងត្រូវស្វែងយល់ឲ្យបានច្បាស់ពីវប្បធម៌នេះ មិនមែនគ្រាន់តែអានតាមអត្ថបទ និងសៀវភៅនោះទេ។

ប្រភព៖ Tagore, R. 1996. The Centre of Indian Culture. Sisir Kumar Das (ed.), The English Writings of Rabindranath Tagore, Vol. 2, Plays, Stories, Essays. New Delhi, Sahitya Akademi, p. 486.

## ការបញ្ចូលប្រព័ន្ធចំណេះដឹងផ្សេងៗគ្នាជាមួយគ្នា

ចាំបាច់ត្រូវមានការស្វែងយល់បន្ថែមពីជម្រើសផ្សេងទៀត ក្រៅតែពីគំរូនៃការទទួលបានចំណេះដឹង ដែលគេកំពុងប្រើប្រាស់ជាទូទៅបច្ចុប្បន្ននេះ។ គេចាំបាច់ត្រូវទទួលស្គាល់ និងពិចារណាឲ្យបានត្រឹមត្រូវពីប្រព័ន្ធទទួលចំណេះដឹងផ្សេងទៀត ជាជាងចាត់ទុកប្រព័ន្ធទាំងនេះថាមានគុណភាពអន់។ សង្គមនៅទីណាក៏ដោយ អាចរៀនសូត្រច្រើនពីគ្នាទៅវិញទៅមក តាមរយៈការបើកចំហស្វែងយល់ ពីទស្សនៈយល់ឃើញពីពិភពលោកផ្សេងទៀត។ មានចំណុចជាច្រើនដែលត្រូវរៀនសូត្រ ដូចជា ពីសង្គមជនបទទូទាំងពិភពលោក ជាពិសេស សង្គមជនជាតិដើមភាគតិច អំពីទំនាក់ទំនងរវាងសង្គមមនុស្ស និងបរិស្ថានធម្មជាតិ ជាដើម។ ក្នុងវប្បធម៌របស់ជនជាតិដើមភាគតិចជាច្រើន ផែនដីត្រូវបានគេចាត់ទុកថាជាមាតា។ គេមិនអាចបង្កការខូចខាតដល់ផែនដី ឬផលិតផលនានារបស់ផែនដី ដោយពុំមានមូលហេតុសមស្រប

> គេចាំបាច់ត្រូវទទួលស្គាល់ និងពិចារណាឲ្យបានត្រឹមត្រូវពីប្រព័ន្ធទទួលចំណេះដឹងផ្សេងទៀត ជាជាងចាត់ទុកប្រព័ន្ធទាំងនេះថាមានគុណភាពអន់។

ឡើយ ដោយមូលហេតុភាគច្រើនគឺពាក់ព័ន្ធជាមួយនឹងការរស់រាន។ ក្នុងវប្បធម៌ជាច្រើន មនុស្សត្រូវបានចាត់ទុកថាជាសមាជិករបស់ធម្មជាតិ ដែលមានសិទ្ធិស្មើគ្នា និងមិនត្រូវបានចាត់ទុកថាមានប្រៀបជាងសភាវរស់ផ្សេងទៀតឡើយ។ សង្គមជនបទជាច្រើនមានការយល់ដឹងពីពេលវេលាតាមរបៀបវិលជុំ ពោលគឺពេលវេលាមិនមែនចេះតែបន្តទៅមុខរហូតនោះទេ។ ពេលវេលាផ្សារភ្ជាប់ជាមួយនឹងការធ្វើកសិកម្ម ការបន្តពីរដូវមួយទៅរដូវមួយទៀត និងពិធីបុណ្យផ្សេងៗ ដើម្បីលើកកម្ពស់សុខុមាលភាពខាងស្មារតីរបស់សហគមន៍។ ដូចគ្នាដែរ របៀបធ្វើការសម្រេចចិត្តជាសមូហភាពក៏មានលក្ខណៈខុសៗគ្នាផងដែរ។ សង្គមមួយចំនួនប្រកាន់លទ្ធិប្រជាធិបតេយ្យ និងប្រើប្រាស់ការបោះឆ្នោត ដើម្បីធ្វើការសម្រេចចិត្តរួមគ្នា សូម្បីតែក្នុងក្រុមតូចៗក៏ដោយ។ សង្គមផ្សេងទៀតស្វែងរកការឯកភាពគ្នាជារួម ដែលមានន័យថាត្រូវមានការប្រកែកគ្នា ការពិភាក្សាគ្នា និងការបញ្ចុះបញ្ចូលគ្នា។ ក្នុងពិភពលោកនេះ មានការយល់ឃើញខុសគ្នាៗមិនចេះអស់ ដែលធ្វើឲ្យជីវិតរបស់យើងកាន់តែសម្បូរបែប ប្រសិនបើយើងសុខចិត្តលះបង់ភាពប្រាកដប្រជារបស់យើង និងបើកចំហគំនិតរបស់យើង ដើម្បីទទួលយកការពន្យល់ផ្សេងៗគ្នាពីតថភាពជុំវិញខ្លួនយើង។

ចំណុចសំខាន់ត្រូវរំឭកឡើងវិញ ដូចអ្វីអ្នកប្រាជ្ញ Frantz Fanon, Aimé Césaire, Rabindranath Tagore និងអ្នកប្រាជ្ញផ្សេងទៀតលើកឡើងថា នៅពេលដែលយើងទទួលបានចំណេះដឹងក្នុងទម្រង់អ្វីមួយ តាមពិត យើងបានបង្កើតនូវប្រព័ន្ធអំណាចមួយរួចទៅហើយ។ ការអប់រំ និងការអភិវឌ្ឍនាពេលអនាគត របស់ពិភពលោកបច្ចុប្បន្ន តម្រូវឲ្យមានការពិគ្រោះយោបល់រវាងអ្នកដែលមានទស្សនៈយល់ឃើញផ្សេងៗគ្នាក្នុងពិភពលោក ក្នុងគោលបំណងដាក់ប្រព័ន្ធចំណេះដឹង ដែលមានប្រភពពីតថភាពខុសគ្នាៗបញ្ចូលគ្នាតែមួយ និងបង្កើតនូវបេតិកភ័ណ្ឌរួមរបស់យើងទាំងអស់គ្នា។ សម្លេងពីភាគខាងត្បូងរបស់ពិភពលោក ចាំបាច់ត្រូវបញ្ចូលទៅក្នុងការជជែកវែកញែកជាអន្តរជាតិអំពីការអប់រំ។ ឧទាហរណ៍ក្នុងសហគមន៍ Andean នៅអាមេរិចឡាទីន ការអភិវឌ្ឍមានន័យថា sumak kawsay ឬ “buen vivir” សម្រាប់ភាសា Quechua ដែលមានន័យថា “ការរស់នៅបានល្អប្រសើរ។ មានប្រភពពីវប្បធម៌របស់ជនជាតិដើមភាគតិច និងពីទស្សនៈយល់ឃើញផ្សេងៗគ្នាក្នុងពិភពលោក sumak kawsay ត្រូវបានលើកស្នើថាជាទស្សនទានមួយទៀតនៃការអភិវឌ្ឍ ហើយត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសអេក្វាឌ័រ និងបូលីវៀ។ ទស្សនទានរបស់មហាត្មៈគន្ធី “អ្នកការពារ ( trusteeship )” ដែលមានន័យថា យើងកាន់កាប់ទ្រព្យសម្បត្តិរបស់ភពផែនដីនេះ មិនមែនក្នុងនាមជា “ម្ចាស់” នោះទេ ប៉ុន្តែជា “អ្នកការពារ” ឲ្យគ្រប់សភាវមានជីវិតទាំងអស់ និងសម្រាប់មនុស្សជំនាន់ក្រោយក៏ជាអ្វីដែលគួរយកមកធ្វើការពិចារណាផងដែរ។[៤៧]

[៤៧] M. K. Gandhi, 1960. Trusteeship. Compiled by Ravindra Kelekar. Ahemadabad, India, Jitendra T. Desai Navajivan Mudranalaya.

**ប្រអប់ទី ៣៖ Sumak kawsay ការយល់ឃើញមួយផ្សេងទៀតពីការអភិវឌ្ឍ**

ទស្សនទាន sumak kawsay មានប្រភពពីទស្សនៈយល់ឃើញចំពោះពិភពលោករបស់ជនជាតិ Quechua ដែលរស់នៅតំបន់ Andes នៃប្រទេសអេក្វាឌ័រ។ មានន័យថា "buen vivir" ជាភាសាអេស្ប៉ាញ ទស្សនទាន sumak kawsay មានន័យជាភាសាអង់គ្លេសថា "ការរស់នៅបានល្អប្រសើរ។ វាមានន័យថាជាការអភិវឌ្ឍរួមគ្នាប្រកបដោយភាពសុខដុមរមនា សម្រាប់មនុស្សដែលស្ថិតក្នុងបរិបទនៃសហគមន៍សង្គម និងវប្បធម៌តែមួយ និងដែលស្ថិតក្នុងបរិយាកាសធម្មជាតិរបស់ពួកគេ។ មានប្រភពពីប្រព័ន្ធជំនឿរបស់ជនជាតិដើមភាគតិចនៃជនជាតិ Quechua ទស្សនទាននេះដាក់បញ្ចូលទស្សនៈរបស់បស្ចឹមប្រទេសអំពីគំរូអភិវឌ្ឍន៍ដែលគ្របលុបលើគំរូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីផ្តល់នូវជម្រើសគំរូអភិវឌ្ឍន៍មួយទៀត ដែលមានមូលដ្ឋានលើភាពសុខដុមរមនារវាងមនុស្ស និងមនុស្ស ក៏ដូចជារវាងមនុស្ស និងបរិស្ថានធម្មជាតិរបស់ពួកគេ។

ទស្សនទាននេះបានជម្រុញឲ្យមានការ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ប្រទេសអេក្វាឌ័រកាលពីពេលថ្មីៗនេះ ដែលឥឡូវនេះលើកឡើងពី "ទម្រង់ថ្មីនៃការរស់នៅជាមួយគ្នាជាសាធារណៈ បើទោះបីជាមានការយល់ឃើញខុសៗគ្នាក៏ដោយ និងរស់នៅដោយសុខដុមរមនាជាមួយធម្មជាតិ ដើម្បីរស់នៅឲ្យបានល្អប្រសើរ ដែលសំដៅលើ sumak kawsay។ រដ្ឋធម្មនុញ្ញនេះ មានមូលដ្ឋានលើការទទួលស្គាល់ "សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការរស់នៅក្នុងបរិយាកាសដែលមានភាពល្អប្រសើរ អាចរក្សាបាននូវលំនឹងប្រព័ន្ធអេកូឡូហ្ស៊ី ដែលអាចធានាបាននូវនិរន្តរភាព និងការរស់នៅល្អប្រសើរ (sumak kawsay)"។ រដ្ឋធម្មនុញ្ញនេះចែងផងដែរថា ការទទួលខុសត្រូវខាងក្រោមនេះត្រូវតែជាការទទួលខុសត្រូវរបស់រដ្ឋ៖ "ដើម្បីជម្រុញឲ្យមានការបង្កើតចំណេះដឹង ជម្រុញឲ្យមានការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងលើកកម្ពស់គតិបណ្ឌិតរបស់បុព្វបុរស សំដៅចូលរួមចំណែកសម្រេចនូវរបៀបរស់នៅល្អប្រសើរ (sumak kawsay)"

## រៀបចំចក្ខុវិស័យឡើងវិញសម្រាប់វិស័យអប់រំ ក្នុងពិភពលោកដែលពោរពេញដោយភាពចម្រុះ

ចាំបាច់ត្រូវមានការពិនិត្យឡើងវិញលើគោលបំណងនៃការអប់រំ ជាពិសេស នៅពេលមានការកែសម្រួលចក្ខុវិស័យនៃការអភិវឌ្ឍមនុស្ស និងសង្គមប្រកបដោយចីរភាព ដែលត្រូវមានសមធម៌ផង និងមានប្រសិទ្ធភាពផង។ ចក្ខុវិស័យជុំវិញនិរន្តរភាពបែបនេះ ត្រូវធ្វើការពិចារណាពីទិដ្ឋភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ច នៃការអភិវឌ្ឍមនុស្ស និងរបៀបដែលទិដ្ឋភាពទាំងនេះមានទំនាក់ទំនងជាមួយនឹងការអប់រំ៖ "ការអប់រំដែលផ្តល់ភាពអង់អាច គឺជាការអប់រំ ដែលកសាងធនធានមនុស្ស ដែលយើងត្រូវការជាចាំបាច់ ឲ្យមានផលិតភាព បន្តធ្វើការរៀនសូត្រ ដោះស្រាយបញ្ហា មានភាពច្នៃប្រឌិត និងរស់នៅជាមួយគ្នាជាមួយនឹងធម្មជាតិ ប្រកបដោយសុខសន្តិភាព និងភាពសុខដុមរមនា។ នៅពេលដែលប្រជាជាតិនានាធានាថា សេវាអប់រំអាចផ្តល់ឲ្យប្រជាពលរដ្ឋរបស់ខ្លួនគ្រប់រូប ពេញមួយជីវិតរបស់ពួកគេ ពេលនោះបដិវត្តដ៏ស្ងៀមស្ងាត់មួយនឹងចាប់ផ្តើមឡើង៖ ការអប់រំក្លាយជាយន្តការ ដែលនាំឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាព និងជាកូនសោរ ដើម្បីបង្កើតពិភពលោកមួយ ដែលកាន់តែល្អប្រសើរជាងមុន" ការអប់រំអាច និងត្រូវតែចូលរួមចំណែកដល់ការសម្រេចចក្ខុវិស័យថ្មីដែលចង់បានការអភិវឌ្ឍជាសកលប្រកបដោយចីរភាព។

## ប្រអប់ទី ៤៖ ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការអប់រំ

"គួរមានការទទួលស្គាល់ថាការអប់រំ ក្នុងនោះរួមមានការអប់រំក្នុងប្រព័ន្ធ ការបង្កើនការយល់ដឹងជាសាធារណៈ និងការបណ្តុះបណ្តាល ថាជាដំណើរការមួយ ដែលមនុស្ស និងសង្គម អាចសម្រេចសក្តានុពលពេញលេញបំផុត។ ការអប់រំមានតួនាទីសំខាន់ ក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងការបង្កើនសមត្ថភាពរបស់មនុស្ស ដើម្បីឆ្លើយតបចំពោះបញ្ហានានា ដែលពាក់ព័ន្ធជាមួយនឹងបរិស្ថាន និងការអភិវឌ្ឍ"

របៀបវារៈ ២១, មាត្រា ៣៦, កថាខណ្ឌទី ៣ ឆ្នាំ ១៩៩២

សេចក្តីប្រកាសអៃឈី-ណាហ្គូយ៉ា ឆ្នាំ ២០១៤ ស្តីពីការអប់រំ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ស្នើឲ្យរដ្ឋាភិបាលនានា "ពង្រឹងការបញ្ចូលគោលការណ៍អប់រំ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនេះ ទៅក្នុងគោលនយោបាយស្តីពីការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍប្រកបដោយចីរភាព"

ការរៀនសូត្រដែលមានការរៀបចំត្រឹមត្រូវក្នុងគ្រប់ទម្រង់ទាំងអស់ អាចធ្វើឲ្យមនុស្សអាចបន្សាំខ្លួនផង និងអាចធ្វើការផ្លាស់ប្តូរផង។ ការអប់រំកម្រិតមូលដ្ឋាន ដែលមានគុណភាពល្អ និងការបន្តរៀនសូត្រ និងការបណ្តុះបណ្តាល មានសារៈសំខាន់ចាំបាច់ ដើម្បីឲ្យបុគ្គល និងសហគមន៍នានា អាចបន្សាំខ្លួនទៅនឹងការប្រែប្រួលបរិស្ថាន សង្គម និងសេដ្ឋកិច្ច នៅកម្រិតមូលដ្ឋាន និងកម្រិតសកល។ ប៉ុន្តែ ការរៀនសូត្រក៏មានសារៈសំខាន់ ចំពោះការផ្តល់ភាពអង់អាច និងការអភិវឌ្ឍសមត្ថភាព ដើម្បីសម្រេចឲ្យបាននូវការផ្លាស់ប្តូរក្នុងសង្គមផងដែរ។ ជាការពិត ការអប់រំអាចរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរដែលពិបាកៗ ដូចជា ការផ្លាស់ប្តូរផ្នត់គំនិត និងទស្សនៈយល់ឃើញរបស់យើងចំពោះពិភពលោកជាដើម។ ការអប់រំមានសារៈសំខាន់ ចំពោះការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ ដើម្បីពង្រីកឱកាស ដែលមនុស្សត្រូវការជាចាំបាច់ ដើម្បីរស់នៅប្រកបដោយអត្ថន័យ និងសេចក្តីថ្លៃថ្នូរដូចៗគ្នា។ ចក្ខុវិស័យថ្មីនៃការអប់រំនេះ គួរដាក់បញ្ចូលការអភិវឌ្ឍការគិតពិចារណាល្អិតល្អន់ ការវិនិច្ឆ័យដោយឯករាជ្យ និងការជជែកវែកញែក។ ការបង្កើនគុណភាពនៃការអប់រំ និងការផ្តល់នូវការរៀនសូត្រដែលឆ្លើយតបចំពោះតម្រូវការសេដ្ឋកិច្ច និងសង្គម ដែលកំណត់ដោយបុគ្គល និងសហគមន៍ មានសារៈសំខាន់ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរទាំងនេះ។

សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព គឺជាសិទ្ធិទទួលបានការរៀនសូត្រប្រកបដោយអត្ថន័យ និងឆ្លើយតបចំពោះតម្រូវការជាក់ស្តែង។ ប៉ុន្តែ សហគមន៍នានាក្នុងពិភពលោកនេះ មានតម្រូវការរៀនសូត្រផ្សេងៗគ្នា។ ដូច្នេះ ការរៀនសូត្រដែលឆ្លើយតប ត្រូវឆ្លុះបញ្ចាំងពីអ្វីដែលវប្បធម៌នីមួយៗ ក្រុមមនុស្សនីមួយៗ កំណត់ថាជាអ្វីដែលចាំបាច់ ដើម្បីរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។ យើងត្រូវទទួលស្គាល់ថា មានវិធីសាស្ត្រច្រើនយ៉ាង ដើម្បីកំណត់និយមន័យនៃគុណភាពជីវិត ដូចគ្នាដែរ មានវិធីសាស្ត្រច្រើនយ៉ាង ដើម្បីកំណត់ពីអ្វីដែលចាំបាច់ត្រូវរៀនសូត្រ។ អ្នកដែលមានគំនិតចង់ឲ្យការអប់រំបម្រើគោលបំណងពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែង គួរទទួលយករបៀបផ្សេងទៀត ដើម្បីយល់ដឹងពីសុខុមាលភាពរបស់មនុស្ស ដូច្នេះពួកគេត្រូវផ្តោតការយកចិត្តទុកដាក់លើភាពពាក់ព័ន្ធ នៃការអប់រំ ដែលត្រូវចាត់ទុកថាជាទំនិញរួម។ ចំណុចនេះតម្រូវឲ្យមានការស្តាប់សម្លេងស្ងៀមស្ងាត់របស់អ្នកដែលមិនទាន់មានឱកាសបញ្ចេញសម្លេងរបស់ខ្លួន។ ការយល់ដឹងពីទស្សនៈវិស័យផ្សេងៗគ្នាបែបនេះ អាចជាប្រទីបបំភ្លឺផ្លូវរបស់យើង ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើង ដើម្បីសម្រេចឲ្យបាននូវសុខុមាលភាព។ ទស្សនវិស័យមនុស្សនិយម គឺជាមូលដ្ឋានដ៏ចាំបាច់ ដើម្បីឲ្យគេរិះរកវិធីសាស្ត្រផ្សេងទៀត ដើម្បីផ្តល់ការអប់រំ និងសម្រេចឲ្យបាននូវសុខុមាលភាពរបស់មនុស្ស។

# ២.	ការបញ្ជាក់ឡើងវិញពីអតិក្រមមនុស្សនិយម



# ២. ការបញ្ជាក់ឡើងវិញពីអភិក្រមមនុស្សនិយម

*“ជាតិជាមនុស្សរបស់ខ្ញុំ គឺជាប់ជាមួយនឹងជាតិជាមនុស្សរបស់អ្នកដែរ ព្រោះថាដោយសារតែយើងជាមនុស្សនេះឯង ទើបរអាចនៅជាមួយគ្នាបាន”*

**Desmond Tutu សង្ឃសាសនាកាតូលិច និងជាសកម្មជនសិទ្ធិសង្គមរបស់អាហ្វ្រិចខាងត្បូង**

ការធានានូវនិរន្តរភាព និងការលើកកម្ពស់សេចក្ដីថ្លៃថ្នូរ សមត្ថភាព និងសុខុមាលភាពរបស់មនុស្ស ដោយផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងមនុស្សផ្សេងទៀត និងជាមួយធម្មជាតិ គួរតែជាគោល-បំណងជាមូលដ្ឋាននៃការអប់រំ ក្នុងសតវត្សរ៍ទី ២១ នេះ។ គេអាចចាត់ទុកបំណងប្រាថ្នាបែបនេះថាស្មារតីមនុស្សនិយម (humanism) ដែលនេះគួរតែជាបេសកកម្មរបស់យូណេស្កូ ដើម្បីអភិវឌ្ឍស្មារតីនេះបន្ថែមទៀត ទាំងផ្នែកទស្សនទាន ទាំងការអនុវត្តជាក់ស្ដែង។ ទស្សនទានមនុស្សនិយម គឺជាប្រពៃណីជាយូរលង់មកហើយរបស់យូណេស្កូ។ តាំងពីឆ្នាំ ១៩៥៣ មក យូណេស្កូបានបោះពុម្ពផ្សាយរបាយការណ៍នៃការពិភាក្សាតុមូលជាអន្តរជាតិ ក្រោមប្រធានបទ “ស្មារតីមនុស្សនិយម និងការអប់រំ ក្នុងបូព៌ា និងបស្ចិមប្រទេស” ដែលបានរៀបចំធ្វើឡើងនៅទីក្រុងញូដេលី។[៥០]

ទស្សនទានមនុស្សនិយមន័យនេះ ក៏ជាប្រពៃណីជាយូរលង់មកហើយក្នុងវប្បធម៌ និងប្រពៃណីសាសនាផ្សេងៗផងដែរ ហើយក៏មានការបកស្រាយបែបបទស្សនវិជ្ជាផ្សេងៗគ្នាផងដែរ។ ឧទាហរណ៍ ការបកស្រាយមួយលើទស្សនទានមនុស្សនិយម បានផ្សារភ្ជាប់ទស្សនទាននេះជាមួយនឹងការពុំមានជំនឿលើសាសនាណាមួយ និងស្មារតីជាតិនិយមបែបអាណាចក្រ។ ទស្សនទាននេះក៏ត្រូវបានផ្សារភ្ជាប់ជាមួយនឹងទស្សន៍វិជ្ជាផ្សេងទៀត ដូចជាការសិក្សាពីបាតុភូត (phenomenology) ឬអត្ថិភាពនិយម (existentialism) ដែលមើលឃើញនូវភាពខុសប្លែកគ្នារវាងមនុស្សជាតិ និងពិភពធម្មជាតិផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ

[៥០] UNESCO Unity and Diversity of Cultures. 1953. Humanism and Education in East and West: An international round-table discussion. Paris, UNESCO.

ការមានការបកស្រាយទស្សនទានមនុស្សនិយមនេះតាមបែបសាសនាផងដែរ ដោយបានចាត់ទុកសមិទ្ធផលដែលមនុស្សសម្រេចបាន ដូចជា សមិទ្ធផលខាងអប់រំ វប្បធម៌ និងវិទ្យាសាស្ត្រ ជាដើម ថាជាឧទាហរណ៍ដែលបង្ហាញពីទំនាក់ទំនងរវាងមនុស្សជាមួយនឹងធម្មជាតិចក្រវាល និងអ្នកបង្កើតចក្រវាល។ ក្នុងចុងសតវត្សរ៍ទី ២០ និងដើមសតវត្សរ៍ទី ២១ ការរិះគន់លើទស្សនទានមនុស្សនិយមដែលផ្តោតលើមនុស្សមណ្ឌល និងទេវមណ្ឌល មានប្រភពចេញពីអ្នកទំនើបនិយម ពីសកម្មជនស្ត្រីមួយចំនួន ពីអ្នកបរិស្ថាននិយម និងកាលពីពេលថ្មីៗនេះ ពីអ្នកដែលចាត់ទុកខ្លួនឯងថាជាអ្នកអំពាវនាវឲ្យមនុស្សមានការផ្លាស់ប្តូរ (trans-humanists) ឬជាអ្នកមើលហួសពីស្មារតី មនុស្សនិយម (post-humanists) ដែលអំពាវនាវឲ្យមានការជ្រើសរើសលក្ខណៈជីវសាស្ត្ររបស់មនុស្ស និងធ្វើឲ្យមានការកែលំអមនុស្សបែបជ្រុលនិយម។

ការបកស្រាយនីមួយៗ ក្នុងចំណោមការបកស្រាយទាំងនេះនាំឲ្យលេចឡើងនូវបញ្ហាពាក់ព័ន្ធនឹងក្រមសីលធម៌ ដែលជាក្តីបារម្ភសម្រាប់វិស័យអប់រំ។

## ■ អភិក្រមអប់រំបែបមនុស្សនិយម

ចក្ខុវិស័យបែបមនុស្សនិយមបញ្ជាក់សារជាថ្មីពីគោលការណ៍ក្រមសីលធម៌ជាសកល ដែលគួរជាមូលដ្ឋាន សម្រាប់បង្កើតនូវអភិក្រមរួមមួយ ដើម្បីសម្រេចឲ្យបាននូវការអប់រំសម្រាប់ទាំងអស់គ្នា។ អភិក្រមបែបនេះ មានភាពពាក់ព័ន្ធសម្រាប់ការរៀបចំដំណើរការរៀនសូត្រដែលជម្រុញលើកទឹកចិត្តឲ្យមានការទទួលបានចំណេះដឹងពាក់ព័ន្ធ និងការអភិវឌ្ឍសមត្ថភាពដើម្បីប្រយោជន៍រួមរបស់មនុស្សជាតិ។ អភិក្រមបែបមនុស្សនិយមវិភាគវែកញែកលើការអប់រំលើសពីតួនាទីនៃការអប់រំ ដែលត្រូវបានគេចាត់ទុកថាមានប្រយោជន៍សម្រាប់តែការអភិវឌ្ឍសេដ្ឋកិច្ច។ អភិក្រមបែបនេះផ្តោតសំខាន់លើបរិយាប័ន្នភាព និងលើការអប់រំ ដែលមិនផាត់ចេញក្រុមណាមួយ និងធ្វើឲ្យក្រុមណាមួយខកខានឱកាស។ អភិក្រមបែបនេះមានតួនាទីជាមគ្គុទេសក៍ សម្រាប់ឆ្លើយតបទៅនឹងការផ្លាស់ប្តូរស្ថានភាពនៃការរៀនសូត្រក្នុងសកលលោកទាំងមូល ពោលគឺស្ថានភាពមួយ ដែលគ្រូ និងអ្នកអប់រំផ្សេងទៀតបំពេញតួនាទីសំខាន់ក្នុងការសម្របសម្រួលការរៀនសូត្រ ដើម្បីឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នា។

## ការខាកចេញពីទ្រឹស្តីអភិវឌ្ឍន៍ដែលធ្លាប់មានកន្លងមក

ខណៈពេលដែលយើងផ្តោតការយកចិត្តទុកដាក់លើសំណួរធំ ពាក់ព័ន្ធនឹងគោលបំណងនៃការអប់រំ និងប្រភេទសង្គម ដែលយើងប្រាថ្នាចង់បាន យើងចាំបាច់ត្រូវគិតពិចារណាពីទិដ្ឋភាពវប្បធម៌ សង្គម សេដ្ឋកិច្ច ក្រមសីលធម៌ និងស៊ីវិលផងដែរ។ ជាការពិត មុខងារសេដ្ឋកិច្ចរបស់ការអប់រំ គឺជាការសំខាន់ ប៉ុន្តែយើងត្រូវមើលឲ្យហួសពីចក្ខុវិស័យដែលចាត់ទុកការអប់រំថាមានប្រយោជន៍សម្រាប់ការអប់រំ និងហួសពីអភិក្រមមូលធនមនុស្ស ដែលតែងត្រូវបានគេលើកមកនិយាយក្នុងការពិភាក្សាអំពីការអភិវឌ្ឍអន្តរជាតិ។[៥១] ការអប់រំមិនត្រឹមតែជាការទទួលបានជំនាញប៉ុណ្ណោះទេ វាគឺជាអ្វីដែលពាក់ព័ន្ធនឹងគុណតម្លៃនៃការគោរពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលចាំបាច់ ដើម្បីឲ្យមានសុខុដុមរមនា ក្នុងសង្គមដែលពោរពេញទៅដោយភាពចម្រុះ។ ការយល់ដឹងថា បញ្ហាក្រមសីលធម៌មានសារៈសំខាន់ចំពោះដំណើរការនៃការអភិវឌ្ឍអាចជាការយល់ខុសពីទ្រឹស្តីទូទៅបច្ចុប្បន្ននេះ។ ការយល់ដឹងបែបនេះ ជាការផ្តល់តម្លៃបន្ថែមដល់តួនាទីរបស់ការអប់រំ ក្នុងការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ ដើម្បីឲ្យមនុស្សអាចរស់នៅប្រកបដោយអត្ថន័យ និងសេចក្តីថ្លៃថ្នូរ ស្របទៅតាមការយល់ឃើញមួយផ្សេងទៀតអំពីការអភិវឌ្ឍ ដែលលើកឡើងដោយ Amartya Sen។[៥២]

## អភិក្រមរួម ដែលមានមូលដ្ឋានលើក្រមសីលធម៌

ដូច្នេះ វាគឺជាការចាំបាច់ ដែលគេត្រូវធ្វើការបញ្ជាក់ឡើងវិញពីអភិក្រមរៀនសូត្របែបមនុស្សនិយម ពេញមួយជីវិត ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ជាធម្មតា ការផ្តោតការយកចិត្តទុកដាក់លើចំណុចអ្វីមួយ អាចធ្វើឲ្យមានការផ្លាស់ប្តូរក្នុងបរិបទនៃការរៀនសូត្រ និងក្នុងដំណាក់កាលផ្សេងៗនៃជីវិត។ ប៉ុន្តែ ក្នុងការកំណត់ឡើងវិញពីភាពពាក់ព័ន្ធនៃការរៀនសូត្រពេញមួយជីវិត ថាជាគោលការណ៍សំខាន់សម្រាប់ការរៀនសូត្រ ជាការ

[៥១] ក្នុងរបាយការណ៍របស់គណៈកម្មាធិការកម្រិតខ្ពស់ឆ្នាំ ២០១៣ ស្តីពីការអភិវឌ្ឍក្រោយឆ្នាំ ២០១៥ មានពីរទំព័រនិយាយពីការអប់រំ ដោយទំព័រទាំងពីរនេះប្រើប្រាស់ភាសា ដែលសំដៅលើអភិក្រមមូលធនមនុស្សពោលគឺបានលើកឡើងពីប្រយោជន៍ដែលទទួលបានមកវិញពីការអប់រំនិងការរួមចំណែកនៃការអប់រំចំពោះការបង្កើតនូវ "ប្រជាពលរដ្ឋដែលមានផលិតភាព"។

[៥២] Sen, A. 1999. Development as Freedom. New York, Random House; Sen, A. 1999. Commodities and Capabilities. New Delhi, Oxford University Press.

សំខាន់ណាស់ ដែលគេត្រូវដាក់បញ្ចូលទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងវប្បធម៌។[៥៣] អភិក្រមអប់រំបែបមនុស្សនិយម មើលហួសពីទស្សនទានមនុស្សនិយមបែបវិទ្យាសាស្ត្រ (scientific humanism) ដែលត្រូវបានស្នើឡើងដោយអគ្គនាយកទីមួយរបស់យូណេស្កូ Julian Huxley ជាគោលការណ៍តម្រង់ទិស សម្រាប់យូណេស្កូ និងដែលត្រូវបានបញ្ចូលក្នុងរបាយការណ៍ Faure ឆ្នាំ ១៩៧។[៥៤] ដូចដែលបានកត់សម្គាល់ខាងលើ ទស្សនទានមនុស្សនិយម នាំឲ្យមានការបកស្រាយជាច្រើន ដែលការបកស្រាយទាំងនេះច្រើនតែផ្ទុយគ្នា ហើយការបកស្រាយនីមួយៗនាំឲ្យមានបញ្ញាក្រមសីលធម៌សំខាន់ៗ ដែលពាក់ព័ន្ធជាមួយនឹងវិស័យអប់រំ។ គេអាចលើកនូវទល្លីករណ៍មួយថា ការធានានិរន្តរភាព និងការលើកកម្ពស់សេចក្ដីថ្លៃថ្នូរ សមត្ថភាព និងសុខុមាលភាពរបស់មនុស្សម្នាក់ ធៀបជាមួយនឹងមនុស្សម្នាក់ទៀត និងធៀបជាមួយវប្បធម៌ គួរតែជាគោលបំណងជាមូលដ្ឋាននៃការអប់រំ ក្នុងសតវត្សរ៍ទី ២១ នេះ។[៥៥] គុណតម្លៃបែបមនុស្សនិយម ដែលគួរជាមូលដ្ឋាន និងជាគោលបំណងនៃការអប់រំ រួមមាន៖ ការគោរពជីវិត និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស សិទ្ធិស្មើភាពគ្នា និងយុត្តិធម៌សង្គម ភាពចម្រុះខាងវប្បធម៌ និងសង្គម និងស្មារតីសាមគ្គីភាពគ្នារបស់មនុស្ស និងការទទួលខុសត្រូវរួមគ្នា សម្រាប់អនាគតរួមរបស់យើង។ ចាំបាច់ត្រូវមានការប្រើប្រាស់អភិក្រមរៀនសូត្របែបសន្ទនាគ្នា ដែលត្រូវបានលើកទឹកចិត្តដោយ Martin Buber [៥៦] និង Paulo

> ការធានានិរន្តរភាព និងការលើកកម្ពស់សេចក្ដីថ្លៃថ្នូរ សមត្ថភាពនិងសុខុមាលភាពរបស់មនុស្សម្នាក់ធៀបជាមួយនឹងមនុស្សម្នាក់ទៀត និងធៀបជាមួយវប្បធម៌ គួរតែជាគោលបំណងជាមូលដ្ឋាននៃការអប់រំ ក្នុងសតវត្សរ៍ទី ២១ នេះ។

---

[៥៣] គួរកត់សម្គាល់ថា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពពាក់ព័ន្ធនឹងការអប់រំ ដែលស្នើឡើង សម្រាប់រយៈពេលក្រោយឆ្នាំ ២០១៥ ត្រូវបានសរសេរសំដៅលើការរៀនសូត្រពេញមួយជីវិត៖ "ការធានាឲ្យមានការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។" https://sustainabledevelopment.un.org/content/documents/1579SDGs%20Proposal.pdf [Accessed February 2015].

[៥៤] See Huxley, J. 1946. UNESCO: Its purpose and philosophy. Paris, UNESCO Preparatory Commission; and, the recent reference to this in Haddad, G. and Aubin, J. P. 2013. Toward a humanism of knowledge, action and cooperation. International Review of Education, Vol. 59, No. 3, pp. 331-341.

[៥៥] See for example the collection of articles in 'On Dignity', Diogenes, August 2007, Nol. 54, No. 3, http://dio.sagepub.com/content/54/3.toc#content-block [Accessed February 2015].

[៥៦] Morgan, W. J. and Guilherme, A. 2014. Buber and Education: Dialogue as conflict resolution. London, Routledge.

Freire។[៥៧] យើងក៏ត្រូវបដិសេធចោលផងដែរនូវប្រព័ន្ធរៀនសូត្រ ដែលបែងចែកមនុស្ស និងចាត់ទុកមនុស្សជាទំនិញ ក៏ដូចជាការអនុវត្តក្នុងសង្គម ដែលធ្វើការបែងចែកមនុស្ស និងផ្ដល់តម្លៃទាបដល់មនុស្ស។ ការអប់រំត្រូវប្រកាន់តាមគុណតម្លៃ និងគោលការណ៍នេះ ប្រសិនបើយើងចង់សម្រេចឲ្យបាននូវនិរន្តរភាព និងសន្តិភាព។

តាមរយៈការពង្រីកវិសាលភាពបែបនេះ ការអប់រំអាចនាំមកនូវការផ្លាស់ប្ដូរ និងរួមចំណែកបង្កើតនូវអនាគតប្រកបដោយនិរន្តរភាព សម្រាប់យើងទាំងអស់គ្នា។ ផ្អែកទៅតាមមូលដ្ឋានក្រមសីលធម៌បែបនេះ ជំនាញគិតពិចារណាល្អិតល្អន់ វិនិច្ឆ័យដោយឯករាជ្យ ដោះស្រាយបញ្ហា និងចំណេះដឹងពីប្រព័ន្ធព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ គឺជាគន្លឹះ សម្រាប់បណ្ដុះនូវតវិយាបថដែលនាំមកនូវការផ្លាស់ប្ដូរ។ អភិក្រមរួមបែបមនុស្សនិយម សម្រាប់ការអប់រំ ដូចដែលត្រូវបានបង្ហាញក្នុងរបាយការណ៍ Delors ឆ្នាំ ១៩៩៦ គឺរឹតតែពាក់ព័ន្ធជាមួយនឹងពិភពលោកបច្ចុប្បន្ននេះ ដែលនិរន្តរភាព បានក្លាយជាការព្រួយបារម្ភសំខាន់នៃការអភិវឌ្ឍសកលលោក។ ការអភិវឌ្ឍប្រកបដោយចីរភាព ដែលក្នុងនោះកំណើនសេដ្ឋកិច្ច ត្រូវនាំមុខដោយការការពារបរិស្ថាន និងការយកចិត្តទុកដាក់ចំពោះយុត្តិធម៌សង្គម តម្រូវឲ្យមានការប្រើប្រាស់អភិក្រមរួមមួយសម្រាប់ផ្ដល់ការអប់រំ ដែលផ្ដោតការយកចិត្តទុកដាក់លើទិដ្ឋភាពផ្សេងៗ ដូចជា ទិដ្ឋភាពសង្គម ក្រមសីលធម៌ សេដ្ឋកិច្ច វប្បធម៌ ស៊ីវិល និងស្មារតី ជាដើម។

យើងត្រូវការអភិក្រមរួមសម្រាប់ការអប់រំ និងការរៀនសូត្រ ដែលអាចជំនះបាននូវការបែងចែកជាប្រពៃណីរវាងចំណេះដឹង អារម្មណ៍ និងក្រមសីលធម៌។ ការជំនះការបែងចែករវាងការរៀនសូត្រក្នុងទម្រង់ជាការស្រូបយកចំណេះដឹង និងទម្រង់ផ្សេងទៀត ត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងៗថាមានសារៈសំខាន់ចំពោះការអប់រំ។ នេះគឺជាការពិត សូម្បីតែក្នុងចំណោមអ្នកដែលផ្ដោតការយកចិត្តទុកដាក់លើការវាស់វែងលទ្ធផលនៃការរៀនសូត្រក្នុងសាលារៀន។ កាលពីពេលថ្មីៗនេះ មានការលើកស្នើឡើងនូវក្របខ័ណ្ឌវាយតម្លៃដែលមានលក្ខណៈក្ដោបរួមមួយ ដែលវាស់វែងលើសពីការរៀនសូត្រចំណេះដឹងទៅទៀត ដោយបានបញ្ចូលការរៀនសូត្រអំពីសង្គមនិងអារម្មណ៍ ឬវប្បធម៌ និងសិល្បៈថែមទៀតផង។[៥៨] បំណងប្រាថ្នាទាំងនេះបង្ហាញពីភាពចាំបាច់ ដែលគេត្រូវមើលហួសពីការរៀនសូត្រចំណេះដឹងធម្មតា បើទោះបីជានៅមានមន្ទិលសង្ស័យពីលទ្ធភាពដែលគេអាចវាស់វែងពីការរៀនសូត្រផ្នែកអារម្មណ៍ សង្គម និងក្រមសីលធម៌បែបនេះក៏ដោយ ជាពិសេស នៅថ្នាក់សកលលោក។

[៥៧] See, for example, Roberts, P. 2000. Education, Literacy, and Humanization: Exploring the work of Paulo Freire. Westport, CT and London, Bergin and Garvey.

[៥៨] See, for instance, the work of the international Learning Metrics Task Force.

## ការបកស្រាយសារជាថ្មី និងការគាំពារសសរស្តម្ភទាំង ៤ នៃការអប់រំ

ទស្សនទានមួយ ក្នុងចំណោមទស្សនទានដ៏មានឥទ្ធិពលជាងគេនៃរបាយការណ៍ Delors ឆ្នាំ ១៩៩៦ គឺទស្សនទានអំពីសសរស្តម្ភទាំង ៤ នៃការរៀនសូត្រ។ របាយការណ៍នេះលើកឡើងថា ការអប់រំក្នុងប្រព័ន្ធច្រើនតែផ្តោតការយកចិត្តទុកដាក់លើប្រភេទចំណេះដឹងមួយចំនួន ដោយមិនយកចិត្តទុកដាក់លើប្រភេទចំណេះដឹងផ្សេងទៀត ដែលមានសារៈសំខាន់ចំពោះការធានានូវចីរភាពនៃការអភិវឌ្ឍមនុស្ស។ របាយការណ៍នេះបានបញ្ជាក់ថា ក្នុងគ្រប់ការរៀនសូត្រដែលមានការរៀបចំត្រឹមត្រូវ គួរមានការផ្តោតការយកចិត្តទុកដាក់ស្មើគ្នាលើសសរស្តម្ភនីមួយៗក្នុងចំណោមសសរស្តម្ភទាំង ៤៖[៥៩]

- រៀន ដើម្បីដឹង - ចំណេះដឹងទូទៅទូលំទូលាយ អមដោយឱកាសស្វែងយល់ស៊ីជម្រៅលើមុខវិជ្ជាមួយចំនួនតូច
- រៀនដើម្បីធ្វើ-ដើម្បីទទួលបានមិនត្រឹមតែជំនាញវិជ្ជាជីវៈប៉ុណ្ណោះទេថែមទាំងសមត្ថភាពឆ្លើយតបចំពោះស្ថានភាពជាច្រើន និងធ្វើការងារជាក្រុមផងដែរ
- រៀន ដើម្បីក្លាយជាពលរដ្ឋល្អ - ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ និងអាចធ្វើសកម្មភាពដោយស្វ័យភាព ការវិនិច្ឆ័យ និងការទទួលខុសត្រូវផ្ទាល់ខ្លួនខ្ពស់ជាងមុន
- រៀន ដើម្បីរស់នៅជាមួយគ្នា - តាមរយៈការស្វែងយល់ពីអ្នកដទៃ និងផ្តល់តម្លៃដល់ការពឹងអាស្រ័យលើគ្នាទៅវិញទៅមក

ទស្សនទានស្តីពីអភិក្រមរួមសម្រាប់ការអប់រំ ដែលត្រូវបានឆ្លុះបញ្ចាំងក្នុងសសរស្តម្ភទាំង ៤ នៃការរៀនសូត្រ មានឥទ្ធិពលធំធេងលើការជជែកវែកញែកកម្រិតគោលនយោបាយការបណ្តុះបណ្តាលគ្រូ និងការអភិវឌ្ឍកម្មវិធីសិក្សាក្នុងប្រទេសជាច្រើនទូទាំងពិភពលោក។ ឧទាហរណ៍ថ្មី៖ សសរស្តម្ភទាំង ៤ ត្រូវបានប្រើប្រាស់ជាចំណុចចាប់ផ្តើមនៃកម្មវិធីសិក្សាថ្នាក់មូលដ្ឋានរបស់ Spanish Basque និងបានយកសសរស្តម្ភទាំងនេះប្រើប្រាស់ ដើម្បីអភិវឌ្ឍខ្លួនបន្ថែមទៀត។ សសរស្តម្ភទាំង ៤ នៃការរៀនសូត្រ នៅតែមានភាពពាក់ព័ន្ធជាមួយនឹង

[៥៩] Delors, J. et al. 1996. Learning: The treasure within. Paris, UNESCO.

អភិក្រមរួមនៃការអប់រំ។ លក្ខណៈទូទៅនៃសសរស្តម្ភទាំងនេះ ផ្តល់លទ្ធភាពឲ្យគេអាចធ្វើការបកស្រាយលើប្រភេទនៃការរៀនសូត្រជារួម ដែលចាំបាច់ ដើម្បីធ្វើការឆ្លើយតបចំពោះបរិបទ និងពេលវេលាផ្សេងៗគ្នា។ សសរស្តម្ភទាំងនេះក៏ប្រហែលជាត្រូវការការបកស្រាយថ្មីៗផងដែរ ក្នុងពេលដែលមានការព្រួយបារម្ភខ្លាំងឡើងៗអំពីនិរន្តរភាព។ ឧទាហរណ៍ រៀន ដើម្បីរស់នៅជាមួយគ្នា ត្រូវផ្តោតលើសពីទិដ្ឋភាពសង្គម និងវប្បធម៌ ក្នុងទំនាក់ទំនងរបស់មនុស្ស ដើម្បីបញ្ចូលការគិតគូរពីទំនាក់ទំនងរវាងសង្គមមនុស្ស ជាមួយនឹងបរិស្ថានធម្មជាតិ។

អ្វីដែលជាការព្រួយបារម្ភកាន់តែធំគឺថា សសរស្តម្ភទាំង ៤ នៃការរៀនសូត្រ កំពុងស្ថិតក្រោមការគំរាមកំហែង ក្នុងបរិបទនៃបញ្ហាប្រឈមក្នុងសង្គមបច្ចុប្បន្ន និងជាពិសេសសសរស្តម្ភ រៀន ដើម្បីក្លាយជាពលរដ្ឋល្អ និងរៀន ដើម្បីរស់នៅជាមួយគ្នា ដែលជាការឆ្លុះបញ្ចាំងល្អបំផុតអំពីមុខងារពាក់ព័ន្ធនឹងការចុះក្នុងសង្គមនៃការអប់រំ។ ការពង្រឹងគោលការណ៍ក្រមសីលធម៌ និងគុណតម្លៃ ក្នុងដំណើរការនៃការរៀនសូត្រ គឺមានសារៈសំខាន់ ដើម្បីការពារសសរស្តម្ភនៃចក្ខុវិស័យមនុស្សនិយម នៃការអប់រំទាំងនេះ។

> សសរស្តម្ភទាំង ៤ នៃការរៀនសូត្រ កំពុងស្ថិតក្រោមការគំរាមកំហែង ក្នុងបរិបទនៃបញ្ហាប្រឈមក្នុងសង្គមបច្ចុប្បន្ន និងជាពិសេសសសរស្តម្ភ រៀន ដើម្បីក្លាយជាពលរដ្ឋល្អ និងរៀន ដើម្បីរស់នៅជាមួយគ្នា។

## ការរៀនសូត្រដើម្បីរៀនចេះចំណេះដឹង និងការអភិវឌ្ឍសមត្ថភាព

បច្ចុប្បន្ននេះ មានការជជែកវែកញែកកម្រិតអន្តរជាតិជាច្រើនអំពីប្រភេទជំនាញ និងសមត្ថភាព ដែលចាំបាច់ត្រូវមាន ក្នុងបរិបទបច្ចុប្បន្ន ដែលពោរពេញទៅដោយភាពស្មុគស្មាញ និងភាពមិនប្រាកដប្រជា។ ប៉ុន្តែ និយមន័យជំនាញ និងសមត្ថភាព ដែលមានលក្ខណៈចម្រុះ និងជារឿយៗ តែងត្រួតគ្នា និងការបែងចែកប្រភេទជំនាញ និងសមត្ថភាពតាមរបៀបច្រើនយ៉ាង អាចនាំឲ្យមានការភ័ន្តច្រលំ។ បើទោះបីជាពាក្យថាជំនាញ និងសមត្ថភាព តែងត្រូវបានគេប្រើប្រាស់ជំនួសឲ្យគ្នាក៏ដោយ ពាក្យទាំងពីរនេះមានលក្ខណៈខុសគ្នា។ សមត្ថភាពមានវិសាលភាពទូលាយ។ សមត្ថភាពសំដៅលើលទ្ធភាពប្រើប្រាស់ចំណេះដឹង ដែលត្រូវបានគេយល់ដឹងក្នុងកម្រិតទូលំទូលាយថាជាក្តោបលើព័ត៌មាន ការយល់ដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ ក្នុងបរិបទជាក់លាក់ និងដើម្បីបំពេញតាមតម្រូវការនានា។

## ប្រអប់ទី ៥៖ ជំនាញមូលដ្ឋាន ជំនាញដែលអាចផ្ទេរបាន និងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ

របាយការណ៍ពិនិត្យតាមដាន ជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ២០១២ លើកស្នើនូវអភិក្រមដ៏មានប្រយោជន៍មួយ សម្រាប់ធ្វើការបែងចែកជំនាញជាប្រភេទផ្សេងៗគ្នា ពាក់ព័ន្ធជាមួយនឹងពិភពការងារ។ របាយការណ៍នេះកំណត់ពីជំនាញ ៣ ប្រភេទធំៗ ដែលមនុស្សវ័យក្មេងទាំងអស់ត្រូវការ នោះគឺ ជំនាញមូលដ្ឋាន ជំនាញដែលអាចផ្ទេរបាន និងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ និងបរិបទដែលគេអាចទទួលបានជំនាញទាំងនេះ៖

**ជំនាញមូលដ្ឋាន៖** នៅកម្រិតសំខាន់បំផុត ជំនាញមូលដ្ឋានសំដៅលើជំនាញលេខអក្សរដែលចាំបាច់ ដើម្បីបានការងារធ្វើ ដែលផ្តល់នូវប្រាក់កម្រៃគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រចាំថ្ងៃ។ មូលដ្ឋានទាំងនេះក៏ជាបុរេលក្ខខណ្ឌ សម្រាប់ទទួលបានការអប់រំ និងការបណ្តុះបណ្តាលបន្តទៀតផងដែរ ក៏ដូចជាសម្រាប់ទទួលបានជំនាញដែលអាចផ្ទេរបាន និងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ។

**ជំនាញដែលអាចផ្ទេរបាន៖** ការស្វែងរកការងារធ្វើ និងការរក្សាការងារឲ្យបានគង់វង្សត្រូវការជំនាញជាច្រើន ដែលគេអាចផ្ទេរបាន និងដែលត្រូវសម្របទៅតាមតម្រូវការ និងបរិយាកាសនៅកន្លែងធ្វើការផ្សេងៗ។ជំនាញដែលអាចផ្ទេរបានរួមមានការវិភាគបញ្ហានិងការស្វែងរកដំណោះស្រាយសមស្រប ការបង្ហាញពីគំនិតនិងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការមានភាពច្នៃប្រឌិត ការបង្ហាញពីភាពជាអ្នកដឹកនាំ និងសតិសម្បជញ្ញៈ និងការបង្ហាញពីសមត្ថភាពសហគ្រិនភាព។ ជំនាញទាំងនេះត្រូវបានរៀនចេះ ក្នុងកម្រិតមួយ នៅខាងក្រៅសាលារៀន។ ប៉ុន្តែ ជំនាញទាំងនេះក៏អាចអភិវឌ្ឍបន្ថែម តាមរយៈការអប់រំ និងការបណ្តុះបណ្តាលផងដែរ។

**ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ៖** កាងារជាច្រើនត្រូវការចំណេះធ្វើបច្ចេកទេសជាក់លាក់មិនថាពាក់ព័ន្ធជាមួយនឹងការដាំបន្លែ ការប្រើម៉ាស៊ីនដេរ ការរៀបឥដ្ឋឬការងារជាងឈើ ឬការធ្វើការជាមួយនឹងកុំព្យូទ័រ ក្នុងការិយាល័យនោះទេ។ គេអាចទទួលបានជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈកម្មវិធីផ្តល់ការងារដែលផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងការអប់រំកម្រិតមធ្យមសិក្សា និងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈក្នុងប្រព័ន្ធ ឬតាមរយៈការបណ្តុះបណ្តាលនៅកន្លែងធ្វើការ ដូចជា ការធ្វើជាកូនជាង និងតាមសហករណ៍កសិកម្មជាដើម។

ប្រភព៖ UNESCO. 2012. *Youth and Skills: Putting education to work. EFA Global Monitoring Report 2012*. Paris, UNESCO.

ការផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់នៃ "ជំនាញទន់" "ជំនាញដែលអាចផ្ទេរបាន" "ជំនាញមិនពាក់ព័ន្ធនឹងការរៀនចេះចំណេះដឹង" ឬ "ជំនាញសតវត្សរ៍ទី ២១" បានផ្តល់នូវភាពសម្បូរបែបបន្ថែមទៀតដល់ការគិតពិចារណាបច្ចុប្បន្នអំពីខ្លឹមសារអប់រំ និងវិធីសាស្ត្រផ្តល់ការអប់រំ។ ហេតុផលដែលនាំឲ្យមានការផ្តោតការយកចិត្តទុកដាក់លើជំនាញទាំងនេះ គឺដោយសារតែភាពច្នៃប្រឌិត និងសហគ្រិនភាព គឺជាអ្វីដែលចាំបាច់ សម្រាប់បង្កើនភាពប្រកួតប្រជែង។ បើទោះបីជាហេតុផលបែបនេះមានសារៈសំខាន់ សម្រាប់មុខងារសេដ្ឋកិច្ចរបស់ការអប់រំក៏ដោយ វាមិនត្រូវបាំងលុបភាពចាំបាច់ ដើម្បីអភិវឌ្ឍសមត្ថភាពដែលមនុស្ស និងសហគមន៍ត្រូវការ ដើម្បីបំពេញតម្រូវការផ្សេងៗនៃអត្ថិភាពរបស់មនុស្សឡើយ ពោលគឺសមត្ថភាពដែលរួមចំណែកចំពោះការបំពេញមុខងារទាំងពីរ។ សមត្ថភាពបង្កើនលទ្ធភាពប្រើប្រាស់ចំណេះដឹង (ដូចជា ព័ត៌មាន ការយល់ដឹង ជំនាញ និងគុណតម្លៃ) សមស្របប្រកបដោយភាពច្នៃប្រឌិតនិងការទទួលខុសត្រូវក្នុងស្ថានភាពណាមួយដើម្បីស្វែងរកដំណោះស្រាយ និងបង្កើតទំនាក់ទំនងថ្មីៗជាមួយអ្នកដទៃ។

ចំណេះដឹង ដែលចាំបាច់ត្រូវមាន មិនត្រូវបានកំណត់ដោយអាជ្ញាធរកណ្តាលឡើយ ប៉ុន្តែត្រូវបានកំណត់តាមរយៈសាលារៀន គ្រូ និងសហគមន៍។ វាគឺជាចំណេះដឹង ដែលមិនគ្រាន់តែត្រូវបានគេបញ្ជូនប៉ុណ្ណោះទេ ប៉ុន្តែជាចំណេះដឹងដែលគេត្រូវស្វែងយល់ ស្រាវជ្រាវ ពិសោធន៍ជាមួយ និងបង្កើតឡើង ទៅតាមតម្រូវការរបស់មនុស្ស។ វាគឺជាចំណេះដឹង ដែលគេប្រើប្រាស់សម្រាប់អភិវឌ្ឍបំណិនភាសា និងប្រាស្រ័យទាក់ទងកម្រិតមូលដ្ឋាន, សម្រាប់ដោះស្រាយបញ្ហា និងសម្រាប់អភិវឌ្ឍជំនាញកម្រិតខ្ពស់ៗ ដូចជា ការគិតបែបតក្កៈ ការវិភាគ ការសំយោគ ការទាញជាសេចក្តីសន្និដ្ឋានបែបអនុមាណញែក អនុមាណរួម និងការគិតផ្អែកលើសម្មតិកម្ម។ វាជាចំណេះដឹង ដែលបណ្តុះជំនាញ ដែលប្រហែលជាជំនាញសំខាន់ជាងគេបំផុត ក្នុងចំណោមជំនាញទាំងអស់ នោះគឺសមត្ថភាពទទួលបាន និងវិភាគល្អិតល្អន់លើព័ត៌មាននានា។ ការរៀនដើម្បីចេះរៀន មិនដែលសំខាន់ ដូចបច្ចុប្បន្ននេះឡើយ។

ការរៀនដើម្បីចេះរៀន មិនដែលសំខាន់ ដូចបច្ចុប្បន្ននេះឡើយ។

បរិមាណព័ត៌មាន ដែលអាចរកបាននាពេលបច្ចុប្បន្ន លើប្រព័ន្ធអេឡិចត្រូនិច គឺមានទំហំធំធេង។ បញ្ហាប្រឈមគឺថាតើត្រូវបង្រៀនអ្នករៀនសូត្រដោយរបៀបណា ដើម្បីឲ្យពួកគេយល់ពីព័ត៌មានដែលពួកគេទទួលបានក្នុងបរិមាណជាច្រើនដែលពួកគេជួបប្រទះជា

រៀងរាល់ថ្ងៃ ចេះសម្គាល់ប្រភពដែលអាចជឿទុកចិត្តបាន វាយតម្លៃលើភាពអាចជឿទុកចិត្តបាន និងសុពលភាពនៃអ្វីដែលពួកគេអាន ស្ទួរដេញដោលពីភាពពិតប្រាកដ និងសុក្រិតភាពនៃព័ត៌មាន ភ្ជាប់ទំនាក់ទំនងរវាងចំណេះដឹងថ្មីនេះជាមួយនឹងការរៀនសូត្រកន្លងមក និងវិនិច្ឆ័យពីសារៈសំខាន់នៃព័ត៌មាននេះធៀបជាមួយនឹងអ្វីដែលពួកគេយល់ដឹងកន្លងមក។[៦០]

## ការគិតពិចារណាឡើងវិញពីការអភិវឌ្ឍកម្មវិធីសិក្សា

ចេញពីទស្សនៈវិស័យនៃការតាក់តែងគោលនយោបាយ និងខ្លឹមសារគោលនយោបាយ តើកម្មវិធីសិក្សាបែបមនុស្សនិយមគួរមានលក្ខណៈបែបណា? ពាក់ព័ន្ធជាមួយនឹងខ្លឹមសារនៃការរៀនសូត្រ និងវិធីសាស្ត្រនៃការរៀនសូត្រ កម្មវិធីសិក្សាបែបមនុស្សនិយម គឺជាប្រភេទកម្មវិធីសិក្សាមួយបែប ដែលលើកជាសំណួរ ច្រើនជាងផ្តល់ចម្លើយ។ កម្មវិធីសិក្សាបែបនេះលើកកម្ពស់ការគោរពភាពចម្រុះ និងបដិសេធរាល់ទម្រង់ទាំងអស់នៃការបែងចែកវប្បធម៌ ផ្នត់គំនិត និងភាពលំអៀង។ វាគឺជាកម្មវិធីសិក្សា ដែលមានមូលដ្ឋានលើការអប់រំអន្តរវប្បធម៌ ដែលធ្វើឲ្យមានភាពចម្រុះក្នុងសង្គម ហើយក្នុងពេលជាមួយគ្នា ធានាបាននូវតុល្យភាពរវាងភាពចម្រុះបែបនេះ និងគុណតម្លៃជាសកល។ ពាក់ព័ន្ធនឹងគោលនយោបាយវិញ យើងត្រូវរំឮកឡើងវិញថា ក្របខ័ណ្ឌកម្មវិធីសិក្សា គឺជាឧបករណ៍ ដែលភ្ជាប់ទំនាក់ទំនងគោលដៅនៃការអប់រំជាមួយនឹងដំណើរការ ដើម្បីសម្រេចគោលដៅទាំងនេះ។ ដើម្បីឲ្យក្របខ័ណ្ឌកម្មវិធីសិក្សាមួយមានលក្ខណៈសមស្រប ដំណើរការពិគ្រោះយោបល់គោលនយោបាយ ដើម្បីកំណត់ពីគោលដៅនៃការអប់រំ ត្រូវតែមានការចូលរួម និងមានលក្ខណៈបរិយាប័ន្ន។[៦១] គោលនយោបាយ និងខ្លឹមសាររបស់កម្មវិធីសិក្សា ត្រូវតែតម្រង់ទិសដោយគោលការណ៍យុត្តិធម៌សង្គម និងសេដ្ឋកិច្ចសមភាព និងការទទួលខុសត្រូវផ្នែកបរិស្ថាន ដែលជាសសរស្តម្ភនៃការអភិវឌ្ឍប្រកបដោយចីរភាព។

[៦០] Facer, K. 2011. Learning Futures: Education, Technology and Social Challenges. New York, Routledge.

[៦១] Amadio, M., Opertti, R., Tedesco, J.C. 2014. Curriculum in the Twenty-First Century: Challenges, Tensions and Open Questions. ERF Working Papers, No. 9. Paris, UNESCO. See also: International Bureau of Education UNESCO. 2013. The Curriculum Debate: Why It Is Important Today. IBE Working Papers on Curriculum Issues No. 10. Geneva, IBE UNESCO.

## ■ ការធានាយ៉ាងណាឲ្យការអប់រំកាន់តែមានបរិយាប័ន្ន

### មានការសម្រេចបានវឌ្ឍនភាពខ្លះ ប៉ុន្តែវិសមភាពនៅតែមានក្នុងការអប់រំកម្រិតមូលដ្ឋាន

យើងបានសម្រេចនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ជាច្រើន ក្នុងការសម្រេចនូវសិទ្ធិទទួលបានការអប់រំកម្រិតមូលដ្ឋាន ចាប់តាំងពីឆ្នាំ ២០០០ មក ដែលមួយផ្នែកដោយសារមានការជម្រុញពីក្របខ័ណ្ឌអប់រំសម្រាប់ទាំងអស់គ្នា (EFA) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ វឌ្ឍនភាពនេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈការកើនឡើងនូវអត្រាចុះឈ្មោះចូលរៀន ការថយចុះនូវចំនួនកុមារបោះបង់ចោលការសិក្សា ការកើនឡើងនូវអត្រាអក្ខរកម្ម ជាពិសេស ក្នុងចំណោមយុវជន និងការកាត់បន្ថយគម្លាតយេនឌ័រ ក្នុងការចូលរៀន និងអក្ខរកម្មមនុស្សពេញវ័យ ទូទាំងពិភពលោក។

បើទោះបីជាមានការសម្រេចនូវវឌ្ឍនភាពនេះក៏ដោយ ការសន្យា ដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍អន្តរជាតិបានផ្តល់ជាយូរមកហើយ ចាប់តាំងពីឆ្នាំ ១៩៩០ មក ថា "នឹងបំពេញតម្រូវការនៃការរៀនសូត្រជាមូលដ្ឋានរបស់កុមារ យុវជន និងមនុស្សពេញវ័យទាំងអស់" មិនត្រូវបានគេគោរពតាមឡើយ។ មានកុមារជិត ៦០ លាននាក់ និងក្មេងជំទង់ ៧០ លាននាក់ ទូទាំងពិភពលោក នៅមិនទាន់បានទទួលការអប់រំកម្រិតមូលដ្ឋានប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ក្នុងឆ្នាំ ២០១១ មានមនុស្សពេញវ័យជិត ៧៧៥ លាននាក់ នៅត្រូវបានគេចាត់ទុកថាមានកម្រិតអក្ខរកម្មមិនគ្រប់គ្រាន់នៅឡើយ។ សូម្បីតែសម្រាប់អ្នកដែលបានទទួលការអប់រំកម្រិតមូលដ្ឋានក្នុងប្រព័ន្ធក៏ដោយ ការរៀនមិនបានចប់ចុងចប់ដើម និងការអប់រំដែលមានគុណភាពទាប ជាកត្តារួមចំណែកធ្វើឲ្យការទទួលបានជំនាញថ្នាក់មូលដ្ឋានមិនបានគ្រប់គ្រាន់ ដូច្នេះគុណភាពនៃការអប់រំ និងការឆ្លើយតបនៃការរៀនសូត្រ នៅតែជាក្តីបារម្ភធំ។ យ៉ាងហោចណាស់មានកុមារចំនួន ២៥០ លាននាក់ ដែលនៅមិនទាន់ចេះអាន សរសេរ ឬរាប់លេខស្ទាត់ជំនាញនៅឡើយ សូម្បីតែក្រោយពេលដែលពួកគេរៀនបានយ៉ាងហោចណាស់ ៤ ឆ្នាំ ក្នុងសាលារៀនក៏ដោយ។[៦២]

---

៦២ UNESCO. 2014. Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014. Paris, UNESCO.

លើសពីនេះ វិសមភាពដែលនៅមានក្នុងកម្រិតគួរឲ្យកត់សម្គាល់នៅឡើយរវាងប្រទេសមួយ និងប្រទេសមួយ នៅតែបន្តមានទៀត ហើយអត្រាមធ្យមនៅថ្នាក់ជាតិ នៅតាមប្រទេសជាច្រើន លាក់កំបាំងមិនឲ្យគេមើលឃើញពីវិសមភាពរវាងក្រុមមួយ និងក្រុមមួយទៀត ក្នុងប្រទេសតែមួយ ពាក់ព័ន្ធនឹងការទទួលបានការអប់រំ និងលទ្ធផលនៃការអប់រំកម្រិតមូលដ្ឋាន។[៦៣] កត្តាជាប្រពៃណី ដែលនាំឲ្យក្រុមមួយចំនួនបាត់បង់ឱកាសទទួលបានការអប់រំ ដូចជា យេនឌ័រ និងកន្លែងរស់នៅក្នុងទីប្រជុំជន ឬជនបទ នៅតែបន្តផ្សំកម្លាំងជាមួយនឹងកត្តាផ្សេងទៀត ដូចជា ប្រាក់ចំណូល ភាសា ស្ថានភាពជាជនជាតិភាគតិច និងពិការភាពជាដើម ដើម្បីបង្កើតនូវ “ភាពចាញ់ប្រៀបដែលពង្រឹងគ្នាទៅវិញទៅមក” ជាពិសេស សម្រាប់ប្រទេសដែលមានចំណូលទាប ឬប្រទេសដែលរងផលប៉ះពាល់ដោយសារជម្លោះ។[៦៤]

[៦៣] ដកស្រង់ចេញពីកិច្ចព្រមព្រៀង Muscat (ឆ្នាំ ២០១៤) ដែលយោងលើទិន្នន័យក្នុងរបាយការណ៍ GMR។ មានកុមារជាង ៥៧ លាននាក់ និងក្មេងជំទង់ ៦៩ លាននាក់ ដែលនៅមិនទាន់បានទទួលការអប់រំកម្រិតមូលដ្ឋានប្រកបដោយគុណភាព។ ក្នុងឆ្នាំ ២០១១ មានមនុស្សពេញវ័យប្រមាណជា ៧៧៤ លាននាក់ មិនចេះអក្សរ។

[៦៤] UNESCO. 2011. The hidden crisis: Armed conflict and education. EFA Global Monitoring Report 2011. Paris, UNESCO.

## ប្រអប់ទី ៦៖ កុមារពិការតែងត្រូវបានគេមើលរំលង

ជារឿយៗ សិទ្ធិទទួលបានការអប់រំ ត្រូវបានគេបដិសេធមិនផ្តល់ដល់កុមារពិការ។ ប៉ុន្តែ គេដឹងតិចតួចប៉ុណ្ណោះពីនិន្នាការនៃការចូលរៀនតាមសាលារៀនរបស់ពួកគេ។ ការប្រមូលទិន្នន័យអំពីកុមារពិការ មិនមែនជារឿងដែលងាយស្រួលឡើយ ប៉ុន្តែទិន្នន័យបែបនេះមានសារៈសំខាន់ ដើម្បីធានាយ៉ាងណាឲ្យមានការដាក់ចេញគោលនយោបាយ ដើម្បីឆ្លើយតបចំពោះឧបសគ្គនានា ដែលកុមារទាំងនេះជួបប្រទះ។

បើតាមការប៉ាន់ប្រមាណមួយ ក្នុងឆ្នាំ ២០០៤ មានកុមារអាយុក្រោម ១៤ ឆ្នាំចំនួន ៩៣ លាននាក់ ឬស្មើនឹង ៥,១% នៃកុមារក្នុងពិភពលោកទាំងមូល កំពុងរស់នៅជាមួយនឹង "ពិការភាពកម្រិតមធ្យមឬកម្រិតធ្ងន់ធ្ងរ។បើតាមការអង្កេតសុខភាពពិភពលោកក្នុងប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ១៤ ក្នុងចំណោម ១៥ ប្រទេស មានជនពិការដល់វ័យធ្វើការងារតិចជាងមួយភាគបីប៉ុណ្ណោះ ដែលបានរៀនចប់បឋមសិក្សា។ ឧទាហរណ៍ ក្នុងប្រទេសបង់ក្លាដេសជនពិការ៣០%បានរៀនចប់បឋមសិក្សាបើធៀបជាមួយនឹងតួលេខ ៤៨% សម្រាប់អ្នកមិនពិការ។ ភាគរយបែបនេះគឺ ៤៣% និង ៥៧% ក្នុងប្រទេសហ្សាំប៊ៀ, ៥៦% និង ៧២% ក្នុងប្រទេសប៉ារ៉ាហ្គាយ។

មានការបង្ហាញថា កុមារដែលប្រឈមហានិភ័យខ្ពស់ទៅនឹងពិការភាព ច្រើនតែពុំមានឱកាសទៅរៀនដូចកុមារផ្សេងទៀត។ ក្នុងប្រទេសបង់ក្លាដេស ប៊ូតាន និងអ៊ីរ៉ាក់ កុមារដែលមានបញ្ហាខ្សោយ មិនត្រូវបានគេផ្តល់សិទ្ធិនេះច្រើនជាងគេ។ ឧទាហរណ៍ ក្នុងប្រទេសអ៊ីរ៉ាក់ ១០% នៃកុមារអាយុពី ៦ ដល់ ៩ ឆ្នាំ ដែលមិនពិការ មិនធ្លាប់បានចូលរៀនសោះ ក្នុងឆ្នាំ ២០០៦ ប៉ុន្តែសម្រាប់កុមារដែលមានកម្សោយខាងការស្តាប់វិញ ភាគរយនេះមានដល់ទៅ ១៩% និងមានកុមារដែលពិការបញ្ញាធ្ងន់ធ្ងរ ៥១% ដែលមិនបានចូលរៀនសោះ។ ក្នុងប្រទេសថៃវិញ កុមារមិនពិការអាយុ ៦ ដល់ ៩ ឆ្នាំស្ទើរតែទាំងអស់ បានចូលរៀន ក្នុងឆ្នាំសិក្សា ២០០៥/០៦ ប៉ុន្តែមានកុមារដែលពិបាកដើរ ឬផ្លាស់ទីរហូតដល់ ៣៤% ដែលមិនធ្លាប់បានចូលរៀន។

ប្រភព៖ UNESCO. 2014. *Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014*: Paris, UNESCO.

## សមភាពយេនឌ័រ ក្នុងការអប់រំកម្រិតមូលដ្ឋាន

សមភាពយេនឌ័រក្នុងការអប់រំ កើតឡើងទន្ទឹមគ្នានឹងយុគភាពយេនឌ័រ នៅកម្រិតផ្សេងៗនៃការអប់រំក្នុងប្រព័ន្ធ។ យេនឌ័រគឺជាកត្តាជាប្រពៃណីមួយ ដែលនាំឲ្យមានវិសមភាព និងអយុតភាព ក្នុងការអប់រំ ដោយក្នុងករណីភាគច្រើន ក្មេងស្រី និងស្ត្រីជាអ្នកចាញ់ប្រៀប។ ទោះជាយ៉ាងណាក៏ដោយ យើងបានកត់សម្គាល់ឃើញថាមានការសម្រេចបាននូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ក្នុងការកាត់បន្ថយគម្លាតយេនឌ័រទូទាំងពិភពលោក ចាប់តាំងពីឆ្នាំ ២០០០ មក ដោយមានក្មេងស្រី និងស្ត្រីកាន់ច្រើននាក់អាចទទួលបានការអប់រំក្នុងប្រព័ន្ធនៅកម្រិតផ្សេងៗ។ ជាការពិត មានការសម្រេចយុគភាពយេនឌ័រ ក្នុងការអប់រំកម្រិតបឋមសិក្សា នៅអឺរ៉ុបកណ្តាល និងបូព៌ា អាស៊ីកណ្តាល អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច អាមេរិចឡាទីន និងការីបៀន អាមេរិចខាងជើង និងអឺរ៉ុបខាងលិច។ លើសពីនេះ ចាប់តាំងពីឆ្នាំ ២០០០ មក មានការសម្រេចបាននូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ជាច្រើន ក្នុងការកាត់បន្ថយគម្លាតយេនឌ័រ ជាពិសេស នៅអាស៊ីខាងត្បូង និងខាងលិច និងមានការសម្រេចវឌ្ឍនភាពដែរ ប៉ុន្តែក្នុងកម្រិតមួយទាបជាង នៅអាហ្វ្រិចសាប់សាហារ៉ា និងរដ្ឋអារ៉ាប់។ ប៉ុន្តែ បើទោះបីជាមានការសម្រេចនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់យ៉ាងណាក៏ដោយ កុមារក្រៅសាលាភាគច្រើននៅតែជាក្មេងស្រី ហើយពីរភាគបីនៃយុវជន និងមនុស្សពេញវ័យ ដែលមានកម្រិតអក្ខរកម្មទាប ក្នុងពិភពលោក គឺជាស្ត្រី។ ដើម្បីជួយផ្តល់ភាពអង់អាចដល់ស្ត្រី ត្រូវមានការជម្រុញឲ្យមានការចូលរួមពីក្មេងប្រុស និងបុរសក្នុងការប្រយុទ្ធប្រឆាំងនឹងវិសមភាពយេនឌ័រ។ ការងារនេះត្រូវចាប់ផ្តើមជាមួយនឹងការអប់រំកម្រិតមូលដ្ឋានទៅ។

---

**ប្រអប់ទី ៧៖ ស្តាប់សម្លេងរបស់ក្មេងស្រីដែលពុំបានទទួលសេវាអប់រំ**

ការអប់រំ គឺជាពរជ័យមួយក្នុងជីវិត ហើយវាក៏ជាអ្វីដែលចាំបាច់ សម្រាប់ជីវិតផងដែរ។

ថ្ងៃនេះ ... ខ្ញុំមិនមែនជាសម្លេងតែមួយនោះទេ ខ្ញុំគឺជាសម្លេងជាច្រើន។

ខ្ញុំគឺជាក្មេងស្រី ៦៦ លាននាក់ ដែលមិនបានទទួលការអប់រំ។

ហើយថ្ងៃនេះ ខ្ញុំមិនមែននិយាយតែសម្រាប់ខ្លួនខ្ញុំនោះទេ។ វាគឺជាសម្លេងរបស់ក្មេងស្រីទាំង ៦៦ លាន នាក់។

សន្ទរកថាទទួលយកពានរង្វាន់ណូបែលរបស់ Malala Yousafzai ទីក្រុងអូស្លូ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤

---

## យុគភាពយេនឌ័រ ក្នុងការអប់រំមធ្យមសិក្សា និងឧត្តមសិក្សា

ក្នុងការអប់រំកម្រិតមធ្យមសិក្សា មានការសម្រេចគោលដៅសមភាពយេនឌ័រ ក្នុងតំបន់ជាច្រើន ដូចជា អាស៊ីភាគកណ្តាល អាស៊ីបូព៌ា អាមេរិចឡាទីននិងការីបៀន ក៏ដូចជាអាមេរិចខាងជើង និងអាមេរិចខាងលិច។ ក្នុងតំបន់ផ្សេងទៀត គម្លាតយេនឌ័រត្រូវបានកាត់បន្ថយជាពិសេស នៅអាស៊ីភាគខាងត្បូងនិងខាងលិចជាដើម និងក្នុងរដ្ឋអារ៉ាប់ផងដែរ ប៉ុន្តែក្នុងកម្រិតមួយតិចតួចជាង។ គម្លាតយេនឌ័រ ក្នុងការចូលរៀននៅកម្រិតមធ្យមសិក្សា ត្រូវបានស្តែងចេញយ៉ាងច្បាស់ នៅអាហ្រ្វិចសាប់សាហារ៉ា អាស៊ីខាងលិច និងអាស៊ីខាងត្បូង ដែលអត្រាចុះឈ្មោះចូលរៀនជាមធ្យម មានកម្រិតទាបបំផុត។ ប៉ុន្តែ ពាក់ព័ន្ធជាមួយនឹងការអប់រំឧត្តមសិក្សាវិញ ភាគរយនៃស្ត្រី ដែលរៀនតាមសកលវិទ្យាល័យនៅអាហ្រ្វិចសាប់សាហារ៉ា នៅមានកម្រិតទាបនៅឡើយ ហើយគោលដៅយុគភាពយេនឌ័រ សម្រាប់ការអប់រំកម្រិតឧត្តមសិក្សា នៅតែជាបញ្ហាប្រឈមដ៏សំខាន់មួយ។ ក្រៅពីតំបន់ទាំងនេះ មានការសង្កេតឃើញថា មានការសម្រេចបាននូវវឌ្ឍនភាពក្នុងតំបន់ភាគច្រើន ជាពិសេស នៅក្នុងរដ្ឋអារ៉ាប់ អាស៊ីបូព៌ានិងប៉ាស៊ីហ្វិច និងអាស៊ីភាគខាងត្បូងនិងខាងលិច។ នៅតាមតំបន់មួយចំនួន ដូចជា អឺរ៉ុបកណ្តាលនិងបូព៌ា ការីបៀនអាមេរិចខាងជើង ប៉ាស៊ីហ្វិច និងអឺរ៉ុបភាគខាងលិចជាដើម ភាគរយនៃស្ត្រី ដែលទទួលបានការអប់រំកម្រិតឧត្តមសិក្សា មានកម្រិតខ្ពស់ជាងភាគរយរបស់បុរសទៅទៀត។ វឌ្ឍនភាពនេះ គឺមិនមែនដោយសារការកើនឡើងឆាប់រហ័សនៃការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅកម្រិតមធ្យមសិក្សាប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែក្មេងប្រុសមានលទ្ធផលអប់រំទាប និងអត្រាបញ្ចប់ការសិក្សាទាប នៅកម្រិតមធ្យមសិក្សា ដែលនិន្នាការនេះត្រូវបានសង្កេតឃើញថាកើតមាន នៅតាមតំបន់ជាច្រើន។ និន្នាការ ដែលក្មេងប្រុសមានអត្រាបោះបង់ចោលការសិក្សាខ្ពស់នៅមធ្យមសិក្សា ក្នុងតំបន់មួយចំនួនក្នុងពិភពលោក ដូចជា តំបន់ការីបៀន និងអាមេរិចឡាទីន ជាដើម ក៏ជាការព្រួយបារម្ភមួយផងដែរ ដោយសារតែវាដាក់បន្ទុកបន្ថែមទៀតដល់ភាពសុខដុមរមនាក្នុងសង្គម។

## ការអប់រំ គឺជាកត្តាដែលមានសក្តានុពលនាំមកនូវសមភាព

ជារឿយៗ ការអប់រំនាំឲ្យមានវិសមភាព ឬបង្កើនទំហំវិសមភាព ប៉ុន្តែការអប់រំក៏អាចធ្វើឲ្យមានសមភាពផងដែរ។ ដំណើរការអប់រំបរិយាប័ន្ន នៅគ្រប់កម្រិតទាំងអស់ មានសារៈសំខាន់ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយសមធម៌។

**ការអប់រំកុមារតូច៖** នៅកម្រិតអប់រំកុមារតូច យើងកត់សម្គាល់ឃើញមានការទទួលស្គាល់កាន់តែខ្លាំងជាងមុនពីសារៈសំខាន់នៃអន្តរាគមន៍ទាន់ពេលវេលាសម្រាប់កុមារតូច ដើម្បីលើកកម្ពស់ឱកាសរៀនសូត្រ និងឱកាសផ្សេងទៀតក្នុងជីវិតរបស់ពួកគេនាពេលអនាគត។ លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា អន្តរាគមន៍ទាន់ពេលវេលា សម្រាប់កុមារតូច មានសារៈសំខាន់ មិនត្រឹមតែសម្រាប់សុខុមាលភាពផ្ទាល់ខ្លួនរបស់កុមារប៉ុណ្ណោះទេ។ អន្តរាគមន៍បែបនេះមានឥទ្ធិពលរយៈពេលវែង ប្រកបដោយនិរន្តរភាពលើការអភិវឌ្ឍធនធានមនុស្ស ភាពសុខដុមរមនាក្នុងសង្គម និងជោគជ័យក្នុងសេដ្ឋកិច្ច។ ភស្តុតាងនានាបង្ហាញថា កុមារជួបការលំបាកបំផុត ដោយសារភាពក្រីក្រ ជាតិពន្ធ ភាសារបស់ពួកគេជាភាសាភាគតិច ការរើសអើងយេនឌ័រ ការរស់នៅតំបន់ដាច់ស្រយាល ពិការភាព អំពើហិង្សា មេរោគ/ជំងឺអេដស៍ អាចទទួលបានប្រយោជន៍ច្រើនជាងគេពីកម្មវិធីអភិវឌ្ឍន៍កុមារតូច ដែលមានគុណភាពល្អ៖ ទោះជាយ៉ាងណាក៏ដោយ កុមារក្នុងក្រុមនេះ គឺជាកុមារដែលមានលទ្ធភាពចូលរួមក្នុងកម្មវិធីបែបនេះបានតិចតួចជាងគេ។[៦៥] ការពិនិត្យឡើងវិញក្នុងទ្រង់ទ្រាយធំលើអន្តរាគមន៍សម្រាប់កុមារតូច បានរកឃើញនូវមូលហេតុមួយ ដែលនាំឲ្យអន្តរាគមន៍ទាំងនេះមានប្រសិទ្ធភាព៖ នៅពេលដែលកុមារអាយុកាន់តែច្រើន ការងាកចេញពីមាគ៌ាអភិវឌ្ឍន៍ធម្មតា និងភាពយឺតយ៉ាវនៃការអភិវឌ្ឍ នឹងកាន់តែធំទៅ។ ឥឡូវនេះ មានការយល់យ៉ាងច្បាស់ថា ការចាប់ផ្តើមអន្តរាគមន៍ទាន់ពេលវេលាត្រូវធនធាន និងកិច្ចខិតខំប្រឹងប្រែងតិច ប៉ុន្តែក្នុងពេលជាមួយគ្នា វាជាអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់។

អន្តរាគមន៍ទាំងនេះកាន់តែផ្តល់ប្រយោជន៍ខ្ពស់ថែមទៀត សម្រាប់កុមារពិការ និងកុមារដែលមានតម្រូវការពិសេស ដូចជា កុមារដែលមានបញ្ហាអូទីសឹម ឬអាស្ពើជើស៊ីនដ្រូម ជាដើម។[៦៦]

---

[៦៥] Global Child Development Group. 2011. Child Development Lancet Series: Executive Summary. www.globalchilddevelopment.org [Accessed February 2015].

[៦៦] Baron-Cohen, S. 2008. The Facts: Autism and Asperger Syndrome. Oxford, UK, Oxford University Press.

### ប្រអប់ទី ៨៖ ប្រទេសសេណេហ្គាល់៖ បទពិសោធន៍ “Case des Tout-Petits”

ស្ថានភាពសុខភាព និងសង្គមរបស់កុមារ ក្នុងប្រទេសសេណេហ្គាល់ នៅមិនទាន់មានភាពល្អប្រសើរហើយបើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយកិច្ចការពារកុមារនៅតែជាការព្រួយបារម្ភចម្បងមួយ។ ជាប្រតិកម្មតបចំពោះស្ថានភាពនេះ ឥឡូវនេះអាជ្ញាធរជាតិរបស់សេណេហ្គាល់ បានចាត់ទុកការគាំពារកុមារតូចគឺជាអាទិភាពមួយ សម្រាប់ការអភិវឌ្ឍ។ ចាប់តាំងពីឆ្នាំ ២០០២ មក “Case des Tout-Petits” ដែលជាគំរូមួយនៃការអភិវឌ្ឍកុមារតូច ត្រូវបានដាក់ឲ្យអនុវត្ត អមជាមួយនឹងរចនាសម្ព័ន្ធនៃការអប់រំមត្តេយ្យសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅផ្លូវការ។ ខណៈពេលដែលនៅមានចំណុចដែលត្រូវកែលំអបន្ថែមក៏ដោយ កម្មវិធីនេះផ្តល់នូវបទពិសោធន៍ក្នុងសហគមន៍ដ៏មានតម្លៃ ផ្អែកតាមប្រពៃណីវប្បធម៌របស់មូលដ្ឋាន។

“Case des Tout-Petits” គឺជាអគារក្នុងសហគមន៍ សម្រាប់ផ្តល់ការគាំទ្រដល់កុមារអាយុពី 0 ដល់ ៦ ឆ្នាំ។ Case ឬមានន័យថាផ្ទះបែបប្រពៃណី សំដៅលើរបៀបរស់នៅ និងគិតពិចារណា និងជាការគូសបញ្ជាក់ពីការប្តេជ្ញាចិត្តគោរពតាមគុណតម្លៃរបស់អាហ្វ្រិច។ Case គឺជាកន្លែងរស់នៅ ចុះក្នុងសង្គម និងផ្តល់ការអប់រំល្អបំផុត ដែលជាចំណុចចាប់ផ្តើមនៃការរៀនសូត្រក្នុងជីវិតរបស់កុមារ។

Cases ទាំងនេះត្រូវបានរៀបចំឡើង សម្រាប់កុមារជួបការលំបាក រស់នៅតាមជនបទដើម្បីធានាឲ្យពួកគេអាចទទួលបានសេវាគ្រប់បែបយ៉ាងឲ្យបានគ្រប់គ្រាន់។ Cases ទាំងនេះត្រូវបានដំណើរការដោយប្រជាពលរដ្ឋផ្ទាល់ និងតំណាងឲ្យ ២០% នៃអគារដែលប្រើប្រាស់សម្រាប់អប់រំកុមារតូចក្នុងប្រទេសសេណេហ្គាល់។ “Case des Tout-Petits” គឺជាអគារដែលមាន ២ បន្ទប់ ក្នុងនោះមួយបន្ទប់ប្រើប្រាស់សម្រាប់សកម្មភាពអប់រំរបស់កុមារ និងមួយបន្ទប់ទៀតប្រើប្រាស់សម្រាប់អប់រំឪពុកម្តាយ។ អគារទាំងនេះផ្តល់នូវសេវាគាំពារកុមារតូចគ្រប់បែបយ៉ាង ដូចជា អប់រំ សុខភាព និងអាហារូបត្ថម្ភជាដើម។

ខណៈពេលដែលកុមារចូលរៀននៅទីនេះមិនមែនដោយមិនគិតថ្លៃ ថ្លៃសេវាមានកម្រិតទាបជាងគ្រឹះស្ថានអប់រំកុមារតូចផ្សេងទៀតក្នុងប្រព័ន្ធ។ ការរួមភាគទានផ្នែកហិរញ្ញវត្ថុធ្វើឡើងជានិមិត្តរូបប៉ុណ្ណោះ និងផ្តល់លទ្ធភាពឲ្យគ្រួសារអាចផ្តួបកម្លាំងគ្នាជុំវិញអគាររួមនេះ ដែលជារបស់សហគមន៍ទាំងមូល និងជាអ្វីដែលសហគមន៍ត្រូវរក្សាការពារ៖

ប្រភព៖ ដកស្រង់ចេញពី Turpin Bassama, S., 2010. La case des tout-petits au Sénégal. Revue Internationale d’éducation de Sèvres. No. 53-2010, pp. 65–75.

**ការអប់រំមធ្យមសិក្សា៖** វាក៏អាចដូចគ្នា សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាផងដែរ។ ការពង្រីកលទ្ធភាពទទួលបានសេវាអប់រំកម្រិតមូលដ្ឋាននៅទូទាំងពិភពលោក បានបង្កើនតម្រូវការការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា និងការព្រួយបារម្ភអំពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ជាពិសេស ក្នុងបរិបទនៃការកើនឡើងនូវភាពគ្មានការងារធ្វើរបស់យុវជន និងដំណើរការនៃការបញ្ជាក់គុណវុឌ្ឍិ និងការបញ្ជាក់គុណវឌ្ឍិសារជាថ្មី។ ឧទាហរណ៍ ក្នុងប្រទេសមួយចំនួន នៅអាមេរិចឡាទីន និងតំបន់ការីបៀន ការពង្រីកឱកាសអប់រំក្រោយកម្រិតមូលដ្ឋាន គួបផ្សំនឹងគោលនយោបាយសាធារណៈ ដែលគាំទ្រដល់ជនក្រីក្រផងនោះ បាននាំឲ្យការថយចុះនូវវិសមភាព៖ “ការវិនិយោគលើការអប់រំ ស្ថាប័នទីផ្សារការងារ និងលិខិតបទដ្ឋានគតិយុត្តិ អាចធ្វើឲ្យមានការផ្លាស់ប្តូរនិន្នាការវិសមភាព។ ក្នុងប្រទេសនៅអាមេរិចឡាទីន ដែលវិសមភាពមានការថយចុះ មានកត្តាសំខាន់ៗចំនួន ២ ដែលនាំឲ្យមានការថយចុះបែបនេះ៖ ការពង្រីកសេវាអប់រំ និងការផ្ទេរធនធានជាសាធារណៈដល់ជនក្រីក្រ... ឧទាហរណ៍ ការបង្កើនចំណាយសាធារណៈសម្រាប់វិស័យអប់រំ នៅអាមេរិចឡាទីន និងការីបៀនទាំងមូល នាំឲ្យមានការកើនឡើងនូវការចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សា ហើយនេះគឺជាកត្តាកំណត់ដ៏ធំមួយនៃការថយចុះវិសមភាព” [៦៧]

ការអប់រំកម្រិតឧត្តមសិក្សា៖ ការទទួលបានការអប់រំកម្រិតឧត្តមសិក្សា មានការកើនឡើងខ្លាំង ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ។ ការចូលរៀនថ្នាក់ឧត្តមសិក្សានៅក្នុងសកលលោកទាំងមូល មានការកើនឡើងទ្វេរដង ចាប់តាំងពីឆ្នាំ ២០០០ មក ដោយបច្ចុប្បន្ននេះ មាននិស្សិតប្រមាណជា ២០០ លាននាក់ ក្នុងសកលលោកទាំងមូល ដែលពាក់កណ្តាលគឺជាស្ត្រី។[៦៨] ប៉ុន្តែគម្លាត ផ្អែកតាមចំណូល និងកត្តាផ្សេងទៀត ដែលនាំឲ្យមានការបាត់បង់ឱកាសក្នុងសង្គម នៅតែមានជាទូទៅ បើទោះបីជាមានការដាក់ចេញនូវវិធានការគោលនយោបាយជាច្រើន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ។ អ្នករៀនសូត្រមកពីក្រុមចំណូលខ្ពស់ នៅតែមានលទ្ធភាពច្រើន ក្នុងការទទួលបានការអប់រំកម្រិតឧត្តមសិក្សាទូទាំងពិភពលោក។ សូម្បីតែនៅក្នុងប្រទេសដែលមានអត្រាចូលរៀនខ្ពស់ ការចូលរួមរបស់ក្រុមភាគតិច នៅតែបន្តមានកម្រិតទាបជាងកម្រិតមធ្យមនៅថ្នាក់ជាតិ។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់ ពាក់ព័ន្ធជាមួយនឹងចំណុចនេះគឺ កំណើននៃការអប់រំឧត្តមសិក្សាភាគច្រើនបាន និងបន្តកើតមានក្នុង

---

៦៧ UN DESA. 2013. Inequality Matters. Report of the World Social Situation 2013. New York, United Nations.

៦៨ ផ្អែកតាមទិន្នន័យនៃវិទ្យាស្ថានស្ថិតិរបស់យូណេស្កូ។

វិស័យឯកជន។ ការកើនឡើងនូវភាគរយនៃគ្រឹះស្ថានឯកជន និងនិន្នាការទៅរកការធ្វើឯកជនភាវូបនីយកម្មវិស័យសាធារណៈទូទាំងពិភពលោក មានភាពពាក់ព័ន្ធជាមួយនឹងលទ្ធភាពទទួលបានសេវា និងសមធម៌។ ចំណាយផ្ទាល់ និងប្រយោលលើការសិក្សានៅកម្រិតឧត្តមសិក្សានៅតែជាមូលហេតុសម្បង ដែលនាំឲ្យមានការផាត់ក្រុមណាមួយចេញ។ ខណៈពេលដែលកម្មវិធីផ្តល់កម្ចីមានភាពទាក់ទង កម្មវិធីទាំងនេះមិនមែនមានជាទូទៅឡើយ។[៦៩]

[៦៩] Altbach, P. G., Reisberg, L. and Rumbley, L. E. 2009. Trends in Global Higher Education: Tracking an Academic Revolution. Paris, UNESCO. (Report Prepared for the UNESCO 2009 World Conference on Higher Education)

## ប្រអប់ទី ៩៖ សកលវិទ្យាល័យអន្តរវប្បធម៌ ក្នុងប្រទេសម៉ិចស៊ិច

ខណៈពេលដែលប្រជាជនម៉ិចស៊ិចប្រមាណជា ១០% គឺជាជនជាតិដើមភាគតិច ចំនួននិស្សិតជនជាតិដើមភាគតិច ដែលចូលរួមក្នុងការអប់រំនៅកម្រិតឧត្តមសិក្សាមានតិចតួចបំផុត។ បើតាមការប៉ាន់ប្រមាណ មាននិស្សិតចន្លោះពី ១% ទៅ ៣% ដែលចុះឈ្មោះចូលរៀនកម្រិតឧត្តមសិក្សាក្នុងប្រទេសម៉ិចស៊ិច គឺជាជនជាតិដើមភាគតិច។

ក្នុងឆ្នាំ ២០០៤ ជាការឆ្លើយតបចំពោះបញ្ហាវិសមភាពបែបនេះ អគ្គនាយកដ្ឋានសម្របសម្រួលការអប់រំពហុវប្បធម៌ និងពីរភាសារបស់ក្រសួងអប់រំ បានបង្កើតសកលវិទ្យាល័យពហុវប្បធម៌ ដោយមានការចូលរួមយ៉ាងសកម្មពីអង្គការជនជាតិដើមភាគតិច និងគ្រឹះស្ថានសិក្សា ក្នុងតំបន់នីមួយៗ។ គ្រឹះស្ថានទាំងនេះ មានទីតាំងក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ហើយបើទោះបីជាគ្រឹះស្ថានទាំងនេះអនុញ្ញាតឲ្យនិស្សិតទូទៅចូលរៀនក៏ដោយ គ្រឹះស្ថានទាំងនេះត្រូវបានបង្កើតឡើង ជាពិសេស សម្រាប់ជនជាតិដើមភាគតិច។ ដោយឈរលើគោលការណ៍អប់រំពហុវប្បធម៌ គ្រឹះស្ថានទាំងនេះមានគោលបំណងលើកកម្ពស់កិច្ចពិគ្រោះយោបល់រវាងវប្បធម៌ផ្សេងៗ និងតំណាងឲ្យរបៀបធ្វើការឆ្លើយតបចំពោះតម្រូវការកន្លងមក និងតម្រូវការថ្មីៗ របស់ជនជាតិដើមភាគតិចផងដែរ។

បើទោះបីជាមានការទទួលស្គាល់ពីលក្ខណៈចម្រុះរបស់និស្សិតក៏ដោយ សកលវិទ្យាល័យពហុវប្បធម៌ពុំបានស្នើឲ្យមានការប្រើប្រាស់អភិក្រមតែមួយបែប សម្រាប់អនុវត្តសកម្មភាពអប់រំរបស់ខ្លួនឡើយ។ ខណៈពេលដែលមានការគោរពតាមគោលការណ៍ជាមូលដ្ឋានមួយចំនួន សកលវិទ្យាល័យនីមួយៗធ្វើការកំណត់កម្មវិធីសិក្សាដោយខ្លួនឯង ទៅតាមតម្រូវការ និងសក្តានុពលក្នុងតំបន់ ដែលខ្លួនតាំងនៅ។ និស្សិតអាចចូលរួមក្នុងសកម្មភាពនានា ដែលភ្ជាប់ទំនាក់ទំនងពួកគេជាមួយនឹងសហគមន៍ជុំវិញ តាមរយៈគម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍដែនដី មនុស្ស និងវប្បធម៌របស់ពួកគេ។

បច្ចុប្បន្ននេះសកលវិទ្យាល័យពហុវប្បធម៌ចំនួន១២កំពុងដំណើរការដោយមាននិស្សិតសរុបប្រមាណជា៧០០០នាក់ដែលភាគច្រើនជានិស្សិតស្រី។បើទោះបីជាមានបញ្ហាប្រឈមខាងហិរញ្ញវត្ថុ ជីវភាពរស់នៅរបស់និស្សិត និងភាពងាយរងគ្រោះខាងនយោបាយ ដែលសកលវិទ្យាល័យទាំងនេះកំពុងប្រឈមក៏ដោយ សកលវិទ្យាល័យទាំងនេះ គឺជាការរួមចំណែកដ៏សំខាន់មួយ ចំពោះការសម្រេចនូវសមធម៌នៃការអប់រំ។

ប្រភព៖ ដកស្រង់ចេញពី Schmelkes, S. 2009. Intercultural Universities in Mexico: Progress and difficulties. Intercultural Education, Vol. 20, No. 1, pp. 5-17. www.tandfonline.com/doi/full/10.1080/14675980802700649 [Accessed February 2015].

## ■ ការប្រែប្រួលនៃទិដ្ឋភាពនៃការអប់រំ

ទិដ្ឋភាពនៃការអប់រំ ក្នុងពិភពលោកសម័យបច្ចុប្បន្ននេះ កំពុងឆ្លងកាត់បម្រែបម្រួលដ៏ខ្លាំងក្លាមួយ ពាក់ព័ន្ធជាមួយនឹងវិធីសាស្ត្រ ខ្លឹមសារ និងឱកាសសម្រាប់រៀនសូត្រ។ នេះគឺជាអ្វីដែលកើតឡើង ចំពោះការរៀនថ្នាក់ទាបៗផង និងការអប់រំកម្រិតឧត្តមសិក្សាផង។ ការកើនឡើងនូវភាពអាចរកបាន និងលទ្ធភាពទទួលបានចំណេះដឹងពីប្រភពផ្សេងៗ កំពុងពង្រីកឱកាសរៀនសូត្របន្ថែមទៀត ដែលអាចមិនមានរចនាសម្ព័ន្ធត្រឹមត្រូវ និងមានការច្នៃប្រឌិតថ្មីជាងមុន ដែលមានឥទ្ធិពលលើថ្នាក់រៀន គរុកោសល្យ គ្រូ និងដំណើការរៀន។

ជារួម ការប្រែប្រួលទិដ្ឋភាពនៃការរៀនសូត្របច្ចុប្បន្ននេះ គឺដូចគ្នានឹងអន្តរកាលកន្លងមកពីគំរូនៃការអប់រំបែបប្រពៃណីមុនសម័យឧស្សាហកម្ម ទៅកាន់គំរូរោងចក្រ ដែលត្រូវបានផ្តួចផ្តើម ក្នុងសតវត្សរ៍ទី ១៩។ ក្នុងគំរូនៃការអប់រំបែបប្រពៃណីមុនសម័យឧស្សាហកម្ម ចំណេះដឹងភាគច្រើន ដែលមនុស្សរៀនចេះ គឺមានប្រភពពីសកម្មភាពរស់នៅ និងការធ្វើការងារប្រចាំថ្ងៃរបស់ពួកគេ។ ផ្ទុយទៅវិញ គំរូនៃការអប់រំជាទ្រង់ទ្រាយធំ ដែលកើតចេញពីបដិវត្តន៍ឧស្សាហកម្ម នាំឲ្យការរៀនសូត្រកើតឡើងស្ទើរតែទាំងស្រុងក្នុងសាលារៀន។ លើសពីនេះ គំរូនៃការអប់រំក្នុងសាលារៀនបន្តភ្ជាប់ទំនាក់ទំនងការរៀនសូត្រ ជាមួយនឹងការបង្រៀនក្នុងថ្នាក់រៀន នៅពេលដែលជាគុពិត ការរៀនសូត្រជាច្រើន (សូម្បីតែក្នុងបរិបទនៃការអប់រំបែបប្រពៃណី) កើតឡើងក្នុងផ្ទះ និងនៅកន្លែងផ្សេងទៀតក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ទីកន្លែងរូបវន្តពោលគឺថ្នាក់រៀន ដែលជាកន្លែងសំខាន់សម្រាប់ការរៀនសូត្រ នៅតែជាលក្ខណៈសំខាន់នៃប្រព័ន្ធអប់រំផ្លូវការនៅគ្រប់កម្រិតទាំងអស់នៃការរៀនសូត្រ។[៧០]

## តើការរៀនសូត្រក្នុងសាលារៀនពិតជាលែងមានទៀតឬ?

បច្ចុប្បន្ននេះ មានមនុស្សមួយចំនួនលើកឡើងថា គំរូនៃការរៀនសូត្រក្នុងសាលារៀនលែងមានអនាគតក្នុងសម័យឌីជីថលទៀតហើយ ដោយសារតែឱកាសដែលផ្តល់ដោយការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិច ការរៀនសូត្រតាមទូរស័ព្ទចល័ត និងបច្ចេកវិទ្យាឌីជីថលដទៃទៀត។ ក្នុងន័យនេះ យើងគួរពិនិត្យឡើងវិញលើការជជែកវែកអំពីការរៀនសូត្រក្រៅសាលារៀន (Deschooling) ក្នុងទសវត្សរ៍ ១៩៦០ និង ១៩៧០ ជាពិសេស ឯកសារដែលជា

[៧០] Frey, T. 2010. The future of education. FuturistSpeaker. www.futuristspeaker.com/2007/03/the-future-ofeducation [Accessed February 2015].

ស្នាដៃរបស់ Paul Goodman[៧១] និង Ivan Illich[៧២]។ វាគឺជាការពិតដែលថាគំរូនៃការរៀនសូត្រក្នុងសាលារៀនសម័យឧស្សាហកម្មបច្ចុប្បន្ន ត្រូវបានរៀបចំឡើង ដើម្បីបំពេញតម្រូវការផលិតកម្ម កាលពីជាងមួយសតវត្សរ៍កន្លងទៅនេះ ប៉ុន្តែគំរូនៃការរៀនសូត្រមានការផ្លាស់ប្តូរយ៉ាងគំហុកក្នុងពីរទសវត្សរ៍ចុងក្រោយ ហើយប្រភពចំណេះដឹងក៏បានផ្លាស់ប្តូរ ដូចគ្នានឹងរបៀបដែលយើងផ្តោះប្តូរព័ត៌មាន និងប្រាស្រ័យទាក់ទងជាមួយគ្នា ដោយប្រើប្រាស់ចំណេះដឹងផងដែរ។ វាគឺជាការពិតផងដែរ ដែលប្រព័ន្ធអប់រំក្នុងប្រព័ន្ធមានភាពយឺតយ៉ាវក្នុងការផ្លាស់ប្តូរ ហើយនៅតែមានលក្ខណៈស្រដៀងគ្នានឹងអ្វីដែលមានក្នុងរយៈពេលពីរសតវត្សរ៍ចុងក្រោយនេះ។[៧៣] ទោះជាយ៉ាងណាក៏ដោយ ការរៀនសូត្រក្នុងសាលារៀននៅតែមានសារៈសំខាន់។ វាគឺជាជំហានទីមួយក្នុងការទទួលបានការរៀនសូត្រជាផ្លូវការ និងការចុះក្នុងសង្គម ក្រៅពីគ្រួសារ ហើយវាគឺជាធាតុផ្សំដ៏សំខាន់នៃការរៀនសូត្រក្នុងសង្គម៖ រៀន ដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនរស់នៅជាមួយគ្នា។ ការរៀនសូត្រមិនគួរត្រឹមតែជាដំណើរការរបស់បុគ្គលម្នាក់ៗប៉ុណ្ណោះនោះទេ។ ដោយសារតែការរៀនសូត្រគឺជាបទពិសោធន៍មួយក្នុងសង្គម វាតម្រូវឲ្យមានការរៀនសូត្រជាមួយអ្នកដទៃ និងតាមរយៈអ្នកដទៃ តាមរយៈការពិភាក្សា និងជជែកវែកញែកជាមួយមិត្តភក្តិផង និងគ្រូផង។

## ឆ្ពោះទៅបង្កើតបណ្តាញនៃកន្លែងផ្តល់ការរៀនសូត្រ

ទោះជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធនឹងការប្រែប្រួលទិដ្ឋភាពនៃការអប់រំក្នុងសហសម័យនេះ មានការទទួលស្គាល់កាន់តែខ្លាំងឡើងនូវសារៈសំខាន់ និងភាពពាក់ព័ន្ធនៃការរៀនសូត្រខាងក្រៅគ្រឹះស្ថានផ្លូវការ។ មានការងាកចេញពីការរៀនសូត្រក្នុងគ្រឹះស្ថានអប់រំបែបប្រពៃណីទៅរកការរៀនសូត្រចម្រុះ ដែលមានលក្ខណៈស្មុគស្មាញ ដែលក្នុងនោះការរៀនសូត្រក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងក្រៅផ្លូវការ ធ្វើឡើងក្នុងគ្រឹះស្ថានអប់រំផ្សេងៗគ្នា និងជាមួយអ្នកផ្តល់សេវាអប់រំដែលជាភាគទី ៣។[៧៤] អ្វីដែលយើងត្រូវការ គឺគោលវិធីរៀនសូត្រដែលមានលក្ខណៈបត់បែន និងបន្តគ្នា ដែលក្នុងនោះការរៀនសូត្រក្នុងសាលារៀន និងគ្រឹះស្ថានផ្តល់ការអប់រំក្នុងប្រព័ន្ធ កាន់តែមានទំនាក់ទំនងជិតស្និទជាមួយនឹងការរៀនសូត្រមិនសូវផ្លូវការ ចាប់ពីវ័យកុមារតូច រហូត

[៧១] Goodman, P. 1971. Compulsory Miseducation. Harmandsworth, UK, Penguin Books.

[៧២] Illich, I. 1973. Deschooling Society. Harmandsworth, UK, Penguin Books.

[៧៣] Davidson, C.N. and Goldberg, D.T. with Jones, Z.M. 2009. The Future of Learning Institutions in the Digital Age. Cambridge, MA, MIT Press (MacArthur Foundation Report on Digital media and Learning).

[៧៤] Scott, C. 2015. The Futures of Learning. ERF Working Papers. Paris, UNESCO.

ដល់ពេលមួយជីវិត។ ការផ្លាស់ប្តូរទីកន្លែង ពេលវេលា និងទំនាក់ទំនងជុំវិញការរៀនសូត្រនេះ លំអៀងទៅរកការបង្កើតបណ្តាញកន្លែងរៀនសូត្រ ដែលកន្លែងផ្តល់ការរៀនសូត្រក្រៅប្រព័ន្ធ និងក្រៅផ្លូវការ មានទំនាក់ទំនងជាមួយ និងបំពេញបន្ថែមឲ្យគ្រឹះស្ថាន ដែលផ្តល់ការអប់រំក្នុងប្រព័ន្ធ។

> អ្វីដែលយើងត្រូវការ គឺគោលវិធីរៀនសូត្រដែលមានលក្ខណៈបត់បែន និងបន្តគ្នា ដែលក្នុងនោះការរៀនសូត្រក្នុងសាលារៀន និងគ្រឹះស្ថានផ្តល់ការអប់រំក្នុងប្រព័ន្ធកាន់តែមានទំនាក់ទំនងជិតស្និទជាមួយនឹងការរៀនសូត្រមិនសូវផ្លូវការ ចាប់ពីវ័យកុមារតូច រហូតដល់ពេលមួយជីវិត។

## កន្លែងរៀនសូត្រថ្មីៗ

ការរៀនសូត្រក្នុងថ្នាក់រៀន ឥឡូវនេះ ត្រូវប្រជែងជាមួយ នឹងការពង្រីកលទ្ធភាពទទួលបានចំណេះដឹង និងការលេចឡើងនូវកន្លែងរៀនសូត្រថ្មីៗ ក្រៅពីថ្នាក់រៀន សាលារៀន សកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំផ្សេងទៀត។[៧៥] ឧទាហរណ៍ ប្រព័ន្ធផ្សព្វផ្សាយសង្គមអាចពង្រីកការងារក្នុងថ្នាក់រៀន តាមរយៈការផ្តល់នូវឱកាសឲ្យមានការធ្វើសកម្មភាពផ្សេងៗ ដូចជា ការសហការគ្នា និងការនិពន្ធរួមគ្នា ជាដើម។ ឧបករណ៍ចល័តផ្តល់លទ្ធភាពឲ្យអ្នករៀនសូត្រទទួលបានធនធានអប់រំ ភ្ជាប់ទំនាក់ទំនងជាមួយអ្នកផ្សេងទៀត ឬបង្កើតខ្លឹមសារ ទាំងក្នុង ទាំងក្រៅថ្នាក់រៀន។[៧៦] ស្រដៀងគ្នានេះដែរ កម្មវិធី Massive Open On-Line Courses ( MOOCs ) ផ្តោតលើការអប់រំកម្រិតឧត្តមសិក្សា ដែលក្នុងនោះក្រុមសកលវិទ្យាល័យបានរួមគ្នាប្រមូលផ្តុំធនធានសាស្ត្រាចារ្យរបស់ខ្លួន ដើម្បីផ្តល់ជាវគ្គសិក្សាផ្សេង។ កម្មវិធីនេះបានបើកផ្លូវថ្មី ដើម្បីឲ្យមនុស្សកាន់តែច្រើននាក់អាចទទួលបានការអប់រំកម្រិតឧត្តមសិក្សា នៅទូទាំងពិភពលោក។ បរិបទបច្ចុប្បន្ននៃបម្រែបម្រួល ទិដ្ឋភាពនៃការអប់រំផ្តល់ឱកាសឲ្យគេអាចប្រមូលផ្តុំកន្លែងរៀនសូត្រទាំងអស់ឲ្យនៅជុំគ្នា តាមរយៈការបង្កើតកម្លាំងផ្គួបរវាងគ្រឹះស្ថានដែលផ្តល់ការអប់រំ និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងបទពិសោធន៍អប់រំផ្សេងទៀត។ បរិបទថ្មីនេះក៏ផ្តល់ឱកាសថ្មីៗឲ្យគេពិសោធន៍ និងបង្កើតអ្វីដែលថ្មីផងដែរ។

---

[៧៥] Hannon, V., Patton, A. and Temperley, J. 2011. Developing an Innovation - Ecosystem for Education. Indianapolis, CISCO; Taddei, F. 2009. Training creative and collaborative knowledge-builders: A major challenge for 21st century education. Report prepared for the OECD on the future of education. Paris, OECD.

[៧៦] Grimus, M. and Ebner, M. 2013. M-Learning in Sub Saharan Africa Context- What is it about. Proceedings of World Conference on Educational Multimedia, Hypermedia and Telecommunications 2013, pp. 2028-2033. Chesapeake, VA: AACE.

## ប្រអប់ទី ១០៖ ការពិសោធន៍ “ប្រហោងក្នុងជញ្ជាំង”

បណ្ឌិត Sugata Mitra ប្រធានក្រុមអ្នកវិទ្យាសាស្ត្រនៅ NIIT គឺជាអ្នកបង្កើតការពិសោធន៍ប្រហោងក្នុងជញ្ជាំងនេះឡើង។ តាំងពីឆ្នាំ ១៩៨២ មក លោកមានគំនិតចង់សាកល្បងការរៀនសូត្រ ដោយប្រើកុំព្យូទ័រ ដោយពុំមានអ្នកចាំឃ្លាំមើល។ ចុងក្រោយ ក្នុងឆ្នាំ ១៩៩៩ ក្រុមការងាររបស់បណ្ឌិត Mitra បានចោះ “ប្រហោងក្នុងជញ្ជាំង” ដែលខណ្ឌបរិវេណ NIIT ពីតំបន់ប្រជាជនក្រីក្រជិតនោះ ក្នុងតំបន់ Kalkaji ទីក្រុងញូដេលី។ តាមរយៈប្រហោងនេះ កុំព្យូទ័រមួយត្រូវបានដាក់ ដើម្បីឲ្យគេប្រើបានដោយសេរី។

កុំព្យូទ័រនេះត្រូវបានប្រើប្រាស់ដោយអ្នករស់នៅតំបន់ក្រីក្រជាច្រើននាក់ ជាពិសេសកុមារ។ ដោយពុំមានបទពិសោធន៍កន្លងមក កុមាររៀនប្រើប្រាស់កុំព្យូទ័រនេះដោយខ្លួនឯង។ នេះធ្វើឲ្យមានការបង្កើតនូវសម្មតិកម្មដូចខាងក្រោម៖ ការរៀនចេះជំនាញកុំព្យូទ័រជាមូលដ្ឋានដោយក្រុមកុមារណាក៏ដោយអាចសម្រេចបានតាមរយៈការរៀនសូត្រដោយចៃដន្យដរាបណាអ្នករៀនសូត្របានទទួលបរិក្ខារកុំព្យូទ័រសមស្រប ដោយមានខ្លឹមសារដែលផ្តល់ឲ្យពួកគេនូវការកម្សាន្តនិងការលើកទឹកចិត្ត និងមានការផ្តល់ការណែនាំ (ពីមនុស្ស) តិចតួច។

ជាមួយនឹងជោគជ័យពីការពិសោធន៍ក្នុងតំបន់ Kalkaji នេះកុំព្យូទ័រដែលគេអាចប្រើប្រាស់បានដោយសេរី ត្រូវបានដំឡើងក្នុងក្រុង Shivpuri (ជាទីប្រជុំជនមួយរបស់រដ្ឋ Madhya Pradesh) និងក្នុងភូមិ Mandatusi (ភូមិមួយក្នុងរដ្ឋ Uttar Pradesh)។ ការពិសោធន៍ទាំងនេះត្រូវបានគេហៅថាការពិសោធន៍ប្រហោងក្នុងជញ្ជាំង។ លទ្ធផលរកឃើញពី Shivpuri និង Mandatusi បញ្ជាក់ពីលទ្ធផលនៃការពិសោធន៍នៅ Kalkaji។ កុមារក្នុងតំបន់ទាំងពីរនេះហាក់បីដូចជារៀនចេះជំនាញកុំព្យូទ័រដោយខ្លួនឯង។ របៀបរៀនបែបថ្មីនេះត្រូវបានគេហៅថាការអប់រំដែលមានការបង្ហាត់តិចតួច (Minimally Invasive Education)។

ចាប់តាំងពីត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ មក ការពិសោធន៍ប្រហោងក្នុងជញ្ជាំងនេះបានរីកចម្រើនពីកុំព្យូទ័រតែមួយគ្រឿងនៅតំបន់ Kalkaji ទីក្រុងញូដេលីរហូតដល់កុំព្យូទ័រជាង ១០០ គ្រឿងនៅតាមទីតាំងផ្សេងៗ-សូម្បីតែនៅកន្លែងដាច់ស្រយាលដែលគ្មានផ្លូវចូលដល់ ក្នុងប្រទេសឥណ្ឌា និងប្រទេសផ្សេងទៀត ដូចជា ប៊ូតាន កម្ពុជា និងអាហ្វ្រិកកណ្តាលជាដើម។

សម្គាល់៖ NIIT Limited គឺជាក្រុមហ៊ុនឥណ្ឌាមួយ ដែលមានមូលដ្ឋាននៅ Gurgaon ប្រទេសឥណ្ឌា ដែលដំណើរការគ្រឹះស្ថានឧត្តមសិក្សារកប្រាក់ចំណេញជាច្រើនកន្លែង។

ប្រភព៖ ដកស្រង់ចេញពី www.hole-in-the-wall.com [Accessed February 2015]

## ការរៀនសូត្រចល័ត

កាលពីពេលថ្មីៗនេះ ចំណាប់អារម្មណ៍លើការប្រើប្រាស់បច្ចេកវិទ្យាចល័តសម្រាប់ការរៀនសូត្រ មានទំហំធំធេង។ ការរៀនសូត្រចល័តតែឯង ឬគួបផ្សំជាមួយនឹងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ផ្សេងទៀត អាចផ្តល់លទ្ធភាពឲ្យមានការរៀនសូត្រនៅពេលណាក៏បាន នៅកន្លែងណាក៏បាន។[៧៧] បច្ចេកវិទ្យាទាំងនេះកំពុងចេះតែវិវឌ្ឍបន្តទៀត ហើយបច្ចុប្បន្ននេះមានដូចជាទូរស័ព្ទដៃ និងទូរស័ព្ទប្រភេទស្មាតហ្វូន, ឧបករណ៍ tablets, e-readers, ប្រដាប់ចាក់សម្លេងចល័ត និងឧបករណ៍កាន់ដៃ។ ការលេចរូបរាងបច្ចេកវិទ្យាថ្មីៗទាំងនេះ បានធ្វើឲ្យមានការផ្លាស់ប្តូរលក្ខណៈនៃដំណើរការអប់រំយ៉ាងធំធេង។ ឧបករណ៍ចល័តដែលមានទំងន់ស្រាល ចាប់ពីទូរស័ព្ទដៃ ឧបករណ៍ tablets រហូតដល់ palmtops បានរំដោះការរៀនសូត្រពីកន្លែងដែលត្រូវបានកំណត់ទុកជាមុន ដោយបានធ្វើការផ្លាស់ប្តូរលក្ខណៈនៃចំណេះដឹងក្នុងសង្គមទំនើប។[៧៨] ដូច្នេះ ការរៀនសូត្រកាន់តែមានលក្ខណៈក្រៅផ្លូវការ មានលក្ខណៈផ្ទាល់ខ្លួន និងអាចធ្វើបាននៅគ្រប់ទិសទី។[៧៩] បច្ចេកវិទ្យាចល័តបានទទួលការចាប់អារម្មណ៍ពិសេសពីអ្នកអប់រំ ដោយសារតែចំណាយរបស់វាអស់តិច បើធៀបជាមួយនឹងកុំព្យូទ័រលើតុ គួបផ្សំជាមួយនឹងធនធានសម្បូរបែបដែលអាចរកបានពីអ៊ីនធឺណិត។[៨០]

កាន់តែទទួលបានការផ្តល់តម្លៃក្នុងវិស័យអប់រំផ្សេងៗ ការរៀនសូត្រចល័តបានលើកកម្ពស់ការអប់រំកម្រិតមូលដ្ឋាន និងការអប់រំកម្រិតឧត្តមសិក្សាបន្ថែមទៀត ក៏ដូចជាបានភ្ជាប់ទំនាក់ទំនងរវាងការអប់រំក្នុងប្រព័ន្ធ និងការអប់រំមិនផ្លូវការផងដែរ។[៨១] ដោយសារតែភាពងាយស្រួលចល័ត និងចំណាយទាប ឧបករណ៍រៀនសូត្រចល័តដែលអស់ចំណាយតិច មានសក្តានុពលបង្កើន

---

[៧៧] UNESCO. 2013. Policy Guidelines for mobile learning. Paris, UNESCO.

[៧៨] O'Malley, C., Vavoula, G., Glew, J.P., Taylor, J., Sharples, M. and Lefrere, P. 2003. MOBIlearn WP4 - Guidelines for Learning/Teaching/Tutoring in a Mobile Environment. www2.le.ac.uk/Members/gv18/gvpublications [Accessed February 2015].

[៧៩] Traxler, J. 2009. Current State of Mobile Learning. M. Alley (ed.), Mobile Learning: Transforming the Delivery of Education and Training Athabasca, AB, Canada, AU Press. pp. 9-24.

[៨០] Kukulska-Hulme, A. 2005. Introduction. J. Traxler and A. Kukulska-Hulme (eds), Mobile learning – A handbook for educators and trainers, New York, Routledge, pp. 1-6. Kukulska-Hulme, A. 2005. Introduction. J. Traxler and A. Kukulska-Hulme (eds), Mobile learning – A handbook for educators and trainers, New York, Routledge, pp. 1-6.

[៨១] Traxler, op. cit.

ភាពងាយស្រួល និងប្រសិទ្ធភាពនៃការអប់រំកម្រិតមូលដ្ឋាន។[៨២] បច្ចេកវិទ្យាចល័ត "គឺជាកូនសោរ ដើម្បីប្រែក្លាយគម្លាតឌីជីថលបច្ចុប្បន្ននេះ ទៅជាភាគលាភឌីជីថលវិញ ដែលនាំមកនូវការអប់រំប្រកបដោយសមធម៌ និងគុណភាពសម្រាប់ទាំងអស់គ្នា។[៨៣] ការអភិវឌ្ឍបច្ចេកវិទ្យាចល័តបានបើកចំហលទ្ធភាពជាច្រើនខាងការរៀនសូត្រអក្ខរកម្ម និងការរៀនសូត្រភាសា។[៨៤] ការស្រាវជ្រាវបានបង្ហាញឲ្យឃើញពីប្រសិទ្ធភាពនៃបច្ចេកវិទ្យាចល័ត ក្នុងការបង្កើនសមត្ថភាពអក្ខរកម្មរបស់អ្នករៀនសូត្រ។ ដោយសារតែបច្ចេកវិទ្យាចល័តអាចសាយភាយដល់មនុស្សជាច្រើននាក់ បច្ចេកវិទ្យានេះអាចធ្វើឲ្យការអប់រំសម្រាប់កុមារ និងយុវជន ដែលរស់នៅដាច់ប៉ែកពីគេ និងរស់នៅកន្លែងខ្វះខាត មានការប្រែប្រួល។[៨៥]

[៨២] Kim, P.H. 2009. Action Research Approach on Mobile Learning Design for the Underserved. Education Technology Research Development. Vol. 57, No. 3, pp. 415-435.

[៨៣] ITU and UNESCO. 2014. Mobile learning week: A revolution for inclusive and better education. UNESCO website. www.unesco.org/new/en/media-services/in-focus-articles/mobile-learning-week-a-revolution-forinclusive-better-education [Accessed February 2015].

[៨៤] Joseph, S., Uther, M. 2006. Mobile language learning with multimedia and multi-modal interfaces. Proceedings of the fourth IEEE International Workshop on Wireless, Mobile and Ubiquitous Technology in Education (ICHIT '06), pp. 124-128.

[៨៥] Saechao, N. 2012. Harnessing Mobile Learning to Advance Global Literacy. The Asia Foundation. http://asiafoundation.org/in-asia/2012/09/05/harnessing-mobile-learning-to-advance-global-literacy/ [Accessed February 2015].

## ប្រអប់ទី ១១៖ ថ្នាក់អក្ខរកម្មចល័តសម្រាប់ក្មេងស្រី ក្នុងប្រទេសប៉ាគីស្ថាន

គម្រោងថ្នាក់អក្ខរកម្មចល័តរបស់យូណេស្កូ បានប្រើប្រាស់ទូរស័ព្ទចល័ត ដើម្បីបំពេញបន្ថែម និងគាំទ្រដល់ថ្នាក់អក្ខរកម្មបែបប្រពៃណី ដែលត្រូវបានផ្តល់ដល់ក្មេងស្រីជំទង់ចំនួន ២៥០នាក់រស់នៅតំបន់ដាច់ស្រយាលនៃប្រទេសប៉ាគីស្ថាន។អនក្ខរកម្មគឺជាបញ្ហាស្រួចស្រាវក្នុងប្រទេសប៉ាគីស្ថាន ដែលមានផលប៉ះពាល់លើសលុបលើស្ត្រី និងក្មេងស្រី។ នៅទូទាំងប្រទេស អត្រាអក្ខរកម្មមនុស្សពេញវ័យគឺ ៦៩% សម្រាប់បុរស ប៉ុន្តែត្រឹមតែ ៤០% សម្រាប់ស្ត្រីតែប៉ុណ្ណោះ។ ដោយសារតែការស្រាវជ្រាវអំពីការអប់រំបង្ហាញថា ជំនាញអក្ខរកម្មដែលទើបទទួលបានថ្មីងាយនឹងបាត់បង់ទៅវិញ នៅពេលដែលពុំមានការអនុវត្តឲ្យបានជាប់លាប់ អ្នករៀបចំផែនការគម្រោងចង់បានវិធីសាស្ត្រអ្វីមួយ ដើម្បីជួយដល់ក្មេងស្រីទាំងនេះពីចំងាយក្រោយពេលដែលពួកគេបានបញ្ចប់ថ្នាក់អក្ខរកម្ម។

វិធីតែមួយគត់ ដើម្បីប្រាស្រ័យទាក់ទងជាមួយនឹងសិស្សថ្នាក់អក្ខរកម្មរស់នៅតាមភូមិដែលពុំមានកុំព្យូទ័រនិងអ៊ីនធឺណិតគឺតាមរយៈទូរស័ព្ទដៃ។គ្រូបង្រៀនក្នុងកម្មវិធីនេះផ្ញើរសារជាអក្សរទៅសិស្សរបស់ពួកគេ ដើម្បីរំឭកពួកគេឲ្យហ្វឹកហាត់ជំនាញសរសេរ ឬអានអត្ថបទក្នុងសៀវភៅលំហាត់។ គ្រូក៏ដាក់សំណួរទៅឲ្យសិស្សឆ្លើយតាមសារជាអក្សរផងដែរ។ រាល់សកម្មភាពនិងការប្រាស្រ័យទាក់ទងទាំងនេះមានបំណងពង្រឹងបន្ថែមជំនាញអក្ខរកម្មដែលក្មេងស្រីទាំងនេះបានទទួល ក្នុងវគ្គសិក្សាផ្ទាល់។

មុនពេលដែលគម្រោងនេះបញ្ចូលការប្រើប្រាស់ទូរស័ព្ទចល័ត ក្នុងចំណោមក្មេងស្រីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មមានតែ ២៨% ប៉ុណ្ណោះ ដែលបានទទួលនិទ្ទេស “A” ក្នុងការប្រលង។ប៉ុន្តែជាមួយនឹងការគាំទ្រពីទូរស័ព្ទចល័តមានក្មេងស្រីជាង៦០%បានទទួលនិទ្ទេស “A” ។ ផ្អែកទៅតាមជោគជ័យដំបូងៗនេះ បច្ចុប្បន្ន គម្រោងនេះកំពុងពង្រីកវិសាលភាពរបស់ខ្លួនបន្ថែមទៀត ហើយបច្ចុប្បន្ននេះ គ្របដណ្តប់លើសិស្សជាង ២៥០០ នាក់។

ប្រភព៖UNESCO. 2013. Policy Guidelines for Mobile Learning. Paris, UNESCO, p. 15.

## វគ្គសិក្សាអនឡាញ Massive Open On-line Courses (MOOCs) - សក្តានុពល និងដែនកំណត់

វគ្គសិក្សាអនឡាញ Massive Open On-line Courses (MOOCs) ក៏កំពុងធ្វើឲ្យមានការផ្លាស់ប្តូរទិដ្ឋភាពនៃការអប់រំកម្រិតឧត្តមសិក្សាផងដែរ។ វគ្គសិក្សាទាំងនេះបានទាក់ទាញចំណាប់អារម្មណ៍ជាច្រើនពីរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងក្រុមធុរកិច្ចនានា។[៨៦] ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលវគ្គសិក្សា MOOCs នេះ បានក្លាយជាវេទិកាដ៏សំខាន់សម្រាប់ពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងនវានុវត្តន៍នៃការអប់រំតាមប្រព័ន្ធអនឡាញ វគ្គសិក្សាទាំងនេះក៏ធ្វើឲ្យមានការព្រួយបារម្ភអំពីការកើនឡើងនូវវិសមភាព និងការព្រួយបារម្ភជុំវិញគរុកោសល្យ ការធានាគុណភាព និងអត្រាបញ្ចប់ការសិក្សាទាប ក៏ដូចជាការចេញវិញ្ញាបនបត្របញ្ជាក់ និងការទទួលស្គាល់ការរៀនសូត្រផងដែរ។[៨៧] គុណភាពគឺជាការព្រួយបារម្ភពិសេសមួយ ដោយសារតែ MOOCs ផ្តោតលើស្វ័យសិក្សា និងពុំប្រើប្រាស់រចនាសម្ព័ន្ធ ដូចវគ្គសិក្សាអនឡាញផ្សេងទៀត។[៨៨] មានការរិះគន់ថាវិធីសាស្ត្របង្រៀនហួសសម័យ ដោយសារតែ MOOCs ភាគច្រើននៅប្រើប្រាស់វិធីសាស្ត្រ "បញ្ជូនព័ត៌មាន ការដាក់កិច្ចការឲ្យធ្វើដោយប្រើប្រាស់កុំព្យូទ័រដាក់ពិន្ទុ និងការវាយតម្លៃគ្នាទៅវិញទៅមក។[៨៩] កង្វះការពិភាក្សាគ្នាផ្ទាល់ ធ្វើឲ្យគេមានការពិបាកក្នុងការឆ្លើយតបពេញលេញចំពោះតម្រូវការរបស់សិស្សម្នាក់ៗ។[៩០] ដូចគ្នាដែរ ការវាយតម្លៃសិស្ស និងការចេញវិញ្ញាបនបត្របញ្ជាក់ នៅមានការខ្វះខាត ឬពុំគ្រប់គ្រាន់ ក្នុង MOOCs។ បើទោះបីជាគ្រឹះស្ថាននានាចាប់ផ្តើមផ្តល់ក្រេឌីតដល់អ្នកដែលចូលរួមក្នុង MOOCs ក៏ដោយ និងមានការប្រើប្រាស់ការបញ្ជាក់ក្នុងទម្រង់ថ្មីៗ ដូចជាស្លាកសម្គាល់ (badges) ក៏ដោយ ការបញ្ជាក់ទាំងនេះនៅតែត្រូវបានគេយល់ឃើញថាជាការ

---

៨៦ Yuan, L. and Powell, S. 2013. MOOCs and Open Education: Implications for Higher Education – A White Paper. Centre for Educational Technology, Interoperability and Standards. http://publications.cetis.ac.uk/2013/667 [Accessed February 2015].

៨៧ Daniel, J.S. 2012. Making Sense of MOOCs: Musings in a Maze of Myth, Paradox and Possibility. Journal of Interactive Media in Education. Vol. 3, No. 18. http://jime.open.ac.uk/article/view/259 [Accessed February 2015].

៨៨ Butcher, N. and Hoosen, S. 2014. A Guide to Quality in Post-Traditional Online Higher Education. Dallas, TX, Academic Partnerships. www.icde.org/filestore/News/2014_March-April/Guide2.pdf [Accessed February 2015].

៨៩ Bates, T. 2012. What's right and what's wrong about Coursera-style MOOCs? www.tonybates.ca/2012/08/05/whats-right-and-whats-wrong-about-coursera-style-moocs [Accessed February 2015].

៩០ Daniel, op. cit.

បញ្ជាក់ដែលមានតម្លៃទាបលើលទ្ធផលនៃការអប់រំ និងជាការបង្ហាញមិនគ្រប់គ្រាន់ពីគុណភាពនៃការរៀនសូត្រ។[៩១] ការរិះគន់ទាំងនេះកាន់តែពាក់ព័ន្ធបន្ថែមទៀតជាមួយនឹងសកលវិទ្យាល័យនៅភាគខាងជើងនៃពិភពលោក បើទោះបីជា MOOCs អាចបំពេញតម្រូវការផ្សេងៗគ្នា របស់ក្រុមគោលដៅខុសៗគ្នានៅភាគខាងត្បូងនៃពិភពលោកយ៉ាងណាក៏ដោយ។

### ប្រអប់ទី ១២៖ ឆ្ពោះទៅការអប់រំកម្រិតឧត្តមសិក្សាហួសផុតពីទម្រង់បែបប្រពៃណី

រូបភាពដែលយើងមានជាធម្មតាអំពីគ្រឹះស្ថានឧត្តមសិក្សា គឺកន្លែងមួយ ដែលមនុស្សទៅតែម្តងក្នុងជីវិតរបស់ពួកគេ ក្នុងអាយុចន្លោះពី ១៨ ដល់ ២២ ឆ្នាំ និងរៀននៅទីនោះរយៈពេល ៤ ឆ្នាំ។ យើងគិតឃើញពីថ្នាក់រៀន និងសាស្ត្រាចារ្យ ដែលជាប្រភពផ្តល់ព័ត៌មានជាចម្បង និងសកលវិទ្យាល័យ ដែលជាមជ្ឈមណ្ឌលសម្រាប់ការរៀនសូត្រ។

ប៉ុន្តែរូបភាពបែបនេះកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។កន្លែងធ្វើការកំពុងទាមទារនូវជំនាញផ្សេងៗ ដូចជា ជំនាញប្រាស្រ័យទាក់ទង និងគិតពិចារណាល្អិតល្អន់ ដែលយើងងាយស្រួលទទួលបាន តាមរយៈការរៀនសូត្រក្រៅផ្លូវការ ជាងតាមគ្រឹះស្ថាននានា។ ដូចគ្នាដែរ វិធីសាស្ត្រថ្មីៗ ដូចជា ការអប់រំពីចំងាយ និងការរៀនសូត្រអនឡាញ កំពុងធ្វើឲ្យការផ្លាស់ប្តូរបទពិសោធន៍របស់និស្សិត សូម្បីតែបទពិសោធន៍ក្នុងបរិវេណសកលវិទ្យាល័យរបស់ពួកគេ។

ប្រភព៖ Butcher, N. and Hoosen, S. 2014. A Guide to Quality in Post-Traditional Online Higher Education. Dallas, TX, Academic Partnerships.

[៩១] Daniel, op. cit.

## បញ្ហាប្រឈមចំពោះគំរូសកលវិទ្យាល័យបែបប្រពៃណី

បញ្ហាប្រឈមមួយ ក្នុងចំណោមបញ្ហាប្រឈមធំៗសម្រាប់ការអប់រំកម្រិតឧត្តមសិក្សានាពេលបច្ចុប្បន្ននេះ គឺថាតើការអប់រំឧត្តមសិក្សាអាចឆ្លើយតបចំពោះតម្រូវការគុណវឌ្ឍិវិជ្ជាជីវៈក្នុងទ្រង់ទ្រាយធំក្នុងសកលលោក ហើយក្នុងពេលជាមួយគ្នា នៅតែរក្សាតួនាទីសំខាន់របស់ខ្លួនក្នុងការបណ្ដុះបណ្ដាលសម្រាប់ ការស្រាវជ្រាវ និងតាមរយៈ ការស្រាវជ្រាវ ដោយរបៀបណា។ កិច្ចសន្យាសង្គម ដែលភ្ជាប់ទំនាក់ទំនងគ្រឹះស្ថានឧត្តមសិក្សា ជាមួយនឹងសង្គមទាំងមូល ចាំបាច់ត្រូវកំណត់សារជាថ្មី ក្នុងបរិបទនៃការកើនឡើងនូវការប្រកួតប្រជែងក្នុងសកលលោកទាំងមូល។ នេះនាំឲ្យមានសំណួរជាច្រើនអំពីអនាគតនៃគំរូសកលវិទ្យាល័យ ដែលយើងធ្លាប់ដឹងកន្លងមក។

> កិច្ចសន្យាសង្គម ដែលភ្ជាប់ទំនាក់ទំនងគ្រឹះស្ថានឧត្តមសិក្សា ជាមួយនឹងសង្គមទាំងមូល ចាំបាច់ត្រូវកំណត់សារជាថ្មី ក្នុងបរិបទនៃការកើនឡើងនូវការប្រកួតប្រជែងក្នុងសកលលោកទាំងមូល។

ជាការពិត ទិដ្ឋភាពនៃការអប់រំឧត្តមសិក្សា កំពុងមានការផ្លាស់ប្ដូរ តាមរយៈការធ្វើពិពិធកម្មរចនាសម្ព័ន្ធ និងគ្រឹះស្ថាន អន្តរជាតិតូបនីយកម្មនៃការអប់រំឧត្តមសិក្សា និងការបង្កើតកម្មវិធី MOOCs ដូចបង្ហាញខាងលើ ការលេចឡើងនូវវប្បធម៌វាយតម្លៃគុណភាពព និងការឆ្លើយតបនៃការរៀនសូត្រ ក៏ដូចជាការកើនឡើងនូវភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ ការផ្លាស់ប្ដូរបរិបទបែបនេះមានភាពពាក់ព័ន្ធខ្លាំងលើការផ្ដល់ហិរញ្ញប្បទាន និងធនធានមនុស្ស វាធ្វើឲ្យមានការចោទសួរលើទម្រង់នៃអភិបាលកិច្ចអប់រំដែលមានកន្លងមក និងធ្វើឲ្យមានការព្រួយបារម្ភអំពីគោលការណ៍ស្វ័យភាព និងសេរីភាពខាងផ្នែកសិក្សាធិការ ដែលជាមូលដ្ឋាននៃគំរូសកលវិទ្យាល័យបែបប្រពៃណី។

## ការដាក់ចំណាត់ថ្នាក់ឲ្យសកលវិទ្យាល័យៈ ការប្រើប្រាស់ចំគោលដៅ និងខុសគោលដៅ[៩២]

ការដាក់ចំណាត់ថ្នាក់ឲ្យសកលវិទ្យាល័យ ឆ្លុះបញ្ចាំងពីនិន្នាការដ៏សំខាន់ នៃចរន្តអន្តរជាតិតូបនីយកម្មនៃការអប់រំឧត្តមសិក្សា និងការកើនឡើងនូវការចាប់អារម្មណ៍លើការប្រៀបធៀបគុណភាពនៃគ្រឹះស្ថានឧត្តមសិក្សា។ ខណៈពេលដែលចំណាប់អារម្មណ៍លើការដាក់ចំណាត់ថ្នាក់ឲ្យសកលវិទ្យាល័យមានការកើនឡើងយ៉ាងណាក៏ដោយ គេក៏បានឮការរិះគន់ពីសាស្ត្រាចារ្យ

[៩២] ដកស្រង់ចេញពី Marope, P.T.M., Wells, P.J. and Hazelkorn, E. 2013. Rankings and Accountability in Higher Education: Uses and Misuses. Paris, UNESCO.

និស្សិត អ្នកផ្តល់សេវាអប់រំ អ្នកតាក់តែងគោលនយោបាយ និងទីភ្នាក់ងារអភិវឌ្ឍន៍នានាផងដែរ។ ខាងផ្នែកវិជ្ជមាន ការដាក់ចំណាត់ថ្នាក់បែបនេះ គឺជាការឆ្លើយតបចំពោះការកើនឡើងនូវការចង់បានព័ត៌មានងាយៗអំពី "គុណភាព" នៃគ្រឹះស្ថានឧត្តមសិក្សា។ តម្រូវការបែបនេះត្រូវបានជម្រុញ ដោយសារភាពចាំបាច់ ក្នុងការធ្វើការសម្រេចចិត្តត្រឹមត្រូវអំពីសកលវិទ្យាល័យក្នុងបរិបទនៃការរីកចម្រើនខ្លាំងផ្នែកឧត្តមសិក្សា និងការកើនឡើងនូវចំនួនគ្រឹះស្ថានដែលផ្តល់សេវានេះ។ សម្រាប់មនុស្សជាច្រើននាក់ ការដាក់ចំណាត់ថ្នាក់បែបនេះ ក៏បានលើកទឹកចិត្តឲ្យមានតម្លាភាពព័ត៌មាន និងគណនេយ្យភាពរបស់គ្រឹះស្ថានឧត្តមសិក្សាផងដែរ។ ប៉ុន្តែ អ្នករិះគន់វិញអះអាងថា ការដាក់ចំណាត់ថ្នាក់អាចបង្វែរការផ្តោតការយកចិត្តទុកដាក់របស់សកលវិទ្យាល័យនានា ពីការបង្រៀន និងការទទួលខុសត្រូវសង្គម ទៅរកការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដែលផ្តល់តម្លៃដោយសូចនាករ ដែលគេប្រើប្រាស់ សម្រាប់ការដាក់ចំណាត់ថ្នាក់បែបនេះ។ លើសពីនេះ ក៏មានការព្រួយបារម្ភដែរថា តាមរយៈការប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលមានកម្រិតលើសកលវិទ្យាល័យនានាក្នុងសកលលោក និងដោយសារតែបំណងប្រាថ្នាចង់បានឈ្មោះក្នុងបញ្ជីសកលវិទ្យាល័យកំពូលៗទាំង ២០០ ក្នុងពិភពលោក ជាតុពិត ការដាក់ចំណាត់ថ្នាក់នេះលើកទឹកចិត្តឲ្យគ្រឹះស្ថានឧត្តមសិក្សាចូលរួមក្នុងប្រភេទតែមួយ ដែលធ្វើឲ្យគ្រឹះស្ថានទាំងនេះមិនសូវជាឆ្លើយតប និងមិនសូវជាពាក់ព័ន្ធ ទៅនឹងបរិបទជាក់ស្តែង។ ដោយសារតែការដាក់ចំណាត់ថ្នាក់នេះត្រូវបានគេលើកឡើងថាលំអៀងទៅរកចំណុចខ្លាំងរបស់គ្រឹះស្ថានដែលទទួលបានចំណាត់ថ្នាក់ខ្ពស់ជាងគេទាំង ២០០ វាក៏មានភាពពាក់ព័ន្ធសំខាន់ជាមួយនឹងសមធម៌ផងដែរ។

## ■ តួនាទីរបស់អ្នកអប់រំក្នុងសង្គមពុទ្ធិ

### បច្ចេកវិទ្យាឌីជីថលមិនបានជំនួសតួនាទីរបស់គ្រូឡើយ[៩៣]

ការកើនឡើងដ៏ខ្លាំងនូវបរិមាណព័ត៌មាន និងចំណេះដឹងដែលគេអាចរកបាន តម្រូវឲ្យមានការប្រើប្រាស់វិធីសាស្រ្តបញ្ជូន ផ្សព្វផ្សាយ និងទទួលព័ត៌មាន និងចំណេះដឹងទាំងនេះប្រកបដោយគុណភាព នៅកម្រិតបុគ្គល និងកម្រិតសមូហភាព។ ដោយសារតែសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍បច្ចុប្បន្ននេះ គ្រូគួរបំពេញតួនាទីជាអ្នកផ្តល់ការណែនាំ ដែលផ្តល់លទ្ធភាពឲ្យអ្នករៀនសូត្រ ចាប់ពីការអប់រំកុមារតូច រហូតដល់ការរៀនសូត្រនៅកម្រិតផ្សេងទៀត ដើម្បីឲ្យអ្នករៀនសូត្រអាចធ្វើការអភិវឌ្ឍខ្លួន ក្នុងពេលដែលបរិមាណចំណេះដឹងចេះតែបន្តកើនឡើងឥតឈប់ឈរ។ ក្នុងកាលៈទេសៈទាំងនេះ មានការព្យាករដំបូងៗថា អាជីពបង្រៀននឹងត្រូវបាត់បង់បន្តិចម្តងៗ។ អ្នកដែលធ្វើការព្យាករបែបនេះ អះអាងថា បច្ចេកវិទ្យាឌីជីថលថ្មីៗនឹងជំនួសតួនាទីរបស់គ្រូបន្តិចម្តងៗ ដោយសារតែបច្ចេកវិទ្យាទាំងនេះអាចផ្តល់ចំណេះដឹងក្នុងទ្រង់ទ្រាយធំ កាន់តែងាយស្រួលប្រើប្រាស់ និងធ្វើឲ្យគេអាចសន្សំសំចៃមធ្យោបាយ និងធនធាននានា ក្នុងពេលដែលតម្រូវការអប់រំកាន់តែមានការកើនឡើង។ ប៉ុន្តែ យើងត្រូវទទួលស្គាល់ថា ការព្យាករបែបនេះលែងសមហេតុសមផលទៀតហើយ៖ អាជីពបង្រៀនដែលមានប្រសិទ្ធភាព នៅតែត្រូវបានគេចាត់ទុកថាជាអាទិភាពមួយនៃគោលនយោបាយអប់រំ ក្នុងគ្រប់ប្រទេសទាំងអស់។

> គ្រូគួរបំពេញតួនាទីជាអ្នកផ្តល់ការណែនាំ ដែលផ្តល់លទ្ធភាពឲ្យអ្នករៀនសូត្រ ចាប់ពីការអប់រំកុមារតូច រហូតដល់ការរៀនសូត្រនៅកម្រិតផ្សេងទៀត ដើម្បីឲ្យអ្នករៀនសូត្រអាចធ្វើការអភិវឌ្ឍខ្លួន ក្នុងពេលដែលបរិមាណចំណេះដឹងចេះតែបន្តកើនឡើងឥតឈប់ឈរ។

[៩៣] ដកស្រង់ចេញពី Haddad, G. 2012. Teaching: A profession with a future. Worlds of Education. No. 159.

## ការផ្លាស់ប្តូរនិន្នាការកាត់បន្ថយតម្លៃវិជ្ជាជីវៈរបស់អាជីពបង្រៀន

ប្រសិនបើគេចង់ឲ្យការអប់រំចូលរួមចំណែកឲ្យបុគ្គលម្នាក់ៗអាចសម្រេចបានពេញលេញនូវសក្តានុពលរបស់ខ្លួន និងរួមចំណែកចំពោះគំរូថ្មីនៃការអភិវឌ្ឍ គ្រូ និងអ្នកអប់រំផ្សេងទៀតនៅតែជាតួអង្គសំខាន់។ ប៉ុន្តែ បើទោះបីជាគេតែងលើកឡើងពីសារៈសំខាន់របស់គ្រូក៏ដោយ និន្នាការជាច្រើនបានបង្ហាញពីការថយចុះនូវតម្លៃវិជ្ជាជីវៈរបស់គ្រូ ទាំងនៅភាគខាងជើង និងភាគខាងត្បូងរបស់ពិភពលោក។ និន្នាការទាំងនេះមានដូចជាការកើនឡើងនូវចំនួនគ្រូដែលពុំមានសមត្ថភាពគ្រប់គ្រាន់ មួយផ្នែក ជាការឆ្លើយតបចំពោះកង្វះចំនួនគ្រូ និងមួយផ្នែកទៀតដោយសារមូលហេតុហិរញ្ញវត្ថុ។ ការជួលគ្រូម្តងម្កាល ដូចជា គ្រូជាប់កិច្ចសន្យា ជាពិសេសនៅកម្រិតឧត្តមសិក្សា ដែលកាន់តែពឹងផ្អែកលើគ្រូពីខាងក្រៅ ដើម្បីឆ្លើយតបទៅនឹងបន្ទុកការងារបង្រៀន ការថយចុះនូវស្វ័យភាពរបស់គ្រូ ការថមថយគុណភាពនៃវិជ្ជាជីវៈបង្រៀន ដោយសារតែការធ្វើតេស្តជាលក្ខណៈស្តង់ដា និងការវាយតម្លៃគ្រូ ការប្រើប្រាស់បច្ចេកទេសគ្រប់គ្រងបែបឯកជនតាមគ្រឹះស្ថានអប់រំ និងគម្លាតបៀវត្សរ៍របស់គ្រូ និងអ្នកជំនាញក្នុងវិស័យផ្សេងទៀត ក្នុងប្រទេសជាច្រើន។

## ប្រអប់ទី ១៣៖ គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិតខ្ពស់ និងទទួលបានការផ្តល់តម្លៃខ្ពស់ ក្នុងប្រទេសហ្វាំងឡង់

បើតាមកម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA) នៃអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ប្រទេសហ្វាំងឡង់ គឺជាប្រទេសមួយ ក្នុងចំណោមប្រទេសនានា ដែលទទួលបានពិន្ទុខ្ពស់ជាងគេខាងអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ សម្រាប់កុមារអាយុ ១៥ ឆ្នាំ។ ខណៈពេលដែលជោគជ័យនេះអាចកើតឡើងដោយសារកត្តាជាច្រើន កត្តាធំជាងគេគឺដោយសារតែគ្រូដែលបានទទួលការបណ្តុះបណ្តាលកម្រិតខ្ពស់ បំពេញតួនាទីប្រកបដោយវិជ្ជាជីវៈ និងទទួលបានការគោរពខ្ពស់ របស់ប្រទេសហ្វាំងឡង់។ ក្នុងប្រទេសហ្វាំងឡង់ ការបង្រៀនគឺជាអាជីពពិសេសមួយ ហើយសង្គមហ្វាំងឡង់ផ្តល់ការជឿជាក់លើប្រព័ន្ធអប់រំ និងលើគ្រូ។ គ្រូមានសមត្ថភាពខ្ពស់ (តម្រូវឲ្យមានសញ្ញាបត្រយ៉ាងណាស់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ សម្រាប់ការងារបង្រៀនពេញម៉ោង) ហើយការជ្រើសរើសគ្រូធ្វើឡើងហ្មត់ចត់ ដោយជ្រើសរើសយកតែបេក្ខជនដែលមានសមត្ថភាពខ្ពស់បំផុត ឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូប៉ុណ្ណោះ។ គ្រូមានសមត្ថភាពខ្ពស់ខាងចំណេះដឹង និងខាងគរុកោសល្យ និងជាអ្នកជំនាញខាងការងារសិក្សាធិការដែលមានស្វ័យភាព និងចេះឆ្លុះបញ្ចាំងល្អិតល្អន់។

ប្រភព៖ Butcher, N. and Hoosen, S. 2014. A Guide to Quality in Post-Traditional Online Higher Education. Dallas, TX, Academic Partnerships.

ដូច្នេះ យើងត្រូវគិតឡើងវិញពីខ្លឹមសារ និងគោលបំណងនៃការអប់រំ និងការបណ្តុះបណ្តាលគ្រូ។ គ្រូចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលពីរបៀបសម្របសម្រួលការរៀនសូត្រ យល់ពីភាពចម្រុះ មានបរិយាប័ន្ន និងអភិវឌ្ឍសមត្ថភាព ដើម្បីអាចរស់នៅជាមួយគ្នា និងការពារបរិស្ថាន ក៏ដូចជាធ្វើឲ្យបរិស្ថានកាន់តែមានភាពល្អប្រសើរ។ គ្រូត្រូវតែបណ្តុះនូវបរិយាកាសក្នុងថ្នាក់រៀន ដែលសិស្សផ្តល់ការគោរពដល់គ្នាទៅវិញទៅមក និងមានសុវត្ថិភាព លើកទឹកចិត្តឲ្យ មានការផ្តល់តម្លៃឲ្យខ្លួនឯង និងមានស្វ័យភាព ក៏ដូចជាចេះប្រើប្រាស់យុទ្ធសាស្ត្រ គរុកោសល្យ និងសម្ភារឧបទ្ទេសច្រើនប្រភេទ។ គ្រូក៏ត្រូវកសាងទំនាក់ទំនងប្រកបដោយផលិតភាពជាមួយនឹងមាតាបិតាសិស្ស និងសហគមន៍ផងដែរ។ គ្រូចាំបាច់ត្រូវធ្វើការងារជាក្រុម ជាមួយនឹងគ្រូផ្សេងទៀត ដើម្បីប្រយោជន៍រួមរបស់សាលារៀនទាំងមូល។ គ្រូគួរស្គាល់សិស្សរបស់ខ្លួន និងគ្រួសាររបស់ពួកគេ និងអាចផ្សារភ្ជាប់ទំនាក់ទំនងការបង្រៀនជាមួយនឹងបរិបទជាក់លាក់របស់ពួកគេ។ គ្រូគួរអាចជ្រើសរើសខ្លឹមសារបង្រៀនណាដែលពាក់ព័ន្ធ និងយកខ្លឹមសារទាំងនេះមកប្រើប្រាស់ សម្រាប់អភិវឌ្ឍសមត្ថភាពរបស់សិស្ស។ គ្រូគួរប្រើប្រាស់បច្ចេកវិទ្យា រួមជាមួយនឹងសម្ភារផ្សេងទៀត ជាឧបករណ៍សម្រាប់បម្រើដល់ការរៀនសូត្រ។ គ្រូក៏គួរទទួលបានការលើកទឹកចិត្ត ដើម្បីបន្តការរៀនសូត្រ និងអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនផងដែរ។

យើងក៏ត្រូវផ្តល់ឲ្យគ្រូនូវជីវភាពរស់នៅ និងលក្ខខណ្ឌការងារ រួមនឹងបៀវត្សរ៍ និងសក្តានុពលអាជីពដែលកាន់តែទាក់ទាញ ផ្តល់ការលើកទឹកចិត្ត និងមានស្ថិរភាពផងដែរ។ នេះជាអ្វីដែលមានសារៈសំខាន់ជាចាំបាច់ ប្រសិនបើយើងចង់បង្ការមិនឲ្យមានការបាត់បង់ចំណាប់អារម្មណ៍លើវិជ្ជាជីវៈនេះ ដែលយើងចាត់ទុកថាជាវិជ្ជាជីវៈជាមូលដ្ឋានដ៏សំខាន់បំផុតនេះ។

យើងក៏ត្រូវផ្តល់ឲ្យគ្រូនូវជីវភាពរស់នៅ និងលក្ខខណ្ឌការងារ រួមនឹងបៀវត្សរ៍ និងសក្តានុពលអាជីព ដែលកាន់តែទាក់ទាញ ផ្តល់ការលើកទឹកចិត្ត និងមានស្ថិរភាពផងដែរ។ នេះជាអ្វីដែលមានសារៈសំខាន់ជាចាំបាច់ ប្រសិនបើយើងចង់បង្ការមិនឲ្យមានការបាត់បង់ចំណាប់អារម្មណ៍លើវិជ្ជាជីវៈនេះ ដែលយើងចាត់ទុកថាជាវិជ្ជាជីវៈជាមូលដ្ឋានដ៏សំខាន់បំផុតនេះ។ ត្រូវតែមានការកែសម្រួល និងពិចារណាឡើងវិញលើបេសកកម្ម និងអាជីពរបស់គ្រូជាពិសេស នៅពេលដែលវិស័យអប់រំកាន់តែមានតម្រូវការថ្មីៗ និងប្រឈមនឹងបញ្ហាថ្មីៗ ក្នុង

ពិភពលោកសកលភាវូបនីយកម្មដែលចេះតែមានការផ្លាស់ប្តូរឥតឈប់ឈរ។ ដើម្បីសម្រេចគោលដៅនេះ ការបណ្តុះបណ្តាលគ្រូនៅគ្រប់កម្រិតទាំងអស់ ចាប់ពីកម្រិតទូទៅបំផុត រហូតដល់កម្រិតឯកទេសបំផុត ត្រូវតែបញ្ចូលសារៈសំខាន់នៃស្មារតីពហុជំនាញ ដែលផ្តល់លទ្ធភាពឲ្យគ្រូ និងសាស្ត្រាចារ្យរបស់យើងអាចនាំយើងដើរតាមផ្លូវនៃភាពច្នៃប្រឌិត និងការគិតពិចារណាសមហេតុសមផល ឆ្ពោះទៅសម្រេចវឌ្ឍនភាព និងការអភិវឌ្ឍសម្រាប់មនុស្សជាតិ ហើយក្នុងពេលជាមួយគ្នាគោរពបេតិកភ័ណ្ឌធម្មជាតិ និងវប្បធម៌រួមរបស់យើង។

## បញ្ហាប្រឈមសម្រាប់អាជីពជាអ្នកសិក្សាស្រាវជ្រាវ

មុខមាត់ និងលក្ខខណ្ឌការងាររបស់អ្នកដែលមានអាជីពខាងសិក្សាស្រាវជ្រាវ នៅទូទាំងពិភពលោក កំពុងទទួលរងការគំរាមកំហែង ដោយសារតែឧបសគ្គធំធេងខាងការទទួលបានសេវា និងថវិកា។ ខណៈពេលដែលអាជីពនេះជួបបញ្ហាប្រឈមផ្សេងគ្នាតាមតំបន់ផ្សេងគ្នា អ្នកដែលចាប់យកអាជីពនេះ កំពុងប្រឈមនឹងការលំបាកធ្ងន់ធ្ងរគ្រប់ទិសទីទាំងអស់។ ការពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតឧត្តមសិក្សា ធ្វើឲ្យគេមានតម្រូវការគ្រូច្រើននាក់សម្រាប់ការបង្រៀននៅសកលវិទ្យាល័យ ប៉ុន្តែគេពុំបានរៀបចំអ្នកសិក្សាស្រាវជ្រាវដែលមានសមត្ថភាពក្នុងល្បឿនមួយឲ្យបានលឿនគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការនេះឡើយ។ គេអាចនិយាយបានថា មានគ្រូនៅសកលវិទ្យាល័យរហូតដល់ពាក់កណ្តាល ដែលមានសញ្ញាបត្រត្រឹមតែបរិញ្ញាបត្រ។ ក្នុងប្រទេសជាច្រើនលើពិភពលោក បុគ្គលិកសិក្សាពាក់កណ្តាលនឹងចូលនិវត្តន៍ក្នុងពេលឆាប់ៗនេះ។ មានអ្នកដែលមានសញ្ញាបត្របណ្ឌិតតិចតួចប៉ុណ្ណោះដើម្បីជំនួសអ្នកដែលចាកចេញពីវិជ្ជាជីវៈនេះ ដោយសារតែបេក្ខជនថ្នាក់បណ្ឌិតជាច្រើននាក់បោះបង់ចោលការសិក្សា ឬទៅធ្វើការងារខាងក្រៅការងារសិក្សាស្រាវជ្រាវវិញ ដោយសារតែបៀវត្សរ៍ដែលពួកគេទទួលបាន សម្រាប់ការងាររបស់ពួកគេពុំមានកម្រិតគ្រប់គ្រាន់។ក្នុងប្រទេសនៅអាមេរិចឡាទីនជាច្រើន គ្រូកម្រិតឧត្តមសិក្សារហូតដល់ ៨០ ភាគរយ ធ្វើការងារក្រៅម៉ោង។ និន្នាការបែបនេះធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃការបង្រៀន ដោយសារតែគ្រូសកលវិទ្យាល័យមិនអាចផ្តោតការយកចិត្តទុកដាក់ពេញលេញលើការងារបង្រៀនរបស់ខ្លួនឡើយ ចុះទម្រាំការស្រាវជ្រាវទៀត។ លើសពីនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទីផ្សារការងារសម្រាប់អ្នកដែលមានអាជីពខាងសិក្សាស្រាវជ្រាវចេះតែមានការរីកចម្រើន៖ អ្នកជំនាញខាងសិក្សាស្រាវជ្រាវតែងផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀតជាអន្តរជាតិ។ ខណៈពេលដែលបៀវត្សរ៍ខ្ពស់ គឺជាកត្តាលើកទឹកចិត្តធំជាងគេ ដែលនាំឲ្យមានលំហូរបែបនេះ កត្តាផ្សេងទៀតដូចជា លក្ខខណ្ឌការងារល្អប្រសើរ ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ការងារ

ស្រាវជ្រាវ ក៏ដូចជាឱកាសរីកចម្រើន និងសេរីភាពខាងការងារសិក្សាស្រាវជ្រាវ។ ករណី "លំហូរចេញនូវធនធានខួរក្បាល (brain drain)" និង "ចរាចរណ៍នៃធនធានខួរក្បាល (brain circulation)" ដែលនឹងត្រូវលើកយកមកពន្យល់លំអិតនៅផ្នែកខាងក្រោយ បានបង្កការលំបាកសម្រាប់ការតាក់តែងគោលនយោបាយ និងការផ្តល់ការអប់រំកម្រិតឧត្តមសិក្សា។

## ការអប់រំ ក្រៅវិស័យក្នុងប្រព័ន្ធ

ចុងក្រោយ យើងត្រូវរំឭកឡើងវិញពីតួនាទី ដែលអ្នកអប់រំបំពេញ ក្នុងការធានាយ៉ាងណាឲ្យមានការរៀនសូត្រពេញមួយជីវិត និងក្រៅប្រព័ន្ធអប់រំក្នុងប្រព័ន្ធ។ សារៈសំខាន់នៃតួនាទីនេះត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងកំណើននៃកម្មវិធីបណ្តុះបណ្តាលទូទាំងពិភពលោក សម្រាប់អ្នកអប់រំ ដែលធ្វើការងារក្នុងបរិបទក្រៅប្រព័ន្ធ និងក្រៅផ្លូវការ។ អ្នកអប់រំទាំងនេះផ្តល់ឱកាសរៀនសូត្រ តាមរយៈមជ្ឈមណ្ឌលសហគមន៍ ស្ថាប័នសាសនា មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កម្មវិធីអក្សរកម្ម សមាគមអ្នកស្ម័គ្រចិត្ត ក្រុមយុវជន កម្មវិធីកីឡា និងកម្មវិធីសិល្បៈ។ គុណតម្លៃនៃឱកាសរៀនសូត្របែបនេះ សម្រាប់ការអភិវឌ្ឍ និងសុខុមាលភាពរបស់បុគ្គលម្នាក់ៗ និងរបស់សហគមន៍មានទំហំធំធេង។

> ចុងក្រោយ យើងត្រូវរំឭកឡើងវិញពីតួនាទី ដែលអ្នកអប់រំបំពេញក្នុងការធានាយ៉ាងណាឲ្យមានការរៀនសូត្រពេញមួយជីវិត និងក្រៅប្រព័ន្ធអប់រំក្នុងប្រព័ន្ធ។

# ៣. ការតាក់តែងគោលនយោបាយអប់រំ ក្នុងពិភពលោកដែលពោរពេញដោយភាពស្មុគស្មាញ



# ៣. ការតាក់តែងគោលនយោបាយអប់រំ ក្នុងពិភពលោកដែលពោរពេញដោយភាពស្មុគស្មាញ

សកលភាវូបនីយកម្ម កាន់តែមានឥទ្ធិពលលើស្វ័យភាពរបស់ប្រជាជាតិ និងរដ្ឋនានា និងធ្វើឲ្យការតាក់តែងគោលនយោបាយកាន់តែមានលក្ខណៈស្មុគស្មាញ។ ឧទាហរណ៍ បើទោះបីជាសកម្មភាពសេដ្ឋកិច្ចកាន់តែមានលក្ខណៈសកលភាវូបនីយកម្មក៏ដោយ ការសម្រេចចិត្ត និងការធ្វើសកម្មភាព នៅកម្រិតគោលនយោបាយ នៅតែធ្វើឡើងនៅថ្នាក់ជាតិនៅឡើយ។ ដូច្នេះ អ្នកតាក់តែងគោលនយោបាយ ថ្នាក់ជាតិ កាន់តែមានការលំបាក ក្នុងការឆ្លើយតប និងទប់ទល់ចំពោះផលវិបាកដែលសកលភាវូបនីយកម្ម មានមកលើការអភិវឌ្ឍជាតិ។ ឧទាហរណ៍ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ ២០០៨ ឬការកើនឡើងនូវអត្រាអត់ការងារធ្វើរបស់យុវជន នៅតាមប្រទេសនានានៅភាគខាងជើង គឺជាភស្តុតាងដែលបង្ហាញពីតថភាពនេះ។ ដូចគ្នានេះដែរ ការកើនឡើងនូវចល័តភាពរបស់អ្នករៀនសូត្រ និងអ្នកធ្វើការ ឆ្លងព្រំដែនរបស់ប្រទេស និន្នាការថ្មីនៃចរាចរណ៍ធនធានខួរក្បាល ក៏ដូចជាទម្រង់ថ្មីៗនៃការចូលរួមសហការរបស់ប្រជាពលរដ្ឋ កំពុងបង្កឲ្យមានបញ្ហាប្រឈមថ្មីៗបន្ថែមទៀត សម្រាប់ការតាក់តែងគោលនយោបាយនៅថ្នាក់ជាតិ។ ក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលឧទាហរណ៍ថាតើចំណុចទាំងអស់នេះមានផលប៉ះពាល់យ៉ាងដូចម្ដេចដល់ការតាក់តែងគោលនយោបាយ។

## ■ ការកើនឡើងនូវតម្លាតរវាងការអប់រំ និងការងារ

### កំណើនការងារមានកម្រិតទាប ហើយភាពងាយរងគ្រោះនៃការងារមានការកើនឡើង

ចរន្តខ្លាំងក្លានៃសកលភាវូបនីយកម្មសេដ្ឋកិច្ច កំពុងធ្វើឲ្យកំណើនការងារមានកម្រិតទាប បង្កើនភាពគ្មានការងារធ្វើរបស់យុវជន និងការងារដែលងាយរងគ្រោះ ដែលមានផលប៉ះពាល់ដល់សង្គម នៅភាគខាងជើងផង និងភាគខាងត្បូងផងនៃសកលលោក។ កាលពីពេលថ្មីៗនេះ កំណើនការងារដែលមានកម្រិតទាប បានបង្កផលប៉ះពាល់ដល់ប្រទេសមួយចំនួននៅអឺរ៉ុប

ដែលមនុស្សជំនាន់ថ្មីត្រូវប្រឈមនឹងបញ្ហាមានការងារធ្វើយឺតពេល ឬពុំអាចបានការងារធ្វើតែម្តង។ ប៉ុន្តែ យើងគួររំឭកឡើងវិញថា បញ្ហាប្រឈមក្នុងការផ្គូរផ្គងជំនាញ ដែលទទួលបានតាមរយៈការអប់រំ និងការបណ្តុះបណ្តាល ជាមួយនឹងតម្រូវការក្នុងទីផ្សារការងារ មិនមែនជារឿងថ្មីនោះទេ។[៩៤] លើសពីនេះ យើងគួរកត់សម្គាល់ទៀតថា បើទោះបីជាភាពគ្មានការងារធ្វើរបស់យុវជន គឺជាសញ្ញាដែលបង្ហាញពីភាពមិនស៊ីគ្នារវាងការអប់រំ ការបណ្តុះបណ្តាល និងការងារក៏ដោយ បញ្ហានេះក៏មានទំនាក់ទំនងជាមួយនឹងជម្រើសគោលនយោបាយសេដ្ឋកិច្ច និងការទទួលខុសត្រូវផ្នែកនយោបាយផងដែរ។ ទោះជាយ៉ាងណាក៏ដោយ និន្នាការការងារបច្ចុប្បន្ននេះកំពុងអំពាវនាវឲ្យមានការសួរដេញដោលទំនាក់ទំនងដែលត្រូវបានបង្កើតយូរមកហើយរវាងការអប់រំក្នុងប្រព័ន្ធ និងការងារ ដែលវាក៏ជាហេតុផលនាំឲ្យតួអង្គអភិវឌ្ឍន៍អន្តរជាតិជាច្រើនធ្វើវិនិយោគលើការអប់រំក្នុងប្រព័ន្ធ ដើម្បីគោលបំណងអភិវឌ្ឍធនធានមនុស្សផងដែរ។

## ការខកចិត្តកាន់តែខ្លាំងរបស់យុវជន

ដោយសារតែការងារដែលសមស្របកាន់តែខ្សត់ទៅៗ វាបានបង្កើនការខកចិត្តរបស់គ្រួសារ និងយុវជនដែលទើបបញ្ចប់ការសិក្សា នៅជុំវិញពិភពលោក។ ការកើនឡើងនូវកម្រិតនៃការទទួលបានការអប់រំក្នុងយុវជន និងអ្នកធ្វើការងារទូទៅ ធ្វើឲ្យមានការប្រកួតប្រជែងដណ្តើមការងារកាន់តែខ្លាំងឡើង។ក្នុងប្រទេសជាច្រើននៅភាគខាងត្បូងនៃសកលលោកការចូលទៅក្នុងទីផ្សារការងាររបស់យុវជនជាច្រើននាក់ ដែលជារឿយៗ ជាក្រុមដំបូងក្នុងសហគមន៍របស់ពួកគេ ដែលបានទទួលប្រយោជន៍ពីការពង្រីកលទ្ធភាពទទួលបានការអប់រំ កំពុងធ្វើឲ្យគម្លាតរវាងបំណងប្រាថ្នា ដែលបង្កើតឡើងដោយការអប់រំក្នុងប្រព័ន្ធ និងស្ថានភាពខ្សត់ការងារធ្វើកាន់តែរីកធំឡើង។ មនុស្សជាច្រើន ដែលចូលទៅក្នុងការអប់រំក្នុងប្រព័ន្ធជាលើកទីមួយ នឹងលែងអាចទទួលបានប្រយោជន៍ពីគុណវឌ្ឍិអប់រំ ដូចដែលពួកគេរំពឹងទុក ពោលគឺបានការងារធ្វើ និងមានអនាគតរុងរឿង ទៀតហើយ។ ភាពស្រងាកចិត្តបែបនេះកំពុងមានការកើនឡើង ក្នុងក្រុមមួយចំនួនក្នុងសង្គម និងក្នុងប្រទេសខ្លះ ដែលការអប់រំ ត្រូវបានប្រើប្រាស់ជាមធ្យោបាយដែលមានប្រសិទ្ធភាព ដើម្បីទទួលបានស្ថានភាពកាន់តែប្រសើរក្នុងសង្គម និងបង្កើនសុខុមាលភាពរបស់ខ្លួន។ ក្តីសង្ឃឹមថានឹងទទួលបានស្ថានភាពកាន់តែប្រសើរក្នុងសង្គម ដោយសារតែការពង្រីកក្នុងទ្រង់ទ្រាយធំនូវលទ្ធភាពទទួលបានឱកាសអប់រំ ចាប់តាំងពីទសវត្សរ៍ ១៩៩០ មក កាន់តែរលាយបាត់រូបរាងបន្តិចម្តងៗ មិនត្រឹមតែក្នុងប្រទេសជាច្រើន នៅ

[៩៤] See, for example: Blaug, M. 1965. The Rate of Return on Investment in Education in Great Britain. The Manchester School. Vol. 33.

ភាគខាងត្បូងនោះទេ ប៉ុន្តែថែមទាំងនៅភាគខាងជើងទៀតផង។ យុវជនកំពុងចាប់ផ្តើមមានមន្ទិលលើ "ប្រយោជន៍ដែលបានពីការវិនិយោគ" លើច្រកអប់រំបែបប្រពៃណី ដែលគេចាត់ទុកថានាំមកនូវ "មុខមាត់ខ្ពស់។[៩៥]

ទោះជាយ៉ាងណាក៏ដោយ អ្វីដែលសំខាន់គឺត្រូវពិនិត្យឲ្យបានល្អិតល្អន់ជាងមុន និងស្វែងយល់ឲ្យបានកាន់តែច្បាស់ ពីដំណាក់កាលដែល យុវជនធ្វើអន្តរកាលចន្លោះពីការអប់រំ និងការបណ្តុះបណ្តាលទៅពេល មានការងារធ្វើ។ ការពន្យាររយៈពេលអន្តរកាលនេះ អាចកើតឡើងដោយសារមូលហេតុជាច្រើន ប៉ុន្តែមិនមែនមូលហេតុទាំងអស់ សុទ្ធតែពាក់ព័ន្ធជាមួយនឹងការមិនផ្គូរផ្គងគ្នារវាងជំនាញ និងតម្រូវការទីផ្សារការងារនោះទេ។ បើទោះបីជាគេអាចចាត់ទុករយៈពេលអន្តរកាលបែបនេះថា "ពុំមានផលិតភាព" ខាងសេដ្ឋកិច្ច សម្រាប់យុវជនក៏ដោយ វាអាចជារយៈពេលដែលយុវជនអាចទទួលបានមេរៀនសំខាន់ៗ តាមរយៈការចូលរួមក្នុងសកម្មភាពសង្គម ការធ្វើការងារស្ម័គ្រចិត្ត ការធ្វើដំណើរការ ការកម្សាន្ត សិល្បៈ និងសកម្មភាពផ្សេងទៀត។ លើសពីនេះ យុវជនដែលបានទទួលការអប់រំ បើទោះបីជាពួកគេពុំទាន់រកការងារបានធ្វើក៏ដោយ អាចជាអ្នកឈរជួរមុខ ដើម្បីចូលរួមក្នុងសកម្មភាពស៊ីវិល សង្គម និងនយោបាយ។

> ភាពស្រងាកចិត្តបែបនេះកំពុងមានការកើនឡើង ក្នុងក្រុមមួយចំនួនក្នុងសង្គម និងក្នុងប្រទេសខ្លះ ដែលការអប់រំ ត្រូវបានប្រើប្រាស់ជាមធ្យោបាយដែលមានប្រសិទ្ធភាពដើម្បីទទួលបានស្ថានភាពកាន់តែប្រសើរក្នុងសង្គម និងបង្កើនសុខុមាលភាពរបស់ខ្លួន។

[៩៥] Facer, K. 2011. Learning Futures: Education, Technology and Social Challenges. New York, Routledge.

## ការពិចារណាឡើងវិញលើទំនាក់ទំនងរវាងការអប់រំ និងពិភពការងារ ដែលមានការផ្លាស់ប្ដូរឆាប់រហ័ស

ការឆ្លើយតបជាច្រើនត្រូវបានលើកស្នើឡើង ដើម្បីឆ្លើយតបចំពោះការដាច់ទំនាក់ទំនងរវាងការអប់រំនិងការបណ្ដុះបណ្ដាលក្នុងប្រព័ន្ធ និងពិភពការងារ ដូចជា ការបណ្ដុះបណ្ដាលសារជាថ្មីដល់កម្មករនិយោជិត កម្មវិធីឱកាសទីពីរ និងការពង្រឹងភាពជាដៃគូជាមួយឧស្សាហកម្ម។ យើងក៏បានកត់សម្គាល់ឃើញផងដែរថា មានការផ្ដោតការយកចិត្តដាក់ជាងមុនលើសមត្ថភាពទៅតាមសេចក្ដីត្រូវការរបស់អាជីពការងារ។ ជាការពិត ការរីកចម្រើនដ៏លឿនខាងបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ធ្វើឲ្យគេកាន់តែមានការពិបាក ដើម្បីព្យាករថាតើនឹងមានការបង្កើតអាជីពថ្មីៗអ្វីខ្លះ និងថាតើមានតម្រូវការជំនាញពាក់ព័ន្ធអ្វីខ្លះ។ ចំណុចនេះបានជម្រុញឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីផ្ដល់នូវការអប់រំ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដែលកាន់តែឆ្លើយតបជាងមុន ដូចជា ការបង្កើនពិពិធកម្ម និងភាពបត់បែន នៃការអប់រំជាដើម ដែលផ្ដល់លទ្ធភាពឲ្យគេអាចកែសម្រួលសមត្ថភាពនានាឲ្យស្របតាមតម្រូវការ ដែលកំពុងតែមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សបាន។ វាក៏មានន័យថាជាការធានាយ៉ាងណាឲ្យបុគ្គលម្នាក់ៗកាន់តែមានភាពធន់ជាងមុន និងអាចអភិវឌ្ឍ និងអនុវត្តជំនាញត្រូវនឹងអាជីពរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពបំផុតផងដែរ។[៩៦] សមត្ថភាពទាំងនេះ តម្រូវឲ្យមានការផ្ដោតការយកចិត្តទុកដាក់បន្ថែមលើអ្វីដែលត្រូវបានគេចាត់ទុកថា "ជំនាញដែលអាចប្រើក្នុងគ្រប់ស្ថានភាព" "ជំនាញសតវត្សរ៍ទី ២១" និង "ជំនាញមិនពាក់ព័ន្ធនឹងការរៀនសូត្រចំណេះដឹង" ដូចជា ការប្រាស្រ័យទាក់ទង ចំណេះដឹងឌីជីថល ការដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម និងសហគ្រិនភាព ជាដើម។

[៩៦] UNESCO. 2011. Education and Skills for Inclusive and Sustainable Development Beyond 2015. Thematic Think Piece for the UN Task Team on the Post-2015 International Development Agenda. Paris, UNESCO.

## ប្រអប់ទី ១៤៖ ការពង្រីកឱកាសការងារ សម្រាប់យុវជន

ដោយសារតែភាពស្មុគស្មាញនៃបញ្ហាការងាររបស់យុវជន មានការលើកឡើងថា ដំណោះស្រាយចំពោះបញ្ហានេះនៅតែមានទំហំតូច ប្រសិនបើអ្នកពាក់ព័ន្ធសំខាន់ៗខកខានមិនបានធ្វើការងាររួមគ្នាដោយមានយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តគ្រប់ជ្រុងជ្រោយច្បាស់លាស់នោះ។ អភិក្រមរួម ដើម្បីសម្រេចលទ្ធផល និងផលជះកាន់តែប្រសើរជាងមុន ត្រូវបានរកឃើញថាមានប្រសិទ្ធភាព ក្នុងឧស្សាហកម្ម និងនៅតាមតំបន់ភូមិសាស្ត្រជាច្រើន។

នៅអាហ្វ្រិចខាងត្បូង ដែលក្នុងចំណោមពលរដ្ឋអាហ្វ្រិចខាងត្បូងអាយុចន្លោះពី ១៨ ដល់ ២៨ ឆ្នាំបីនាក់ មានពីរនាក់ដែលគ្មានការងារធ្វើ កម្មវិធីពន្លឿនការងារយុវជន Harambee កំពុងជួយដល់យុវជនអាហ្វ្រិចខាងត្បូងដែលមានចំណូលទាបមួយក្រុមតូច ជាស្ពាន ដើម្បី "តភ្ជាប់" ពួកគេ ជាមួយនឹងការងារដំបូងៗរបស់ពួកគេ ក្នុងវិស័យឯកជន។ បើទោះបីជាបច្ចុប្បន្ន គំនិតផ្តួចផ្តើមនេះនៅមានទំហំតូចក៏ដោយ គំនិតផ្តួចផ្តើមនេះបានបង្កើតនូវម៉ូដែលជាវិជ្ជមាន ដើម្បីឲ្យមានការចូលរួមពីវិស័យឯកជន។ ក្រុមហ៊ុនធំៗជាងគេមួយចំនួនក្នុងវិស័យលក់រាយ បដិសណ្ឋារកិច្ច និងទេសចរណ៍របស់អាហ្វ្រិចខាងត្បូង កំពុងចាប់ដៃគូជាមួយគ្នា ដើម្បីបង្កើតការងារដល់យុវជនទាំងនេះ។ ធនាគារអភិវឌ្ឍន៍អាហ្វ្រិចខាងត្បូង បានបង្កើតមូលនិធិការងារ សម្រាប់ផ្តល់ធនធាន ដែលបានពីវិនិយោគិនឯកជន និងការបង់ថ្លៃសេវារបស់និយោជក ដើម្បីផ្តល់លទ្ធភាពឲ្យគំនិតផ្តួចផ្តើម Harambee អាចពង្រីកកម្មវិធីរបស់ខ្លួនបាន។

ក្នុងប្រទេសកូស្តារីកា CAMTIC ដែលជាសមាគមក្រុមហ៊ុនបច្ចេកវិទ្យា កំពុងអនុវត្តកម្មវិធីឯកទេសមួយ ក្នុងគោលបំណងផ្គូរផ្គងយុវជនងាយរងគ្រោះ ជាមួយនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន (IT) ដែលគេត្រូវការ ដើម្បីបំពេញការងារមិនទាន់មានអ្នកធ្វើរាប់ពាន់កន្លែង ក្នុងវិស័យ IT។ គ្រឹះស្ថានអប់រំនានា ដែលបានទទួលព័ត៌មាននេះពីក្រុមហ៊ុន IT ដូចជា Cisco, Microsoft និងក្រុមហ៊ុនផ្សេងទៀតជាដើម បានរៀបចំវគ្គបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ ដែលផ្តល់ជំនាញទន់ ភាសា និងការបណ្តុះបណ្តាលបច្ចេកទេសរួមគ្នា និងនាំឲ្យសិក្ខាកាមអាចទទួលបានការងារ ដែលផ្តល់បៀវត្សរ៍ច្រើនជាងប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសពីបីដល់ប្រាំដង។

ប្រភព៖ Banerji, A., Lopez, V., McAuliffe, J., Rosen, A., and Salazar-Xirinachs, J.M., with Ahluwalia, P., Habib, M., and Milberg, T. 2014. An 'E.Y.E.' to the Future: Enhancing Youth Employment. Education and Skills 2.0: New Targets and Innovative Approaches. Geneva, World Economic Forum.

ដូច្នេះ គេអាចចោទសួរសំណួរសំខាន់ៗជាច្រើន។ តើគេអាចពង្រឹងទំនាក់ទំនងរវាងការអប់រំ និងការងារ ដោយរបៀបណា? តើគេអាចបង្កើនតម្លៃសេដ្ឋកិច្ច និងសង្គមនៃការអប់រំ និងការបណ្តុះបណ្តាលដោយរបៀបណា ក្នុងបរិបទបច្ចុប្បន្ននេះ? តើគេអាចបង្កើនភាពឆ្លើយតបនៃការអប់រំ ជាពិសេស នៅកម្រិតមធ្យមសិក្សា ដោយរបៀបណា ដើម្បីវាកាន់តែអាចឆ្លើយតបចំពោះជីវិតរបស់យុវជន និងធ្វើឲ្យពួកគេកាន់តែអាចរកការងារធ្វើបាន? តើវិធានការបច្ចុប្បន្នគ្រប់គ្រាន់ដែរឬទេ?ចុងក្រោយ ដំណោះស្រាយគឺការបង្កើតការងារ ដែលមានន័យថារដ្ឋមានការទទួលខុសត្រូវកាន់តែខ្ពស់ជាងមុន លើការបង្កើតគោលនយោបាយការងារដែលរឹងមាំ។ ការអប់រំតែឯង មិនអាចដោះស្រាយបញ្ហាគ្មានការងារធ្វើនោះទេ។ វាតម្រូវឲ្យមានការពិចារណាសារជាថ្មីលើគំរូនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលក៏ជាការផ្តល់ឱកាសឲ្យគេអាចធ្វើការពិចារណាសារជាថ្មីលើទំនាក់ទំនងរវាងការអប់រំ និងពិភពការងារផងដែរ។ ចុងក្រោយ គេត្រូវទទួលស្គាល់ពីសារៈសំខាន់នៃការរៀនសូត្រ និងការរៀនសូត្រសារជាថ្មីក្រៅពីការរៀនសូត្រដែលកើតឡើងក្នុងប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ សមត្ថភាពពាក់ព័ន្ធ ក៏ត្រូវអភិវឌ្ឍ តាមរយៈការរៀនសូត្រដោយខ្លួនឯង ការរៀនសូត្រពីគ្នាទៅវិញទៅមក ការរៀនសូត្រនៅកន្លែងធ្វើការ (ដូចជា ការហាត់ការ និងការហ្វឹកហាត់កូនជាងជាដើម) ការបណ្តុះបណ្តាលផ្ទាល់ពេលកំពុងធ្វើការងារ ឬតាមរយៈរបៀបរៀនសូត្រ និងអភិវឌ្ឍជំនាញផ្សេងទៀត ក្រៅពីការអប់រំ និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ ដូច្នេះ យើងត្រូវរិះគិតបង្កើតអភិក្រមថ្មីៗ សម្រាប់ផ្តល់ការអប់រំ និងអភិវឌ្ឍជំនាញ ដែលទាញប្រយោជន៍ពីសក្តានុពលនៃគ្រប់បរិបទនៃការរៀនសូត្រទាំងអស់។

> **ការអប់រំតែឯង មិនអាចដោះស្រាយបញ្ហាគ្មានការងារធ្វើនោះទេ។**

## ■ ការទទួលស្គាល់ និងការបញ្ជាក់សុពលភាពលើការរៀនសូត្រក្នុងពិភពលោក ដែលមនុស្សផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត

### ការផ្លាស់ប្តូរនិន្នាការនៃការផ្លាស់ទីរបស់មនុស្ស

ការផ្លាស់ទីរបស់មនុស្ស ទាំងឆ្លងប្រទេស ទាំងក្នុងប្រទេស បានឈានដល់កម្រិតខ្ពស់បំផុត មិនធ្លាប់មានក្នុងប្រវត្តិសាស្រ្តកន្លងមក។[៩៧] ក្នុងចំណោមមនុស្ស ៧ នាក់ ដែលរស់នៅក្នុងពិភពលោក មាន ១ នាក់ ឬសរុបមានមនុស្សប្រមាណជា ១ ពាន់លាននាក់ អាចត្រូវបានគេចាត់ទុកថា “កំពុងផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត” ក្នុងពិភពលោកបច្ចុប្បន្ននេះ។[៩៨] ខណៈពេលលំហូរនៃការធ្វើចំណាកស្រុក ពីភាគខាងត្បូងទៅភាគខាងជើងនៅតែបន្តមាន លំហូរនៃការធ្វើចំណាកស្រុកពីភាគខាងត្បូងទៅភាគខាងត្បូង កាន់តែមានការកើនឡើងយ៉ាងឆាប់រហ័ស ហើយទំនងជានឹងកើនឡើងកាន់តែលឿន នាពេលអនាគត។[៩៩] លើសពីនេះ “ការផ្លាស់ប្តូរភូមិសាស្រ្តនៃកំណើនសេដ្ឋកិច្ច” រួមនឹងឥទ្ធិពលរបស់វាមកលើការងារ និងសុខុមាលភាព កំពុងលើកទឹកចិត្តឲ្យមនុស្សកាន់តែច្រើននាក់ ដែលរស់នៅភាគខាងជើង ធ្វើចំណាកស្រុកទៅភាគខាងត្បូង។[១០០] ការផ្លាស់ប្តូរនិន្នាការនៃការផ្លាស់ទីរបស់មនុស្សបែបនេះ ធ្វើឲ្យមានផលវិបាកសំខាន់ៗមកលើការអប់រំ និងការងារ។

### ពីលំហូរចេញនៃធនធានខួរក្បាល (brain drain) ទៅជាការទទួលបានប្រយោជន៍ពីធនធានខួរក្បាល (brain gain)

ដោយសារតែនិន្នាការប្រជាសាស្រ្តសកលមានលក្ខណៈបែបនេះ កម្លាំងពលកម្មភាគច្រើនរបស់ពិភពលោក នឹងស្ថិតនៅភាគខាងត្បូង។ គេប៉ាន់ប្រមាណថា កម្លាំងពលកម្ម ២៥ ភាគរយរបស់ពិភពលោក ឬដែលហៅថា “ក្រុមបញ្ញាជនរបស់ពិភពលោក” នឹងមានប្រភពពីប្រទេសឥណ្ឌាតែឯង នៅឆ្នាំ ២០៣។ និន្នាការនៃចរាចរណ៍ធនធានខួរក្បាល (brain circulation) បែបនេះ នាំឲ្យមានការព្រួយបារម្ភអំពីការផ្តល់ថវិកាសាធារណៈដល់ការអប់រំ និងការអភិវឌ្ឍជំនាញ ដោយសារតែកម្លាំងពលកម្មមួយភាគធំនឹងធ្វើចំណាកស្រុកទៅរស់នៅ

---

[៩៧] Rio+20, UNCSD. 2012. Migration and sustainable development. Rio 2012 Issues Briefs. No. 15, p. 1.

[៩៨] International Organization for Migration. 2011. World Migration Report 2011. Communicating effectively about migration. Geneva, International Organization for Migration.

[៩៩] UN DESA. 2011. Urban Population, Development and the Environment. New York, United Nations.

[១០០] OECD. 2011. Perspectives on Global Development 2012: Social Cohesion in a Shifting World. Paris, OECD.

និងធ្វើការក្រៅប្រទេស។ ការប៉ាន់ប្រមាណឆ្នាំ ២០១២ បានកំណត់ការខាតបង់ដោយសារតែ "ការចាកចេញនៃធនធានមនុស្ស" ពីប្រទេសឥណ្ឌាបែបនេះ ថាមានចំនួន ២ ពាន់លានដុល្លារ។[១០១] ប៉ុន្តែ យើងត្រូវកត់សម្គាល់ផងដែរថា ការហូរចេញនូវធនធានខួរក្បាល ក៏អាចធ្វើឲ្យមានការទទួលបានប្រយោជន៍ពីធនធានខួរក្បាលផងដែរ ដោយសារតែទេសន្តរប្រវេសន៍ជនទាំងនេះបង្កើតនូវបណ្ដាញដ៏ធំធេង និងបំពេញតួនាទីនាំមកនូវមូលធន និងបច្ចេកវិទ្យា មកក្នុងប្រទេសកំណើតរបស់ពួកគេវិញ។[១០២]

**ប្រអប់ទី ១៥៖ ការផ្លាស់ប្ដូរនិន្នាការនៃការធ្វើចំណាកស្រុកទៅកាន់ Bangalore និង Hyderabad**

Bangalore និង Hyderabad ត្រូវបានចាត់ទុកថាជា "ទីក្រុងនាំមុខគេក្នុងពិភពលោក" ខាងវិស័យបច្ចេកវិទ្យាព័ត៌មាន។ ក្នុងកំឡុងទសវត្សរ៍ ១៩៧០ និង ១៩៨០ មានការព្រួយបារម្ភថា ប្រទេសឥណ្ឌាកំពុងបាត់បង់កម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់របស់ខ្លួនទៅបស្ចិមប្រទេស ជាពិសេស សហរដ្ឋអាមេរិច តាមរយៈបាតុភូតិមួយ ដែលមានឈ្មោះថា "ការហូរចេញនូវលំហូរខួរក្បាល។ កាលពីពេលថ្មីៗនេះ ភស្តុតាងនានាបង្ហាញថានិន្នាការបញ្ច្រាសលំហូរចេញនូវធនធានខួរក្បាលកំពុងកើតឡើង នៅពេលដែលអ្នកជំនាញជនជាតិឥណ្ឌា ដែលទទួលបានការបណ្ដុះបណ្ដាលពីសហរដ្ឋអាមេរិច កំពុងវិលត្រលប់មកប្រទេសកំណើតរបស់ពួកគេវិញ ក្នុងចំនួនមួយដ៏ច្រើន ដើម្បីទាញប្រយោជន៍ពីឱកាសរីកចម្រើន និងការងារថ្មី។ កម្លាំងពលកម្មដែលមានជំនាញ និងមានការងារធ្វើឆ្លងប្រទេស មានឥទ្ធិពលធំធេងលើវិស័យនានារបស់សេដ្ឋកិច្ច លើហេដ្ឋរចនាសម្ព័ន្ធសង្គម និងរូបរន្តរបស់ Bangalore និង Hyderabad និងក្នុងការបង្កើត និងពង្រឹងទំនាក់ទំនងអន្តរជាតិរវាងប្រទេសឥណ្ឌា និងសហរដ្ឋអាមេរិច។

ប្រភព៖ Chacko, E., 2007. From brain drain to brain gain: reverse migration to Bangalore and Hyderabad, India's globalizing high tech cities. GeoJournal, 68 (2), pp. 131-140

[១០១] IOM. 2013. Migrant, Well-Being and Development. World Migration Report 2013. Geneva, IOM; OECD. 2013. International Migration Outlook 2013. Paris. OECD.

[១០២] Winthrop, R. and Bulloch, G. 2012. The Talent Paradox: Funding education as a global public good. Brookings Institution. www.brookings.edu/blogs/up-front/posts/2012/11/06-funding-education-winthrop [Accessed February 2015].

## កំណើនចល័តភាពរបស់កម្លាំងពលកម្ម និងអ្នករៀនសូត្រ

បន្ថែមពីកំណើននៃការផ្លាស់ទីឆ្លងដែននៃកម្លាំងពលកម្មជំនាញ យើងក៏សង្កេតឃើញមានការចល័តរវាងការងារមួយ និងការងារមួយទៀតរបស់កម្លាំងពលកម្មផងដែរ។ ជាការឆ្លើយតបចំពោះកំណើនចល័តភាពក្នុងអាជីពវិជ្ជាជីវៈ និងចល័តភាពរវាងតំបន់ភូមិសាស្ត្រមួយ និងតំបន់ភូមិសាស្ត្រមួយទៀតបែបនេះ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (NQFs) ត្រូវបានបង្កើតឡើងក្នុងប្រទេសប្រមាណជា ១៤០ ជុំវិញពិភពលោក។ ស្រដៀងគ្នានេះដែរ ក្របខ័ណ្ឌគុណវុឌ្ឍិតំបន់ដែលយកគំរូតាមក្របខ័ណ្ឌគុណវុឌ្ឍិរបស់អឺរ៉ុប (EQFs) បានលេចចេញជារូបរាងឡើង។ ប៉ុន្តែដោយសារតែការធ្វើចំណាកស្រុកកាន់តែមានវិសាលភាពធំឡើងៗ និងផ្លាស់ប្តូរនិន្នាការដែលធ្លាប់តែមានកន្លងមក ចល័តភាពនៃកម្លាំងពលកម្មជំនាញកាន់តែមានភាពស្មុគស្មាញ នៅគ្រប់តំបន់ទាំងអស់ក្នុងពិភពលោក។

ដូចគ្នាដែរ ចំនួននិស្សិតដែលផ្លាស់ទីពីកន្លែងមួយ ទៅកន្លែងមួយក្នុងពិភពលោក បានកើនឡើងគួរឲ្យកត់សម្គាល់ ក្នុងទសវត្សរ៍ទីមួយ នៃសតវត្សរ៍ទី ២១ នេះ ហើយរំពឹងថានឹងបន្តកើនឡើង។ ដូច្នេះ កិច្ចព្រមព្រៀងថ្នាក់តំបន់ស្តីពីការទទួលស្គាល់ការសិក្សា វិញ្ញាបនបត្រ និងសញ្ញាបត្រឧត្តមសិក្សា លែងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឆ្លើយតបចំពោះអន្តរជាតិតូបនីយកម្មការអប់រំកម្រិតឧត្តមសិក្សា និងកំណើនចល័តភាពរបស់និស្សិតទៀតហើយ។

លើសពីនេះ ចល័តភាពរបស់អ្នករៀនសូត្រ មិនមែនកំហិតត្រឹមតែជាការផ្លាស់ទីរបស់សិស្សនិស្សិតរវាងគ្រឹះស្ថានអប់រំក្នុងប្រព័ន្ធមួយ និងគ្រឹះស្ថានអប់រំក្នុងប្រព័ន្ធមួយទៀតនោះទេ។ ចល័តភាពនេះ ក៏រាប់បញ្ចូលកំណើនចល័តភាពនៃអ្នករៀនសូត្រ រវាងកន្លែងរៀនសូត្រ ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅផ្លូវការផងដែរ។ នេះនាំឲ្យមានការចោទសំណួរអំពីការវាយតម្លៃ និងការបញ្ជាក់សុពលភាពចំណេះដឹង និងសមត្ថភាពនានា ដោយមិនគិតពីមាគ៌ាចម្រុះ ដែលគេប្រើប្រាស់ ដើម្បីទទួលបានចំណេះដឹង និងសមត្ថភាពទាំងនេះឡើយ។

## កំណើនចំណាប់អារម្មណ៍លើការវាយតម្លៃលើការរៀនសូត្រជាទ្រង់ទ្រាយធំ៖ អត្ថប្រយោជន៍ និងហានិភ័យ

ចេញពីការផ្តោតការយកចិត្តទុកដាក់ ដែលធ្លាប់តែមានកន្លងមកលើខ្លឹមសារនៃកម្មវិធីអប់រំ និងបណ្តុះបណ្តាល ឥឡូវនេះ យើងកំពុងផ្លាស់ទៅផ្តោតការយកចិត្តទុកដាក់លើការទទួលស្គាល់ ការវាយ តម្លៃ និងការបញ្ជាក់សុពលភាពចំណេះដឹង ដែលទទួលបានវិញ។ ក្រៅតែពីការបង្កើតនូវ ក្របខ័ណ្ឌគុណវឌ្ឍិផ្អែកលើលទ្ធផលនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ការវាយតម្លៃទ្រង់ទ្រាយធំលើកម្រិតជំនាញរបស់មនុស្សពេញវ័យ ក៏កាន់តែទទួលបានការយកចិត្តទុកដាក់ផងដែរ ដូចជាកម្មវិធីវាយតម្លៃអន្តរជាតិលើសមត្ថភាពមនុស្សពេញវ័យ (PIAAC) របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ជាដើម។ សម្រាប់អ្នករៀនសូត្រវិញ ការព្រួយបារម្ភអំពីគុណភាពនៃការអប់រំ បានជម្រុញឲ្យមានការកើនឡើងនូវចំនួន និងវិសាលភាពនៃការវាយតម្លៃការរៀនសូត្រក្នុងទ្រង់ទ្រាយធំ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។[១០៣] ការវាយតម្លៃទ្រង់ទ្រាយធំទាំងនេះ អាចបំពេញនាទីជាឧបករណ៍ដ៏មានតម្លៃ សម្រាប់ការទាមទារឲ្យមានការទទួលខុសត្រូវនៅថ្នាក់ជាតិលើការវិនិយោគជាសាធារណៈ និងឯកជនលើវិស័យអប់រំ ជាពិសេស តាមរយៈការពិនិត្យតាមដានលើលទ្ធផលនៃការរៀនសូត្ររបស់អ្នកដែលជួបការលំបាកជាងគេ ពីសំណាក់ប្រព័ន្ធអប់រំ។ ប៉ុន្តែ ការវាយតម្លៃបែបនេះក៏ជាមូលហេតុ ដែលនាំឲ្យមានការព្រួយបារម្ភផងដែរ។ ការវាយតម្លៃទាំងនេះធ្វើឲ្យប៉ះពាល់ដល់គុណភាព ភាពពាក់ព័ន្ធ និងភាពចម្រុះនៃបទពិសោធន៍ដែលបានពីការអប់រំ ដោយសារតែមានការលើកទឹកចិត្តឲ្យមានការបង្រៀនតែអ្វីដែលនឹងចេញក្នុងតេស្ត ដែលធ្វើឲ្យការអភិវឌ្ឍកម្មវិធីសិក្សាផ្តោតតែលើខ្លឹមសារដែលមានលក្ខណៈចង្អៀត។[១០៤] ការយកចិត្តទុកដាក់ខាងគោលនយោបាយច្រើនផ្តោតតែលើលទ្ធផល

ចេញពីការផ្តោតការយកចិត្តទុកដាក់ដែលធ្លាប់តែមានកន្លងមកលើខ្លឹមសារនៃកម្មវិធីអប់រំ និងបណ្តុះបណ្តាល ឥឡូវនេះ យើងកំពុងផ្លាស់ទៅផ្តោតការយកចិត្តទុកដាក់លើការទទួលស្គាល់ ការវាយតម្លៃ និងការបញ្ជាក់សុពលភាពចំណេះដឹង ដែលទទួលបានវិញ។

---

[១០៣] Morgan, W. J., Appleton, S. and Sives, A. 2006. Teacher mobility, brain drain and educational resources in the Commonwealth. Educational Paper No. 66. London, UK Government Department for International Development.

[១០៤] UNESCO. 2014. Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014. Paris, UNESCO.

នៃការរៀនសូត្រដែលមានលក្ខណៈចង្អៀត។ ហានិភ័យពាក់ព័ន្ធជាមួយនឹងការវាយតម្លៃជាទ្រង់ទ្រាយធំបែបនេះ មានកម្រិតខ្ពស់ នៅពេលដែលការវាយតម្លៃទាំងនេះត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ ក្រៅតែពីការផ្តល់ព័ត៌មានសម្រាប់ការរៀបចំគោលនយោបាយអប់រំ ដូចជា ការកំណត់ពីបៀវត្សរ៍គ្រូ ឬការដាក់ចំណាត់ថ្នាក់ឲ្យសាលារៀនជាដើម។

## ឆ្ពោះទៅរកប្រព័ន្ធរៀនសូត្រពេញមួយជីវិតដែលមានលក្ខណៈចំហ និងបត់បែន

ការទទួលស្គាល់ និងការបញ្ជាក់សុពលភាពចំណេះដឹង និងសមត្ថភាព ដែលទទួលបានតាមមាគ៌ានៃការរៀនសូត្រចម្រុះ ពុំមែនជាផ្នែកមួយនៃក្របខ័ណ្ឌរៀនសូត្រពេញមួយជីវិតនោះទេ។ ដូចដែលយើងបានលើកឡើងពីខាងដើម ការអភិវឌ្ឍសង្គមកំពុងពង្រឹងឡើងវិញនូវភាពឆ្លើយតបនៃការអប់រំ ដែលជាការអប់រំពេញមួយជីវិតផង និងជាការអប់រំដែលពាក់ព័ន្ធនឹងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតផង។ ទស្សនទាននេះមិនមែនជាទស្សនទានដែលថ្មីនោះទេ ប៉ុន្តែទស្សនទាននេះនៅតែមានភាពលេចធ្លោរ ដោយសារតែវាជាមធ្យោបាយសម្រាប់រៀបចំការរៀនសូត្រឲ្យមានលក្ខណៈជាប្រព័ន្ធ គ្រប់ជ្រុងជ្រោយ និងមានសមធម៌។[១០៥] ទស្សនទាននេះផ្តោតការយកចិត្តទុកដាក់លើការផ្តល់ភាពអង់អាចដល់អ្នករៀនសូត្រគ្រប់វ័យទាំងអស់។[១០៦]

ដោយសារតែបញ្ហាប្រឈមដែលបង្កឡើងដោយសារការអភិវឌ្ឍខាងបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ កំណើនដ៏ខ្លាំងក្លានៃព័ត៌មាន និងចំណេះដឹង ដែលយើងបានកត់សម្គាល់ឃើញ ការរៀនសូត្រពេញមួយជីវិតមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ត្រៀមខ្លួនសម្រាប់និន្នាការថ្មីៗ និងសម្រេចឲ្យបាននូវកម្រិត និងប្រភេទនៃសមត្ថភាព ដែលបុគ្គល និងសង្គមត្រូវការ។

> ការអភិវឌ្ឍសង្គមកំពុងពង្រឹងឡើងវិញនូវភាពឆ្លើយតបនៃការអប់រំ ដែលជាការអប់រំពេញមួយជីវិតផង និងជាការអប់រំដែលពាក់ព័ន្ធនឹងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតផង។

---

១០៥ For the trend toward the globalization of curricula see, for instance, Baker, D. and LeTendre, G.K. 2005. National Differences, Global Similarities: World Culture and the Future of Schooling. Stanford CA, Stanford University Press.
See also: IBE UNESCO. 2013. Learning in the post-2015 education and development agenda. Geneva, IBE UNESCO. Text available in English, French, Spanish, and Arabic

១០៦ See, for example: UNESCO. 2014. The Muscat Agreement. Global Education for All Meeting. Muscat, Oman 12-14 May 2014, ED-14/EFA/ME/3 and United Nations. 2014. Open Working Group proposal for Sustainable Development Goals. New York, UN General Assembly.

ការអនុវត្តប្រព័ន្ធរៀនសូត្រពេញមួយជីវិតដែលមានលក្ខណៈបើកចំហ និងបត់បែន ពឹងអាស្រ័យលើយន្តការ សម្រាប់ផ្តល់ការទទួលស្គាល់ បញ្ជាក់សុពលភាព និងវាយតម្លៃលើចំណេះដឹង និងសមត្ថភាព ដែលផ្តល់ដោយគ្រឹះស្ថានអប់រំ និងកន្លែងធ្វើការ៖

- **ការភ្ជាប់ទំនាក់ទំនងក្របខ័ណ្ឌគុណវឌ្ឍិផ្អែកលើលទ្ធផលដែលមានតម្លាភាព**

ស្មារតីនៃសន្និសីទអន្តរជាតិលើកទី ៣ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (សៀងហៃ ឆ្នាំ ២០១២) បានដាក់ចេញនូវអនុសាសន៍ខាងក្រោម៖ "គាំទ្រដល់មាគ៌ានៃការរៀនសូត្រដែលមានភាពបត់បែន និងការប្រមូលផ្តុំ ការទទួលស្គាល់ និងការផ្ទេរការរៀនសូត្ររបស់បុគ្គលម្នាក់ៗ តាមរយៈប្រព័ន្ធគុណវឌ្ឍិដែលមានតម្លាភាព ក្បោះក្បាយ និងផ្អែកលើលទ្ធផល"

- **ឆ្ពោះទៅបង្កើត "កម្រិតយោងសម្រាប់សកលលោកទាំងមូល" សម្រាប់ការផ្តល់ការទទួលស្គាល់ដល់ការរៀនសូត្រ?**

ការផ្លាស់ទីឆ្លងតំបន់របស់កម្មករនិយោជិតក្នុងទ្រង់ទ្រាយធំ កំពុងលើកទឹកចិត្តឲ្យមានការសិក្សាពីលទ្ធភាពបង្កើតកម្រិតយោងសម្រាប់ពិភពលោកទាំងមូល ដើម្បីផ្តល់ការទទួលស្គាល់ដល់ចំណេះដឹង និងសមត្ថភាព នៅថ្នាក់តំបន់។[១០៧]

- **ឆ្ពោះទៅរៀបចំអនុសញ្ញាអន្តរជាតិស្តីពីការទទួលស្គាល់ការអប់រំកម្រិតឧត្តមសិក្សា**

ក្រៅតែពីអនុសញ្ញាថ្នាក់តំបន់ស្តីពីការ ទទួលស្គាល់ការអប់រំឧត្តមសិក្សា កាលពីពេលថ្មីៗនេះ យូណេស្កូបានចាប់ផ្តើមពិនិត្យមើលលទ្ធភាពរៀបចំអនុសញ្ញាអន្តរជាតិមួយស្តីពីការទទួលស្គាល់ការអប់រំឧត្តមសិក្សា។

---

[១០៧] UNESCO Institute for Lifelong Learning. 2010. Annual Report 2009. Hamburg, UNESCO Institute for Lifelong Learning.

## ■ ការពិចារណាឡើងវិញលើការអប់រំភាពជាពលរដ្ឋ ក្នុងពិភពលោកដែលពោរពេញដោយភាពចម្រុះ និងការភ្ជាប់ទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក

### រូបភាពថ្មីៗនៃភាពជាពលរដ្ឋ

ការអប់រំសាធារណៈ ជានិច្ចកាលតែមានមុខងារដ៏សំខាន់ ពាក់ព័ន្ធជាមួយនឹងសង្គម ភាពជាពលរដ្ឋ និងនយោបាយ។ ការអប់រំនេះមានទំនាក់ទំនងជាមួយនឹងអត្តសញ្ញាណជាតិ ការបង្កើតនូវស្មារតីជោគវាសនាតែមួយ និងការកំណត់ពីភាពជាពលរដ្ឋ។ ទស្សនទានភាពជាពលរដ្ឋសំដៅលើសមាជិកភាពរបស់បុគ្គលម្នាក់ៗ ក្នុងសហគមន៍នយោបាយ ដែលត្រូវបានកំណត់ក្នុងប្រទេសមួយ ឬរដ្ឋមួយ។ ដូច្នេះ ភាពជាពលរដ្ឋអាចទស្សនទានដែលមានការបកស្រាយខុសគ្នា ជាពិសេស ក្នុងសង្គមដែលមានការប្រេះឆា។ សិទ្ធិជាមូលដ្ឋាន ពាក់ព័ន្ធជាមួយនឹងភាពជាពលរដ្ឋ អាចមិនត្រូវបានគេផ្តល់ទៅឲ្យក្រុមភាគតិច ដូចជា ក្រុមជនចំណាកស្រុក និងជនភៀសខ្លួន ជាដើម។ បច្ចុប្បន្ន និយមន័យភាពជាពលរដ្ឋ នៅតែផ្តោតលើអ្វីដែលកើតឡើងក្នុងជាតិ-រដ្ឋមួយ ប៉ុន្តែទស្សនទាន និងការអនុវត្ត កំពុងមានការផ្លាស់ប្តូរ ក្រោមឥទ្ធិពលនៃសកលភាវូបនីយកម្ម។[១០៨] សហគមន៍សង្គម និងនយោបាយ សង្គមស៊ីវិល និងយុទ្ធនាការជាអន្តរជាតិ គឺជារូបភាពដែលបង្ហាញពីទម្រង់ភាពជាពលរដ្ឋថ្មីៗ ដែលហួសពីព្រំដែនរបស់រដ្ឋមួយ។[១០៩] តាមរយៈការបងកើតនូវបរិបទសេដ្ឋកិច្ច សង្គម និងវប្បធម៌ថ្មីៗ ហួសពីព្រំដែនរបស់ជាតិ-រដ្ឋ សកលភាវូបនីយកម្មកំពុងរួមចំណែកបង្កើតនូវវិធីសាស្ត្រថ្មីៗ សម្រាប់កំណត់អត្តសញ្ញាណ និងកៀងគរចលនាសង្គម ហួសពីព្រំដែនរបស់រដ្ឋ។

[១០៨] Keevy, J. and Chakroun, B. 2015. The use of level descriptors in the twenty-first century. Paris, UNESCO.

[១០៩] Adapted from Tawil, S. 2013. Education for ‘global citizenship’: A framework for discussion. ERF Working Papers, No. 7. Paris, UNESCO.

## បញ្ហាប្រឈម សម្រាប់ការអប់រំថ្នាក់ជាតិ

ដូច្នេះ តួនាទីរបស់រដ្ឋក្នុងការកំណត់និយមន័យភាពជាពលរដ្ឋ រឹតតែជួបនឹងបញ្ហាប្រឈមជាច្រើន ដោយសារតែការលេចចេញនូវទម្រង់ភាពជាពលរដ្ឋឆ្លងពីប្រទេសមួយទៅប្រទេសមួយទៀត។ នេះគឺជាការពិត បើទោះបីជារដ្ឋនៅតែជាទីតាំងសំខាន់ជាងគេ សម្រាប់ភាពជាពលរដ្ឋក៏ដោយ ទាំង “ក្នុងនាមជាការផ្តល់នូវភាពស្របច្បាប់ជាផ្លូវការ និងជាគម្រោងដែលមានលក្ខណៈជានិយាមការ ឬជាបំណងប្រាថ្នាអ្វីមួយ។[១១១] បច្ចេកវិទ្យាសារគមនាគមន៍ថ្មីៗ និងប្រព័ន្ធផ្សព្វផ្សាយសង្គម គឺជាកាតាលីករដ៏សំខាន់ដែលនាំឲ្យមានការផ្លាស់ប្តូរបែបនេះ ជាពិសេសក្នុងចំណោមយុវជន។ ជាការពិត យុវជនសម័យបច្ចុប្បន្ននេះ បានទទួលឱកាសដែលមិនធ្លាប់មានកន្លងមក ដោយសារតែពួកគេគឺជាជំនាន់មនុស្សដែលទទួលបានការអប់រំ ព័ត៌មាន និងភ្ជាប់ទំនាក់ទំនងជាមួយគ្នាច្រើនបំផុត ក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស។ ពួកគេចូលរួមកាន់តែសកម្ម ក្នុងយុទ្ធនាការស៊ីវិល សង្គម និងនយោបាយនានា ដែលជម្រុញដោយប្រព័ន្ធផ្សព្វផ្សាយសង្គម និងបច្ចេកវិទ្យា ដែលផ្តល់ឲ្យពួកគេនូវច្រកថ្មីៗ សម្រាប់ធ្វើការកៀងគរចលនា សហការ និងច្នៃប្រឌិតថ្មីៗ។ តួនាទីនៃការអប់រំក្នុងប្រព័ន្ធ ក្នុងការកៀងគរចលនាស៊ីវិល និងនយោបាយក្នុងសង្គម កំពុងមានការប្រែប្រួល ដោយសារតែឥទ្ធិពលនៃកន្លែងផ្តល់ការអប់រំថ្មីៗ ទំនាក់ទំនង និងចរន្តនានា ដែលបង្កើតឡើងដោយសារប្រព័ន្ធផ្សព្វផ្សាយសង្គម។ លើសពីនេះ ពិភពឌីជីថលថ្មី ដូចជា blogs, Facebook, Twitter និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀត តម្រូវឲ្យយើងធ្វើការពិចារណាឡើងវិញលើទស្សនទានសំខាន់ៗ និងលើការបែងចែករវាងសាធារណៈ និងឯកជន។


> តួនាទីនៃការអប់រំក្នុងប្រព័ន្ធ ក្នុងការកៀងគរចលនាស៊ីវិល និងនយោបាយក្នុងសង្គម កំពុងមានការប្រែប្រួល ដោយសារតែឥទ្ធិពលនៃកន្លែងផ្តល់ការអប់រំថ្មីៗ ទំនាក់ទំនង និងចរន្តនានា ដែលបង្កើតឡើង ដោយសារប្រព័ន្ធផ្សព្វផ្សាយសង្គម។


[១១១] Ibid.

## ការទទួលស្គាល់វប្បធម៌ចម្រុះ និងការបដិសេធចោលនូវវប្បធម៌ជ្រុលនិយម

មានការទទួលស្គាល់កាន់តែច្រើនជាងមុនលើវប្បធម៌ចម្រុះ មិនថាជាវប្បធម៌ដែលមានកន្លងមកក្នុងប្រទេសមួយ (ដូចជា ភាសា និងវប្បធម៌របស់ក្រុមភាគតិច និងក្រុមជនជាតិដើមភាគតិច) ឬវប្បធម៌ដែលបង្កើតឡើងដោយសារការធ្វើទេសន្តរប្រវេសន៍នោះទេ។ ទេសន្តរប្រវេសន៍ កំពុងរួមចំណែកធ្វើឲ្យវប្បធម៌កាន់តែមានលក្ខណៈចម្រុះ ក្នុងប្រព័ន្ធអប់រំ ក៏ដូចជា នៅកន្លែងធ្វើការ និងក្នុងសង្គមទូទៅ។ ទោះជាយើងណាក៏ដោយ យើងក៏សង្កេតឃើញការកើនឡើងនូវប្បធម៌ជ្រុលនិយម និងការកៀងគរចលនានយោបាយផ្អែកទៅតាមអត្តសញ្ញាណផងដែរ ដែលនេះជាបញ្ហាប្រឈមធំមួយ ចំពោះភាពសុខដុមរមនា ទូទាំងពិភពលោកទាំងមូល។ ខណៈពេលដែលភាពចម្រុះនៃវប្បធម៌ គឺជាប្រភពនៃភាពសម្បូរបែប ភាពចម្រុះបែបនេះក៏នាំឲ្យមានការកើនឡើងនូវជម្លោះផងដែរ នៅពេលដែលភាពសុខុដុមរមនាក្នុងសង្គមត្រូវទទួលរងសម្ពាធ។

## ការលើកកម្ពស់ភាពជាពលរដ្ឋប្រកបដោយការទទួលខុសត្រូវ និងសាមគ្គីភាព ក្នុងពិភពលោកទាំងមូល[១១២]

ការអប់រំ មានតួនាទីសំខាន់ ក្នុងការលើកកម្ពស់ចំណេះដឹង ដែលយើងត្រូវការ ដើម្បីឲ្យមានការអភិវឌ្ឍ៖ ទីមួយ ស្មារតីទទួលយកជោគវាសនារួម ក្នុងបរិយាកាសសង្គម វប្បធម៌ និងនយោបាយនៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិ ក៏ដូចជា រួមជាមួយនឹងមនុស្សជាតិទាំងមូល។ ទីពីរ ការយល់ដឹងពីបញ្ហាប្រឈម ដែលធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍសហគមន៍ តាមរយៈការយល់ដឹងពីការពឹងអាស្រ័យលើគ្នាទៅវិញទៅមក នៃនិន្នាការនៃការផ្លាស់ប្តូរក្នុងសង្គមសេដ្ឋកិច្ច និងបរិស្ថាន នៅថ្នាក់មូលដ្ឋាន និងថ្នាក់សកល និងទីបី ការប្តេជ្ញាចិត្តចូលរួមក្នុងសកម្មភាពស៊ីវិល និងសង្គម ស្របតាមស្មារតីនៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗចំពោះសហគមន៍ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សកលលោកទាំងមូល។

- **ការសាទរចំពោះវប្បធម៌ចម្រុះក្នុងការអប់រំ**

ការអប់រំគួរទទួលយក និងសាទរចំពោះភាពចម្រុះនៃវប្បធម៌។ ភាពចម្រុះក្នុងការអប់រំអាចបង្កើនគុណភាពនៃការអប់រំ តាមរយៈការណែនាំអ្នកអប់រំ និងអ្នករៀនសូត្រ ឲ្យដឹងពីទស្សនវិស័យផ្សេងៗគ្នា និងភាពចម្រុះនៃពិភពលោកដែលយើងកំពុងរស់នៅ។ ចាំបាច់ត្រូវមាន

[១១២] Tawil, op.cit.

ការផ្ដោតការយកចិត្តទុកដាក់សំខាន់លើទិដ្ឋភាពវប្បធម៌នៃការអប់រំក្នុងស្មារតីនៃសេចក្ដីប្រកាសជាសកលស្ដីពីភាពចម្រុះខាងវប្បធម៌របស់យូណេស្កូ ឆ្នាំ ២០០១ និងអនុសញ្ញាស្ដីពីការការពារ និងការលើកកម្ពស់ភាពចម្រុះនៃការសម្ដែងចេញខាងវប្បធម៌ ឆ្នាំ ២០០។[១១៣]

- **ការលើកទឹកចិត្តឲ្យមានការតាក់តែងគោលនយោបាយបែបបរិយាប័ន្ន**

ការកើនឡើងនូវភាពចម្រុះ គឺជាបញ្ហាប្រឈម ដល់ការសម្រេចឲ្យបាននូវការឯកភាពជារួមលើជម្រើសគោលនយោបាយអប់រំ ដែលមានឥទ្ធិពលដោយផ្ទាល់ជាងគេ និងដែលកំណត់អត្តសញ្ញាណ។ ចំណុចនេះប្រហែលជាត្រូវបានស្ដែងចេញច្បាស់ជាងគេ តាមរយៈការជ្រើសរើសភាសាសម្រាប់បង្រៀន និងលក្ខណៈនៃការអប់រំភាពជាពលរដ្ឋ ដូចជា ការសិក្សាពីប្រវត្តិសាស្ត្រ ភូមិវិទ្យា វិទ្យាសាស្ត្រសង្គម និងសាសនា ក្នុងសង្គមបែបពហុវប្បធម៌ជាដើម។ ដំណើរការពិគ្រោះយោបល់ដែលមានលក្ខណៈបរិយាប័ន្ន លើបញ្ហាគោលនយោបាយសំខាន់នានា មានសារៈសំខាន់ សម្រាប់ការអប់រំភាពជាពលរដ្ឋដែលមានលក្ខណៈស្ថាបនា នៅក្នុងសង្គមដែលមានលក្ខណៈចម្រុះបែបនេះ។

## ■ អភិបាលកិច្ចលើការអប់រំជាសកល និងការតាក់តែងគោលនយោបាយជាតិ

### ទម្រង់ថ្មីៗនៃអភិបាលកិច្ចជាសកល

ប្រព័ន្ធ សម្រាប់បង្កើតនូវនិយាមការ និងលិខិតបទដ្ឋានគតិយុត្តិនានា ក្នុងការផ្ដល់នូវទំនិញជាសកល ដូចជា ការអប់រំនេះ ជាដើម មិនមែនជារឿងថ្មីនោះទេ ប៉ុន្តែជាអ្វីដែលកាន់តែមានលក្ខណៈស្មុគស្មាញ។ កន្លងមក ប្រព័ន្ធទាំងនេះស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ និងស្ថាប័នអន្តររដ្ឋាភិបាលនានា ប៉ុន្តែយើងកំពុងឃើញមានការចូលរួមកាន់តែច្រើនឡើងពីតួអង្គមិនមែនរដ្ឋជាច្រើន។ “បច្ចុប្បន្ននេះ មានតួអង្គរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដើម្បីប្រាក់ចំណេញ និងមិនដើម្បី

> ការរៀបចំអភិបាលកិច្ចនៅកម្រិតសកល កាន់តែមានលក្ខណៈស្មុគស្មាញ។

[១១៣] Sharp, J. and Vally, R. 2009. Unequal cultures? Racial integration at a South African university and Stoczowski, W. 2009.UNESCO’s doctrine of human diversity: a secular soteriology? Anthropology Today, 25 (3) June 2009, pp. 3-11.

ប្រាក់ចំណេញជាច្រើន ដែលចូលរួមក្នុងការរៀបចំអភិបាលកិច្ចដែលមានលក្ខណៈចម្រុះ និង ដែលថែមទាំងមានលក្ខណៈប្រកួតប្រជែងគ្នាទៀតផងនោះ នៅកម្រិតសកល។[១១៤] លទ្ធផល គឺការបោះជំហានបន្តិចម្តងៗពីការគ្រប់គ្រងនៅថ្នាក់រដ្ឋ ទៅថ្នាក់សកល ដែលគោលការណ៍នេះ ត្រូវបានជម្រុញឲ្យមាន មិនត្រឹមតែដោយសារស្ថាប័នអន្តររដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ដោយសារអង្គការសង្គមស៊ីវិល សាជីវកម្ម មូលនិធិ និងធនាគារខួរក្បាលទៀតផង។ ការរៀបចំ អភិបាលកិច្ច នៅកម្រិតសកល ក៏កាន់តែមានលក្ខណៈស្មុគស្មាញជាងមុនផងដែរ ដូចដែល បង្ហាញតាមរយៈការរៀបចំ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធចម្រុះ ដូចជា ភាពជាដៃគូសកល សម្រាប់ការអប់រំ (GPE) ជាដើម។ ឥទ្ធិពលដែលអាចមាននៃការរៀបចំអភិបាលកិច្ចជាសកល ក្នុងវិស័យអប់រំ និងអភិវឌ្ឍន៍ជំនាញ អាចនិយាយបានថា មានលក្ខណៈចម្រូងចម្រាស់ជាងក្នុង វិស័យអភិវឌ្ឍន៍ផ្សេងទៀត ដូចជា វិស័យសុខាភិបាល ជាដើម។ នេះគឺដោយសារតែលក្ខណៈ នយោបាយនៃគោលនយោបាយអប់រំ ជាតិ និងទិដ្ឋភាពក្រមសីលធម៌ វប្បធម៌ សេដ្ឋកិច្ច សង្គម និងស៊ីវិលចម្រុះ ដែលពាក់ព័ន្ធគ្នាទៅវិញទៅមក ក្នុងគោលនយោបាយនេះ។

## គណនេយ្យភាព និងតម្រូវការទិន្នន័យដែលពាក់ព័ន្ធ

ទិន្នន័យក៏មានសារៈសំខាន់សម្រាប់អភិបាលកិច្ច និងគណនេយ្យភាព សម្រាប់អ្នកពាក់ព័ន្ធ ចម្រុះ ដែលចូលរួម និងធ្វើការងារពាក់ព័ន្ធនឹងការអប់រំសាធារណៈ នៅថ្នាក់ជាតិ និងថ្នាក់សកល ផងដែរ។ នៅថ្នាក់ជាតិ វាជាការសំខាន់ណាស់ ដែលអាជ្ញាធរអប់រំត្រូវទទួលខុសត្រូវធានាឲ្យ ភាគរយនៃចំណាយសាធារណៈមានទំហំគ្រប់គ្រាន់ (ដោយមានការបំពេញបន្ថែមដោយ ការវិនិយោគឯកជន) ដើម្បីធានាសិទ្ធិរបស់កុមារ យុវជន និងមនុស្សពេញវ័យទាំងអស់ ក្នុងការទទួលបានឱកាសអប់រំកម្រិតមូលដ្ឋាន ដែលនាំឲ្យពួកគេអាចទទួលបានការរៀន សូត្រប្រកបដោយប្រសិទ្ធភាព និងពាក់ព័ន្ធ។ ដូចគ្នាដែរ វាគឺជាគន្លឹះ ដើម្បីឲ្យអាជ្ញាធរនៅ ថ្នាក់ជាតិ អាចទទួលខុសត្រូវក្នុងការធានាឲ្យមានការផ្តល់ឱកាសស្មើគ្នា សម្រាប់ការអប់រំ និងការបណ្តុះបណ្តាលក្រោយកម្រិតមូលដ្ឋាន។ នៅកម្រិតសកលវិញ ទិន្នន័យកាន់តែមាន លក្ខណៈស្តង់ដាជាងមុន និងស្ថិតក្នុងទម្រង់ស្ថិតិ សូចនាករ និងសន្ទស្សន៍ដែលអាចឲ្យគេ ធ្វើការប្រៀបធៀបជាលក្ខណៈអន្តរជាតិបាន ក៏ដូចជាទិន្នន័យវាយតម្លៃក្នុងទ្រង់ទ្រាយធំ ដែល គេអាចប្រើប្រាស់ សម្រាប់ពិនិត្យតាមដាន កំណត់ចំណុចដៅ និងដាក់ចំណាត់ថ្នាក់។[១១៥]

[១១៤] NORRAG. 2014. Global governance in education and training and the politics of data scoping workshop report. www.norrag.org/en/event/archive/2014/June/16/detail/scoping-meeting-on-the-global-governanceof-education-16-17-june.html [Accessed February 2015].

[១១៥] Ibid. These include PISA, PIACC, UIS and OECD statistics, and SABER.

ទិន្នន័យទាំងនេះ កាន់តែត្រូវបានគេយកមកប្រើប្រាស់ សម្រាប់ផ្តល់ជាព័ត៌មាន ក៏ដូចជាផ្តល់នូវភាពស្របច្បាប់ដល់ការតាក់តែងគោលនយោបាយ និងការវិនិយោគក្នុងវិស័យអប់រំ។

ដោយឈរលើហេតុផលនេះ មានការអំពាវនាវឲ្យមាន "បដិវត្តទិន្នន័យ" តាមទិដ្ឋភាពផ្សេងៗនៃការអភិវឌ្ឍ។[១១៦] ជាការពិត បទពិសោធន៍ ដែលគេទទួលបានពីការកំណត់ចំណុចដៅជាសកល ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងបទពិសោធន៍ពីការងារអប់រំសម្រាប់ទាំងអស់គ្នា ចាប់តាំងពីឆ្នាំ ២០០០ មក បានលើកទឹកចិត្តឲ្យមានការរាយការណ៍ទិន្នន័យថ្នាក់ជាតិដែលមានលក្ខណៈក្តោបរួម ដែលជារឿយៗ ទិន្នន័យបែបនេះលាក់កំបាំងវិសាលភាពនៃវិសមភាព និងគម្លាត ដែលកើតមានក្នុងប្រទេសមួយ។ ប្រសិនបើយើងមានការព្រួយបារម្ភអំពីសមធម៌ ក្នុងការផ្តល់នូវឱកាសរៀនសូត្រដែលមានប្រសិទ្ធភាព និងពាក់ព័ន្ធ សម្រាប់ទាំងអស់គ្នា នោះការកំណត់ចំណុចដៅនៅថ្នាក់ជាតិ គួរផ្តល់លទ្ធភាពឲ្យមានការរាយការណ៍ទិន្នន័យដែលបែងចែកតាមប្រភេទឲ្យបានកាន់តែលំអិត។ ការប្រមូល និងការប្រើប្រាស់ទិន្នន័យ ត្រូវផ្តោតឲ្យហួសពីកត្តានៃការរើសអើងដែលធ្លាប់មានកន្លងមក ដូចជា យេនឌ័រ និងកន្លែងរស់នៅប្រជុំជន ឬជនបទ និងត្រូវបញ្ចូលកម្រិតចំណូល និងបើអាចស្ថានភាពភាគតិចផងដែរ។ គេអាចធ្វើបែបនេះ តាមរយៈការប្រើប្រាស់សំណុំទិន្នន័យផ្សេងៗ ដូចជា ទិន្នន័យអំពីជីវភាពរស់នៅ ការអង្កេតសុខភាព ឬការអង្កេតកម្លាំងពលកម្ម ជាដើម។

## ការផ្លាស់ប្តូរនិន្នាការនៃការផ្តល់ហិរញ្ញប្បទានអប់រំ

នៅពេលដែលលទ្ធភាពទទួលបានការអប់រំកម្រិតមូលដ្ឋាន និងក្រោយកម្រិតមូលដ្ឋាន មានការកើនឡើង យើងមានការយល់ដឹងកាន់តែច្រើនអំពីសម្ពាធដែលមានមកលើការផ្តល់ហិរញ្ញប្បទានសាធារណៈដល់ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ អ្វីដែលចាំបាច់ត្រូវធ្វើ គឺត្រូវបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដែលមានកំណត់ទាំងនេះ ដើម្បីបង្កើនគណនេយ្យភាពលើការវិនិយោគធនធានសាធារណៈសម្រាប់វិស័យអប់រំ ក៏ដូចជារិះរកវិធី ដើម្បីបំពេញបន្ថែមធនធានទាំងនេះ តាមរយៈការបង្កើនសមត្ថភាពសារពើពន្ធ ការតស៊ូមតិឲ្យមានការបង្កើនជំនួយអភិវឌ្ឍន៍ផ្លូវការ និងការបង្កើតភាពជាដៃគូថ្មីៗ ជាមួយនឹងតួអង្គមិនមែនរដ្ឋនានា។ កន្លងមក អ្នកផ្តល់ជំនួយបានបំពេញតួនាទីសំខាន់ ក្នុងការបំពេញបន្ថែមឲ្យចំណាយសាធារណៈរបស់ជាតិ ជាពិសេស សម្រាប់ការអប់រំកម្រិតមូលដ្ឋាន។ មានការកត់សម្គាល់ថា

[១១៦] United Nations. 2013. A New Global Partnership: Eradicate poverty and transform economies for sustainable development. The Report of the High-Level Panel of Eminent Persons on the Post-2015 Development Agenda. New York, United Nations.

“របាយការណ៍សាធារណៈ របស់ស្ថាប័នពហុជាតិជាច្រើនបង្ហាញឲ្យឃើញពីការប្ដេជ្ញាចិត្តរឹងមាំខ្លាំងក្លាចំពោះវិស័យអប់រំ។ លើសពីនេះ ការអង្កេតលើអ្នកពាក់ព័ន្ធក្នុងប្រទេសកំពុងអភិវឌ្ឍ ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន បង្ហាញឲ្យឃើញពីការកើនឡើងនូវតម្រូវការឲ្យមានការគាំទ្រដល់វិស័យអប់រំឲ្យបានកាន់តែទូលំទូលាយបន្ថែមទៀត។ ប៉ុន្តែបើទោះបីជាមានការដាក់អាទិភាព និងតម្រូវការរឹងមាំបែបនេះក៏ដោយ មានភស្តុតាងបង្ហាញថាការគាំទ្រពហុភាគីដល់ការអប់រំកម្រិតមូលដ្ឋាន កំពុងមានការថមថយ បើធៀបជាមួយនឹងវិស័យផ្សេងទៀត” ការថមថយនេះកើតឡើងចំពេល ដែលប្រទេសមួយចំនួនកំពុងត្រូវការធនធាននេះជាងគេ។[១១៧] ជាការពិត ភាគរយនៃជំនួយសាធារណៈ សម្រាប់វិស័យអប់រំសាធារណៈ នៅតែមានសារៈសំខាន់ចំពោះប្រទេសដែលមានចំណូលទាបជាច្រើន។ ក្នុងប្រទេសចំនួន ៩ ដែលសុទ្ធតែជាប្រទេសនៅអាហ្រ្វិចសាប់សាហារ៉ា ចំណាយជាសាធារណៈលើវិស័យអប់រំបានពីជំនួយអន្តរជាតិដល់ទៅជាងមួយភាគបួន។[១១៨] លើសពីនេះ ការទទួលស្គាល់កាន់តែខ្លាំងឡើងនូវចរាចរណ៍ធនធានខួរក្បាល ឆ្លងព្រំប្រទល់ដែនរបស់ជាតិ កំពុងអំពាវនាវឲ្យមានការធ្វើសកម្មភាពរួមគ្នាជាសកល ជាពិសេស បង្កើតនូវយន្តការផ្ដល់ហិរញ្ញប្បទានមួយ ដែលអាចបំពេញបន្ថែមដល់ចំណាយសាធារណៈរបស់ជាតិសម្រាប់ការអប់រំដែលត្រូវបានចាត់ទុកជាទំនិញសាធារណៈជាសកល។[១១៩]

## ឥទ្ធិពលរបស់អ្នកផ្ដល់ជំនួយលើការតាក់តែងគោលនយោបាយនៅថ្នាក់ជាតិ

អ្នកផ្ដល់ជំនួយមិនត្រឹមតែផ្ដល់ជំនួយអភិវឌ្ឍន៍ ដើម្បីបំពេញបន្ថែមលើធនធានក្នុងស្រុកដែលនៅមានការខ្វះខាតនោះទេ ពួកគេក៏មានឥទ្ធិពលធំធេងលើគោលនយោបាយអប់រំផងដែរ។ ចំណុចនេះមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង។ ឧទាហរណ៍ មូលនិធិអប់រំរបស់សង្គមស៊ីវិល ( CSEF ) និងភាពជាដៃគូសកលសម្រាប់ការអប់រំ ( GPE ) បានជម្រុញ

---

[១១៧] Pauline, R. and Steer, L. 2013. Financing for Global Education Opportunities for Multilateral Action: A report prepared for the UN Special Envoy for Global Education for the High-level Roundtable on Learning for All. Center for Universal Education (CUE) at Brookings Institution and UNESCO EFA GMR. It addresses issues concerning the financing of basic education (Basic Education at risk). www.brookings.edu/~/media/research/files/reports/2013/09/financing%20global%20education/basic%20education%20financing%20final%20%20webv2.pdf [Accessed February 2015].

[១១៨] Bokova, I. 2014. Opening Speech. Global Education for All Meeting. 12-14 May 2014. Muscat, Sultanate of Oman. www.unesco.org/new/fileadmin/MULTIMEDIA/HQ/ED/ED_new/pdf/UNESCO-DG.pdf [Accessed February 2015].

[១១៩] UNESCO. 2012. Youth and skills: Putting education to work. EFA Global Monitoring Report 2012. Paris, UNESCO, p. 146.

ឲ្យមានការចូលរួមពីសង្គមស៊ីវិលក្នុងក្រុមអប់រំថ្នាក់មូលដ្ឋាន (LEG) ។ គំនិតផ្តួចផ្តើមនេះផ្តល់លទ្ធភាពឲ្យសង្គមស៊ីវិលចូលរួម ក្នុងការរៀបចំកម្មវិធីអប់រំ រួមជាមួយនឹងរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយនានា និងធ្វើការតាមដានវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា។[១២០] ប៉ុន្តែ នៅពេលដែលអ្នកផ្តល់ជំនួយដាក់លក្ខខណ្ឌ ឬកំណត់គោលការណ៍ សម្រាប់ផ្តល់ជំនួយ រដ្ឋាភិបាលប្រហែលជាត្រូវបង្ខំចិត្តធ្វើការផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន។[១២១] និន្នាការបច្ចុប្បន្ននៃការផ្តល់ហិរញ្ញប្បទានទៅតាមលទ្ធផលដែលទីភ្នាក់ងារផ្តល់ជំនួយជាច្រើនបានប្រើប្រាស់ អាចសម្រេចទៅតាមគោលបំណងដែលអ្នកផ្តល់ជំនួយទាំងនោះចង់បាន។ ប៉ុន្តែ វាអាចមានលក្ខណៈខុសគ្នាពីគោលនយោបាយរបស់ប្រទេសនីមួយៗ និងមិនបានពិចារណាលើដំណោះស្រាយដែលរៀបចំក្នុងប្រទេសស្របតាមបរិបទក្នុងប្រទេស មាននិរន្តរភាព និងស្ថិតក្រោមភាពជាម្ចាស់របស់ប្រទេស។ ដូច្នេះ អ្នកផ្តល់ជំនួយគួរផ្តល់ការគាំទ្រដល់រដ្ឋាភិបាល សង្គមស៊ីវិលក្នុងមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដែលធ្វើការងារពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគោលនយោបាយ ដោយត្រូវធ្វើការពិចារណាលើបំណងប្រាថ្នា អាទិភាព បរិបទ និងលក្ខខណ្ឌក្នុងប្រទេស។

## ការផ្លាស់ប្តូរលក្ខណៈនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ

ចាប់តាំងពីការបោះពុម្ពផ្សាយរបាយការណ៍ Delors (១៩៩៦) និងការអនុម័តលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (២០០០) មក លក្ខណៈនៃជំនួយអន្តរជាតិមានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ខណៈពេលដែលលំហូរជំនួយពីភាគខាងជើង ទៅភាគខាងត្បូង នៅតែមានសារៈសំខាន់ កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ បានបំពេញតួនាទីកាន់តែសំខាន់ ក្នុងការអភិវឌ្ឍអន្តរជាតិ។ វិបត្តិហិរញ្ញវត្ថុសកល និងការលេចរូបរាងមហាអំណាចសេដ្ឋកិច្ចថ្មីៗ ក៏បានរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរទំនាក់ទំនងរវាងប្រទេសមួយ និងប្រទេសមួយ និងធ្វើឲ្យមានការរៀបចំ ថ្មីសម្រាប់ការផ្តល់ជំនួយអន្តរជាតិ។ នៅពេលដែលប្រទេសនានាជួបប្រទះនឹងការលំបាកកាន់តែស្រដៀងគ្នា

> ចាប់តាំងពីការបោះពុម្ពផ្សាយរបាយការណ៍ Delors (១៩៩៦) និងការអនុម័តលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (២០០០) មក លក្ខណៈនៃជំនួយអន្តរជាតិមានការប្រែប្រួលគួរឲ្យកត់សម្គាល់។

[១២០] Winthrop, R. and Bulloch, G. 2012.

[១២១] GPE web site www.globalpartnership.org/civil-society-education-fund [Accessed February 2015].

(ដូចជា ភាពគ្មានការងារធ្វើ វិសមភាព ការប្រែប្រួលអាកាសធាតុ ។ល) ឥឡូវនេះ មានការអំពាវនាវឲ្យមានប្រើប្រាស់គោលការណ៍សកលកម្ម និងសមាហរណកម្ម ជាធាតុផ្សំសំខាន់សម្រាប់របៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥។ សកលកម្ម មានន័យថា គ្រប់ប្រទេសទាំងអស់ចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរមាគ៌ានៃការអភិវឌ្ឍរបស់ខ្លួន ដោយត្រូវប្រើប្រាស់អភិក្រមរៀងៗខ្លួន និងទៅតាមកាលៈទេសៈរៀងៗខ្លួន។ ការផ្លាស់ប្តូរនេះ ជម្រុញឲ្យយើងគិតពិចារណាពីការទទួលខុសត្រូវរួមគ្នា សម្រាប់អនាគតរួមគ្នារបស់យើង។

# ៤. ការអប់រំជាធំនិញរួម?



# ៤. ការអប់រំជាទំនិញរួម ?

*"តាមរយៈការចាត់ទុកការអប់រំថាជាគោលដៅចុងក្រោយ យើងទទួលស្គាល់ចំណេះដឹងថាជាអ្វីដែលមានគុណតម្លៃខ្ពស់បំផុត"*

**Abul Kalam Azad រដ្ឋមន្ត្រីក្រសួងអប់រំប្រទេសឥណ្ឌា (១៩៤៧-១៩៥៨)**

ក្នុងការកំណត់ចក្ខុវិស័យសារជាថ្មីសម្រាប់ការអប់រំ ក្នុងបរិបទសកលថ្មី យើងត្រូវធ្វើការពិចារណាឡើងវិញមិនត្រឹមតែអំពីគោលបំណងនៃការអប់រំប៉ុណ្ណោះទេ ប៉ុន្តែថែមទៀតរបៀបដែលការរៀនសូត្រត្រូវបានរៀបចំឡើងផងដែរ។ ដោយសារតែភាពជាដៃគូមានលក្ខណៈចម្រុះខ្លាំង និងដោយសារតែមានការកំណត់ព្រំដែនមិនច្បាស់លាស់រវាងវិស័យសាធារណៈ និងវិស័យឯកជន យើងចាំបាច់ត្រូវពិចារណាឡើងវិញលើគោលការណ៍នានា ដែលតម្រង់ទិសអភិបាលកិច្ចអប់រំ និងជាពិសេស គោលការណ៍និយាមការ ដែលចាត់ទុកការអប់រំជាទំនិញសាធារណៈ និងការយល់ដឹងពីគោលការណ៍នេះ ក្នុងបរិបទដែលមានការផ្លាស់ប្តូរក្នុងសង្គម រដ្ឋ និងទីផ្សារ។[១២៣]

## ■ គោលការណ៍ដែលចាត់ទុកការអប់រំថាជាទំនិញសាធារណៈ កំពុងទទួលរងសម្ពាធ

### ការអំពាវនាវឲ្យមានបរិយាប័ន្ន តម្លាភាព និងគណនេយ្យភាព

បុគ្គល និងសហគមន៍នានា កាន់តែទទួលបានភាពអង់អាច តាមរយៈការពង្រឹងលទ្ធិប្រជាធិបតេយ្យ ក្នុងប្រទេសជាច្រើន និងតាមរយៈការពង្រីកលទ្ធភាពទទួលបានចំណេះដឹងតាមរយៈការអប់រំក្នុងប្រព័ន្ធផង និងតាមរយៈបច្ចេកវិទ្យាឌីជីថលផង។ ការពង្រីកបែបនេះនាំឲ្យ

[១២៣] Morgan, W. J. and White, I. 2014. Education for Global Development: Reconciling society, state, and market. Weiterbildung, 1, 2014, pp. 38-41.

មានការកើនឡើងនូវតម្រូវការចង់បញ្ចេញសម្លេងក្នុងកិច្ចការសាធារណៈ និងចង់ធ្វើឲ្យមានការផ្លាស់ប្តូររបៀបអនុវត្តអភិបាលកិច្ចនៅកម្រិតមូលដ្ឋាន និងកម្រិតសកល។ ប្រជាពលរដ្ឋទូទៅកាន់តែទាមទារចង់បានគណនេយ្យភាព ភាពបើកចំហ សមធម៌ និងសមភាព ក្នុងកិច្ចការសាធារណៈ។ បើទោះបីជាការចង់បញ្ចេញសម្លេងរបស់ប្រជាពលរដ្ឋភាគច្រើន គឺជាការចង់បាននៅកម្រិតមូលដ្ឋាន ឬកម្រិតជាតិយ៉ាងណាក៏ដោយ ការចង់បញ្ចេញសម្លេងបែបនេះកាន់តែមានលក្ខណៈឆ្លងដែន និងផ្តោតលើបញ្ហាដែលជាការព្រួយបារម្ភរបស់សកលលោកទាំងមូល។ មានន័យថា តួអង្គមិនមែនរដ្ឋ មិនថាសង្គមស៊ីវិល ឬសាជីវកម្មនានានោះទេ កាន់តែមានតួនាទីធំជាងមុន ក្នុងការគ្រប់គ្រងកិច្ចការសាធារណៈ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សកល។ នេះគឺជាអ្វីដែលកើតឡើងចំពោះគោលនយោបាយអប់រំ ដែលទាំងវិស័យសាធារណៈ និងវិស័យឯកជន សុទ្ធតែមានតួនាទីក្នុងការកសាងនូវសង្គមពុទ្ធិមួយដែលមានលក្ខណៈបរិយាប័ន្ន។ យើងសង្កេតឃើញថា ការបង្កើនសម្លេងរបស់ពលរដ្ឋបែបនេះមានឥទ្ធិពលលើក្របខ័ណ្ឌកម្មវិធីសិក្សា សៀវភៅសិក្សា និងគោលនយោបាយ ពាក់ព័ន្ធជាមួយនឹងសកម្មភាពជាវិជ្ជមានដែលត្រូវមាន។

> ប្រជាពលរដ្ឋទូទៅកាន់តែទាមទារចង់បានគណនេយ្យភាព ភាពបើកចំហ សមធម៌ និងសមភាព ក្នុងកិច្ចការសាធារណៈ។

## កំណើននៃការចូលរួមនៃវិស័យឯកជនក្នុងវិស័យអប់រំ

និន្នាការទៅរកការធ្វើឯកជនភាវូបនីយកម្មនៃវិស័យអប់រំ កំពុងមានការកើនឡើងនៅគ្រប់កម្រិតទាំងអស់នៃការផ្តល់សេវាអប់រំ នៅទូទាំងពិភពលោក។ ក្នុងទសវត្សរ៍កន្លងទៅនេះ ការចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថានអប់រំឯកជនមានការកើនឡើង ជាពិសេស នៅកម្រិតអប់រំបឋមសិក្សា ក្នុងប្រទេសដែលមានចំណូលទាប និងកម្រិតអប់រំក្រោយមធ្យមសិក្សា ប៉ុន្តែមិនមែនឧត្តមសិក្សា ក្នុងប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍ និងនៅអាស៊ីភាគកណ្តាល។[១២៤] ឯកជនភាវូបនីយកម្មការអប់រំ គឺជាដំណើរការនៃការផ្ទេរសកម្មភាព ទ្រព្យសម្បត្តិ ការគ្រប់គ្រងមុខងារ និងការទទួលខុសត្រូវ ពាក់ព័ន្ធជាមួយនឹងវិស័យអប់រំ ពីគ្រឹះស្ថានរដ្ឋ ឬសាធារណៈ ទៅបុគ្គល និងទីភ្នាក់ងារឯកជន។[១២៥] ក្នុងករណីនៃការអប់រំតាមសាលារៀន ដំណើរការនេះមានច្រើនទម្រង់ ដូចជា សាលារៀនសាសនា សាលារៀនឯកជនដែលយកថ្លៃសេវាទាប សាលារៀន

---

១២៤ UIS database. Time period: 2000-2011.

១២៥ Adapted from: Right to Education Project. 2014. Privatisation of Education: Global Trends of Human Rights Impacts. London, Right to Education Project.

ដែលទទួលបានជំនួយពីបរទេសឬអន្តរជាតិ ដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល សាលារៀនពិសេស (Charter Schools) សាលារៀនកិច្ចសន្យា (Contract Schools) និង សាលារៀនប្រើប្រាស់ប័ណ្ណ (Voucher Schools) ការបង្រៀន តាមផ្ទះ ការបង្រៀនពិសេស ផ្ទាល់ខ្លួន សាលារៀនដែលផ្តល់ការបង្រៀនទៅតាមទីផ្សារ និងសម្រាប់រកប្រាក់ចំណេញ។[១២៦] ខណៈពេលដែលការចូលរួមរបស់វិស័យឯកជន ក្នុងវិស័យអប់រំ មិនមែនជារឿងថ្មី "អ្វីដែលថ្មីអំពី ការលេចចេញនូវទម្រង់ទាំងនេះ គឺវិសាលភាព ភាពស៊ីជម្រៅ និងការជ្រៀតចូល របស់វិស័យ ឯកជន ទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃវិស័យអប់រំ"។[១២៧]

## ផលប៉ះពាល់នៃឯកជនភាវូបនីយកម្មមកលើសិទ្ធិទទួលបានការអប់រំ

ឯកជនភាវូបនីយកម្មនៃការអប់រំ អាចមានផលប៉ះពាល់ជាវិជ្ជមានមកលើក្រុមសង្គម មួយចំនួន ក្នុងទម្រង់ជាការផ្តល់ឱកាសរៀនសូត្រច្រើនជាងមុន បង្កើនជម្រើសសម្រាប់ មាតាបិតា និងផ្តល់នូវកម្មវិធីសិក្សាជាច្រើនប្រភេទ។ ប៉ុន្តែ វាក៏អាចមានផលប៉ះពាល់ អវិជ្ជមាន ដោយសារតែការពុំមានការពិនិត្យតាមដាន និងការធ្វើនិយ័តកម្មគ្រប់គ្រាន់ ពី អាជ្ញាធរសាធារណៈ (ដូចជា សាលារៀនពុំមានអាជ្ញាប័ណ្ណ ការជួលគ្រូដែលពុំបានទទួល ការបណ្តុះបណ្តាលត្រឹមត្រូវ និងការពុំមានការធានាគុណភាពជាដើម) ដែលអាចធ្វើឲ្យមាន ហានិភ័យដល់ភាពសុខុដុមរមនា និងសាមគ្គីភាពក្នុងសង្គម។ អ្វីដែលជាការព្រួយបារម្ភ ជាពិសេស៖ "ក្រុមដែលបាត់បង់ឱកាសខកខានមិនបានទទួលផលជាវិជ្ជមានពីការអប់រំ ហើយ ត្រូវទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារតែឯកជនភាវូបនីយកម្មទៅវិញ"។[១២៨] លើសពីនេះ ការយកថ្លៃសេវារបស់អ្នកផ្តល់សេវាឯកជន ដោយពុំមានការគ្រប់គ្រងត្រឹមត្រូវ អាចធ្វើឲ្យប៉ះពាល់ដល់សកលកម្មនៃការទទួលបានការអប់រំ។ ជាទូទៅ វាមានផលប៉ះពាល់ ជាអវិជ្ជមានលើសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព និងការទទួលបានឱកាសអប់រំ ស្មើភាពគ្នា។

---

[១២៦] Patrinos, H.A. et al. 2009. The Role and Impact of Public-Private Partnership in Education. Washington, DC, World Bank. Lewis L., and Patrinos H.A. 2012. Impact Evaluation of Private Sector Participation in Education. London, CfBT Education Trust. Right to Education Project. 2014. Privatisation of Education: Global Trends of Human Rights Impacts. London, Right to Education Project.

[១២៧] Macpherson, I., Robertson, S. and Walford, G. 2014. Education, Privatization and Social Justice: case studies from Africa, South Asia and South East Asia. Oxford, Symposium Books.

[១២៨] The Right to Education Project. 2014. op. cit.

ការបង្រៀនគួរបន្ថែម ឬ “ការអប់រំស្រមោល” ដែលជារូបភាពមួយនៃឯកជនភាវូបនីយកម្មការអប់រំ ក៏កំពុងមានការកើនឡើង ក្នុងពិភពលោកទាំងមូលផងដែរ។[១២៩] ការបង្រៀនគួរ ជារឿយៗ គឺជាសញ្ញាដែលបង្ហាញពីប្រព័ន្ធសាលារៀនដែលដំណើរការមិនបានល្អ[១៣០] ហើយដូចគ្នានឹងរូបភាពផ្សេងទៀតនៃការអប់រំដែលផ្តល់ដោយវិស័យឯកជនដែរ អាចមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង លើអ្នករៀនសូត្រ និងលើគ្រូរបស់ពួកគេ។ ម្យ៉ាងការបង្រៀនបែបនេះអាចកែសម្រួលឲ្យស្របតាមតម្រូវការរបស់សិស្សរៀនយឺត ហើយគ្រូអាចទទួលបានចំណូលបន្ថែមពីលើបៀវត្សរ៍ ដែលសាលារៀនផ្តល់ឲ្យពួកគេ។ ម្យ៉ាងទៀត ថ្លៃសេវាសម្រាប់ការបង្រៀនគួរនេះអាចស្រូបយកចំណូលគ្រួសារមួយភាគធំ ជាពិសេស គ្រួសារក្រីក្រដែលនាំឲ្យមានការបង្កើតវិសមភាពក្នុងឱកាសរៀនសូត្រ។ ហើយដោយសារតែគ្រូមួយចំនួនត្រូវចំណាយការខិតខំប្រឹងប្រែងរបស់ខ្លួនលើការបង្រៀនគួរបែបនេះ និងមិនយកចិត្តទុកដាក់ចំពោះភារកិច្ចចម្បងរបស់ពួកគេ វាអាចធ្វើឲ្យមានផលប៉ះពាល់ជាអវិជ្ជមានលើគុណភាពនៃការបង្រៀន និងរៀន ក្នុងសាលារៀន។[១៣១] កំណើននៃការអប់រំស្រមោល ធនធានហិរញ្ញវត្ថុដែលបុគ្គលម្នាក់ៗនិងគ្រួសារត្រូវប្រមូលកៀងគរ និងការព្រួយបារម្ភពាក់ព័ន្ធជាមួយនឹងទង្វើមិនគប្បី និងអំពើពុករលួយ ដែលអាចប្រព្រឹត្តដោយគ្រូ កំពុងធ្វើឲ្យក្រសួងអប់រំមួយចំនួនមានផែនការធ្វើនិយ័តកម្មលើករណីបែបនេះ។[១៣២]

[១២៩] Bray, M. 2009. Confronting the shadow education system. What government policies for what private tutoring? Paris, UNESCO-IIEP.

[១៣០] UNESCO. 2014. Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014. Paris, UNESCO.

[១៣១] Bray, M. and Kuo, O. 2014. Regulating Private Tutoring for Public Good. Policy options for supplementary education in Asia. CERC Monograph Series in Comparative and International Education and Development. No. 10. Hong Kong, Comparative Education Research Center and UNESCO Bangkok Office.

[១៣២] Ibid.

## ប្រអប់ទី ១៦៖ ការបង្រៀនគួរឯកជន ធ្វើឲ្យប៉ះពាល់ដល់ឱកាសទទួលបានការអប់រំរបស់ប្រជាពលរដ្ឋក្រីក្រ ក្នុងប្រទេសអេហ្ស៊ីប [១៣៣]

ក្នុងប្រទេសអេហ្ស៊ីប ការបង្រៀនគួរឯកជន ស្រូបយកចំណាយមួយភាគធំរបស់គ្រួសារលើការអប់រំ ពោលគឺគិតជាមធ្យម ៤៧% ក្នុងតំបន់ជនបទ និង ៤០% ក្នុងតំបន់ប្រជុំជន។ ចំណាយប្រចាំឆ្នាំ លើការបង្រៀនគួរឯកជន ត្រូវបានគេរាយការណ៍ថាមានចំនួន ២,៤ ពាន់លានដុល្លារ ឬស្មើនឹង ២៧% នៃចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ ក្នុងឆ្នាំ ២០១។

ការវិនិយោគបែបនេះត្រូវបានគេយល់ឃើញថា ជាការដាក់បន្ទុកផ្នែកហិរញ្ញវត្ថុលើគ្រួសារ ដែលមានលទ្ធភាពបង់ថ្លៃបាន។ ប៉ុន្តែ មិនមែនគ្រប់គ្នាសុទ្ធតែមានលទ្ធភាពបែបនេះនោះទេ។ កុមារមកពីតាមគ្រួសារដែលមានជីវភាពធូរធាមានលទ្ធភាពរៀនគួរឯកជនជិតពីរដងបើធៀបជាមួយនឹងកុមារដែលគ្មានលទ្ធភាព។ កុមារ ដែលគ្រួសារពុំមានលទ្ធភាពបង់ថ្លៃសម្រាប់ការរៀនគួរឯកជន ត្រូវជួបនឹងផលវិបាក ដែលបង្កឡើងដោយសារប្រព័ន្ធអប់រំក្នុងប្រព័ន្ធដែលមានគុណភាពទាប ដែលគ្រូច្រើនតែចំណាយថាមពល និងធនធានរបស់ខ្លួនលើការបង្រៀនគួរឯកជន ជាងការបង្រៀនក្នុងថ្នាក់។

មូលហេតុដ៏សំខាន់មួយ ដែលធ្វើឲ្យមានការបង្រៀនគួរឯកជនក្នុងទ្រង់ទ្រាយធំបែបនេះគឺដោយសារតែមុខមាត់ក្នុងសង្គមរបស់គ្រូក្នុងប្រទេសអេហ្ស៊ីបមានការថយចុះក្នុងទសវត្សរ៍ថ្មីៗនេះ នៅពេលដែលរដ្ឋាភិបាលចាប់ផ្តើមជួលគ្រូដែលមិនសូវមានសមត្ថភាព ដើម្បីបំពេញតម្រូវការនៃការពង្រីកសេវាអប់រំសាធារណៈ។ ជារឿយៗ សិស្សបោះបង់ចោលការសិក្សាបានក្លាយខ្លួនជាគ្រូបង្រៀន មិនមែនដោយសារតែការជ្រើសរើសរបស់ពួកគេនោះទេ ប៉ុន្តែជាជម្រើសចុងក្រោយសម្រាប់ពួកគេ។ ការផ្តល់តម្លៃទាបដល់អាជីពគ្រូបង្រៀន ក្នុងប្រទេសអេហ្ស៊ីប ធ្វើឲ្យការងារបង្រៀននេះ ក្លាយជាការងារដែលទទួលបានបៀវត្សរ៍ទាបជាងគេរបស់រដ្ឋាភិបាល។ ដូច្នេះ គ្រូត្រូវបង្រៀនគួរ ដើម្បីរកចំណូលបន្ថែមពីលើបៀវត្សរ៍របស់ពួកគេ។

ប្រភព៖ UNESCO. 2014. Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014. Paris, UNESCO.

---

[១៣៣] UNESCO. 2014. Teaching and Learning: Achieving quality for all. EFA Global Monitoring Report 2013-2014. Paris, UNESCO. [Based on the following sources: Central Agency for Public Mobilization and Statistics (2013); Elbadawy et al. (2007); Hartmann (2007); UNESCO (2012a).]

ការបង្កើតឲ្យមាន និងធ្វើឲ្យកាន់តែមានវិសមភាពឱកាសរៀនសូត្រ ដែលកើតឡើងដោយសារឯកជនភាវូបនីយកម្មក្នុងគ្រប់ទម្រង់ទាំងអស់ ធ្វើឲ្យមានការចោទសំណួរសំខាន់ៗអំពីទស្សនទាននៃការអប់រំ ក្នុងទម្រង់ជាទំនិញសាធារណៈ និងអំពីតួនាទីរបស់រដ្ឋ ក្នុងការធានាសិទ្ធិទទួលបានការអប់រំ។

## ការរៀបចំបរិបទសារជាថ្មីសម្រាប់សិទ្ធិទទួលបានការអប់រំ

> ការបង្កើតឲ្យមាន និងធ្វើឲ្យកាន់តែមានវិសមភាពឱកាសរៀនសូត្រ ដែលកើតឡើងដោយសារឯកជនភាវូបនីយកម្ម ក្នុងគ្រប់ទម្រង់ទាំងអស់ ធ្វើឲ្យមានការចោទសំណួរសំខាន់ៗអំពីទស្សនទាននៃការអប់រំ ក្នុងទម្រង់ជាទំនិញសាធារណៈ និងអំពីតួនាទីរបស់រដ្ឋ ក្នុងការធានាសិទ្ធិទទួលបានការអប់រំ។

ក្នុងការពិភាក្សា អំពីការអភិវឌ្ឍអន្តរជាតិជារឿយៗ ការអប់រំតែងត្រូវបានលើកឡើងថាជាសិទ្ធិមនុស្សផង និងជាទំនិញសាធារណៈផង។ គោលការណ៍អប់រំ ក្នុងនាមជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលជាមូលដ្ឋានដើម្បីឲ្យ មានការទទួលបានសិទ្ធិមនុស្សផ្សេងទៀត បានចាក់ឫសទៅក្នុងក្របខ័ណ្ឌនិយាមការនានា។[១៣៤] ចំណុចនេះបង្ហាញពីតួនាទីរបស់រដ្ឋ ក្នុងការធានាឲ្យមានការគោរពសិទ្ធិ ការបំពេញ និងការការពារសិទ្ធិទទួលបានការអប់រំ។ ក្រៅពីតួនាទីក្នុងការផ្តល់សេវាអប់រំ រដ្ឋត្រូវបំពេញនាទីជាអ្នកធានា សិទ្ធិទទួលបានការអប់រំផងដែរ។

[១៣៤] សូមមើលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨ (មាត្រា ២៦) និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ឆ្នាំ ១៩៦៦ (មាត្រា ១៣) និងអនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ ១៩៨៩ (មាត្រា ២៨)។

## ប្រអប់ទី ១៧៖ ការគោរព ការបំពេញ និងការការពារសិទ្ធិទទួលបានការអប់រំ

៤៦. សិទ្ធិទទួលបានការអប់រំ ដូចគ្នានឹងសិទ្ធិមនុស្សទាំងអស់ដែរ ដាក់កាតព្វកិច្ច ៣ ប្រភេទ ឬ ៣ កម្រិតលើរដ្ឋភាគី៖ កាតព្វកិច្ចគោរព ការពារ និងបំពេញ។ កាតព្វកិច្ចបំពេញបញ្ចូលកាតព្វកិច្ចសម្របសម្រួលផង និងកាតព្វកិច្ចផ្តល់សេវាផង។

៤៧. កាតព្វកិច្ចគោរព តម្រូវឲ្យរដ្ឋភាគីចៀសវាងអនុវត្តវិធានការនានា ដែលធ្វើឲ្យរាំងស្ទះ ឬរារាំងមិនឲ្យមានការទទួលបានសិទ្ធិទទួលបានការអប់រំ។ កាតព្វកិច្ចការពារ តម្រូវឲ្យរដ្ឋភាគីចាត់វិធានការរារាំងភាគីទីបី មិនឲ្យជ្រៀតជ្រែកជាមួយនឹងការទទួលបានសិទ្ធិទទួលបានការអប់រំ។ កាតព្វកិច្ចបំពេញ (បង្កលក្ខណៈងាយស្រួល) តម្រូវឲ្យរដ្ឋចាត់វិធានការវិជ្ជមាន ដែលបង្កលក្ខណៈ និងជួយឲ្យបុគ្គល និងសហគមន៍ អាចទទួលបានសិទ្ធិទទួលបានការអប់រំ។ ចុងក្រោយ រដ្ឋភាគីមានកាតព្វកិច្ចបំពេញ (ផ្តល់សេវា) សិទ្ធិទទួលបានការអប់រំ។ ជាគោលការណ៍ទូទៅរដ្ឋភាគីមានកាតព្វកិច្ចបំពេញ (ផ្តល់សេវា) សិទ្ធិ ដែលចែងក្នុងកតិកាសញ្ញានេះ នៅពេលដែលបុគ្គល ឬក្រុមមួយមិនអាចទទួលបានសិទ្ធិនេះដោយខ្លួនឯង ដោយប្រើប្រាស់មធ្យោបាយដែលពួកគេមាន ដោយសារមូលហេតុដែលពួកគេមិនអាចគ្រប់គ្រងបាន។ ប៉ុន្តែវិសាលភាពនៃការបំពេញកាតព្វកិច្ចនេះ គឺជាកម្មវត្ថុនៃខ្លឹមសារកតិកាសញ្ញានេះ។

ប្រភព៖ UN Committee on Economic, Social and Cultural Rights (CESCR). 1999. General Comment No. 13: The Right to Education (Art. 13 of the Covenant), 8 December 1999, E/C.12/1999/10 (46/47), available at: www.refworld.org/docid/4538838c22.html [Accessed 6 March 2015]

បើទោះបីជាមានកាព្វកិច្ចផ្លូវច្បាប់ជាក់លាក់ ពាក់ព័ន្ធជាមួយនឹងការផ្តល់សិទ្ធិអប់រំបែបក៏ដោយ រហូតមកទល់នឹងពេលថ្មីៗនេះ ការពិភាក្សាជាច្រើនអំពីសិទ្ធិទទួលបានការអប់រំផ្តោតការយកចិត្តទុកដាក់លើការរៀនសូត្រក្នុងសាលារៀន និងកាន់តែចង្អៀតទៅទៀតលើការអប់រំកម្រិតបឋមសិក្សា។ ទស្សនទាននៃការអប់រំកម្រិតមូលដ្ឋាន ដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩០ នៅក្នុងវេទិកាអប់រំពិភពលោក ក្នុងទីក្រុងចំទៀន ប្រទេសថៃ មានវិសាលភាពទូលំទូលាយ។ ទស្សនទាននេះបានដាក់បញ្ចូលឧបករណ៍សម្រាប់រៀនសូត្រកម្រិតមូលដ្ឋាន ដូចជា ចំណេះដឹងអក្សរ និងលេខនពន្ធ ក៏ដូចជាចំណេះដឹង ជំនាញ និងគុណតម្លៃ ដែលឆ្លើយតបចំពោះបរិបទ។

ចេញពីទស្សនវិស័យនៃការអប់រំក្នុងប្រព័ន្ធ ការអប់រំកម្រិតមូលដ្ឋាន ជារឿយៗ ត្រូវបានគេចាត់ទុកថាដូចគ្នាការអប់រំដែលជាកាតព្វកិច្ចតាមច្បាប់ ។ ប្រទេសភាគច្រើនលើសលុបក្នុងសកលលោក មានច្បាប់ជាតិ ដែលកំណត់រយៈពេលអប់រំណាមួយ ជារយៈពេលដែលតម្រូវដោយច្បាប់។ ចេញពីជ្រុងនេះ គោលការណ៍សិទ្ធិទទួលបានការអប់រំកម្រិតមូលដ្ឋាន ពុំមានការតវ៉ាពីភាគីណាឡើយ ដោយសារតែរដ្ឋជាអ្នកដែលមានតួនាទីការពារគោលការណ៍នេះ និងធានានូវឱកាសស្មើភាពគ្នា។

ប៉ុន្តែ ខណៈពេលដែលគោលការណ៍ទាំងនេះមិនត្រូវបានគេតវ៉ាសម្រាប់ការអប់រំកម្រិតមូលដ្ឋានក៏ពិតមែន ពុំមានការឯកភាពគ្នាជាទូទៅលើការអនុវត្តគោលការណ៍នេះ ក្នុងការអប់រំក្រោយកម្រិតមូលដ្ឋានឡើយ។[១៣៩] ការពង្រីកលទ្ធភាពទទួលបានការអប់រំថ្នាក់មូលដ្ឋាន ក៏ធ្វើឲ្យមានការកើនឡើងនូវតម្រូវការការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាផងដែរ និងធ្វើឲ្យមានការកើនឡើងនូវការព្រួយបារម្ភអំពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ជាពិសេស ក្នុងបរិបទដែលភាពគ្មានការងារធ្វើរបស់យុវជនកាន់តែមានការកើនឡើង និងក្នុងបរិបទនៃដំណើរការបញ្ជាក់គុណវឌ្ឍិ និងបញ្ជាក់គុណវឌ្ឍិសារជាថ្មី។ ដោយសារតែតម្រូវការការអប់រំក្រោយកម្រិតមូលដ្ឋាន និងតម្រូវការការរៀនសូត្រពេញមួយជីវិតមានការកើនឡើងបែបនេះ តើគេត្រូវយល់ និងអនុវត្តគោលការណ៍សិទ្ធិទទួលបានការអប់រំយ៉ាងដូចម្តេច? តើវាខុសពីសិទ្ធិទទួលបានការអប់រំកម្រិតមូលដ្ឋាន (ដែលជាកាតព្វកិច្ចតម្រូវដោយច្បាប់) ពាក់ព័ន្ធជាមួយនឹងអត្ថប្រយោជន៍ដែលអ្នកទាមទារសិទ្ធិត្រូវទទួលបាន និងភារកិច្ចរបស់អ្នកដែលមានកាតព្វកិច្ចយ៉ាងដូចម្តេច? តើរដ្ឋមានការទទួលខុសត្រូវ និងកាតព្វកិច្ចអ្វីខ្លះ សម្រាប់ការអប់រំនៅកម្រិតក្រោយកម្រិតដែលតម្រូវដោយច្បាប់ មិនថានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឧត្តមសិក្សា និងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ នៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សានោះទេ? តើគេអាចចែករំលែកការទទួលខុសត្រូវ ហើយក្នុងពេលជាមួយគ្នា នៅតែរក្សាគោលការណ៍មិនរើសអើង និងសមភាពនៃឱកាស ក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាលក្រោយកម្រិតមូលដ្ឋានដោយរបៀបណា?

---

១៣៩ Morgan, W. J. and White, I. 2014. The value of higher education: public or private good? Weiterbildung, 6, 2014, pp. 38-41.

## ភាពមិនច្បាស់លាស់នៃព្រំដែនរវាងវិស័យសាធារណៈ និងឯកជន

ក្នុងការពិភាក្សាជាអន្តរជាតិអំពីការអប់រំ ជារឿយៗ ការអប់រំត្រូវបានគេចាត់ទុកថាជាទំនិញសាធារណៈ។ អ្នករាយការណ៍ពិសេសរបស់សហប្រជាជាតិស្តីពីសិទ្ធិទទួលបានការអប់រំ បានគូសបញ្ជាក់ពីសារៈសំខាន់នៃការការពារផលប្រយោជន៍សង្គម ក្នុងការអប់រំ ហើយក្នុងពេលជាមួយគ្នា លើកកម្ពស់ទស្សនទាននៃការអប់រំជាទំនិញសាធារណៈ។[១៣៦] ប៉ុន្តែ ការទទួលខុសត្រូវជាចម្បងរបស់រដ្ឋ ក្នុងការផ្តល់ការអប់រំសាធារណៈ កាន់តែជួបនឹងឧបសគ្គ នៅពេលដែលមានការអំពាវនាវឲ្យមានការកាត់បន្ថយចំណាយសាធារណៈ និងការបង្កើនការចូលរួមរបស់តួអង្គមិនមែនរដ្ឋ។ អ្នកពាក់ព័ន្ធក្នុងចំនួនដ៏ច្រើន ដូចជា អង្គការសង្គមស៊ីវិល សហគ្រាសឯកជន និងមូលនិធិ ក៏ដូចជាប្រភពជាច្រើននៃការផ្តល់ហិរញ្ញប្បទាន កំពុងធ្វើឲ្យព្រំប្រទល់រវាងការអប់រំដែលផ្តល់ដោយវិស័យសាធារណៈ និងវិស័យឯកជនមានភាពមិនច្បាស់លាស់។ ឥឡូវនេះលែងមានភាពច្បាស់លាស់ទៀតហើយថាតើពាក្យថា “សាធារណៈ” មានន័យយ៉ាងដូចម្តេច ក្នុងបរិបទសកលថ្មីនៃការរៀនសូត្រ ដែលមានអ្នកពាក់ព័ន្ធកាន់តែច្រើនកាន់តែចម្រុះ ការថមថយសមត្ថភាពរបស់រដ្ឋជាច្រើនក្នុងការកំណត់គោលនយោបាយសាធារណៈ និងការលេចចេញនូវទម្រង់ថ្មីៗនៃអភិបាលកិច្ចសកល។ លក្ខណៈ និងកម្រិត នៃការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់សេវាអប់រំ កំពុងធ្វើឲ្យព្រំដែនរវាងការអប់រំដែលផ្តល់ដោយវិស័យសាធារណៈ និងវិស័យឯកជនពុំមានភាពច្បាស់លាស់។ ចំណុចនេះត្រូវបានស្តែងចេញយ៉ាងច្បាស់ តាមរយៈការពឹងអាស្រ័យកាន់តែខ្លាំងឡើងរបស់គ្រឹះស្ថានអប់រំឧត្តមសិក្សាសាធារណៈលើប្រភពថវិកាពីឯកជន ការកើនឡើងនូវចំនួនគ្រឹះស្ថានរកប្រាក់ចំណេញផង និងមិនរកប្រាក់ចំណេញផង និងការបង្កើតនូវរបៀបធ្វើធុរកិច្ចតាមរយៈការបើកដំណើរការគ្រឹះស្ថានឧត្តមសិក្សា។ ការលេចចេញនូវទម្រង់ថ្មីៗនៃវិស័យឯកជន ដែលបើកចំហការអប់រំកម្រិតមូលដ្ឋាន និងក្រោយកម្រិតមូលដ្ឋានឲ្យវិស័យឯកជនរកប្រាក់ចំណេញ និងធ្វើពាណិជ្ជកម្ម និងកំណត់របៀបវារៈ ដើម្បីប្រយោជន៍ខាងពាណិជ្ជកម្ម កំពុងធ្វើឲ្យមានការផ្លាស់ប្តូរលក្ខណៈនៃសេវាអប់រំ ពីក្នុងទម្រង់ជាទំនិញសាធារណៈ ទៅជាទំនិញឯកជន។[១៣៧] ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃទំនាក់ទំនងរវាងសង្គម រដ្ឋ និងទីផ្សារ កំពុងបង្កើតឲ្យមានទ្វេគ្រោះផងដែរ។ តើគេអាចការពារគោលការណ៍ស្នូលដែលចាត់ទុកការអប់រំជាទំនិញសាធារណៈដោយរបៀបណា ក្នុងបរិបទសកលថ្មីនៃការរៀនសូត្រ?

> តើគេអាចការពារគោលការណ៍ស្នូលដែលចាត់ទុកការអប់រំជាទំនិញសាធារណៈដោយរបៀបណា ក្នុងបរិបទសកល?

---

[១៣៦] Singh, K. 2014. Report of the Special Rapporteur on the right to education. United Nations. A/69/402, 24 September 2014. http://ap.ohchr.org/documents/dpage_e.aspx?si=A/69/402 [Accessed February 2015].

[១៣៧] Macpherson, Robertson and Walford, op.cit., p. 9.

## ■ ការអប់រំ និងចំណេះដឹង ក្នុងនាមជាទំនិញរួមជាសកល

### ដែនកំណត់នៃទ្រឹស្តីទំនិញសាធារណៈ

ទ្រឹស្តីទំនិញសាធារណៈមានប្រវត្តិជាយូរមកហើយ និងមានមូលដ្ឋានលើសេដ្ឋកិច្ចទីផ្សារ។[១៣៨] ក្នុងទសវត្សរ៍ ១៩៥០ ទំនិញសារធារណៈ ត្រូវបានគេចាត់ទុកថាជាទំនិញទាំងឡាយ "ដែលមនុស្សគ្រប់រូបទទួលបាន ក្នុងន័យដែលថា ការប្រើប្រាស់ទំនិញបែបនេះរបស់បុគ្គលម្នាក់ៗ មិនធ្វើឲ្យមានការដកហូតលទ្ធភាពប្រើប្រាស់ទំនិញនេះរបស់បុគ្គលដទៃទៀតឡើយ។[១៣៩] ការផ្ទេរទស្សនទានដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ច មកក្នុងវិស័យអប់រំបែបនេះ ជានិច្ចកាលតែងបង្កឲ្យមានបញ្ហាចោទ។ ទំនិញសាធារណៈត្រូវបានគេចាត់ទុកថាមានទំនាក់ទំនងផ្ទាល់ជាមួយនឹងគោលនយោបាយសាធារណៈ និងគោលនយោបាយរបស់រដ្ឋ។ ពាក្យថា សាធារណៈ តែងនាំឲ្យគេមានការភ័ន្តច្រលំថា "ទំនិញសាធារណៈ" គឺជាទំនិញដែលផ្តល់ដោយវិស័យសាធារណៈ។[១៤០] ម៉្យាងវិញទៀត ទំនិញរួម ត្រូវបានគេផ្តល់និយមន័យឲ្យថាជាទំនិញទាំងឡាយ ដែលមានទិសដៅរួម និងចាំបាច់ ដើម្បីសម្រេចឲ្យបាននូវសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប មិនថាទំនិញនេះមានប្រភពពីវិស័យសាធារណៈ ឬឯកជននោះទេ។[១៤១]

ចេញពីទស្សនវិស័យនេះ ទស្សនទាន "ទំនិញរួម" អាចជាជម្រើសមួយទៀត ដែលមានលក្ខណៈស្ថាបនា។ ទំនិញរួមអាចត្រូវបានគេឲ្យនិយមន័យថាជា "ទំនិញដែលមនុស្សចែករំលែកគ្នា និងជាទំនិញដែលធ្វើឲ្យពួកគេធ្វើប្រាស្រ័យទាក់ទងជាមួយគ្នា ដូចជា គុណតម្លៃគុណធម៌ និងតម្លៃយុត្តិធម៌ជាដើម។[១៤២] វាគឺជា "ការរួមសាមគ្គីគ្នារបស់មនុស្សគ្រប់គ្នា លើសពីទំនិញដែលបុគ្គលម្នាក់ៗទទួលបាន។ វាគឺជាទំនិញដែលធ្វើឲ្យមនុស្សអាចរួមគ្នាបង្កើតជាសហគមន៍ - "ជាទំនិញ ដែលសម្រេចបាន នៅពេលដែលបុគ្គលមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ដែលក្នុងទំនាក់ទំនង និងតាមរយៈទំនាក់ទំនងនេះ មនុស្សអាចសម្រេចបាននូវ

---

[១៣៨] Menashy, F. 2009. Education as a global public good: the applicability and implications of a framework. Globalisation, Societies and Education, Vol. 7, No. 3, pp. 307-320.

[១៣៩] Samuelson, P. A. 1954. The Pure Theory of Public Expenditure, The Review of Economics and Statistics, Vol. 36, No. 4, pp. 387-389.

[១៤០] Adapted from Zhang, E. 2010. Community, the Common Good, and Public Healthcare – Confucianism and its relevance to contemporary China. Department of Religion and Philosophy, Hong Kong Baptist University.

[១៤១] Adapted from Marella, M.R. 2012. Oltre il pubblico e il privato: per un diritto dei beni comuni. Verona, Ombre Corte.

[១៤២] Deneulin, S., and Townsend, N. 2007. Public Goods, Global Public Goods and the Common Good. International Journal of Social Economics, Vol. 34 (1-2), pp. 19-36

សុខុមាលភាពដែលខ្លួនចង់បាន”។[១៤៣] ដូច្នេះ ទំនិញរួមបែបនេះ ត្រូវបានបង្កប់ក្នុងទំនាក់ទំនងរវាងសមាជិកនានារបស់សង្គម ដែលចូលរួមជាមួយគ្នា ក្នុងកិច្ចខិតខំប្រឹងប្រែងជាសមូហភាពបែបនេះ។ ដូច្នេះ ទំនិញប្រភេទនេះគឺជាទំនិញដែលមានលក្ខណៈដូចគ្នា សម្រាប់ “ផលិតកម្ម” ផង និងអត្ថប្រយោជន៍ដែលបានពីទំនិញនេះផង។[១៤៤] ចេញពីទស្សនវិស័យនេះ ទស្សនទានទំនិញរួមផ្តល់លទ្ធភាពឲ្យយើងសម្លឹងហួសពីដែនកំណត់នៃទស្សនទាន “ទំនិញសាធារណៈ” តាមទិដ្ឋភាពយ៉ាងហោចណាស់ចំនួន ៣៖

១. ទស្សនទានទំនិញរួម មានវិសាលភាពលើសពីទស្សនទានទំនិញសាធារណៈ ត្រង់ថាសុខុមាលភាពរបស់មនុស្សត្រូវបានកំណត់ដោយ ទ្រឹស្តីសង្គមសេដ្ឋកិច្ចបែបបុគ្គលនិយម។ ចេញពីទស្សនវិស័យ “ទំនិញរួម” វាមិនត្រឹមតែ “ការរស់នៅល្អប្រសើរ” របស់បុគ្គលម្នាក់ៗប៉ុណ្ណោះទេ ដែលមានសារៈសំខាន់ ភាពល្អប្រសើរនៃជីវិតរបស់មនុស្សទាំងអស់ក៏សំខាន់ផងដែរ។[១៤៥] ដូច្នេះ ការអប់រំនេះមិនអាចត្រឹមតែជាទំនិញផ្ទាល់ខ្លួន ឬទំនិញដើម្បីសម្រេចគោលបំណងរយៈពេលខ្លីនោះទេ។[១៤៦] ចំណុចសំខាន់ ដែលត្រូវគូសបញ្ជាក់នៅទីនេះគឺថា ការងាកចេញពី “ការអប់រំ” ទៅ “ការរៀនសូត្រ” ក្នុងការពិភាក្សាកម្រិតអន្តរជាតិ ជាសញ្ញាបង្ហាញពីការមិនយកចិត្តទុកដាក់លើលក្ខណៈសមូហភាព និងគោលបំណងនៃការអប់រំ ដែលជាកិច្ចខិតខំប្រឹងប្រែងរួមក្នុងសង្គម។ នេះគឺជាអ្វីដែលជាការពិតសម្រាប់លទ្ធផលធំៗមកលើសង្គម ដែលគេរំពឹងថានឹងទទួលបានពីការអប់រំ និងរបៀបរៀបចំផ្តល់ឱកាសអប់រំ។ ទស្សនទានដែលចាត់ទុកការអប់រំជា “ទំនិញរួម” គូសបញ្ជាក់សារជាថ្មីពីលក្ខណៈសមូហភាពរបស់ការអប់រំ ក្នុងនាមជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម (ការទទួលខុសត្រូវរួមគ្នា និងការប្តេជ្ញាចិត្តដើម្បីឲ្យមានសាមគ្គីភាព)។

២. អ្វីដែលត្រូវបានគេចាត់ទុកថាជាទំនិញរួម អាចកំណត់បាន តែនៅពេលដែលគិតពិចារណាពីភាពចម្រុះនៃបរិបទ និងទស្សនទានសុខុមាលភាព និងជីវិតរួមតែប៉ុណ្ណោះ។ ដូច្នេះ សហគមន៍ខុសៗគ្នា មានការយល់ដឹងខុសៗគ្នាពីបរិបទជាក់លាក់នៃទំនិញរួមបែបនេះ។[១៤៧] ដោយសារតែការបកស្រាយវប្បធម៌មានលក្ខណៈចម្រុះខុសគ្នាលើអ្វីដែលត្រូវបានគេចាត់ទុកថាជាទំនិញរួម គោលនយោបាយសាធារណៈចាំបាច់ត្រូវទទួលស្គាល់ និងទទួល

---

[១៤៣] Cahill cited in: Deneulin and Townsend, ibid.

[១៤៤] Adapted from: Deneulin and Townsend, ibid.

[១៤៥] Deneulin and Townsend, ibid.

[១៤៦] Holster, K. 2003. The Common Good and Public Education. Educational Theory, 53(3), 347-361.

[១៤៧] Zhang, op.cit.

យកភាពចម្រុះនៃបរិបទ ទស្សនៈយល់ឃើញក្នុងពិភពលោក និងប្រព័ន្ធចំណេះដឹងបែបនេះ ហើយក្នុងពេលជាមួយគ្នា គោរពដល់សិទ្ធិជាមូលដ្ឋាន ប្រសិនបើគេធ្វើបែបនេះ មិនធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាពរបស់មនុស្ស។[១៤៨]

៣. ទស្សនទាននេះគូសបញ្ជាក់ពីដំណើរការដែលមានការចូលរួម ដែលក៏ជាទំនិញរួមមួយផងដែរ។ សកម្មភាពដែលត្រូវធ្វើរួមគ្នាបែបនេះ គឺជាលក្ខណៈមួយដែលមានក្នុងទំនិញនេះខ្លួនឯងផង និងជាអ្វីដែលមានសារៈសំខាន់ង ហើយអត្ថប្រយោជន៍ក៏ត្រូវទទួលបានក្នុងកំឡុងពេលធ្វើសកម្មភាពរួមគ្នានេះដែរ។[១៤៩] ដូច្នេះ ការអប់រំដែលត្រូវបានចាត់ទុកថាជាទំនិញរួមបែបនេះ តម្រូវឲ្យមានការរៀបចំ និងការអនុវត្តគោលនយោបាយសាធារណៈត្រូវធ្វើឡើង តាមរយៈដំណើរការដែលមានលក្ខណៈបរិយាប័ន្ន ដោយមានកំណត់ពីគណនេយ្យភាពត្រឹមត្រូវ។ ការដាក់ទំនិញរួមឲ្យផុតពីវិសាលភាពនៃវិស័យសាធារណៈ និងវិស័យឯកជន តម្រូវឲ្យមានការបង្កើត និងការចង់បាននូវលទ្ធិប្រជាធិបតេយ្យដែលមានការចូលរួមក្នុងទម្រង់ថ្មី និងស្ថាប័នថ្មី។ ចំណុចនេះតម្រូវឲ្យគេមើលហួសពីគោលនយោបាយឯកជនភាវូបនីយកម្មបច្ចុប្បន្ន ដោយមិនត្រូវត្រលប់ទៅរករបៀបគ្រប់គ្រងវិស័យសាធារណៈតាមបែបប្រពៃណីវិញ។[១៥០]

## ការទទួលស្គាល់ការអប់រំ និងចំណេះដឹង ជាទំនិញរួមជាសកល

ការអប់រំ គឺជាដំណើរការទទួលបានចំណេះដឹង និងអភិវឌ្ឍសមត្ថភាពដោយចេតនា ដើម្បីយកចំណេះដឹងនេះ ទៅប្រើប្រាស់ក្នុងស្ថានភាពពាក់ព័ន្ធ។ ការអភិវឌ្ឍ និងការប្រើប្រាស់ចំណេះដឹង គឺជាគោលបំណងចុងក្រោយនៃការអប់រំ ក្រោមក្របខ័ណ្ឌគោលការណ៍នៃប្រភេទសង្គម ដែលយើងចង់បាន។ ប្រសិនបើគេចាត់ទុកការអប់រំថាជាដំណើរការនៃការរៀនសូត្រដែលធ្វើឡើងដោយចេតនា និងត្រូវមានការរៀបចំត្រឹមត្រូវបែបនេះ នោះការពិភាក្សានានាអំពីការអប់រំលែងអាចត្រឹមតែផ្ដោតការយកចិត្តទុកដាក់លើដំណើរការនៃការទទួលបាន (និងការបញ្ជាក់សុពលភាព) ចំណេះដឹងទៀតហើយ។ យើងត្រូវធ្វើការពិចារណាមិនត្រឹមតែលើរបៀបដែលគេទទួលបានចំណេះដឹង និងរបៀបបញ្ជាក់សុពលភាពចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរបៀបដែលគេត្រួតពិនិត្យលើលទ្ធភាពទទួលបានចំណេះដឹង និងរបៀបធ្វើយ៉ាងណាឲ្យការអប់រំអាចរកបានដោយមនុស្សគ្រប់រូបផងដែរ។

[១៤៨] Deneulin, and Townsend, op.cit

[១៤៩] Adapted from Deneulin and Townsend, ibid.

[១៥០] Marella, op. cit.

## ប្រអប់ទី ១៨៖ ការបង្កើត ការត្រួតពិនិត្យ ការទទួលបាន ការបញ្ជាក់សុពលភាព និងការប្រើប្រាស់ចំណេះដឹង

គេអាចយល់ដោយទូលាយថាចំណេះដឹងគ្របដណ្តប់លើព័ត៌មាន ការយល់ដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ។ សមត្ថភាព សំដៅលើលទ្ធភាពយកចំណេះដឹងនេះទៅប្រើប្រាស់ក្នុងស្ថានភាពណាមួយ។ ការពិភាក្សាអំពីការអប់រំ (ឬការរៀនសូត្រ) គឺពាក់ព័ន្ធជាមួយនឹងដំណើរការនៃការទទួលបាន ចំណេះដឹង និងអភិវឌ្ឍសមត្ថភាពប្រើប្រាស់ចំណេះដឹងនេះដោយចេតនា។ កិច្ចខិតខំប្រឹងប្រែងផ្តល់ការអប់រំក៏កាន់តែពាក់ព័ន្ធជាមួយនឹងការបញ្ជាក់សុពលភាពចំណេះដឹង ដែលទទួលបានផងដែរ។




ប៉ុន្តែ ការពិភាក្សាអំពីការអប់រំ និងការរៀនសូត្រ ក្នុងពិភពលោកដែលមានការប្រែប្រួលដូចបច្ចុប្បន្ននេះ តម្រូវឲ្យមានការពិចារណាលើសពីដំណើរការនៃការទទួល ការបញ្ជាក់សុពលភាព និងការប្រើប្រាស់ចំណេះដឹង៖ ការពិភាក្សាទាំងនេះក៏ត្រូវផ្តោតការយកចិត្តទុកដាក់លើបញ្ហាជាមូលដ្ឋានពាក់ព័ន្ធនឹងការបង្កើត និងការត្រួតពិនិត្យ ចំណេះដឹងផងដែរ។

ប្រភព៖ អ្នកនិពន្ធ

ចំណេះដឹង គឺជាមរតករួមរបស់មនុស្សជាតិ។ ដូច្នេះ ចំណេះដឹង ដូចគ្នានឹងការអប់រំដែរ ត្រូវចាត់ទុកថាជាទំនិញរួមជាសកល។ ប្រសិនបើគេចាត់ទុកចំណេះដឹងត្រឹមតែជាទំនិញសាធារណៈ ជាសកល[១៥១] នោះនឹងមានការរិតត្បិតលើការទទួលបានការអប់រំជាមិនខាន។[១៥២] និន្នាការបច្ចុប្បន្ន ឆ្ពោះទៅធ្វើឯកជនភាវូបនីយកម្មការផលិត និងការផ្សព្វផ្សាយចំណេះដឹង គឺជាមូលហេតុមួយ ដែលនាំឲ្យមានការព្រួយបារម្ភធ្ងន់ធ្ងរ។ លក្ខណៈរួមគ្នានៃចំណេះដឹង ត្រូវបានគេធ្វើឯកជនភាវូបនីយកម្មបន្តិចម្តងៗ តាមរយៈច្បាប់ និងជាពិសេស តាមរយៈរបបកម្មសិទ្ធិបញ្ញា ដែលគ្របដណ្តប់លើការផលិតចំណេះដឹង។ការធ្វើឯកជនភាវូបនីយកម្មបន្តិចម្តងៗនៃការផលិត និងការផលិតឡើងវិញនូវចំណេះដឹងនេះ គឺស្តែងចេញ តាមរយៈការងាររបស់សកលវិទ្យាល័យ ធនាគារគំនិត ក្រុមផ្តល់ប្រឹក្សា និងការបោះពុម្ពផ្សាយនានា។ ជាលទ្ធផល ចំណេះដឹងជាច្រើន ដែលយើងចាត់ទុកថាជាទំនិញសាធារណៈ និងដែលយើងជឿថាស្ថិតក្នុងប្រភេទជាចំណេះដឹងរួម កំពុងត្រូវបានគេធ្វើឯកជនភាវូបនីយកម្ម។ នេះបង្កឲ្យមានការព្រួយបារម្ភជាពិសេស នៅពេលដែលចំណេះដឹងអំពីបរិស្ថាន និងវេជ្ជសាស្ត្ររបស់សហគមន៍ជនជាតិដើមភាគតិច កំពុងត្រូវបានគេកេងចំណេញដោយសាជីវកម្មសកល។ ការជំទាស់ទៅនឹងនិន្នាការបែបនេះ កំពុងលេចចេញជារូបរាងឡើង ក្នុងចំណោមជនជាតិដើមភាគតិច។ និន្នាការនេះក៏ធ្វើឲ្យមានចលនាប្រឆាំងនឹងការចែករំលែក ក្នុងពិភពឌីជីថល ដូចជាសហ្វវែរ Linux ដែលផ្តល់សេរីភាពឲ្យអ្នកប្រើប្រាស់ដំណើរការ ចម្លង ចែកចាយ សិក្សា ផ្លាស់ប្តូរ និងកែលំអផលិតផលដើមផងដែរ។[១៥៣]

> ការអប់រំ និងចំណេះដឹង គួរត្រូវបានចាត់ទុកថាជាទំនិញរួមជាសកល។ នេះមានន័យថា ការបង្កើតចំណេះដឹង ការត្រួតពិនិត្យ ការទទួល ការបញ្ជាក់សុពលភាព និងការប្រើប្រាស់ចំណេះដឹង គឺជាអ្វីដែលកើតមានរួមគ្នាសម្រាប់មនុស្សទាំងអស់ក្នុងនាមជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម។

ដោយសារតែការអភិវឌ្ឍប្រកបដោយចីរភាពបានក្លាយជាការព្រួយបារម្ភដ៏សំខាន់មួយ ក្នុងពិភពលោក ដែលកាន់តែមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ការអប់រំ និងចំណេះដឹងគួរត្រូវបានចាត់ទុកថាជាទំនិញរួមជាសកល។ នេះមានន័យថា ការបង្កើតចំណេះដឹង

---

[១៥១] Kaul, I., le Goulven, K. et al. (eds) 1999. Global Public Goods. International Cooperation in the 21st Century, New York, Oxford University Press.

[១៥២] Stiglitz, J. 1999. Knowledge as a global public good. In Kaul, I., le Goulven K. et al. (eds), ibid., pp. 308-325. See also UNDP. 1999. Human Development Report. New York, Oxford University Press.

[១៥៣] www.linuxfoundation.org [Accessed February 2015].

ការត្រួតពិនិត្យ ការទទួល ការបញ្ជាក់សុពលភាព និងការប្រើប្រាស់ចំណេះដឹង គឺជាអ្វីដែលកើតមានរួមគ្នាសម្រាប់មនុស្សទាំងអស់ក្នុងនាម ជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម។ អភិបាលកិច្ចលើការអប់រំលែងអាច បែងចែកដោយឡែកចេញពីអភិបាលកិច្ចចំណេះដឹងទៀតហើយ។

## ការការពារគោលការណ៍ជាមូលដ្ឋាន

ជាការសំខាន់ ដែលត្រូវគូសបញ្ជាក់ថា ការពិភាក្សាជាអន្តរជាតិបច្ចុប្បន្នេះ អាចធ្វើឲ្យប៉ះពាល់ដល់គោលការណ៍ជាមូលដ្ឋាន ដែលបានតម្រង់ទិសដល់ការរៀបចំគោលនយោបាយអប់រំ និងការអនុវត្តនៅថ្នាក់អន្តរជាតិ និងនៅថ្នាក់ជាតិ។ ជាការពិត ការពិភាក្សាអំពីការអប់រំជាអន្តរជាតិបច្ចុប្បន្ននេះ កំណត់និយមន័យការរៀនសូត្រ ថាជាលទ្ធផល នៃដំណើរការអប់រំ និងជានិន្នាការដែលមិនបានយកចិត្តទុកដាក់លើដំណើរការ នៃការរៀនសូត្រ។ ក្នុងការផ្តោតការយកចិត្តទុកដាក់លើលទ្ធផល ដំណើរការនេះសំដៅលើលទ្ធផលនៃការរៀនសូត្រ[១៥៤] ៖ មានន័យថាជាចំណេះដឹង និងជំនាញ ដែលគេងាយវាស់វែងជាងគេ។

ដូច្នេះ ដំណើរការនេះពុំបានយកចិត្តទុកដាក់លើវិសាលភាពទាំងមូលនៃលទ្ធផលនៃការរៀនសូត្រ ដូចជា ចំណេះដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ ដែលអាចចាត់ទុកថាសំខាន់ សម្រាប់ការអភិវឌ្ឍបុគ្គល និងសង្គម ដោយសារតែសមាសភាគនីមួយៗទាំងនេះមិនអាចវាស់វែងបាន (ដោយងាយស្រួល)។ លើសពីនេះ ការរៀនសូត្រត្រូវបានចាត់ទុកថាជាដំណើរការរបស់បុគ្គលម្នាក់ៗ ក្នុងការទទួលបានជំនាញ និងមានការយកចិត្តទុកដាក់តិចតួចលើគោលបំណងនៃការអប់រំ និងការរៀបចំឱកាសអប់រំ ដែលជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម។ ដូច្នេះ ការពិភាក្សាបែបនេះធ្វើឲ្យប៉ះពាល់ដល់គោលការណ៍ដែលចាត់ទុកការអប់រំជាទំនិញរួម។

[១៥៤] 'Learning achievement refers to the actual skills, attitudes, values and level of knowledge acquired by the individual; it implies some measurement or demonstration that learning has occurred.' World Conference on Education for All. 1990. Meeting Basic Learning Needs: A vision for the 1990s. Background Documents. New York, Inter-Agency Commission for the WCEFA.

## តួនាទី និងការទទួលខុសត្រូវ ក្នុងការធ្វើនិយ័តកម្មលើទំនិញរួម

ផ្អែកតាមគុណតម្លៃសាមគ្គីភាព និងយុត្តិធម៌សង្គម ដែលចាក់ឫសក្នុងគោលការណ៍មនុស្សជាតិរួមរបស់យើង គោលការណ៍ ដែលចាត់ទុកចំណេះដឹង និងការអប់រំ ជាទំនិញរួមជាសកល មានភាពពាក់ព័ន្ធជាមួយនឹងតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនានានៅក្នុងកិច្ចខិតខំប្រឹងប្រែងរួម ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍមនុស្ស និងសង្គមប្រកបដោយចីរភាព និងបរិយាប័ន្នភាព។

- **លើកកម្ពស់តួនាទីរបស់សង្គមស៊ីវិល និងដៃគូដទៃទៀត**

ក្នុងបរិបទបច្ចុប្បន្ននេះ ជាការសំខាន់ ដែលត្រូវលើកកម្ពស់តួនាទីដ៏សំខាន់របស់សង្គមស៊ីវិល ក្នុងការអប់រំ។ ដើម្បីទប់ទល់ជាមួយនឹងនិន្នាការបច្ចុប្បន្ននៃការចាត់ទុកការអប់រំសាធារណៈជាទំនិញ គួរមានការពង្រឹងភាពជាដៃគូជាមួយនឹងសមាគមសហគមន៍ និងអង្គការមិនរកប្រាក់ចំណេញនានា។ ជាការពិត ដោយសារតែការអប់រំមានមុខងារច្រើនយ៉ាង ការទទួលខុសត្រូវនេះមិនមែនជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលតែឯងនោះទេ ប៉ុន្តែជាការទទួលខុសត្រូវរបស់សង្គមទាំងមូល។ អភិបាលកិច្ចល្អ ក្នុងវិស័យអប់រំ តម្រូវឲ្យមានការបង្កើតភាពជាដៃគូរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ហើយគោលនយោបាយអប់រំជាតិគួររៀបចំដោយមានការពិគ្រោះយោបល់ឲ្យបានទូលំទូលាយក្នុងសង្គម និងមានការឯកភាពគ្នានៅថ្នាក់ជាតិ។

យន្តការដែលមានលក្ខណៈច្នៃប្រឌិតថ្មី សម្រាប់ផ្ដល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍ ដោយប្រើប្រាស់ធនធានពីវិស័យសាជីវកម្ម និងពីមូលនិធិនានា កំពុងឆ្លងកាត់ការពិសោធន៍ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេស ក្នុងវិស័យអប់រំ។ ការពិសោធន៍នេះក៏បានរួមចំណែកធ្វើឲ្យមានការពង្រីកភាពជាដៃគូប្រកបដោយប្រសិទ្ធភាព និងច្នៃប្រឌិតថ្មីក្នុងចំណោមគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដូចជា ប្រទេស វិស័យឯកជន សង្គមស៊ីវិល ស្ថាប័នសិក្សាស្រាវជ្រាវ ប្រជាពលរដ្ឋ ដើម្បីទាញប្រយោជន៍ពីសមត្ថភាព ជំនាញ និងធនធានរបស់ដៃគូខាងក្រៅនានា។ មានឧទាហរណ៍ជាច្រើន ដែលបង្ហាញពីភាពជាដៃគូប្រកបដោយជោគជ័យ ដែលបានជួយធ្វើឲ្យមានការសម្រេចលទ្ធភាពយ៉ាងធំធេង សូម្បីតែជាមួយនឹងទំនិញដែលកន្លងមកត្រូវបានគេចាត់ទុកថាជាទំនិញសាធារណៈ ដូចជា ការអប់រំ ជាដើម។

ធុរកិច្ចឯកជនក៏អាចបំពេញតួនាទីសំខាន់ផងដែរ តាមរយៈការវិនិយោគលើការអប់រំ លើសពីអ្វីដែលជាតម្រូវការបន្ទាន់នូវជំនាញដែលបុគ្គលិករបស់ខ្លួនត្រូវការ ជាផ្នែកមួយនៃការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន។ ឧទាហរណ៍ ក្នុងប្រទេសឥណ្ឌា រដ្ឋកំពុងលើកទឹកចិត្តឲ្យក្រុមហ៊ុនឯកជនវិនិយោគ ២ ភាគរយនៃចំណូលប្រចាំឆ្នាំរបស់ខ្លួនរបៀបនេះ។ មូលនិធិសម្រាប់ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុននេះ ក៏អាចប្រើប្រាស់ ដើម្បីរួមចំណែកបំពេញតម្រូវការសង្គម និងអប់រំ របស់សហគមន៍ដែលមានឱកាសតិចតួចផងដែរ។ ច្បាប់ ដែលផ្តល់អត្ថប្រយោជន៍ផ្នែកពន្ធដល់ក្រុមហ៊ុននានា ប្រហែលជាអ្វីដែលចាំបាច់ត្រូវមាន ដើម្បីគេអាចកៀងគរធនធានបន្ថែមទាំងនេះ។

- **ពង្រឹងតួនាទីរបស់រដ្ឋ ក្នុងការធ្វើនិយ័តកម្មលើទំនិញរួម**

ក្នុងបរិបទបច្ចុប្បន្ននៃសកលភាវូបនីយកម្មសេដ្ឋកិច្ច និងសេរីភាវូបនីយកម្មទីផ្សារ រដ្ឋត្រូវរក្សាមុខងាររបស់ខ្លួន ក្នុងការធានាលទ្ធភាពទទួលបានទំនិញរួម និងធ្វើនិយ័តកម្មលើទំនិញរួមទាំងនេះ ជាពិសេស ក្នុងវិស័យអប់រំ។ គេមិនអាចប្រគល់វិស័យអប់រំទៅឲ្យទីផ្សារជាអ្នកចាត់ចែងទាំងស្រុងនោះទេ ដោយសារតែការអប់រំគឺជាការភ្ជាប់ទំនាក់ទំនងទីមួយ ក្នុងសង្វាក់សមភាពឱកាស។ ចេញពីទស្សនវិស័យនេះ រដ្ឋមានកាតព្វកិច្ចចំនួនពីរ៖

> គេមិនអាចប្រគល់វិស័យអប់រំទៅឲ្យទីផ្សារជាអ្នកចាត់ចែងទាំងស្រុងនោះទេ ដោយសារតែការអប់រំគឺជាការភ្ជាប់ទំនាក់ទំនងទីមួយ ក្នុងសង្វាក់សមភាពឱកាស។

១. ធ្វើកំណែទម្រង់វិស័យអប់រំសាធារណៈនិងរៀបចំវិស័យអប់រំសាធារណៈឲ្យ មានលក្ខណៈវិជ្ជាជីវៈ ដូចជា តាមរយៈការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងវិស័យនេះ ដោយប្រើប្រាស់នីតិវិធីឲ្យបានច្បាស់លាស់ ដើម្បីទាមទារឲ្យវិស័យអប់រំកាន់តែមានគណនេយ្យភាព ចំពោះសង្គមទូទៅ។

២. ពិនិត្យតាមដាន និងធ្វើនិយ័តកម្មលើការចូលរួមរបស់វិស័យឯកជនក្នុងវិស័យអប់រំ។ ការពិនិត្យតាមដានគួរតែជាមុខងាររដ្ឋបាល និងការិយាល័យធិបតេយ្យ - វាមិនមែនជាមុខងារពាក់ព័ន្ធនឹងការអនុវត្តច្បាប់ឡើយ។ មុខងារពិនិត្យតាមដានរបស់រដ្ឋគួរធានាឲ្យមានការអនុវត្តស្តង់ដា ដែលទទួលយកដោយអ្នកជំនាញខាងអប់រំ ដែលធ្វើការងារក្នុងវិស័យឯកជនផង និងវិស័យសាធារណៈផង ក៏ដូចជាការអនុវត្តក្របខ័ណ្ឌនិយាមការអន្តរជាតិនានា។

- **ពង្រឹងតួនាទីរបស់ទីភ្នាក់ងារអន្តររដ្ឋាភិបាល ក្នុងការធ្វើនិយ័តកម្មលើទំនិញរួមដែលមានលក្ខណៈសកល**

សហគមន៍អន្តរជាតិ មានការទទួលខុសត្រូវធ្វើអភិបាលកិច្ចលើទំនិញរួមដែលមានលក្ខណៈសកល។ អភិបាលកិច្ចលើទំនិញដែលមានលក្ខណៈសកល គឺជាបញ្ហាមួយ សម្រាប់ប្រព័ន្ធសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងទៀតដោះស្រាយ ដែលស្ថាប័នទាំងនេះត្រូវពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួន ទាំងផ្នែកគោលនយោបាយ ទាំងការអនុវត្ត។ ក្រៅតែមុខងារបច្ចេកទេសរបស់ខ្លួន ទីភ្នាក់ងារសហប្រជាជាតិមានតួនាទីបង្កើតនូវនិយាមការអន្តរជាតិ សម្រាប់តម្រង់ទិសដល់ការធ្វើអភិបាលកិច្ចលើទំនិញរួមដែលមានលក្ខណៈសកលដូចជា ចំណេះដឹង ការអប់រំ និងបេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបី។ ក្នុងន័យនេះ យើងសូមរំឭកនូវការងារចំនួនពីរ ដែលយូណេស្កូបានបំពេញតួនាទីសម្របសម្រួល និងផ្តល់ការលើកទឹកចិត្តកន្លងមក៖ ចលនាអប់រំសម្រាប់ទាំងអស់គ្នា និងការដាក់ចេញនូវគោលបំណងនៃការអប់រំ ដែលប្រើប្រាស់ជានិយាមការ។[១៥៥]

## ■ ចំណុចសម្រាប់ពិចារណាជាជំហានបន្ទាប់

ការពិភាក្សាក្នុងឯកសារនេះ ដោយសារតែមានការព្រួយបារម្ភចំពោះការអភិវឌ្ឍមនុស្ស និងសង្គមប្រកបដោយចីរភាព បានរៀបរាប់ពីនិន្នាការ ភាពតានតឹង និងចំណុចផ្ទុយគ្នា ដែលបង្កើតឡើងដោយបម្លាស់ប្តូរសង្គមជាសកល និងឱកាសផ្តល់ចំណេះដឹងថ្មី។ ការពិភាក្សានេះរំលេចឲ្យឃើញពីសារៈសំខាន់នៃការស្វែងរកអភិក្រមជាជម្រើសផ្សេងៗ សម្រាប់សម្រេចឲ្យបាននូវសុខុមាលភាពមនុស្ស និងភាពចម្រុះនៃការយល់ឃើញក្នុងពិភពលោក និងប្រព័ន្ធចំណេះដឹង ក៏ដូចជាភាពចាំបាច់ ដើម្បីរក្សានិរន្តរភាពអភិក្រមទាំងនេះ។ ការពិភាក្សានេះគូសបញ្ជាក់សារជាថ្មីពីការអប់រំបែបមនុស្សនិយម ដែលអំពាវនាវឲ្យមានការប្រើប្រាស់អភិក្រមដែលមានលក្ខណៈក្តោបរួម ផ្អែកទៅតាមមូលដ្ឋានក្រមសីលធម៌ថ្មី។ ការពិភាក្សានេះចង្អុលបង្ហាញពីដំណើរការនៃការអប់រំ ដែលមានលក្ខណៈបរិយាប័ន្ន ពោលគឺមិនមែនជាដំណើរការដែលគ្រាន់តែបង្កើតឲ្យមានវិសមភាពនោះទេ៖ វាជាដំណើរការ ដែលធានានូវភាពយុត្តិធម៌ និងគណនេយ្យភាព។ ការពិភាក្សានេះគូសបញ្ជាក់ថា តួនាទីរបស់គ្រូ និងអ្នកអប់រំដទៃទៀត

[១៥៥] Bray, M. and Kwo, O. 2014. Regulating Private Tutoring for Public Good Policy Options for Supplementary Education in Asia. CERC Monograph Series in Comparative and International Education and
Development, No. 10. Comparative Education Research Center, University of Hong Kong. Documents. New York, Inter-Agency Commission for the WCEFA.

នៅតែមានសារៈសំខាន់ ក្នុងការបំផុសឲ្យមានការគិតពិចារណាល្អិតល្អន់ និងការវិនិច្ឆ័យដោយឯករាជ្យ ជំនួសឲ្យការចេះតែឯកភាពតាម ដោយមិនធ្វើការឆ្លុះបញ្ចាំង។

អត្ថបទនេះធ្វើការពិភាក្សាពីបញ្ហា ពាក់ព័ន្ធជាមួយនឹងការតាក់តែងគោលនយោបាយអប់រំ ក្នុងពិភពលោកដែលមានលក្ខណៈស្មុគស្មាញ។ ទីមួយ យើងត្រូវទទួលស្គាល់ និងត្រូវឆ្លើយតបចំពោះគម្លាតរវាងការអប់រំក្នុងប្រព័ន្ធ និងការងារ។ ទីពីរ យើងត្រូវទទួលយកបញ្ហាប្រឈម ពាក់ព័ន្ធជាមួយនឹងការទទួលស្គាល់ និងការបញ្ជាក់សុពលភាពលើការរៀនសូត្រ ក្នុងពិភពលោក ដែលមានការកើនឡើងនូវចល័តភាពឆ្លងដែន ចល័តភាពរវាងវិជ្ជាជីវៈមួយ និងវិជ្ជាជីវៈមួយទៀត និងរវាងកន្លែងរៀនសូត្រមួយ និងកន្លែងរៀនសូត្រមួយទៀត។ ទីបី យើងត្រូវពិចារណាឡើងវិញ លើការអប់រំភាពជាពលរដ្ឋ ដោយត្រូវថ្លឹងថ្លែងការគោរព ចំពោះភាពចម្រុះ ជាមួយនឹងគុណតម្លៃសកល និងការព្រួយបារម្ភអំពីមនុស្សជាតិរួម។ ចុងក្រោយ យើងត្រូវពិចារណាលើភាពស្មុគស្មាញ នៃការតាក់តែងគោលនយោបាយអប់រំជាតិ រួមជាមួយនឹងទម្រង់អភិបាលកិច្ចសកលដែលអាចមាន។ ខណៈពេលដែលយើងលើកឡើងពីបញ្ហាទាំងនេះ នៅមានសំណួរជាច្រើន ដែលនៅមិនទាន់មានចម្លើយ។

ការពិភាក្សានេះក៏ពិនិត្យផងដែរលើភាពចាំបាច់ដើម្បីកំណត់សារជាថ្មីនៃបរិបទនៃគោលការណ៍ជាមូលដ្ឋាន សម្រាប់អភិបាលកិច្ចការអប់រំជាពិសេស សិទ្ធិទទួលបានការអប់រំ និងគោលការណ៍ដែលចាត់ទុកការអប់រំថាជាទំនិញសាធារណៈ។ ការពិភាក្សានេះស្នើឲ្យមានការបង្កើនការយកចិត្តទុកដាក់កាន់តែច្រើនជាងមុនលើចំណេះដឹង ក្នុងគោលនយោបាយអប់រំ និងរបៀបបង្កើត ទទួលបាន បញ្ជាក់សុពលភាព និងប្រើប្រាស់ចំណេះដឹង។ ការពិភាក្សានេះលើកស្នើថាការចាត់ទុកការអប់រំ និងចំណេះដឹងថាជាទំនិញរួមជាសកល អាចជាអភិក្រមដ៏មានប្រយោជន៍ សម្រាប់ធ្វើការសម្របសម្រួលគោលបំណង និងការរៀបចំការរៀនសូត្រជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម ក្នុងពិភពលោកដែលកំពុងមានការផ្លាស់ប្តូរ។

ការពិភាក្សានេះក៏ពិនិត្យផងដែរលើភាពចាំបាច់ ដើម្បីកំណត់សារជាថ្មីនៃបរិបទនៃគោលការណ៍ជាមូលដ្ឋានសម្រាប់អភិបាលកិច្ចការអប់រំជាពិសេស សិទ្ធិទទួលបានការអប់រំ និងគោលការណ៍ដែលចាត់ទុកការអប់រំថាជាទំនិញសាធារណៈ។

ក្នុងការពិចារណាអំពីជំហានបន្ទាប់ និងជាការអំពាវនាវឲ្យមានការពិគ្រោះយោបល់ មានសំណួរជាច្រើន ដែលត្រូវបានលើកស្នើឡើង សម្រាប់ការជជែកវែកញែកបន្ថែមទៀត។

ខណៈពេលដែលសសរស្តម្ភទាំងបួននៃការរៀនសូត្រ ដើម្បីដឹង ដើម្បីធ្វើ ដើម្បីក្លាយជាពលរដ្ឋល្អ និងដើម្បីរស់នៅជាមួយគ្នា រឹតតែមានភាពពាក់ព័ន្ធជាមុន នាពេលបច្ចុប្បន្ននេះ សសរស្តម្ភទាំង ៤ កំពុងទទួលរងការគំរាមកំហែងពីសកលភាវូបនីយកម្ម និងការលេចឡើងនូវនយោបាយដែលមានមូលដ្ឋានលើអត្តសញ្ញាណ។ តើគេអាចពង្រឹងសសរស្តម្ភទាំងនេះសារជាថ្មីដោយរបៀបណា?

តើការអប់រំអាចឆ្លើយតបកាន់តែប្រសើរចំពោះបញ្ហាប្រឈម ដែលធ្វើឲ្យរាំងស្ទះដល់ការសម្រេចនិរន្តរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដោយរបៀបណា? តើគេអាចសម្រេចនូវអភិក្រមមនុស្សនិយមនេះ តាមរយៈគោលនយោបាយអប់រំ និងការអនុវត្ត ដោយរបៀបណា?

តើគេអាចបង្រួបបង្រួមទស្សនៈយល់ឃើញផ្សេងៗគ្នាក្នុងសង្គម ដោយប្រើប្រាស់អភិក្រមអប់រំបែបមនុស្សនិយម ដោយរបៀបណា? តើសកលភាវូបនីយកម្មបង្កឲ្យមានការគំរាមកំហែង និងនាំមកនូវឱកាសអ្វីខ្លះ សម្រាប់ការតាក់តែងគោលនយោបាយជាតិ និងការធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធនឹងការអប់រំ ដោយរបៀបណា?

តើការអប់រំគួរទទួលបានហិរញ្ញប្បទានយ៉ាងដូចម្តេច? តើមានភាពពាក់ព័ន្ធអ្វីខ្លះ សម្រាប់ការអប់រំ ការបណ្តុះបណ្តាល ការអភិវឌ្ឍ និងការគាំទ្រគ្រូ? តើការអប់រំមានភាពពាក់ព័ន្ធអ្វីខ្លះទៅនឹងការបែងចែកភាពខុសប្លែកគ្នារវាងទស្សនទានស្តីពីទំនិញឯកជន ទំនិញសាធារណៈ និងទំនិញរួម?

យូណេស្កូ ក្នុងនាមជាទីភ្នាក់ងារសហប្រជាជាតិ ដែលមានឯកទេសខាងអប់រំ រួមជាមួយនឹងវិស័យពាក់ព័ន្ធផ្សេងទៀត ដូចជា វិទ្យាសាស្ត្រ វប្បធម៌ និងការប្រាស្រ័យទាក់ទង គួរពង្រឹងតួនាទីរបស់ខ្លួន ក្នុងនាមជា "មន្ទីរពិសោធន៍គំនិត" ដើម្បីពិនិត្យតាមដាននិន្នាការនៃការអភិវឌ្ឍជាសកល និងភាពពាក់ព័ន្ធ សម្រាប់ការរៀនសូត្រ។ នេះគឺជាអ្វីដែលស្របទៅតាមអណត្តិខាងអប់រំរបស់យូណេស្កូ និងតួនាទីរបស់អង្គការនេះ ក្នុងនាមជាទីភ្នាក់ងារបញ្ញាញាណ និងជាធនាគារគំនិត។[១៥៦] ដោយសារតែការរៀបចំគោលនយោបាយដាច់តែឯងលែងមានប្រសិទ្ធភាព

[១៥៦] Elfert, M. 2015. UNESCO, the Faure Report, the Delors Report, and the Political Utopia of Lifelong
Learning. European Journal of Education. Vol. 50, No. 1, pp. 88-100.

ទៀតហើយ គួរមានការកៀងគងអ្នកពាក់ព័ន្ធនានាដែលមានទស្សនៈវិស័យខុសៗគ្នាឲ្យមកជួបជុំគ្នា ដើម្បីចែករំលែកលទ្ធផលរកឃើញពីការស្រាវជ្រាវ និងរៀបចំដាក់ចេញនូវគោលការណ៍និយាមការ សម្រាប់ផ្តល់ការតម្រង់ទិសដល់ការរៀបចំគោលនយោបាយ។

ចំណុចដែលគួរកត់សម្គាល់ផងដែរនោះគឺថា យូណេស្កូគឺជាស្ថាប័នពិសេស ក្នុងប្រព័ន្ធសហប្រជាជាតិ ដែលមានបណ្តាញជាសកល ដូចជា គណៈកម្មការជាតិ ប្រធានយូណេស្កូ និងវិទ្យាស្ថានឯកទេសនានា។ គេអាចប្រើប្រាស់បណ្តាញទាំងនេះ ជាមធ្យោបាយ សម្រាប់ធ្វើការវាយតម្លៃឡើងវិញលើគោលបំណង និងការអនុវត្តអប់រំ ជាទៀងទាត់ នៅពេលដែលកាលៈទេសៈ និងតម្រូវការនានា មានការផ្លាស់ប្តូរ។ គោលដៅនេះគួរសម្រេច តាមរយៈការបង្កើតនូវយន្តការសង្កេតការណ៍ជាអចិន្ត្រៃយ៍មួយ ដែលធ្វើការពិនិត្យឡើងវិញ និងវាយការណ៍ពីនិន្នាការអភិវឌ្ឍនានា និងភាពពាក់ព័ន្ធនៃនិន្នាការទាំងនោះ សម្រាប់ការអប់រំ។

មនុស្សជាតិ បានចូលមកក្នុងដំណាក់កាលថ្មីនៃប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ការអភិវឌ្ឍទាំងនេះផ្តល់នូវលទ្ធភាពលើកកម្ពស់មនុស្សជាតិផង និងធ្វើឲ្យអន្តរាយដល់មនុស្សជាតិផង។ ដើម្បីឲ្យយើងអាចទទួលបានប្រយោជន៍ដោយសេរី យុត្តិធម៌ និងចីរភាព យើងត្រូវតែស្វែងយល់ និងចេះគ្រប់គ្រងឱកាស និងហានិភ័យនានា។ ការសម្រេចគោលដៅនេះ គួរតែជាគោលបំណងជាមូលដ្ឋាននៃការអប់រំ និងការរៀនសូត្រ ក្នុងសតវត្សរ៍ទី ២១។ នេះគួរតែជាភារកិច្ចជាមូលដ្ឋានរបស់យូណេស្កូ ដែលជាមន្ទីរពិសោធន៍គំនិតជាសកល ដើម្បីបង្កើនការយល់ដឹងរបស់យើងអំពីលទ្ធភាពទាំងនេះ ក្នុងគោលបំណងធានានិរន្តរភាពមនុស្សជាតិ ក៏ដូចជាសុខុមាលភាពជារួមរបស់មនុស្សជាតិ។ ឯកសារបោះពុម្ពផ្សានេះមានគោលបំណងរួមភាគទាន បំផុសឲ្យមានការជជែកវែកញែកបែបនេះ។

**យើង** កំពុងរស់នៅ ក្នុងពិភពលោកមួយ ដែលពោរពេញដោយការផ្លាស់ប្តូរ ភាពស្មុគស្មាញ និងនិន្នាការដែលមានចរិតផ្ទុយគ្នា។ កំណើនសេដ្ឋកិច្ច និងការបង្កើតទ្រព្យសម្បត្តិបានជួយកាត់បន្ថយអត្រា នៃភាពក្រីក្រក្នុងសកលលោកទាំងមូល តែទោះជាយ៉ាងណាក៏ដោយ ភាពងាយរងគ្រោះ វិសមភាពការផាត់ក្រុមមួយចំនួនចេញ និងអំពើហិង្សាបានកើនឡើងក្នុងសង្គមនានា ទូទាំងសកលលោកទាំងមូល។ និន្នាការនៃផលិតកម្ម និងការប្រើប្រាស់ក្នុងសេដ្ឋកិច្ចដែលពុំមាននិរន្តរភាព កាន់តែជម្រុញឲ្យមានការឡើងកម្តៅផែនដី ការរិចរឹលបរិស្ថាន និងការកើនឡើងនូវគ្រោះមហន្តរាយធម្មជាតិ។ លើសពីនេះ ខណៈពេលដែលក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ យើងបានពង្រឹងក្របខ័ណ្ឌសិទ្ធិមនុស្សក៏ពិតមែន ការអនុវត្ត និងការការពារបទដ្ឋានទាំងនេះនៅតែជាការលំបាក។ ហើយបើទោះបីជាការរីកចម្រើនខាងបច្ចេកវិទ្យាបានបង្កើនការភ្ជាប់ទំនាក់ទំនង និងបង្កើតនូវច្រកថ្មីៗ ដើម្បីឲ្យមានការផ្លោះប្តូរព័ត៌មាន ពង្រឹងកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពក៏ដោយ យើងក៏សង្កេតឃើញផងដែរនូវការសាយភាយនូវការមិនយោគយល់គ្នាខាងវប្បធម៌ និងសាសនា ការកៀងគរចលនានយោបាយផ្អែកតាមអត្តសញ្ញាណ និងជម្លោះជាដើម។ ការផ្លាស់ប្តូរទាំងនេះជាសញ្ញាបង្ហាញឲ្យឃើញពីការលេច ឡើងនូវបរិបទសកលថ្មីមួយសម្រាប់ការរៀនសូត្រដែលមានភាពពាក់ព័ន្ធសំខាន់សម្រាប់ការអប់រំ។ ដូច្នេះ ការពិចារណាឡើងវិញពីគោលបំណងនៃការអប់រំ និងការរៀបចំការរៀនសូត្រ មិនដែលជាការងារបន្ទាន់ដូចពេលនេះឡើយ។

សៀវភៅនេះមានគោលបំណងធ្វើជាការអំពាវនាវឲ្យមានការពិគ្រោះយោបល់។ គំនិតដែលបំផុសឲ្យមានការរៀបចំសៀវភៅនេះឡើង គឺចក្ខុវិស័យចង់បានការអប់រំ និងការអភិវឌ្ឍដែលមានមូលដ្ឋានលើការគោរពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សិទ្ធិស្មើភាពគ្នា យុត្តិធម៌សង្គម ភាពចម្រុះខាងវប្បធម៌ សាមគ្គីភាពជាអន្តរជាតិនិងការចែករំលែកការទទួលខុសត្រូវ ដើម្បីអនាគតមួយប្រកបដោយចីរភាព។ សៀវភៅស្នើឲ្យយើងទាំងអស់គ្នាចាត់ទុកការអប់រំ និងចំណេះដឹងថាជាទំនិញរួមជាសកល ដើម្បីឲ្យការខិតខំសម្រេចគោលបំណងនៃការអប់រំ និងការរៀបចំការអប់រំ ក្លាយជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសង្គម ក្នុងពិភពលោកដែលពោរពេញដោយភាពស្មុគស្មាញនេះ។

UNESCO

Education
Sector

United Nations
Educational, Scientific and
Cultural Organization

9 789231 000881